# របាយការណ៍ សិក្សាវិសាលភាព ស្តីពីការគ្រប់គ្រង សំណល់រឹងនៅក្នុង ខេត្តកែប




គម្របរូបភាព: រូបសំណាកក្ដាមនៅខេត្តកែប (Christopher Godlove 2019)

ខែសីហា ឆ្នាំ២០២០

The Asia Foundation

# ការគ្រប់គ្រងសំណល់រឹងនៅក្នុងខេត្តកែប

## សីហា ឆ្នាំ ២០២០

**អ្នកនិពន្ធ៖**
Christopher Godlove
ប៉ាក់ គឹមជឿន

**ការគាំទ្រផ្នែកថវិកា៖**
អង្គការមូលនិធិអាស៊ី

© កម្មសិទ្ធិបញ្ញា ២០២០ អង្គការមូលនិធិអាស៊ី និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
សិទ្ធិទាំងអស់ត្រូវបានរក្សា។ មិនមានផ្នែកណាមួយនៃរបាយការណ៍នេះ អាចត្រូវបានរៀបរៀងឡើងវិញដោយមិនមានការអនុញ្ញាតពី អង្គការមូលនិធិអាស៊ី និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនោះឡើយ។

# អារម្ភកថា

កម្ពុជា ស្ថិតក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចលូតលាស់លឿនជាងគេក្នុងតំបន់អាស៊ីប៉ូព៉ាប៉ាស៊ីហ្វិក។ ដោយឡែក កំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័សនេះ ក៏បណ្តាលឱ្យមាននូវការកើនឡើងនូវបរិមាណសំរាម សំណល់រឹងនៅទីប្រជុំជនផងដែរ ដោយសារកត្តាជាច្រើនដូចជា កំណើនប្រជាជនយ៉ាងឆាប់រហ័ស ប្រាក់ចំណូលខ្ពស់ និងកំណើនតម្រូវការប្រើប្រាស់ជាដើម។ កត្តាទាំងនេះ ធ្វើឱ្យមានភាពស្មុគស្មាញ និងបញ្ហាប្រឈមដល់ប្រព័ន្ធគ្រប់គ្រងសំណល់រឹង។

ការប្រមូល ការដឹកជញ្ជូន និងការចាក់ចោលសំរាម នៅតាមទីក្រុងធំៗ និងតំបន់ទីរួមស្រុកមួយចំនួនក្នុងប្រទេសកម្ពុជា ត្រូវបានវិនិយោគដោយក្រុមហ៊ុនឯកជន ក្រោមការត្រួតពិនិត្យរបស់ស្ថាប័នជំនាញរបស់រាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះយ៉ាងណាក៏ដោយ ការផ្តល់សេវាកម្មប្រមូលសំរាម នៅមានកម្រិត និងមិនបានគ្រប់ទីតាំងនោះទេ។ តំបន់មួយចំនួន ជាពិសេស តំបន់ជនបទ នៅតែមិនទទួលបានសេវាប្រមូលសំរាម។ ហេតុដូច្នេះហើយ ក្រុមគ្រួសារមួយចំនួន នៅតែបន្តប្រកាន់ខ្ជាប់នូវការអនុវត្តរបៀបទុកដាក់សំណល់តាមលក្ខណៈប្រពៃណីដូចជា ការដុត ការកប់ ឬការបោះចោលដោយខុសច្បាប់នៅលើដីទំនេរ ដងផ្លូវ ឬចូលទៅក្នុងទឹក។ ការគ្រប់គ្រងសំរាម សំណល់រឹងមិនត្រឹមត្រូវ អាចនឹងមានផលប៉ះពាល់ដល់ទឹក ខ្យល់ និងដី ហើយផលប៉ះពាល់ទាំងនេះ អាចគំរាមកំហែងដល់សុខភាពសាធារណៈ ប្រព័ន្ធអេកូឡូស៊ី អាកាសធាតុ ក៏ដូចជាការអភិវឌ្ឍប្រកបដោយចីរភាពផងដែរ។

បច្ចុប្បន្ន ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន គឺជាបញ្ហាអាទិភាពមួយដែលបាននិងកំពុងប្រឈមខ្លាំង ជាពិសេស បញ្ហាកង្វះការធ្វើប្រព្រឹត្តកម្ម និងសម្ភារៈទុកដាក់សំណល់ ក៏ដូចជាបច្ចេកទេសនៃការរៀបចំ និងគ្រប់គ្រងទីលានចាក់សំរាម។ ការយកចិត្តទុកដាក់នេះ ទាមទារឱ្យមានគោលវិធីថ្មីៗ ដើម្បីកំណត់អន្តរាគមន៍ផ្នែកបច្ចេកវិទ្យា ការគ្រប់គ្រង និងអភិបាលកិច្ច ដែលអាចជួយពង្រឹង និងគ្រប់គ្រងការទុកដាក់ និងញែកសំរាមឱ្យបានសមស្របតាមបទដ្ឋានបច្ចេកទេស។ ការវិភាគលើវិស័យនេះ ទាមទារឱ្យមានការចូលរួមពីដៃគូខាងក្រៅជាច្រើន ដែលអាចចែករំលែកនូវការអនុវត្តល្អៗកម្រិតសាកលក្នុងការគ្រប់គ្រងសំណល់ ដើម្បីគាំទ្រដល់កំណែទម្រង់ការគ្រប់គ្រងសំណល់ក្នុងប្រទេសកម្ពុជា និងរកដំណោះស្រាយសមស្រប ចំពោះបញ្ហាប្រឈមនានាដែលនឹងអាចកើតមានក្នុងទសវត្សរ៍ខាងមុខ។

អនុស្សរណៈនៃការយោគយល់ រវាង ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងអង្គការមូលនិធិអាស៊ី ក្នុងឆ្នាំ២០១៨ បានផ្តល់នូវក្របខ័ណ្ឌការងារ ដើម្បីចាប់ផ្តើមដំណើរការនេះ។ ក្រុងកែប ជាក្រុងដែលមានបរិមាណសំណល់រឹងកើនឡើងពី ៣០តោន ក្នុងមួយថ្ងៃ ក្នុងឆ្នាំ២០១៦ រហូតដល់ ៥៥តោន ក្នុងមួយថ្ងៃ ក្នុងឆ្នាំ២០១៨ និងត្រូវបានជ្រើសរើសជាក្រុងស្ថិតក្រោមការផ្តោតការយកចិត្តទុកដាក់សម្រាប់ការសិក្សានេះ។ ការសិក្សានេះ មានសកម្មភាពជាច្រើន ត្រូវបានតាក់តែងឡើងដើម្បីអនុញ្ញាតឱ្យមានការប្រមូលទិន្នន័យ ព្រមទាំងធ្វើការសិក្សាទៅលើការអនុវត្តក្នុងគ្រប់គ្រងសំណល់នាពេលបច្ចុប្បន្នផងដែរ។ ដំណាក់កាលចុងក្រោយនៃការសិក្សានេះ នឹងផ្តោតលើការស្វែងរកឱកាសដើម្បីកែលំអបន្ថែម ផ្សារភ្ជាប់ការអនុវត្តសកម្មភាពសាកល្បងជាកិច្ចឆ្លើយតបចំពោះបញ្ហាប្រឈមដែលបានរកឃើញ។

ខ្ញុំជឿជាក់ថា របាយការណ៍សិក្សាកំណត់វិសាលភាពនេះ នឹងក្លាយជាឯកសារបង្ហាញផ្លូវដ៏មានសារៈសំខាន់មួយសម្រាប់ក្រសួងពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុងកែប អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍នានា និងវិស័យឯកជន ក្នុងការសហការរៀបចំ និងអនុវត្តផែនការគ្រប់គ្រងសំណល់រឹងទីប្រជុំជនដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងនិរន្តរភាព ដើម្បីកាត់បន្ថយផលប៉ះពាល់លើបរិស្ថានធ្វើឱ្យប្រសើរឡើងនូវសោភ័ណភាពក្នុងសហគមន៍ និងសុខមាលភាពសង្គម រួមទាំងការទាក់ទាញភ្ញៀវទេសចរឱ្យកាន់តែច្រើនផងដែរ។ ខ្ញុំសង្ឃឹមថា ឯកសារនេះ នឹងមានប្រយោជន៍សម្រាប់ជាឯកសារយោងសម្រាប់ភាគីពាក់ព័ន្ធនានាក្នុងការបង្កើតគោលយោបាយ និងការសិក្សាផ្សេងៗ។

ខ្ញុំសូមអរគុណដល់ អង្គការមូលនិធិអាស៊ី ដែលបានសហការយ៉ាងជិតស្និទ្ធជាមួយ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួងបរិស្ថាន និងលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សម្រាប់ការចុះសិក្សា និងការរៀបចំបង្កើតនូវរបាយការណ៍ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនេះឡើង និងសូមអរគុណចំពោះការចូលរួមចំណែករបស់អាជ្ញាធរខេត្តកែប និងអ្នកពាក់ព័ន្ធដទៃទៀតដែលបានផ្តល់ជាធាតុចូល និងការសម្របសម្រួលលើដំណើរការទាំងមូល៕

ថ្ងៃ សុក្រ ៣រោច ខែ ស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០២០

**ប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**
**និងជារដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

# សេចក្តីថ្លែងអំណរគុណ

អង្គការមូលនិធិអាស៊ី សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដែលបានផ្តល់ការគាំទ្រ និងកិច្ចសហការសម្រាប់ការសិក្សានេះ។ យើងខ្ញុំ សូមគោរព និងកោតសរសើរយ៉ាងខ្លាំង ចំពោះដំបូន្មានដែលមិនអាចកាត់ថ្លៃបាន និងមតិយោបល់នានា។ យើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះថ្នាក់ដឹកនាំជាន់ខ្ពស់ និងមន្ត្រីរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដែលរួមមាន៖

- ឯកឧត្តម **ទិន ពន្លក** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- ឯកឧត្តម **ឯ វុឌ្ឍី** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- លោកជំទាវ **ង៉ិន លីណា** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- លោក **តាំង ម៉េងអៀង** ប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតងនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- លោក **ណុប សុខៃ** អនុប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតងនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះអ្នកប្រឹក្សាយោបល់របស់យើង រួមមាន លោក **Christopher Godlove** និងលោកបណ្ឌិត **ប៉ក់ គឹមជឿន** ក្នុងការរៀបចំចងក្រងរបាយការណ៍សិក្សាវិសាលភាពនេះ និងលោកបណ្ឌិត **សេង ប៊ុនរិទ្ធិ** សម្រាប់ការផ្តល់ជាដំបូន្មានផ្នែកបច្ចេកទេស និងធាតុចូល។ សូមថ្លែងអំណរគុណជាពិសេសផងដែរចំពោះអ្នកតំណាងស្ថាប័ន រួមមាន៖ លោក **ដែក វិមានរស្មី** អនុប្រធាននាយកដ្ឋានគ្រប់គ្រងសំណល់រឹងរបស់ក្រសួងបរិស្ថាន អ្នកស្រី **ឈួន សុជាតា** មន្ត្រីបច្ចេកទេស ក្នុងនាយកដ្ឋានសេដ្ឋកិច្ចបៃតងរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អ្នកស្រី **គង់ ប៊ុណ្ណា** អនុប្រធានផ្នែកវិភាគគោលនយោបាយ និងការអភិវឌ្ឍ របស់លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងអ្នកស្រី **ចាប ស្រីភា** មន្ត្រីកម្មវិធីរបស់អង្គការមូលនិធិអាស៊ី ដែលបានផ្តល់ការគាំទ្រដូចជា ការសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធនានា ការប្រមូលទិន្នន័យ និងការផ្តល់មតិយោបល់លើរបាយការណ៍។

យើងខ្ញុំ សូមថ្លែងអំណរគុណចំពោះការចូលរួមចំណែកដ៏សំខាន់របស់សហការីអង្គការមូលនិធិអាស៊ី មានជាអាទិ៍ លោក **Kim J. DeRidder** អ្នកស្រី **Meloney C. Lindberg** អ្នកស្រី **Marguerite Bennett** លោក **Dylan Davis** អ្នកស្រី **Juan Wei** កញ្ញា **សាន សុជាតា** និង អ្នកស្រី **ណុប ណារី** សម្រាប់ការណែនាំ និងមតិយោបល់លើរបាយការណ៍។

ជាចុងក្រោយ អង្គការមូលនិធិអាស៊ី សូមថ្លែងអំណរគុណចំពោះអ្នកជំនាញដែលក្រុមការងារស្រាវជ្រាវបានជួបពិភាក្សាយោបល់ និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងខេត្តកែបដែលជាតំបន់ក្រុមការងារចុះធ្វើការសិក្សា។ ក្រុមការងារ ពិតជាមិនអាចរៀបចំរបាយការណ៍សិក្សាវិសាលភាពនេះបាននោះទេ ប្រសិនបើមិនមានការលះបង់ពេលវេលា ការចែករំលែកចំណេះដឹង និងព័ត៌មានពីសំណាក់អ្នកជំនាញ និងអ្នកពាក់ព័ន្ធទាំងអស់។

# មាតិកា


**មាតិកាតារាង** ........ IV

**មាតិកាប្រអប់** ........ IV

**មាតិការូបភាព** ........ V

**បញ្ជីអក្សរកាត់** ........ VI

**សេចក្តីសង្ខេប** ........ ១

**១. សេចក្តីផ្តើម** ........ ៥

១.១ សាវតារ ........ ៥

១.២ ភាពជាដៃគូរវាងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងអង្គការមូលនិធិអាស៊ី ........ ៦

១.៣ គោលបំណងនៃការសិក្សា ........ ៦

**២. គោលវិធី និងវិធីសាស្ត្រ** ........ ៧

២.១ លទ្ធផលការងារ និងសកម្មភាព ........ ៧

២.២ ការសម្របសម្រួលលើការចូលរួម និងធាតុចូលរបស់ស្ថាប័ននានា ........ ៨

២.៣ ការប្រមូល និងការរៀបចំទិន្នន័យស្តីពីសំណល់រឹង ........ ៨

**៣. ការសង្កេត និងការវិភាគ** ........ ១០

៣.១ ប្រព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងសំណល់រឹងដែលមានបច្ចុប្បន្ន ........ ១១

៣.២ និរន្តរភាពហិរញ្ញវត្ថុរបស់ប្រតិបត្តិការគ្រប់គ្រងសំណល់រឹង ........ ១២

៣.៣ តួនាទីរបស់ស្ត្រីក្នុងការគ្រប់គ្រងសំណល់រឹង ........ ១៤

៣.៤ វិមជ្ឈការការគ្រប់គ្រងសំណល់រឹង ........ ១៥

៣.៤.១ សាវតារផ្នែកលិខិតបទដ្ឋានគតិយុត្តិ ........ ១៦

៣.៤.២ ការអនុវត្ត និងបញ្ហាប្រឈម ........ ១៧

**៤. កំណែទម្រង់សាកល្បង - សកម្មភាពអនុវត្តសាកល្បង និងអនុសាសន៍ដែលស្នើឡើង** ........ ២០

៤.១ អភិបាលកិច្ចលើប្រព័ន្ធគ្រប់គ្រងសំណល់រឹង ........ ២០

៤.២ គោលវិធីបច្ចេកទេស និងលក្ខណៈប្រព័ន្ធ ដើម្បីឆ្លើយតបចំពោះអាទិភាពស្តីពីសំណល់ ........ ២៣

៤.៣ វិមជ្ឈការ ........ ២៦

៤.៤ ការចូលរួមក្នុងភាពជាដៃគូ ........ ២៧

៤.៤.១ វិស័យក្រៅប្រព័ន្ធ ........ ២៨

៤.៤.២ វិស័យឯកជន ........ ២៨

៤.៤.៣ ការចូលរួមរបស់សហគមន៍ ........ ២៩

៤.៤.៤ ទេសចរណ៍ប្រកបដោយនិរន្តរភាព ........ ២៩

៤.៥ សំណើសកម្មភាពអនុវត្តសាកល្បង ........ ៣០

៤.៦ ធាតុចូល ធនធាន និងកិច្ចសហការសម្រាប់សកម្មភាពអនុវត្តសាកល្បង ........ ៣៣

**៥. ការផ្តោតការយកចិត្តទុកដាក់លើកំណែទម្រង់គោលនយោបាយ** ........ ៣៦

**៦. សន្និដ្ឋាន** ........ ៣៨

**ឧបសម្ព័ន្ធ ១៖ ការសិក្សាឯកសារពាក់ព័ន្ធមុនការចុះប្រមូលទិន្នន័យ** ........ ៣៩

**ឧបសម្ព័ន្ធ ២៖ ពង្រាងពិយុទ្ធសាស្ត្រទៅជាសកម្មភាពសាកល្បងរយៈពេល ០៣ឆ្នាំ** ........ ៥០

**ឯកសារយោង** ........ ៥៣

# មាតិកាតារាង


តារាងទី ១៖ ទិន្នន័យពីប្រជាសាស្ត្រ ទេសចរណ៍ និងសំណល់រឹងរបស់ខេត្តកែប ..... ១០

តារាងទី ២៖ កម្មករ និងបុគ្គលិកបច្ចុប្បន្នដែលអ្នកផ្តល់សេវាឯកជនជួលឱ្យធ្វើការក្នុងខេត្តកែប..... ១៣

តារាងទី ៣៖ ជំហានរយៈពេលមធ្យម និងរយៈពេលវែងដែលចាំបាច់ត្រូវមាន ដើម្បីដោះស្រាយបញ្ហាប្រឈមស្តីពីសំណល់ក្នុងខេត្តកែប ..... ៣០

តារាងទី ៤៖ ធាតុផ្សេងៗទាំង ០៥ នៅក្នុងទស្សនទានសកម្មភាពអនុវត្តសាកល្បងដែលត្រូវបានស្នើឡើងសម្រាប់ខេត្តកែប..... ៣៣

តារាងទី ៥៖ ធាតុចូលសំខាន់ៗដែលត្រូវការពីដៃគូនៅក្នុងសកម្មភាពអនុវត្តសាកល្បងដែលត្រូវបានស្នើឡើងទាំង ០៥..... ៣៥


# មាតិកាប្រអប់


ប្រអប់ទី ១៖ ការចំណាយដែលត្រូវបានប៉ាន់ប្រមាណសម្រាប់សេវាក្នុងកម្រិត "អាចទទួលយកបាន" ផ្អែកលើកម្មវិធីគណនាថ្លៃចំណាយសម្រាប់ការគ្រប់គ្រងសំណល់ទីក្រុង របស់កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ..... ១៤

ប្រអប់ទី ២៖ លិខិតបទដ្ឋានគតិយុត្តិសំខាន់ៗ និងវឌ្ឍនភាពនាពេលថ្មីៗនេះពាក់ព័ន្ធជាមួយការគ្រប់គ្រងសំណល់រឹងបែបរិមជ្ឈការក្នុងប្រទេសកម្ពុជា..... ១៧

ប្រអប់ទី ៣៖ និយមន័យរបស់ការពិនិត្យតាមដាន និងវាយតម្លៃ..... ១៩

ប្រអប់ទី ៤៖ និន្នាការផ្នែកប្រជាសាស្ត្រដែលប៉ះពាល់ដល់ការគ្រប់គ្រងសំណល់..... ២០

ប្រអប់ទី ៥៖ ផលប៉ះពាល់នៃប្លាស្ទិកមកលើតំបន់ឆ្នេរកម្ពុជា..... ២៥

ប្រអប់ទី ៦៖ គ្រោះថ្នាក់បង្កឡើងដោយឡដុតសំរាមខ្នាតតូចក្នុងប្រទេសចិន..... ២៦

ប្រអប់ទី ៧៖ សហករណ៍សំណល់ និងធនាគារសំណល់ ..... ២៨

# មាតិការូបភាព


រូបភាពទី ១៖ ទីតាំងរបស់ក្រុងកែប និងខេត្តកែប ........ ៧

រូបភាពទី ២៖ ទិដ្ឋភាពទូទៅនៃការប្រមូលព័ត៌មាន វិភាគព័ត៌មាន និងសកម្មភាព ក្នុងខេត្តកែប ........ ៨

រូបភាពទី ៣៖ លំហូរសំណល់រឹងទីក្រុងក្នុងប្រទេសកម្ពុជា ........ ១២

រូបភាពទី ៤៖ ការកែច្នៃសំណល់ឱ្យក្លាយទៅជាផលិតផលផ្សេងៗនៅក្នុងសមាគមស្ត្រីអន្តរជាតិកែប ........ ១៥

រូបភាពទី ៥៖ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅកម្ពុជា និងតួនាទី ........ ១៥

រូបភាពទី ៦៖ ក្របខ័ណ្ឌក្នុងការសម្រេចចិត្តពីឋានានុក្រមសំណល់ ........ ២០

រូបភាពទី ៧៖ ប្រតិបត្តិការទីលានចាក់សំរាមខាងក្រៅក្រុងកែប ........ ២២

រូបភាពទី ៨៖ ដេប៉ូអេតចាយក្នុងខេត្តកែប ........ ២៤

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| **ADB** | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| **CCAC** | Climate and Clean Air Coalition | សម្ព័ន្ធភាពអាកាសធាតុ និងខ្យល់ស្អាត |
| **COMPED** | Cambodian Education and Waste Management Organization | អង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា |
| **EIU** | Economist Intelligence Unit | អង្គភាពអ្នកសេដ្ឋកិច្ចវៃឆ្លាត |
| **ETAGIW** | Expert Team for Assessment and Guidance for the Implementation of Waste legislation | ក្រុមការងារជំនាញវាយតម្លៃ និងមគ្គុទ្ទេសក៍សម្រាប់ការអនុវត្តលិខិតបទដ្ឋានគតិយុត្តិស្តីពីសំណល់ |
| **GGGI** | Global Green Growth Institute | វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល |
| **GIZ** | Deutsche Gesellschaft für Internationale Zusamme-narbeit | កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ |
| **IGES** | Institute for Global Environmental Strategies | វិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានសាកល |
| **KAS** | Konrad-Adenauer-Stiftung | មូលនិធិខុនរ៉ាតអាឌិនណៅអ៊ែរ |
| **MEF** | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **MoE** | Ministry of Environment | ក្រសួងបរិស្ថាន |
| **MoI** | Ministry of Interior | ក្រសួងមហាផ្ទៃ |
| **MSW** | Municipal Solid Waste | សំណល់រឹងទីក្រុង |
| **NCSD** | National Council for Sustainable Development | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| **NCDD** | National Committee for Sub-National Democratic Development | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| **OBG** | Oxford Business Group | ក្រុមអាជីវកម្ម Oxford |
| **PDoE** | Provincial Department of Environment | មន្ទីរបរិស្ថាន |
| **PDoT** | Provincial Department of Tourism | មន្ទីរទេសចរណ៍ |
| **PPCA** | Phnom Penh Capital Administration | រដ្ឋបាលក្រុងភ្នំពេញ |
| **RGC** | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| **SALGA** | South African Local Government Association | សមាគមរដ្ឋាភិបាលថ្នាក់មូលដ្ឋានអាហ្វ្រិកខាងត្បូង |
| **UN** | United Nations | អង្គការសហប្រជាជាតិ |
| **UNDP** | United Nations Development Programme | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| **UNEP** | United States Environment Programme | អង្គការកម្មវិធីបរិស្ថានសហប្រជាជាតិ |
| **US EPA** | United States Environmental Protection Agency | ទីភ្នាក់ងារការពារបរិស្ថានសហរដ្ឋអាមេរិក |
| **WRI** | World Resources Institute | វិទ្យាស្ថានធនធានពិភពលោក |

# សេចក្តីសង្ខេប

ការផ្តួចផ្តើមគំនិតរួមគ្នារវាងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) និងអង្គការមូលនិធិអាស៊ី (The Asia Foundation) ដែលផ្តោតការយកចិត្តទុកដាក់លើការកែលំអការគ្រប់គ្រងសំណល់រឹង សំរាមទីក្រុងនៅខេត្តកែប បានផ្តល់រូបភាពទូលំទូលាយស្តីពីប្រតិបត្តិការគ្រប់គ្រងសំណល់ក្នុងក្រុងគោលដៅ (Secondary City) នៅកម្ពុជា។ ដើម្បីអភិវឌ្ឍការយល់ដឹងឱ្យបានសុក្រឹតពីស្ថានភាពបច្ចុប្បន្ន និងទទួលព័ត៌មានបឋមជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់សកម្មភាពនាពេលអនាគត សំដៅឆ្លើយតបចំពោះតម្រូវការ ឬដំណោះស្រាយបញ្ហានានាក្នុងប្រតិបត្តិការគ្រប់គ្រងសំណល់ទីក្រុងនៅខេត្តកែប ក.ជ.អ.ច. និងអង្គការមូលនិធិអាស៊ី បានសហការរៀបចំការសិក្សាស្រាវជ្រាវមួយ ដោយក្នុងនោះរួមមានការរៀបចំរបាយការណ៍សិក្សាលើឯកសារពាក់ព័ន្ធដែលមានស្រាប់ រួមជាមួយការចុះសិក្សានៅមូលដ្ឋានខេត្តកែបផ្ទាល់ ដើម្បីប្រមូល និងវិភាគព័ត៌មានដែលមាន។ សមិទ្ធិផលនៃការសិក្សានេះ ដូចជា រួមមានរបាយការណ៍សិក្សាវិសាលភាព និងឯកសារសង្ខេបគោលនយោបាយដែលផ្តល់ព័ត៌មានជាមូលដ្ឋានសម្រាប់ការរៀបចំសកម្មភាពអនុវត្តសាកល្បង ឆ្លើយតបចំពោះបញ្ហាប្រឈមជាក់លាក់ដែលជួបប្រទះនៅក្នុងប្រព័ន្ធបច្ចុប្បន្ន និងផ្តល់ជាអនុសាសន៍គោលនយោបាយជាច្រើន ដើម្បីជំរុញឱ្យមានភាពប្រសើរឡើងក្នុងការគ្រប់គ្រងសំណល់រឹង សំរាមនៅក្នុងរយៈពេលមធ្យម និងរយៈពេលវែង។

## ស្ថានភាពនៃការគ្រប់គ្រងសំណល់រឹងក្នុងខេត្តកែប

ការបង្កើតសំរាមនៅក្នុងក្រុងកែប រងឥទ្ធិពលពីវិស័យទេសចរណ៍តាមរដូវកាល។ គម្លាតគ្នាប្រចាំថ្ងៃក្នុងការបង្កើតសំរាម គឺខុសគ្នាប្រមាណ ១០ តោន រវាងរដូវមានទេសចរច្រើន និងរដូវមានទេសចរតិច ដោយក្នុងនោះ រដូវមានទេសចរតិច ត្រូវបានប៉ាន់ប្រមាណថា មានការបង្កើតសំរាមចន្លោះពី ៤៥ ដល់ ៥១ តោន ក្នុងមួយថ្ងៃ និងនៅរដូវកាលដែលមានទេសចរច្រើន បរិមាណសំរាម មានប្រមាណ ៥៥ តោន។

| ទិន្នន័យសំខាន់ៗពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹងទីក្រុងក្នុងក្រុងកែប | |
|---|---|
| ចំនួនប្រជាជនក្នុងខេត្ត | ៤០.៤៧០ |
| ចំនួនប្រជាជនក្នុងក្រុង | ៥.៦៧១ |
| ចំនួនអ្នកទេសចរប្រចាំឆ្នាំ | ១.៦៧៦.៥០៩ |
| បរិមាណសំណល់/ថ្ងៃ | ៤៥ ដល់ ៥១ តោន |
| បរិមាណសំណល់/ថ្ងៃ (រដូវទេសចរឡើងខ្ពស់) | ៥៥ តោន |
| សំណល់ដែលត្រូវបានចោលនៅទីលាន/ថ្ងៃ | ២៥ តោន |
| ការគ្របដណ្តប់សេវា | ៥០% |

បញ្ហាប្រឈមចម្បងមួយក្នុងការគ្រប់គ្រងសំណល់រឹងសំរាមក្នុងក្រុងកែប គឺពាក់ព័ន្ធជាមួយអត្រាទាបនៃការប្រមូលសំណល់។ បរិមាណសំណល់រឹងដែលត្រូវបានបង្កើតឡើងប្រមាណតែ ៥០% ប៉ុណ្ណោះដែលត្រូវបានប្រមូល និងយកទៅបោះចោលនៅទីលានចាក់សំរាម។ ការសិក្សា បានកត់សម្គាល់ឃើញពីតួនាទីដ៏សំខាន់របស់ស្ត្រី និងអ្នកធ្វើការក្នុងវិស័យក្រៅប្រព័ន្ធនៅក្នុងប្រតិបត្តិការបច្ចុប្បន្នផងដែរ ដែលតួនាទីទាំងអស់នេះ មានសារៈសំខាន់ ជាពិសេស នៅពេលពិចារណាពីការចូលរួមចំណែករបស់ពួកគេចំពោះការប្រមូល និងការកែច្នៃសំរាមយកមកប្រើប្រាស់ឡើងវិញ។

## បញ្ហាប្រឈមក្នុងការគ្រប់គ្រងសំណល់រឹង

បញ្ហាប្រឈមផ្នែកវិមជ្ឈការដែលផ្តោតជាក់លាក់សម្រាប់ក្រុងកែប ត្រូវបានបង្ហាញ ព្រមជាមួយការវិភាគដែលរំលេចឱ្យឃើញពីមូលហេតុដែលធ្វើឱ្យមានបញ្ហាប្រឈមទាំងអស់នេះ ទាំងនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។ បញ្ហាប្រឈមនៅថ្នាក់ក្រោមជាតិទាំងអស់នេះ មានប្រភពចម្បងចេញពីអាជ្ញាធរថ្នាក់ខេត្ត ជាជាងអាជ្ញាធរថ្នាក់ក្រុង ដែលចុះកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន។ បញ្ហាទាំងនោះ រួមមានភាពមិនអនុលោមតាមលិខិតបទដ្ឋានគតិយុត្តិដោយអាជ្ញាធរស្រុក/ក្រុងក្នុងការរៀបចំកិច្ចសន្យាជាមួយក្រុមហ៊ុនប្រមូលសំរាម និងការប្រើប្រាស់មូលនិធិសេវាអនាម័យរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ រួមទាំងការជំរុញការអនុវត្តច្បាប់ និងការពិនិត្យតាមដាន និងវាយតម្លៃ នៅមានកម្រិតកំណត់ពីសំណាក់អាជ្ញាធរថ្នាក់ខេត្ត និង/ឬថ្នាក់ស្រុក/ក្រុងទៅលើការអនុវត្តកិច្ចសន្យា។ អនុក្រឹត្យលេខ ១១៣ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន បញ្ជាក់ជាផ្លូវការថា ការគ្រប់គ្រងសំរាម សំណល់រឹងត្រូវទុកឱ្យអាជ្ញាធរថ្នាក់ស្រុក និងក្រុងជាអ្នកគ្រប់គ្រង។

ចំណែកនៅថ្នាក់ជាតិ បញ្ហាប្រឈមទាំងនេះ ភាគច្រើនគឺកង្វះទិន្នន័យជឿជាក់ស្តីពីស្ថានភាពបច្ចុប្បន្ននៃការរៀបចំកិច្ចសន្យាក្នុងការគ្រប់គ្រងសំណល់ទាំងនៅថ្នាក់ខេត្ត និងស្រុក/ក្រុង ភាពមានកម្រិតនៃការពិនិត្យតាមដាន និងវាយតម្លៃ នៅថ្នាក់ជាតិ លើការគ្រប់គ្រងសំណល់របស់អាជ្ញាធរថ្នាក់ក្រោមជាតិ និងភាពមានកម្រិតនៃការគ្របដណ្តប់របស់អនុក្រឹត្យលេខ ១១៣ និងប្រកាសលេខ ០៧៣ ស្តីពីការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ តាមទីប្រជុំជនក្រុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការគ្រប់គ្រងសំណល់ទីផ្សារ។

## ការពិចារណាលើគោលវិធីដើម្បីធ្វើកំណែទម្រង់

បន្ថែមលើការយល់ដឹងដ៏រឹងមាំពីប្រព័ន្ធគ្រប់គ្រងសំណល់របស់ខេត្តកែប ការធ្វើផែនការដោយប្រុងប្រយ័ត្នសម្រាប់កំណែទម្រង់ទាមទារឱ្យមានការពិចារណាលើទិដ្ឋភាពជាច្រើន ក្នុងនោះរួមមានទាំងទិដ្ឋភាពផ្នែកអភិបាលកិច្ច បច្ចេកវិទ្យា និងប្រព័ន្ធ ការចូលរួមពីដៃគូ និងធនធាន។

ទស្សនទានសាកល្បងចំនួន ០៥ ដែលបានរៀបរាប់លម្អិតក្នុងរបាយការណ៍នេះ ជាអនុសាសន៍តំណាងឱ្យគោលវិធីបែបគ្រប់ជ្រុងជ្រោយ ត្រូវបានតាក់តែងឡើងដើម្បីឆ្លើយតបនឹងសមាសធាតុសារវន្តដែលចាំបាច់ សំដៅជំរុញឱ្យខេត្តកែបឈានឆ្ពោះទៅរកដំណោះស្រាយក្នុងការគ្រប់គ្រងសំណល់រឹង។ ទស្សនទានទាំង ០៥ ដែលត្រូវបានស្នើឡើងរួមមាន៖

១. អភិបាលកិច្ច - ការស្នើឡើងនូវទស្សនទាននេះ គឺដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមដែលកើតឡើងដោយសារដំណើរការធ្វើវិមជ្ឈការមិនពេញលេញ ក្នុងនោះគឺភាពត្រួតគ្នានៃសមត្ថកិច្ចគ្រប់គ្រង និងត្រួតពិនិត្យរបស់អាជ្ញាធរ ដែលអាចនាំឱ្យប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងសំណល់រឹងនៅមានកម្រិត។ ទស្សនទានសាកល្បងនេះ នឹងបញ្ចូលការផ្តោតការយកចិត្តទុកដាក់លើការពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីឱ្យការគ្រប់គ្រង និងប្រតិបត្តិការកាន់តែមានភាពល្អប្រសើរជាងមុន។

២. បច្ចេកវិទ្យា និងប្រព័ន្ធបែបវិមជ្ឈការ - ការលើកឡើងនូវទស្សនទាននេះ គឺផ្អែកតាមទ្រឹស្តីស្តីពីការគ្រប់គ្រងសំណល់ដែលជំរុញឱ្យមានការធ្វើប្រព្រឹត្តិកម្មសំណល់ក្នុងទ្រង់ទ្រាយតូចប្រើប្រាស់បច្ចេកវិទ្យាកម្រិតទាប និងចំណាយតិច នៅកៀកនឹងប្រភពដែលបង្កើតសំណល់ ដែលអាចឱ្យគេយកទៅប្រើប្រាស់បែបវិមជ្ឈការនៅកម្រិតសហគមន៍ ឬនៅថ្នាក់ស្រុក។

៣. សេវាប្រមូលសំរាមគ្របដណ្តប់ទាំងស្រុង និងកែលំអទីលានចាក់សំរាម - ទស្សនទាននេះ ផ្តោតលើកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រីកសេវាប្រមូលសំរាមតាមរយៈការកំណត់រកតំបន់ដែលមិនទាន់ទទួលបានសេវាប្រមូលសំរាម ឬតំបន់ដែលមិនទាន់ទទួលបានសេវាពេញលេញ និងដើម្បីកែលំអទីលានចាក់សំរាមរបស់ខេត្តកែបតាមរយៈការអនុវត្តវិធានការការពារបរិស្ថាន។

៤. តួនាទីនៃវិស័យក្រៅប្រព័ន្ធ - ទស្សនទាននេះ សំដៅលើការផ្តួចផ្តើមឱ្យមានការសន្ទនារវាងអាជ្ញាធរក្រុង និងកម្មករប្រមូលសំរាមក្នុងវិស័យក្រៅប្រព័ន្ធ។ តាមរយៈកិច្ចពិភាក្សា និងកិច្ចព្រមព្រៀង អាជ្ញាធរក្រុង អាចគាំទ្រដល់កម្មករប្រមូលសំរាមក្នុងវិស័យក្រៅប្រព័ន្ធ ក្នុងការធ្វើការងារឆ្ពោះទៅរកដំណោះស្រាយដែលនឹងផ្តល់ផលប្រយោជន៍ដល់សហគមន៍ទាំងមូល ក្នុងនោះរួមទាំងភាពល្អប្រសើរជាងមុននៃការញែក និងការទាញយកធនធានដែលអាចកែច្នៃឡើងវិញបាន។

៥. ការអប់រំ និងការយល់ដឹង - ទស្សនទាននេះ គឺជាការរៀបចំយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈឱ្យស្របតាមបរិបទរបស់កម្ពុជា ដោយមានការចូលរួមពីតួអង្គពាក់ព័ន្ធនៅគ្រប់កម្រិត និងគ្រប់ផ្នែកនៃសង្គមកម្ពុជា។ យុទ្ធនាការនេះ នឹងផ្តោតលើសារអប់រំផ្សព្វផ្សាយពីប្រធានបទដែលឆ្លុះបញ្ចាំងពីគុណតម្លៃ ប្រវត្តិសាស្ត្រ និងវប្បធម៌ក្នុងមូលដ្ឋាន និងផ្សារភ្ជាប់ជាមួយនឹងការគ្រប់គ្រងសំណល់រឹងផងដែរ។

## ការផ្តោតទៅលើកំណែទម្រង់គោលនយោបាយ

ស្របតាមគោលបំណងនៃទស្សនទានសាកល្បង អនុសាសន៍គោលនយោបាយមួយចំនួន ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នាត្រូវបានលើកឡើង។ អនុសាសន៍ទាំងនេះ ឆ្លើយតបចំពោះគោលបំណងជាច្រើនក្នុងពេលជាមួយគ្នា ប៉ុន្តែផ្តោតជុំវិញទស្សនទានជាមូលដ្ឋានមួយចំនួន ដូចជា ការអភិវឌ្ឍបៃតង និរន្តរភាពបរិស្ថាន សេដ្ឋកិច្ចចក្រា (Circular Economy) ការលើកកម្ពស់ជីវភាពរស់នៅ និងប្រសិទ្ធភាពចំណាយ។ សកម្មភាពសាកល្បងសំខាន់ៗដែលពាក់ព័ន្ធជាមួយនឹងទស្សនទាននីមួយៗរួមមាន៖

១. ពង្រឹង ការិយាល័យសាធារណៈការ ដឹកជញ្ជូន អនាម័យបរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ ក្នុងរដ្ឋបាលក្រុងកែប៖ សកម្មភាពនេះ មានគោលបំណងពង្រឹងគណនេយ្យភាពរបស់អាជ្ញាធរក្រុងលើការគ្រប់គ្រងសំណល់នៅមូលដ្ឋាន ជាមួយគ្នានឹងការផ្តល់លទ្ធភាពបង្កើនការយល់ដឹងរបស់មន្ត្រីក្រុងពីប្រតិបត្តិការគ្រប់គ្រងសំណល់រឹង។ សកម្មភាពនេះ ជាការផ្តោតផងដែរលើការធានានូវភាពជោគជ័យនៃការផ្ទេរតួនាទីត្រួតពិនិត្យសេវាគ្រប់គ្រងសំណល់ទៅឱ្យអាជ្ញាធរក្រុងកែប ជាពិសេសការិយាល័យដែលទើបបង្កើតថ្មី ឱ្យមានចំនួនមន្ត្រី និងថវិកាគ្រប់គ្រាន់។

*សកម្មភាពសាកល្បងនៅក្រោម៖ អភិបាលកិច្ច*

២. រៀបចំប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីគាំទ្រការធ្វើវិមជ្ឈការ និងការកែលំអប្រតិបត្តិការគ្រប់គ្រងសំណល់រឹងតាមរយៈការផ្តោតលើការគ្រប់គ្រងទិន្នន័យ៖ ដើម្បីធានាប្រសិទ្ធភាពប្រតិបត្តិការ និងដំណើរការប្រព័ន្ធឱ្យបានរឹងមាំ ចាំបាច់ត្រូវយកចិត្តទុកដាក់បន្ថែមលើប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ។ គួរមានការផ្តោតការយកចិត្តទុកដាក់បែបនេះលើប្រតិបត្តិការគ្រប់គ្រង ដូចជា ការបំពេញការងារផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាលរបស់អង្គភាពគ្រប់គ្រងសំណល់ ដោយធ្វើការសម្របសម្រួលជាមួយនឹងស្ថាប័នដែលធ្វើការត្រួតពិនិត្យនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជា ផ្សារភ្ជាប់ទំនាក់ទំនងជាមួយការពិនិត្យតាមដានប្រតិបត្តិការគ្រប់គ្រងសំណល់រឹងនៅក្នុងមូលដ្ឋានផងដែរ។ ការស្វែងយល់ឱ្យបានគ្រប់ជ្រុងជ្រោយពីប្រភេទសំណល់ និងបរិមាណសំណល់ មានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ការរៀបចំផែនការប្រតិបត្តិការ និងការវិនិយោគ ព្រមទាំងការធ្វើសេចក្តីសម្រេចចិត្តក្នុងការគ្រប់គ្រងសំណល់ ជាពិសេស ដើម្បីកំណត់ពីរបៀបគ្រប់គ្រងប្រភេទសំណល់ផ្សេងៗគ្នា។

*សកម្មភាពសាកល្បងនៅក្រោម៖ អភិបាលកិច្ច*

៣. កំណត់ពីធនធានដែលចាំបាច់ ដើម្បីសម្រេចគោលដៅនៃការគ្រប់គ្រងសំណល់រឹងទីក្រុង និងរៀបចំយុទ្ធសាស្ត្របង្កើនចំណូល ដើម្បីឆ្លើយតបចំពោះតម្រូវការចាំបាច់៖ ស្របគ្នានឹងការពង្រឹងការយកចិត្តទុកដាក់លើការពិនិត្យតាមដាន និងវាយតម្លៃ អាជ្ញាធរដែលពាក់ព័ន្ធក្នុងខេត្ត និងក្រុងកែប ត្រូវធានាឱ្យមានការផ្តល់ធនធានឱ្យបានគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការសម្រេចគោលបំណងនៃការគ្រប់គ្រងសំណល់តាមរយៈភាពដៃគូនៅមូលដ្ឋាន។ នេះ តម្រូវឱ្យមានការវិភាគលើជម្រើសយន្តការផ្តល់ថវិកាគាំទ្រដល់ប្រតិបត្តិការគ្រប់គ្រង

សំណល់រឹង។ នាពេលបច្ចុប្បន្ន ប្រតិបត្តិការនៅក្នុងខេត្តកែប ពឹងអាស្រ័យលើការប្រមូលថ្លៃសេវាគ្រប់គ្រងដោយប្រតិបត្តិករវិស័យឯកជនដែលនាំឱ្យសេវាប្រមូលសំរាមនេះ ផ្តោតការយកចិត្តទុកដាក់ភាគច្រើនលើតម្រូវការនៃសហគ្រាសពាណិជ្ជកម្មដែលជាអ្នកបង្កើតសំរាមក្នុងទ្រង់ទ្រាយធំ។ ដើម្បីយកចិត្តទុកដាក់ឱ្យបានគ្រប់គ្រាន់លើការគ្រប់គ្រងសំណល់នៅថ្នាក់សហគមន៍ ថវិកាសម្រាប់ប្រតិបត្តិការសំណល់ចាំបាច់ត្រូវមានការពង្រីក និងស្វែងរកបន្ថែមពីប្រភពផ្សេងៗ។

*សកម្មភាពសាកល្បងនៅក្រោម៖ អភិបាលកិច្ច*

៤. សាកល្បងគំរូភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន ដែលរួមបញ្ចូលការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច ដើម្បីគាំទ្រការញែកសំរាមនៅប្រភពដើមផ្ទាល់ដែលជាផ្នែកមួយនៃសេដ្ឋកិច្ចចក្រា៖ គម្រោងលើកទឹកចិត្តផ្នែក សេដ្ឋកិច្ច ត្រូវបានរកឃើញថា មានប្រសិទ្ធភាពក្នុងការបង្កើនការចូលរួមក្នុងការញែកសំណល់។ រដ្ឋបាលក្រុងកែប អាចទទួលបានលទ្ធផលនេះ តាមរយៈការអនុវត្តគំរូសាកល្បងដែលមានឈ្មោះថា ធនាគារសំណល់។ ប្រជាពលរដ្ឋ អាចទទួលបានការទូទាត់ជាសាច់ប្រាក់ពីសំរាមស្ងួត (ប្លាស្ទិក លោហៈ និងអាលុយមីញ៉ូមជាដើម) ដែលបានយកទៅដាក់នៅធនាគារ។ គំរូមួយទៀត គឺជាការដាក់បញ្ចូលកម្មករក្រៅប្រព័ន្ធទៅក្នុងប្រព័ន្ធគ្រប់គ្រងសំណល់ដែលមានស្រាប់។ ការខិតខំប្រឹងប្រែងប្រមូលសំរាមរបស់កម្មករក្នុងវិស័យក្នុង និងក្រៅប្រព័ន្ធ អាចកាត់បន្ថយបរិមាណសំរាមនៅទីលានចាក់សំរាមក្នុងខេត្តកែប ព្រមទាំងជួយគាំទ្រដល់ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋងាយរងគ្រោះផងដែរ។ រដ្ឋបាលក្រុងកែប គួរតែបង្កើតកន្លែងប្រមូលសំរាមស្ងួតដែលអាចកែច្នៃបាន និងធ្វើការងារជាមួយនឹងវិស័យក្រៅប្រព័ន្ធដើម្បីបង្កើតគំរូសហការគ្នាសម្រាប់ការប្រមូល និងលក់សំណល់ ដែលអាចកែច្នៃបានទៅជាផលិតផលថ្មី និងប្រភពនៃថាមពល។ ភាពជាដៃគូជាមួយដេប៉ូទិញ-លក់អេតចាយ និង/ឬវិស័យឯកជន គួរតែជាផ្នែកមួយនៃគំរូសាកល្បងទាំងពីរផងដែរ ដើម្បីបញ្ជូនសំណល់ទៅកាន់កន្លែងកែច្នៃសំណល់។

*សកម្មភាពសាកល្បងនៅក្រោម៖ ការអប់រំ និងការយល់ដឹង និងតួនាទីរបស់វិស័យក្រៅប្រព័ន្ធ*

៥. បង្កើតភាពជាដៃគូ ដើម្បីសាកល្បងការផលិតជីវឧស្ម័នពីសំណល់សរីរាង្គពីផ្សារនៅខេត្តកែប តាមរយៈការបំបែកដោយគ្មានអុកស៊ីសែន (Anaerobic Digestion) ដែលអាចបញ្ចៀសសំណល់សរីរាង្គចេញពីទីលានចាក់សំរាមចុងក្រោយ និងធ្វើការសិក្សាសមិទ្ធិលទ្ធភាពនៃការធ្វើជីកំប៉ុស្តនៅនឹងប្រភពសំណល់ផ្ទាល់៖ ទីផ្សារ និងកន្លែងផ្តល់សេវាអាហារ រួមទាំងកន្លែងកែច្នៃអាហារផ្សេងទៀត បង្កើតបានសំណល់សរីរាង្គក្នុងបរិមាណដ៏ច្រើន។ សំណល់សរីរាង្គ អាចប្រើប្រាស់ជាវត្ថុធាតុដើមសម្រាប់ដំណើរការឡជីវឧស្ម័ន ដែលជាដំណើរការមួយជួយកាត់បន្ថយបរិមាណសំរាមក្នុងពេលជាមួយគ្នាអាចជួយផលិតជីវឧស្ម័នបានផងដែរ។ ទីផ្សារក្នុងក្រុងកែប ផ្តល់ឱកាសសាកល្បងគំនិតផ្តួចផ្តើមនេះជាមួយនឹង កម្មវិធីឡជីវឧស្ម័នជាតិ ដើម្បីគាំទ្រដល់និរន្តរភាពក្នុងការធ្វើប្រព្រឹត្តិកម្មសំណល់រឹងក្នុងក្រុងកែប។ សំណល់សរីរាង្គ ក៏ជាឱកាសមួយទៀតសម្រាប់ធ្វើជីកំប៉ុស្តសម្រាប់ប្រើប្រាស់ក្នុងវិស័យកសិកម្ម។ ក្រុងកែប គួរតែធ្វើការវាយតម្លៃសមិទ្ធិលទ្ធភាពសម្រាប់ការធ្វើជីកំប៉ុស្តនៅនឹងកន្លែងផ្ទាល់នៅក្នុងតំបន់ដែលមិនទទួលបានការផ្តល់សេវាប្រមូលសំរាម។

*សកម្មភាពសាកល្បងនៅក្រោម៖ បច្ចេកវិទ្យា និងប្រព័ន្ធបែបវិមជ្ឈការ*

៦. បង្កើតផែនទីបង្ហាញផ្លូវដើម្បីសម្រេចឱ្យបាននូវការប្រមូលសំរាមទូទាំងខេត្តកែប៖ ការពង្រីកការគ្របដណ្តប់នៃការប្រមូលសំរាមឱ្យបានទាំងស្រុង មានសារៈសំខាន់ ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមនៃការគ្រប់គ្រងសំណល់ដែលខេត្តកែបកំពុងជួបប្រទះ។ ការជំរុញឱ្យមានការប្រមូលសំរាមទូទាំងខេត្តបែបនេះ នឹងជួយឱ្យរដ្ឋបាលខេត្តកែប អាចឆ្លើយតបចំពោះបញ្ហានៃការដុតសំរាមពាសវាលពាសកាល និងបញ្ហាកើនឡើង ប្លាស្ទិកក្នុងសមុទ្រផងដែរ។ ការកំណត់គោលដៅច្បាស់លាស់ និងជំហានដែលចាំបាច់ ជាមាគ៌ាបង្ហាញផ្លូវយ៉ាងច្បាស់ដើម្បីឈានទៅសម្រេចគោលដៅ។

*សកម្មភាពសាកល្បងនៅក្រោម៖ សេវាប្រមូលសំរាមគ្របដណ្តប់ទាំងស្រុង និងកែលំអទីលានចាក់សំរាម*

៧. រៀបចំផែនការសកម្មភាព ដើម្បីធានាឱ្យមានទីលានចាក់សំរាមត្រឹមត្រូវ និងកែលំអប្រតិបត្តិការដោយវិធីសាស្ត្រដែលចំណាយទាប ដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថាន៖ ខេត្តកែប គួរតែផ្តោតការយកចិត្តទុកដាក់លើការកែលំអប្រតិបត្តិការនៅទីលានចាក់សំរាម។ ផ្លូវចូលទៅកាន់ទីលាននេះគួរតែជួសជុល និងការប្រតិបត្តិការ គួរតែផ្លាស់ប្តូរតាមរយៈការកាត់បន្ថយការដុតសំរាម ការទុកដាក់សំរាមឱ្យបានសមស្រប និងការប្រើប្រាស់សម្ភារសម្រាប់គ្របសំរាមជាប្រចាំ ដើម្បីជួយកាត់បន្ថយផលប៉ះពាល់បរិស្ថាន។

*សកម្មភាពសាកល្បងនៅក្រោម៖ សេវាប្រមូលសំរាមគ្របដណ្តប់ទាំងស្រុង និងកែលំអទីលានចាក់សំរាម*

៨. គាំទ្រដល់ការអនុវត្តគំនិតផ្តួចផ្តើមបង្កើនការយល់ដឹង ដើម្បីអប់រំប្រជាពលរដ្ឋពីសារៈសំខាន់នៃការចោលសំរាមឱ្យបានត្រឹមត្រូវ ផលប៉ះពាល់ទៅលើសុខភាព និងបរិស្ថានដែលបង្កឡើងដោយសារការដុតសំរាម និងការផាកពិន័យចំពោះករណីចោលសំរាមពុំបានត្រឹមត្រូវ៖ មានតែតាមរយៈការគាំទ្រ និងការជំរុញឱ្យមានការចូលរួមពីប្រជាពលរដ្ឋនៅមូលដ្ឋានតែប៉ុណ្ណោះ ដែលអាចធ្វើឱ្យមានភាពជឿនលឿនពិតប្រាកដឆ្ពោះទៅរកការកែលំអការគ្រប់គ្រងសំណល់។ ការបង្ហាញពីសញ្ញាយ៉ាងរឹងមាំរបស់អ្នកដឹកនាំនៅមូលដ្ឋាន គឺជាការបង្ហាញពីការប្តេជ្ញាចិត្តអនុវត្តសកម្មភាព ដើម្បីផ្សព្វផ្សាយសារនេះ។ សកម្មភាពទាំងនេះ អាចរួមមានការរៀបចំយុទ្ធនាការសម្អាតឆ្នេរ ដោយមានការដឹកនាំពីមន្ត្រីនៅមូលដ្ឋាន ការរៀបចំព្រឹត្តិការណ៍ផ្សារភ្ជាប់ជាមួយនឹងការញែកសំរាម ការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ឬការប្តេជ្ញាមិនដុតសំរាមតាមទីវាល និងមិនចោលសំរាមខុសច្បាប់ជាដើម។

*សកម្មភាពសាកល្បងនៅក្រោម៖ ការអប់រំ និងការយល់ដឹង*

សរុបសេចក្តីមក របាយការណ៍នេះ ព្យាយាមប្រមូលព័ត៌មានចាំបាច់ពីបទពិសោធន៍របស់ខេត្តកែប ដើម្បីរៀបចំកំណែទម្រង់មួយដែលចាំបាច់ផ្តោតលើសកម្មភាពអនុវត្តសម្រាប់ជំហានបន្ទាប់។ ការអនុវត្តសកម្មភាពសាកល្បង បូករួមជាមួយការវិភាគពីកំណែទម្រង់ដែលចាំបាច់ នឹងជួយជំរុញកិច្ចពិភាក្សាឱ្យឈានចូលកាន់តែជិតទៅរកការរៀបចំគោលនយោបាយ។ កិច្ចខំប្រឹងប្រែងទាំងនេះ ត្រូវបានរៀបចំឡើង ដើម្បីកែប្រែវិស័យដែលបច្ចុប្បន្នកំពុងមានភាពទន់ខ្សោយ និងមានធនធានមិនគ្រប់គ្រាន់នេះ និងដើម្បីផ្តល់ឧបករណ៍ថ្មីៗ ដើម្បីធ្វើដំណើរឆ្ពោះទៅរកបច្ចេកវិទ្យាបច្ចុប្បន្នភាព ការតម្រង់ទិសការគ្រប់គ្រង និងបង្កើនការយកចិត្តទុកដាក់លើការចូលរួមរបស់សាធារណជន ដែលគាំទ្រដល់កំណែទម្រង់នេះ។

# ១. សេចក្តីផ្តើម

*"របាយការណ៍សិក្សាវិសាលភាព"* នេះ ព្យាយាមប្រមូល និងចងក្រងចំណេះដឹង ពីការអនុវត្តក្នុងការគ្រប់គ្រងសំណល់ និងបញ្ហាប្រឈមដែលជួបប្រទះនៅក្នុងខេត្តកែបនាពេលបច្ចុប្បន្ន។ ព័ត៌មាននេះ អមមកជាមួយនូវការពិពណ៌នាសង្ខេបពីបរិបទការគ្រប់គ្រងសំណល់ក្នុងប្រទេសកម្ពុជា ដើម្បីតម្រង់ទិសអ្នកអាននៅក្នុងទស្សនវិស័យស្តីពីសំណល់នៅថ្នាក់ជាតិ។ បន្ទាប់មក មានការវិភាគលើបញ្ហាប្រឈមជាក់លាក់ចំពោះខេត្តកែប និងការពិពណ៌នាពីដំណោះស្រាយ ក្នុងនោះរួមមានទាំងធាតុចូល និងធនធានដែលត្រូវការ និងជាចុងក្រោយ គឺការពិពណ៌នាពីសកម្មភាពអនុវត្តសាកល្បងជាច្រើន ដើម្បីដោះស្រាយបញ្ហាប្រឈមដែលបានរកឃើញ។ ផ្អែកលើក្របខ័ណ្ឌនៃការវិភាគ និងអនុសាសន៍ទាំងអស់នេះ អនុសាសន៍គោលនយោបាយសម្រាប់ការពិចារណារបស់អ្នកធ្វើការសម្រេចចិត្តផ្នែកការគ្រប់គ្រងសំណល់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានលើកឡើង និងដាក់បញ្ចូលនៅផ្នែកចុងក្រោយនៃរបាយការណ៍។

## ១.១ សាវតារ

កំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ បាននាំឱ្យមានសេចក្តីត្រូវការជាបន្ទាន់ក្នុងការឆ្លើយតបចំពោះបញ្ហាប្រឈមក្នុងការគ្រប់គ្រងសំណល់។ ផ្អែកតាមការប៉ាន់ប្រមាណ ក្នុងឆ្នាំ២០១៤ ប្រទេសកម្ពុជា បង្កើតសំរាមតែប្រមាណជាង ១ លានតោនបន្តិចប៉ុណ្ណោះ ហើយតួលេខនេះត្រូវបានប៉ាន់ប្រមាណថា បានកើនដល់ ៣,៦៥ លានតោនក្នុងឆ្នាំ២០១៧ (Modak et al., 2017; Pech, 2018)។ កំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័ស និងនិន្នាការឈានឡើងនៃការប្រើប្រាស់ទំនិញក្នុងប្រទេសកំពុងជំរុញឱ្យមានការកើនឡើងយ៉ាងឆាប់រហ័សនូវការបង្កើតសំរាម។ ក្រសួងបរិស្ថាន បានប៉ាន់ប្រមាណថា កំណើននេះមានអត្រា ១០% ក្នុងមួយឆ្នាំ (Bual, 2018) ។

បញ្ហាការគ្រប់គ្រងសំណល់នេះ ទើបតែបានទទួលការចាប់អារម្មណ៍ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះប៉ុណ្ណោះ ថាជាអាទិភាពផ្នែកបរិស្ថាន ដោយមានការយកចិត្តទុកដាក់ច្រើនបំផុតទៅលើការគ្រប់គ្រងសំណល់ក្នុងក្រុងភ្នំពេញ និងទីក្រុងសក្តានុពលជាច្រើនទៀត (Min, 2016)។ ឧទាហរណ៍មួយពីទិដ្ឋភាពនេះ គឺកម្មវិធីលើកកម្ពស់សេវាទីក្រុង ដែលអង្គការមូលនិធិអាស៊ី បានបញ្ចប់ការអនុវត្តសាកល្បងកន្លងមក ដែលមានគោលបំណងកែលំអការគ្រប់គ្រងសំណល់រឹងក្នុងក្រុងភ្នំពេញ ដោយផ្តោតការយកចិត្តទុកដាក់លើការកំណត់ពីបញ្ហាលំបាក ការជួយសម្របសម្រួលលទ្ធភាពទទួលបានព័ត៌មាន និងធនធាន រួមទាំងការកំណត់រកដំណោះស្រាយចំពោះបញ្ហាប្រឈមជាក់ស្តែងក្នុងការគ្រប់គ្រងសំណល់។ កិច្ចខិតខំផ្នែកការស្រាវជ្រាវធ្វើឡើងក្នុងបរិបទកម្មវិធីនេះ ត្រូវបានតាក់តែងឡើង ដើម្បីកំណត់រូបរាងការប្រមូលសំណល់នៅក្នុងរាជធានីឡើងវិញ និងដើម្បីផ្តល់ធាតុចូលចំពោះដំណើរការកំណែទម្រង់ជាបន្តបន្ទាប់លើវិស័យគ្រប់គ្រងសំណល់រឹង (Deny, 2016)។ ម្យ៉ាងវិញទៀត ជាយក្រុង និងខេត្តក្រៅពីរាជធានីភ្នំពេញ ទទួលបានការយកចិត្តទុកដាក់តិចតួចប៉ុណ្ណោះចំពោះបញ្ហាការគ្រប់គ្រងសំណល់នេះ ហើយការយកចិត្តទុកដាក់ទាំងនោះ មាននៅតែកន្លែងដែលមានសារៈសំខាន់ពិសេសចំពោះជាតិ និងអន្តរជាតិប៉ុណ្ណោះ (Gordon, 2015) ។

បន្ថែមលើសំណល់ពីការវេចខ្ចប់កាន់តែច្រើនឡើងដែលពាក់ព័ន្ធជាមួយកំណើនប្រជាជន និងជីវភាពរស់នៅកាន់តែចម្រើនរុងរឿង វិស័យទេសចរណ៍ដែលកំពុងរីកលូតលាស់ ក៏ជាកត្តាជំរុញដ៏សំខាន់មួយទៀត បណ្តាលឱ្យមានការបង្កើតសំរាមផងដែរ ជាពិសេសនៅក្នុងតំបន់ដែលមានអ្នកទេសចរណ៍ច្រើន ជាពិសេសនៅតាមតំបន់ឆ្នេរ ក៏ដូចជានៅក្នុងខេត្តសៀមរាប និងរាជធានីភ្នំពេញ។ យោងតាមការប៉ាន់ប្រមាណមួយបានឱ្យដឹងថា អ្នកទេសចរណ៍ដែលមកទស្សនានៅប្រទេសកម្ពុជា បង្កើតឱ្យមានដបប្លាស្ទិកចំនួន ១០ លានដប ជារៀងរាល់ខែ ដោយដបទាំងនោះនៅទីបំផុតត្រូវបានប្រមូល និងយកទៅចាក់នៅទីលានចាក់សំរាម ឬចោលនៅតាមទីកន្លែងនានា ហើយពេលខ្លះត្រូវបានទឹកអូរ ឬទន្លេនាំយកទៅកាន់សមុទ្រ (Refill Asia, 2019) ។

ចំណុចសំខាន់ៗដែលត្រូវយកចិត្តទុកដាក់ នៅពេលពិចារណាលើការគ្រប់គ្រងសំណល់នៅក្នុងប្រទេសកម្ពុជា រួមមាន៖

- ការប្រមូលសំណល់ក្នុងក្រុងគោលដៅធំៗ ភាគច្រើន គឺត្រូវបានជួលទៅឱ្យក្រុមហ៊ុនឯកជន (Kaza et al., 2018)។
- អត្រាការប្រមូលសំរាម មិនទាន់បានពេញលេញ ដោយការប្រមូលនោះមានអត្រាចាប់ពី ៣០% ដល់ ៨០% ក្នុងតំបន់ទីប្រជុំជនភាគច្រើន (Sour, 2017)។
- ការជំរុញការអនុវត្តនិយាម និងលិខិតបទដ្ឋានគតិយុត្តិផ្នែកបរិស្ថាន និងការមើលខុសត្រូវលើការបោះចោលសំរាមនៅមានកម្រិត (Min, 2016)។
- កន្លែងចាក់សំរាម ជាកន្លែងចម្បងសម្រាប់ការបោះចោលសំរាម បូករួមជាមួយការដុតសំណល់តាម ទីវាលដែលរួមចំណែកបង្កឱ្យមានការបំពុលខ្យល់ ដីរេចរឹល និងទាក់ទងនឹងផលប៉ះពាល់អវិជ្ជមានផ្នែកសុខភាព (MoE & UNEP, 2009)។
- ប្រព្រឹត្តិកម្មផ្លូវការលើសំណល់ ភាគច្រើនគឺពុំមាននោះទេ ហើយភាគច្រើនត្រូវបានធ្វើឡើងដោយ វិស័យក្រៅប្រព័ន្ធ ដែលរកចំណូលបានពីការលក់សម្ភារៈអេតចាយ ដូចជាលោហៈ និងប្លាស្ទិកជាដើម (Min, 2016)។
- សមាសធាតុសរីរាង្គនៅក្នុងសំណល់រឹងទីក្រុងនៅកម្ពុជា ត្រូវបានប៉ាន់ប្រមាណថា មានចាប់ពី ៥០% ដល់ ៧០% (Sang-Arun et al., 2011)។

## ១.២ ភាពជាដៃគូរវាងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងអង្គការមូលនិធិអាស៊ី

ក.ជ.អ.ច. ចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមក្នុងការគ្រប់គ្រងសំណល់នៅក្នុងប្រទេសកម្ពុជា ព្យាយាមបង្កើតនវានុវត្តន៍តាមរយៈការវាយតម្លៃលើឱកាស ដើម្បីអនុវត្តគោលវិធីសេដ្ឋកិច្ចចក្រា (Circular Economy Approaches) ក៏ដូចជាតាមរយៈការទទួលស្គាល់កាន់តែច្រើនឡើងពីសេចក្តីត្រូវការក្នុងការដាក់បញ្ចូលគោលការណ៍ឋានានុក្រមសំណល់ (Waste Hierarchy Principles) ទៅក្នុងដំណោះស្រាយគោលនយោបាយ (Sok, 2019)។ ចំណាប់អារម្មណ៍កាន់តែខ្លាំងឡើងនេះ គឺដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តគោលវិធីបរិស្ថានថ្មីៗ ដែលដាក់បញ្ចូលទស្សនទានស្តីពីកំណើនសេដ្ឋកិច្ចបៃតង និងនិរន្តរភាព ជាមួយនឹងការអនុវត្តការគ្រប់គ្រងសំណល់រឹង ដែលហាក់មានប្រភពចេញមកពីការទទួលស្គាល់ពីសម្ពាធផ្នែកបរិស្ថាន ពាក់ព័ន្ធជាមួយការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ក៏ដូចជាគោលបំណង ដើម្បីអភិរក្សធនធាន ស្របពេលជាមួយការជួយការពារតំបន់ទេសភាពធម្មជាតិរបស់ប្រទេសសម្រាប់មនុស្សជំនាន់ក្រោយ (MoE & UNEP, 2009)។

ដោយប្រកាន់ខ្ជាប់នូវគោលគំនិតនេះ ក.ជ.អ.ច. និងអង្គការមូលនិធិអាស៊ី បានបង្កើតឱ្យមានកិច្ចព្រមព្រៀងផ្លូវការមួយនៅខែតុលា ឆ្នាំ២០១៨ ដើម្បីគាំទ្រដល់គោលនយោបាយសំដៅឆ្លើយតបចំពោះនិរន្តរភាពបរិស្ថាន នៅក្នុងអំឡុងពេលប្រទេសមានសេដ្ឋកិច្ចអភិវឌ្ឍដ៏ឆាប់រហ័ស។ កិច្ចព្រមព្រៀងនេះ ធ្វើឡើងក្នុងទម្រង់ជាអនុស្សរណៈនៃការយោគយល់ និងផ្តល់យន្តការឱ្យ ក.ជ.អ.ច. មានលទ្ធភាពអាចទទួលបានចំណេះដឹង និងចំណេះធ្វើកម្រិតសាកល ចូលរួមឆ្លើយតបសំណួរស្តីពីការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងកំណើនសេដ្ឋកិច្ចបៃតង។

នៅដើមឆ្នាំ២០១៩ ក.ជ.អ.ច. និងអង្គការមូលនិធិអាស៊ី បានចាប់ផ្តើមពិភាក្សាឡើងវិញថាតើធ្វើយ៉ាងណា ដើម្បីបន្តការងារដោយឈរលើកិច្ចសហការនាពេលកន្លងមក ដែលបង្កើតឡើងដោយអនុស្សរណៈនៃការយោគយល់នេះ។ ការពិភាក្សា បាននាំឱ្យមានការយកចិត្តទុកដាក់លើគោលវិធីស្តីពីទីក្រុងគំរូតាមរយៈការពិនិត្យមើលតម្រូវការការកែលំអការគ្រប់គ្រងសំណល់នៅក្នុងប្រទេស ដោយយក ក្រុងកែប ជាមូលដ្ឋានសម្រាប់ការវិភាគ និងការវាយតម្លៃ។ ការសិក្សានេះ ដើរស្របជាមួយកិច្ចខិតខំជាច្រើនដទៃទៀត ដែលគាំទ្រដល់រដ្ឋាភិបាល និងម្ចាស់ជំនួយ ដែលផ្តោតការយកចិត្តទុកដាក់លើការធ្វើឱ្យប្រសើរឡើងនូវសេវាទីប្រជុំជន និងកិច្ចការពារបរិស្ថាន ក្នុងនោះរួមមាន ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍បៃតងសម្រាប់ទីក្រុងគោលដៅ ដោយវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល និងកិច្ចខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់សេដ្ឋកិច្ចចក្រាដឹកនាំដោយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ដោយមានការគាំទ្រពីរដ្ឋាភិបាលស៊ុយអែត (Sen, 2019)។ ការសិក្សារបស់ ក.ជ.អ.ច. និងអង្គការមូលនិធិអាស៊ីនេះ ផ្សារភ្ជាប់បញ្ហាស្តីពីការគ្រប់គ្រងសំណល់ ជាមួយការផ្តោតការយកចិត្តទុកដាក់ជាច្រើនឆ្នាំរបស់រដ្ឋាភិបាលកម្ពុជា លើវិមជ្ឈការដំណើរការសម្រេចចិត្ត ពោលគឺជាកិច្ចខិតខំមួយ ដែលត្រូវបានសម្របសម្រួលដោយក្រសួងមហាផ្ទៃ តាមរយៈលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (Niaza, 2011)។

## ១.៣ គោលបំណងនៃការសិក្សា

គោលបំណងនៃការសិក្សានេះ គឺ៖

១. ធ្វើការស្វែងយល់ពីប្រព័ន្ធគ្រប់គ្រងសំណល់រឹង និងហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់

២. ធ្វើការស្វែងយល់ពីនិរន្តរភាពហិរញ្ញវត្ថុរបស់ប្រតិបត្តិករប្រមូលសំរាម

៣. យល់ដឹងពីតួនាទីយេនឌ័រនៅក្នុងការគ្រប់គ្រងសំណល់

៤. កំណត់រកបញ្ហាប្រឈមសំខាន់ៗនៅក្នុងការអនុវត្តនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិពីការគ្រប់គ្រងសំណល់រឹង

៥. វិភាគពីឱកាសក្នុងការដាក់បញ្ចូលការត្រួតពិនិត្យ និងធនធាន ដែលត្រូវការដើម្បីគាំទ្រដល់ ដំណើរការប្រព័ន្ធប្រតិបត្តិការតាមរយៈសំណើអនុសាសន៍ និងសកម្មភាពសាកល្បង។

# ២. គោលវិធី និងវិធីសាស្ត្រ

ដើម្បីអនុវត្តគំនិតផ្តួចផ្តើមដែលផ្តោតការយកចិត្តទុកដាក់លើខេត្តកែប ការអភិវឌ្ឍការយល់ដឹងពីស្ថានភាពបច្ចុប្បន្ននៃការគ្រប់គ្រងសំណល់នៅក្នុងខេត្តនេះ ជាការសំខាន់ណាស់។ ដើម្បីបង្ហាញរូបភាពឱ្យបានសុក្រឹត និងបង្កើតការយល់ដឹងជាមូលដ្ឋានឱ្យបានរឹងមាំពីស្ថានភាពនេះ ក.ជ.អ.ច. និងអង្គការមូលនិធិអាស៊ី បានរៀបចំការស្រាវជ្រាវ និងគោលវិធីនៃការវិភាគ ដើម្បីកំណត់រកអនុសាសន៍ផ្នែកគោលនយោបាយ ដែលឆ្លើយតបចំពោះផ្នែកដែលមានតម្រូវការចាំបាច់ក្នុងការធ្វើកំណែទម្រង់ក្នុងវិស័យការគ្រប់គ្រងសំណល់ទីប្រជុំជន។




*រូបភាពទី ១៖ ទីតាំងរបស់ក្រុងកែប និងខេត្តកែប*

## ២.១ លទ្ធផលការងារ និងសកម្មភាព

ដូចបានបញ្ជាក់នៅក្នុងផ្នែកគោលវិធី និងវិធីសាស្ត្រខាងលើ កម្រងការងារមានអន្តរទំនាក់ទំនងគ្នាទៅវិញទៅមក ត្រូវបានផ្តួចផ្តើមឡើង ដើម្បីផ្តល់មូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការសម្រេចចិត្តនាពេលអនាគត ពាក់ព័ន្ធជាមួយការគ្រប់គ្រងសំណល់ទីក្រុង។ ការរៀបរាប់ដោយសង្ខេបពីធាតុចូលនីមួយៗទៅក្នុងដំណើរការនេះមានដូចខាងក្រោម៖

ការសិក្សាឯកសារពាក់ព័ន្ធ៖ របាយការណ៍បឋមស្តីពីការសិក្សាឯកសារពាក់ព័ន្ធ ត្រូវបានតាក់តែងឡើងដើម្បីចងក្រង និងរៀបចំទិន្នន័យដែលមានស្រាប់ទាំងអស់ពាក់ព័ន្ធជាមួយការគ្រប់គ្រងសំណល់ក្នុងខេត្តកែប។ ការសិក្សានេះ ដឹកនាំដោយអ្នកពិគ្រោះយោបល់អន្តរជាតិម្នាក់ ដែលមានចំណេះដឹងពីការអនុវត្តល្អផ្នែកការគ្រប់គ្រងសំណល់កម្រិតសាកល និងការយល់ដឹងពីបញ្ហាប្រឈមដែលបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ជួបប្រទះ ហើយព្យាយាមកែលំអ និងកែទម្រង់ប្រព័ន្ធគ្រប់គ្រងសំណល់។ ការសិក្សានេះ ពិនិត្យលើសមាសភាគផ្សេងៗជាច្រើននៃការគ្រប់គ្រងសំណល់ក្នុងខេត្តកែប៖ ការប្រមូល ការដឹកជញ្ជូន ប្រព្រឹត្តិកម្ម និងការបោះចោលតាមទីសាធារណៈ។ ទិដ្ឋភាពសំខាន់ៗដទៃទៀតដែលត្រូវបានយកមកពិចារណា រួមមាន៖ ការបង្កើតសំរាមសមុទ្រ និងប្លាស្ទិក ការគ្រប់គ្រងសំណល់នៅលើកោះចំនួនពីរ (កោះទន្សាយ និងកោះពោធិ៍) ដែលជាផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រងសំណល់របស់ក្រុងកែប ព្រមទាំងឱកាសសម្រាប់ការកែច្នៃអេតចាយស្ងួត និងសំណល់សរីរាង្គ (របាយការណ៍នេះ មានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី១)។

ការចុះប្រមូលព័ត៌មានផ្ទាល់នៅទីវាល៖ ការចុះសិក្សាផ្ទាល់ទៅកាន់ខេត្តកែប ត្រូវបានធ្វើឡើងស្របពេលជាមួយការរៀបចំរបាយការណ៍សិក្សាឯកសារពាក់ព័ន្ធ។ គោលបំណងនៃការចុះសិក្សាផ្ទាល់នេះ គឺដើម្បីធ្វើការសង្កេតដោយផ្ទាល់លើការអនុវត្តការគ្រប់គ្រងសំណល់ក្នុងខេត្តកែប និងដើម្បីពិភាក្សាពីបញ្ហាប្រឈមនានាក្នុងការគ្រប់គ្រងសំណល់រឹងជាមួយអាជ្ញាធរថ្នាក់ស្រុក/ក្រុង។ ការចុះសិក្សាផ្ទាល់នេះ រួមមានកិច្ចប្រជុំជាមួយរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ក្រុមហ៊ុនដែលបានចុះកិច្ចសន្យាប្រមូលដឹកជញ្ជូន និងបោះចោលសំណល់ ទស្សនកិច្ចផ្នែកបច្ចេកទេសទៅកាន់ទីលានចាក់សំរាម កន្លែងកែច្នៃសំណល់រឹងឡើងវិញ និងដេប៉ូទិញលក់អេតចាយ ក៏ដូចជាទស្សនកិច្ចទៅកាន់ទីផ្សារ សណ្ឋាគារ ភោជនីយដ្ឋាន ឆ្នេរសមុទ្រ និងកោះទាំងពីរដែលជាផ្នែកនៃប្រព័ន្ធគ្រប់គ្រងសំណល់រឹងរបស់ក្រុងកែប និងទីតាំងធ្វើជីកំប៉ុស្តនៅខេត្តកំពតផងដែរ។

របាយការណ៍សិក្សាវិសាលភាព៖ របាយការណ៍នេះ បានដាក់បញ្ចូល និងវិភាគលទ្ធផលដែលបានរកឃើញតាមរយៈវិធីសាស្ត្រខាងលើ និងជាឯកសារមួយដែលបានរៀបចំព័ត៌មានស្តីពីការគ្រប់គ្រងសំណល់នៅខេត្តកែបទាំងអស់ដែលប្រមូលបាន។ របាយការណ៍នេះ ផ្តល់នូវការវិភាគស្តីពីចំណុចអាទិភាពដែលទាមទារការយកចិត្តទុកដាក់ពីអ្នកធ្វើគោលនយោបាយ ក៏ដូចជាគោលគំនិតបឋមសម្រាប់ធ្វើកំណែទម្រង់គោលនយោបាយដែលត្រូវបានផ្តល់ជាអនុសាសន៍។ សេចក្តីសន្និដ្ឋានរបស់ឯកសារនេះ រំលេចឱ្យឃើញនូវជំហានកំណែទម្រង់គោលនយោបាយដែលចាំបាច់ ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមដែលមាននៅក្នុងប្រព័ន្ធនាពេលបច្ចុប្បន្ន ក៏ដូចជាឱកាសដើម្បីកែសម្រួលកំណែទម្រង់លើវិស័យនេះឱ្យបានកាន់

តែរលុនបន្ថែមទៀត តាមរយៈកំណែទម្រង់ ដែលនឹងត្រូវបានពិនិត្យជាមុន ដោយការអនុវត្តគោលដៅសកម្មភាពសាកល្បងតាក់តែងឡើង ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមផ្នែកការគ្រប់គ្រងសំណល់ជាក់លាក់ ដែលបានរកឃើញនៅក្នុងខេត្តកែប។

សិក្ខាសាលាពិគ្រោះយោបល់៖ សិក្ខាសាលាពិគ្រោះយោបល់មួយ ត្រូវបានរៀបចំឡើងនៅចុងខែឧសភា ឆ្នាំ២០១៩ នៅខេត្តកែប ក្នុងគោលបំណងចែករំលែក និងផ្ទៀងផ្ទាត់លទ្ធផលបឋមចេញពីការសិក្សានេះ ដោយមានការចូលរួមពី ក.ជ.អ.ច. ក្រសួងបរិស្ថាន និង គ.ជ.អ.ប ក្រសួងមហាផ្ទៃ អជ្ញាធរខេត្ត និងស្រុក/ក្រុង មន្ទីរពាក់ព័ន្ធ ប្រតិបត្តិករទេសចរណ៍ក្នុងមូលដ្ឋាន និងសហគមន៍។ នៅពាក់កណ្ដាលខែកញ្ញា កិច្ចប្រជុំពិគ្រោះយោបល់មួយទៀត ត្រូវបានរៀបចំឡើងដោយមានការចូលរួមពីនាយកដ្ឋានពាក់ព័ន្ធនៃ ក្រសួងបរិស្ថាន និង ក.ជ.អ.ច. ដើម្បីសុំមតិយោបល់ចុងក្រោយ និងការគាំទ្រលើរបាយការណ៍សិក្សាវិសាលភាព និងឯកសារគោលនយោបាយសង្ខេប រួមទាំងពង្រាងផែនការសកម្មភាពសាកល្បងមុននឹងទទួលបានការឯកភាពពីក្រសួងបរិស្ថានសម្រាប់ការបោះពុម្ព។

## ២.២ ការសម្របសម្រួលលើការចូលរួម និងធាតុចូលរបស់ស្ថាប័ននានា

ដើម្បីធានាឱ្យមានការចូលរួមប្រកបដោយសមធម៌ និងពេញលេញនៅក្នុងការផ្ដួចផ្ដើមគំនិតនេះ ក្រុមការងារបច្ចេកទេសមួយត្រូវបានបង្កើតឡើងដោយមានការចូលរួមពី ទីប្រឹក្សាយោបល់របស់អង្គការមូលនិធិអាស៊ី និងតំណាង ក.ជ.អ.ច. និងក្រសួងបរិស្ថាន និងតំណាងមកពីលេខាធិការដ្ឋាន គ.ជ.អ.ប។

ការចូលរួមរបស់ ក.ជ.អ.ច. គឺមានមន្ត្រីបច្ចេកទេសមកពីនាយកដ្ឋានសេដ្ឋកិច្ចបៃតង។ ការចូលរួមរបស់ក្រសួងបរិស្ថានមានមន្ត្រីបច្ចេកទេសមកពីនាយកដ្ឋានគ្រប់គ្រងសំណល់រឹង។ ការចូលរួមរបស់ លេខាធិការដ្ឋាន គ.ជ.អ.ប គឺឆ្លើយតបចំពោះសេចក្ដីត្រូវការ ដើម្បីពិនិត្យលើផលប៉ះពាល់នៃវិមជ្ឈការមកលើការគ្រប់គ្រងសំណល់នៅក្នុងតំបន់ទីក្រុង។ ការចូលរួមរបស់ អង្គការមូលនិធិអាស៊ី គឺរួមមានអ្នកតំណាងជាបុគ្គលិកបច្ចេកទេសគ្រប់កម្រិតបន្ថែមទៅលើទីប្រឹក្សាយោបល់ជាតិ និងអន្តរជាតិ។ ការចូលរួមរបស់អ្នកពិគ្រោះយោបល់ពីខាងក្រៅ គឺតំណាងចម្រុះលើជំនាញឯកទេសលើផ្នែកការគ្រប់គ្រងសំណល់ជាសាកល និរន្តរភាព និងអភិបាលកិច្ច។




*រូបភាពទី ២៖ ទិដ្ឋភាពទូទៅនៃការប្រមូលព័ត៌មាន វិភាគព័ត៌មាន និងសកម្មភាព ក្នុងខេត្តកែប*

ក្រុមការងារដែលរួមមានអ្នកតំណាងមកពីស្ថាប័ននានា និងអ្នកឯកទេសលើវិស័យនេះ បានជួបប្រជុំគ្នានៅក្នុងដំណាក់កាលសំខាន់ៗក្នុងពេលប្រមូលព័ត៌មានដែលមានស្រាប់ ការប្រមូលទិន្នន័យបឋមនៅខេត្តកែប និងការវិភាគទិន្នន័យ។ ចាប់ពីពេលចាប់ផ្ដើមកិច្ចពិភាក្សាដំបូង អន្តរទំនាក់ទំនង និងការសម្រេចចិត្តរបស់ក្រុមការងារដែលមានការសម្របសម្រួលបានល្អ ដែលនាំឱ្យក្រុមការងារធ្វើផែនការ និងអនុវត្តសកម្មភាពប្រកបដោយប្រសិទ្ធផល។

## ២.៣ ការប្រមូល និងការរៀបចំទិន្នន័យស្ដីពីសំណល់រឹង

ចាប់ពីពេលចាប់ផ្ដើមការផ្ដួចផ្ដើមគំនិតនេះ កិច្ចខិតខំមួយត្រូវបានធ្វើឡើង ដើម្បីស្វែងរកប្រភពទិន្នន័យគួរជាទីជឿទុកចិត្ត ដើម្បីធានាឱ្យមានការវិភាគឱ្យបានត្រឹមត្រូវ និងការបង្កើតផាតុចេញជាអនុសាសន៍។ ដូចបានកត់សម្គាល់នៅក្នុងផ្នែកដែលពិភាក្សាស្ដីពីការសិក្សាឯកសារពាក់ព័ន្ធខាងលើហើយថា បញ្ហាស្ដីពីទិន្នន័យសំណល់ក្នុងប្រទេសកម្ពុជា ជាបញ្ហាប្រឈមគួរជាទីកត់សម្គាល់ជាពិសេសព័ត៌មានស្ដីពីប្រតិបត្តិការរបស់ប្រព័ន្ធគ្រប់គ្រងសំណល់របស់ក្រុងណាមួយបែបនេះ។ ផ្នែកនេះ ពិពណ៌នាពីកិច្ចខិតខំក្នុងការប្រមូលទិន្នន័យពីប្រភពឯកសារបន្ទាប់បន្សំ និងប្រភពព័ត៌មានចម្បង។ ព្រំដែនរដ្ឋបាលសម្រាប់ការសិក្សានេះ គឺខេត្តកែប ដោយក្នុងនោះ រួមមានទាំងកោះពោធិ៍ និងកោះទន្សាយ ដោយផ្ដោតការយកចិត្តទុកដាក់ជាចម្បងលើក្រុងកែប។

ការប្រមូលទិន្នន័យបន្ទាប់បន្សំ៖ ជំហានដំបូងមួយក្នុងដំណើរការប្រមូលទិន្នន័យ រួមមានការពិនិត្យ ឯកសារពាក់ព័ន្ធធ្វើឡើង

ជាបឋម ដើម្បីចងក្រងនូវរាល់ឯកសារបោះពុម្ពផ្សាយពាក់ព័ន្ធជាមួយការគ្រប់គ្រងសំណល់ក្នុងប្រទេសកម្ពុជា និងជាពិសេស គឺនៅក្នុងខេត្តកែប។ យើងបានប្រមូលទិន្នន័យបន្ទាប់បន្សំមានសារៈប្រយោជន៍ជាច្រើន ដែលទិន្នន័យទាំងនោះទទួលបានពីឯកសារបោះពុម្ពផ្សាយដែលបានរកឃើញក្នុងដំណាក់កាលពិនិត្យឯកសារពាក់ព័ន្ធ។ ព័ត៌មានពាក់ព័ន្ធបំផុតដែលប្រមូលបានក្នុងអំឡុងពេលដំណើរការនេះរួមមានព័ត៌មានស្តីពីលក្ខណៈនៃសំណល់លិខិតបទដ្ឋានគតិយុត្តិ និងប្រតិបត្តិការគ្រប់គ្រងរបស់ក្រុង ដូចជាប្រតិបត្តិការគ្រប់គ្រងទៅលើការចោលសំណល់ជាដើម។ កិច្ចការនេះក៏មានសារៈប្រយោជន៍ផងដែរ ក្នុងការជួយកំណត់រកទិន្នន័យតំណាង ដោយភាគច្រើនរួមមានសមាសធាតុនៃសំណល់ក្នុងក្រុងសក្តាលនុពលរបស់កម្ពុជា ដើម្បីបំពេញបន្ថែមលើការវិភាគពាក់ព័ន្ធជាមួយខេត្តកែបដែលនៅមានកង្វះខាតទិន្នន័យ ហើយពុំអាចរកបាននៅកន្លែងផ្សេងទៀត។

ការប្រមូលទិន្នន័យបឋម៖ ក្នុងអំឡុងពេលចុះសិក្សាផ្ទាល់ទៅកាន់ខេត្តកែប កិច្ចប្រជុំ និងសម្ភាសន៍ត្រូវបានធ្វើឡើង ដើម្បីប្រមូលទិន្នន័យគោលពាក់ព័ន្ធជាមួយការគ្រប់គ្រងសំណល់ក្នុងខេត្តកែប បំពេញបន្ថែមលើទិន្នន័យបន្ទាប់បន្សំដែលប្រមូលបានរួចហើយ។ ការប្រមូលទិន្នន័យសំខាន់ៗទាំងនេះ រួមមាន៖ ទិន្នន័យស្តីពីការប្រមូល និងការបោះចោលសំណល់ ព័ត៌មានប្រជាសាស្ត្រពាក់ព័ន្ធជាមួយប្រជាជន និងទេសចរណ៍ បន្ថែមលើព័ត៌មានស្តីពីការរៀបចំផ្នែកកិច្ចសន្យា និងផ្នែកការគ្រប់គ្រងពាក់ព័ន្ធនឹងសំណល់។ កិច្ចប្រជុំ និងសម្ភាសន៍ គឺជាវិធីដ៏មានប្រសិទ្ធភាពមួយក្នុងការកំណត់រកបញ្ហាប្រឈមជាក់លាក់ ដែលប្រតិបត្តិករគ្រប់គ្រងសំណល់ក្នុងខេត្តកែបជួបប្រទះ។ កិច្ចពិភាក្សាទាំងអស់នេះ ត្រូវបានធ្វើឡើងរយៈពេល ០៣ ថ្ងៃ នៅខែមេសា ឆ្នាំ២០១៩។ ដើម្បីបំពេញបន្ថែមលើកិច្ចពិភាក្សាទាំងអស់នេះ កិច្ចប្រជុំជាច្រើននៅមុនពេលចុះសិក្សាផ្ទាល់ ត្រូវបានធ្វើឡើងនៅក្រុងភ្នំពេញជាមួយអ្នកមានតួនាទីពាក់ព័ន្ធក្នុងវិស័យសំណល់នៅក្នុងប្រទេសកម្ពុជា ដូចជា៖ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ អង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា និងវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល។

ដើម្បីសម្របសម្រួលដល់ការវិភាគ និងការប្រមូលទិន្នន័យ ក្រុមការងារផ្នែកបច្ចេកទេស ក.ជ.អ.ច. និងអង្គការមូលនិធិអាស៊ី បានប្រើប្រាស់ឧបករណ៍ប្រមូលទិន្នន័យបន្ថែមមួយទៀតដែលបានតាក់តែងឡើងជាពិសេស ដើម្បីជាជំនួយដល់រដ្ឋបាលក្រុងក្នុងការរៀបចំរចនាសម្ព័ន្ធ កិច្ចខិតខំប្រឹងប្រែងក្នុងការគ្រប់គ្រងទិន្នន័យដែលមានភាពច្បាស់លាស់ និងមិនស្មុគស្មាញ ផ្អែកលើបទពិសោធន៍របស់ទីក្រុងជាច្រើនដែលចូលរួមនៅក្នុងសកម្មភាពកសាងសមត្ថភាពផ្នែកការគ្រប់គ្រងសំណល់នៅទូទាំងសាកលលោក។ ឧបករណ៍នេះ គឺជាឧបករណ៍វាយតម្លៃទីក្រុងរបស់សម្ព័ន្ធភាពអាកាសធាតុ និងខ្យល់ស្អាត ( CCAC MSW Initiative, 2013 )។[១]

---

[១] ឧបករណ៍វាយតម្លៃទីក្រុង បង្កើតឡើងដោយការផ្តួចផ្តើមគំនិតផ្នែកសំណល់របស់សម្ព័ន្ធភាពអាកាសធាតុ និងខ្យល់ស្អាត។ ឧបករណ៍នេះ អាចរកបានតាមរយៈ https://www.waste.ccacoalition.org/document/city-msw-rapid-assessment-data-collection-tool-english

# ៣. ការសង្កេត និងការវិភាគ

ការគ្រប់គ្រងសំណល់ក្នុងក្រុងកែប គឺស្រដៀងគ្នានឹងប្រតិបត្តិការគ្រប់គ្រងសំណល់ ដែលយើងឃើញមាននៅក្នុងក្រុងដែលមានទំហំប្រហាក់ប្រហែលគ្នាដទៃទៀតក្នុងប្រទេសកម្ពុជាដែរ។ ថ្វីបើខេត្តកែបមានប្រជាជនក្នុងតំបន់ទីក្រុងតិច បើប្រៀបធៀបជាមួយខេត្តដទៃទៀតរបស់កម្ពុជា ពោលគឺមានចំនួនប្រមាណ ៤០.០០០ នាក់ (UNDP, 2019) ប៉ុន្តែ បរិបទការគ្រប់គ្រងសំណល់ក្នុងខេត្តកែបនៅតែមានលក្ខណៈដូចបានឃើញមាននៅក្នុងតំបន់ដទៃទៀត ដោយមន្ត្រីទទួលបន្ទុកការគ្រប់គ្រងសំណល់ ជួបប្រទះបញ្ហាប្រឈម ស្រដៀងគ្នាទាក់ទងជាមួយសមត្ថភាព ធនធាន និងការជំរុញការអនុវត្តលិខិតបទដ្ឋានគតិយុត្តិ (Min, 2016)។

ដូចបានគូសបញ្ជាក់ក្នុងការសិក្សាឯកសារពាក់ព័ន្ធបឋមហើយថា ការទទួលបានទិន្នន័យដែលអាចជឿជាក់បានស្តីពីប្រតិបត្តិការគ្រប់គ្រងសំណល់ គឺនៅតែជាបញ្ហាប្រឈមដ៏គួរកត់សម្គាល់ក្នុងការឆ្លើយតបកំណែទម្រង់គ្រប់គ្រងសំណល់ក្នុងប្រទេសកម្ពុជា។ ក្រុងកែប ក៏ដូចជាក្រុងដទៃទៀតដែរ គឺជួបប្រទះនឹងចន្លោះខ្វះខាតគួរ កត់សម្គាល់ផ្នែកទិន្នន័យ ហើយទិន្នន័យដែលមានបច្ចុប្បន្ន ជាទិន្នន័យប៉ាន់ប្រមាណអាស្រ័យដោយកង្វះការវាស់វែងដោយប្រើប្រាស់ឧបករណ៍ជាក់ស្តែង។ ផ្អែកលើការពិចារណាទាំងអស់នេះ ទិន្នន័យមូលដ្ឋានមួយចំនួនត្រូវបានចងក្រង ដែលនាំឱ្យមានការវិភាគមួយគួរជឿជាក់បានស្តីពីប្រតិបត្តិការដែលមានបច្ចុប្បន្ន។

ទិន្នន័យសំខាន់ៗដែលអាចរកបាន មានដូចជា៖

ការបង្កើតសំណល់៖ ការបង្កើតសំណល់បានកើនឡើងក្នុងអំឡុងពេលប៉ុន្មានឆ្នាំកន្លងមកនេះ ដែលមានបរិមាណក្នុងចន្លោះចាប់ពី ៤៥ ដល់ ៥១ តោនក្នុងមួយថ្ងៃក្នុងឆ្នាំ ២០១៨។[២]

សមាសធាតុរបស់សំណល់៖ ទិន្នន័យស្តីពីសមាសធាតុសំណល់គួរជាទីជឿជាក់ គឺនៅពុំទាន់មាននៅឡើយសម្រាប់ក្រុងកែប ដោយហេតុថា ពុំមានការវិភាគលម្អិតត្រូវបានធ្វើឡើងនាពេលថ្មីៗនេះទេ។ រាជធានីភ្នំពេញ មានទិន្នន័យពេញលេញបំផុតដែលអាចយោងបានពាក់ព័ន្ធនឹងសមាសធាតុសំណល់រឹងទីក្រុងក្នុងប្រទេសកម្ពុជា ដោយក្នុងនោះ សំណល់សរីរាង្គមានប្រហែល ៧០% នៃសំណល់សរុបដែលត្រូវបានបង្កើតឡើង បន្ទាប់មកគឺសំណល់ជាក្រដាស (៥%) ប្លាស្ទិក (៦%) និងលោហៈ (២%)។ យោងតាមការប៉ាន់ប្រមាណបានមកពីក្រុងដទៃទៀតរបស់កម្ពុជា អត្រាសំណល់សរីរាង្គ គឺទាបជាងនេះបន្តិច ក្នុងនោះ ៥៤% ក្នុងក្រុងសៀមរាប និងឡើងខ្ពស់រហូតដល់ ៦០% ក្នុងក្រុងកំពង់ចាម (Sang-Arun et al., 2011)។ ដើម្បីធ្វើផែនការហេដ្ឋារចនាសម្ព័ន្ធ និងសេវាដែលចាំបាច់បន្ថែមលើការយល់ដឹងពីសក្តានុពលសម្រាប់ការកែច្នៃ និងការប្រើប្រាស់ឡើងវិញ យើងខ្ញុំសូមផ្តល់ជាអនុសាសន៍ស្នើធ្វើបច្ចុប្បន្នភាពទិន្នន័យស្តីពីសមាសធាតុរបស់សំណល់។

**តារាងទី ១៖ ទិន្នន័យពីប្រជាសាស្ត្រ ទេសចរណ៍ និងសំណល់រឹងរបស់ខេត្តកែប**

| ទិន្នន័យពីប្រជាសាស្ត្រ និងទេសចរណ៍របស់ខេត្តកែប | |
|---|---|
| ចំនួនឃុំ/សង្កាត់ | ០៥ |
| ចំនួនប្រជាជន | ៤០.៤៧០ (៥.៦៧១ នាក់ក្នុងទីប្រជុំជន) (UNDP, 2019) |
| ចំនួនគ្រួសារក្នុងខេត្ត | ៨.៩១៧ |
| ភោជនីយដ្ឋាន សណ្ឋាគារ និងកន្លែងកម្សាន្តដទៃទៀត | សណ្ឋាគារ ១២ កន្លែង ផ្ទះសំណាក់ ៥៧ កន្លែង ប៊ីងហ្គាឡូ ២២ កន្លែង កន្លែងកម្សាន្តផ្សេងទៀត ៥៩ កន្លែង និងភោជនីយដ្ឋាន ៣០ កន្លែង (PDoT, 2019) |
| ចំនួនភ្ញៀវទេសចរណ៍ | ១.៦៧៦.៥០៩[៣] |
| **ព័ត៌មានសំខាន់ៗពីការគ្រប់គ្រងសំណល់រឹងក្នុងក្រុងកែប** | |
| បរិមាណសំរាមក្នុងមួយថ្ងៃ (ជាមធ្យម) | ៤៥ ទៅ ៥១ តោនត្រូវបានបង្កើត (PDoE, 2018) ក្នុងនោះ៖ ២៥ តោន ត្រូវបានចោលនៅទីលានចាក់សំរាម[៤] |
| បរិមាណសំរាមក្នុងមួយថ្ងៃ (ក្នុងរដូវដែលមានភ្ញៀវទេសចរណ៍ច្រើន) | ៥៥ តោន[៥] |
| អ្នកផ្តល់សេវាប្រមូលសំរាម | ប៉ុង សុឃីម (ចាប់ផ្តើមប្រតិបត្តិការ ឆ្នាំ ២០១៥) |
| ការិយាល័យសាធារណៈការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ | មាន |
| ខ្សែបណ្តោយគណនេយ្យភាពរបស់អ្នកផ្តល់សេវា | ចុះកិច្ចសន្យាជាមួយនឹងអាជ្ញាធរក្រុង<br>ចុះកិច្ចសន្យាជាមួយអាជ្ញាធរខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត |
| បុគ្គលិករបស់អ្នកផ្តល់សេវា | កម្មករ ២៩ នាក់ អ្នកប្រមូលសំរាមចំនួន ២ នាក់ អ្នកចាត់ការទូទៅចំនួន ១ នាក់ |
| អត្រាគ្របដណ្តប់នៃសេវា | ៥០% |
| ការប្រមូលថ្លៃសេវាប្រចាំខែ | ២,៤៥$ (ផ្ទះតូច) - ៣០$ (សណ្ឋាគារធំៗ) |
| ទីលានចាក់សំរាម | ភូមិដំណាក់ចង្អើរ សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប |
| ចម្ងាយទៅទីលានចាក់សំរាម | ១១,៥ គីឡូម៉ែត្រពីទីរួមក្រុង |

២ កិច្ចប្រជុំពិគ្រោះយោបល់នៅខេត្តកែបក្នុងខែឧសភា ឆ្នាំ ២០១៩

៣ កិច្ចប្រជុំជាមួយអាជ្ញាធរខេត្ត ខែមេសា ឆ្នាំ២០១៩

៤ កិច្ចប្រជុំជាមួយក្រុមហ៊ុនប្រមូលសំរាម ខែ មេសា ឆ្នាំ ២០១៩

៥ កិច្ចប្រជុំពិគ្រោះយោបល់នៅខេត្តកែប ខែ ឧសភា ឆ្នាំ ២០១៩

## ៣.១ ប្រព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងសំណល់រឹងដែលមានបច្ចុប្បន្ន

ការពិពណ៌នាលម្អិតស្ដីពីការរកឃើញពាក់ព័ន្ធជាមួយប្រព័ន្ធគ្រប់គ្រងសំណល់បច្ចុប្បន្ន និងហេដ្ឋារចនាសម្ព័ន្ធដែលបានដាក់ឱ្យប្រើប្រាស់នៅក្នុងខេត្តកែប គឺមានដូចខាងក្រោម។ ផ្នែកនេះលើកឡើងពីដំណាក់កាលទាំង ០៤ របស់ការគ្រប់គ្រងសំណល់ ពោលគឺ ការប្រមូល ប្រព្រឹត្តិកម្ម ការដឹកជញ្ជូន និងការបោះចោល។

ការប្រមូលសំណល់៖ ការប្រមូលសំណល់នៅខេត្តកែប គឺប្រមូលផ្ដុំជុំវិញកន្លែងបង្កើតសំណល់ធំៗដូចជា ទីផ្សារ និងកន្លែងទាក់ទាញភ្ញៀវទេសចរសំខាន់ៗ។ ប្រតិបត្តិការភាគច្រើន គឺជាសកម្មភាពផ្នែកពាណិជ្ជកម្មមានធនធាន និងផ្ដោតលើផលប្រយោជន៍អាជីវកម្មជាមូលដ្ឋាន ដែលទាមទារឱ្យមានការទទួលបាននូវសេវាប្រមូលសំរាមប្រកបដោយប្រសិទ្ធផល និងគួរជាទីជឿជាក់។ ដូចគ្នានឹងក្រុង និងរាជធានីដទៃទៀតក្នុងប្រទេសកម្ពុជាដែរ ក្រុងកែបត្រូវពឹងផ្អែកយ៉ាងខ្លាំងលើប្រតិបត្តិករប្រមូលសំណល់ឯកជន ដែលផ្ដោតការយកចិត្តទុកដាក់ជាចម្បងលើការឆ្លើយតបចំពោះសេចក្ដីត្រូវការរបស់អ្នកបង្កើតសំណល់ធំៗ ហើយផ្ដោតការយកចិត្តទុកដាក់ជាបន្ទាប់លើការធានាឱ្យមានការយកសំណល់ ចេញពីទីកន្លែងសាធារណៈមានមនុស្សចេញចូលច្រើន ដូចជាសួនច្បារ និងទីវត្តអារាមជាដើម (Min, 2016)។ ការពិនិត្យលើអ្នកបង្កើតសំណល់ដែលជាពាណិជ្ជករខ្នាតតូច និងលក្ខណៈគ្រួសារ បានបង្ហាញពីនិន្នាការនៃការផ្ដល់សេវា មានលក្ខណៈមិនផ្លូវការ និងការមិនទទួលបានសេវា។ ចំណុចនេះ ត្រូវបានកត់សម្គាល់នៅក្នុងកិច្ចពិភាក្សាជាមួយអាជ្ញាធរស្រុកក្នុងស្រុកដំណាក់ចង្កើរ ក៏ដូចជាក្នុងកិច្ចពិភាក្សាជាមួយអ្នកតំណាងរបស់សហគមន៍មូលដ្ឋាន សណ្ឋាគារតូចៗ និងភោជនីយដ្ឋាន ប្រតិបត្តិការបែបពាណិជ្ជកម្មនៅលើកោះទន្សាយ។[៦] ក្នុងអំឡុងពេលកិច្ចប្រជុំជាមួយអ្នកផ្ដល់សេវាប្រមូលសំណល់ក្នុងខេត្តកែប មានតែគ្រួសារក្នុងចំនួនតិចតួចរស់នៅតាមបណ្ដោយផ្លូវ ដែលទទួលបានសេវាប្រមូលសំណល់ ជាហេតុធ្វើឱ្យគ្រួសារភាគច្រើនគ្រប់គ្រងសំណល់ដោយប្រើប្រាស់វិធីសាស្ត្រតាមបែបប្រពៃណី ដូចជាការដុតសំណល់ចោលជាដើម។[៧]

ប្រព្រឹត្តិកម្មសំណល់៖ ការទាញយកធនធានដែលអាចកែច្នៃជាថ្មីបាន ឬដំណើរការដទៃទៀត ដែលផ្ដោតការយកចិត្តទុកដាក់លើការកាត់បន្ថយបរិមាណសំណល់មុនពេលយកទៅបោះចោល គឺពុំមែនជាផ្នែកផ្លូវការនៃប្រតិបត្តិការគ្រប់គ្រងសំណល់ក្នុងខេត្តកែបទេ ហើយផ្អែកលើកិច្ចពិភាក្សាជាមួយអាជ្ញាធរក្រុងបានឱ្យដឹងថា ពុំមានផែនការនាពេលឆាប់ៗនេះ ដើម្បីដាក់បញ្ចូលផ្នែកនេះទៅក្នុងប្រតិបត្តិការគ្រប់គ្រងសំណល់ផ្លូវការនៅឡើយ។[៨] ទោះយ៉ាងណាក្ដី អវត្តមាននៃប្រព័ន្ធប្រព្រឹត្តិកម្មសំណល់ផ្លូវការ ត្រូវបានដោះស្រាយមួយផ្នែកដោយវិស័យក្រៅប្រព័ន្ធ ដែលបានចូលរួមយ៉ាងសកម្មក្នុងការប្រមូលលោហៈ និងប្លាស្ទិក ហើយធនធានទាំងអស់នេះត្រូវបានយកទៅលក់បន្តឱ្យឈ្មួញកណ្ដាល។ ខណៈពេលដែលសំណល់សរីរាង្គ (សំណល់អាហារ និងស្លឹកឈើ) មានចំនួនលើសពី ៥០% នៃសំណល់សរុបរបស់ក្រុងដែលត្រូវបានបង្កើតឡើង មានការកំណត់សម្គាល់ថា ការផ្ដោតការយកចិត្តទុកដាក់លើប្រព្រឹត្តិកម្មលើសំណល់នេះ ក៏នឹងផ្ដល់លទ្ធផលល្អដែរ ដែលជាជម្រើសជំនួសឱ្យការយកទៅចោលនៅទីលានចាក់សំរាម (Sang-Arun et al., 2011)។ ទោះយ៉ាងណាក្ដី នៅក្នុងកិច្ចពិភាក្សាជាមួយមន្ត្រីអាជ្ញាធរក្រុង ចំណាប់អារម្មណ៍ចំពោះជម្រើសនេះ គឺមានស្ដួចស្ដើងប៉ុណ្ណោះ។

ការចោលសំណល់រឹង៖ សំណល់ដែលត្រូវបានប្រមូលដោយប្រតិបត្តិករឯកជនប្រមូលសំណល់នៅក្នុងក្រុងកែប ត្រូវបានបញ្ជូនទៅទីលានចាក់សំរាមដែលស្ថិតនៅភូមិដំណាក់ចង្កើរ សង្កាត់ព្រៃធំ ក្រុងកែប។ អត្រាការបោះចោលសំណល់ប្រចាំថ្ងៃនៅទីលានចាក់សំរាមនេះ ត្រូវបានប៉ាន់ប្រមាណថា មានបរិមាណ ២៥ តោនក្នុងមួយថ្ងៃ។ ទិដ្ឋភាពទូទៅរបស់ទីលានចាក់សំរាមនេះ ភាគច្រើនជាការយកសំណល់ទៅទុកចោលដោយគ្មានការគ្រប់គ្រងត្រឹមត្រូវ។ ការដុតសំណល់ចោលនៅទីនេះ ជាការអនុវត្តជាប្រក្រតី។ ទីតាំងនេះខ្វះប្រព័ន្ធគ្រប់គ្រងទឹកភ្លៀង (Stormwater) ឬប្រព័ន្ធគ្រប់គ្រងទឹកលេចចេញពីសំរាម (Leachate)។ សំណល់ ត្រូវបានគ្រប់គ្រងនៅក្នុងលក្ខណៈគ្មានរបៀបរៀបរយ ក្នុងនោះមានឧបករណ៍ឈូសឆាយដីត្រូវបានប្រើប្រាស់ ដើម្បីជីករណ្ដៅ ដើម្បីដាក់សំណល់ដែលនឹងយកមកចាក់។ បន្ថែមលើនេះ វត្តមាននៃអ្នករើសអេតចាយដែលរើសសំណល់នៅជុំវិញរថយន្តដែលទើបមកដល់ និងឧបករណ៍ឈូសឆាយដី បង្កហានិភ័យផ្នែកសុខភាព និងសុវត្ថិភាពយ៉ាងជាក់ច្បាស់។ ស្ថានភាពផ្លូវដីរយៈចម្ងាយ ០៣ គីឡូម៉ែត្រ សម្រាប់ចេញចូលទីនោះ បានធ្វើឱ្យលទ្ធភាពចេញចូលទៅកាន់ទីតាំងមានកម្រិតកំណត់ ហើយកាត់បន្ថយប្រសិទ្ធផលតាមរយៈការចំណាយពេលវេលាច្រើនក្នុងការដឹកជញ្ជូនសំណល់ទៅចាក់ចោលនៅទីលាន។ បញ្ហានេះ មិនត្រឹមតែបង្កើនពេលវេលាក្នុងការដឹកជញ្ជូនសំណល់តែប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏បង្កើនការចំណាយលើប្រេងឥន្ធនៈ ពេលវេលារបស់បុគ្គលិកជាអ្នកបើកបរ និងការសឹករេចរឹលកាន់តែច្រើនចំពោះរថយន្ត និងឧបករណ៍ផងដែរ។[៩]

វិធីសាស្ត្របោះចោលសំណល់ស្វ័យជម្រើស៖ ដូចបានពិពណ៌នាខាងលើហើយថា កង្វះការប្រមូលសំណល់ផ្លូវការគួរជាទីជឿជាក់ បាននាំឱ្យអ្នកបង្កើតសំណល់ស្វែងរកជម្រើសផ្សេងទៀតសម្រាប់ការបោះចោលសំណល់ដែលខ្លួនបានបង្កើតឡើង។ ការប៉ាន់ប្រមាណពាក់ព័ន្ធជាមួយវិធីសាស្ត្រផ្សេងទៀតនៃការបោះចោលសំណល់ក្នុងតំបន់ទីប្រជុំជននៅកម្ពុជា បានបង្ហាញថា ការដុត ឬការបោះចោលសំណល់ដោយខុសច្បាប់ មានចំនួនចាប់ពី ២,៥% ដល់ ៥០% នៃសំណល់ទាំងអស់ដែលបានបង្កើតឡើង (Sour,

៦ កិច្ចប្រជុំជាមួយអាជ្ញាធរស្រុកដំណាក់ចង្កើរ ក្នុងខែមេសា ឆ្នាំ ២០១៩

៧ កិច្ចប្រជុំជាមួយអ្នកតំណាងអាជីវកម្មនៅកោះទន្សាយ ក្នុងខែមេសា ឆ្នាំ ២០១៩

៨ កិច្ចប្រជុំជាមួយអាជ្ញាធរក្រុងកែប ក្នុងខែមេសា ឆ្នាំ ២០១៩

៩ ទស្សនកិច្ចបច្ចេកទេស ទៅកាន់ទីលានចាក់សំរាម ក្នុងខែមេសា ឆ្នាំ ២០១៩

2017 )។ ការដុតសំរាមពាសវាលពាសកាល គឺនៅតែជាការអនុវត្តសាមញ្ញនៅទីជនបទ និងទីប្រជុំជនដែលគេជួបញឹកញាប់បំផុតក្នុងតំបន់ដែលមិនមានសេវាប្រមូលសំណល់ល្អ។ ការដុតសំណល់តាមទីវាល ចូលរួមចំណែកគួរកត់សម្គាល់ចំពោះការបំពុលខ្យល់ និងបរិយាកាស។ សារធាតុបំពុលគឺ ខុសៗគ្នាជាខ្លាំងអាស្រ័យទៅតាមសមាសធាតុនៃសំណល់ដែលត្រូវបានដុត។ ពេលមានវត្ថុមានប្លាស្ទិក ការដុតនេះ បណ្តាលឱ្យកើតមានការបំភាយជាតិពុលខ្ពស់ ជាហេតុធ្វើឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរ ជាពិសេស មានការប៉ះពាល់ខ្លាំងចំពោះសុខភាពកុមារ និងមនុស្សចាស់ ( US EPA, 2003 )។ ជាមួយគ្នាដែរ ការបោះចោលសំរាមខុសច្បាប់ ជាទូទៅធ្វើឱ្យមានការថមថយបរិស្ថាន រូបវន្ត និងសោភណ្ឌភាព ( Mazza et al., 2015 )។

**ការវិភាគលំហូរសំណល់៖** ការបង្ហាញពីលំហូរសំណល់ដោយរូបភាព មានសារប្រយោជន៍ ដើម្បីបង្ហាញឱ្យកាន់តែច្បាស់ទៀត ពីរចនាសម្ព័ន្ធបច្ចុប្បន្ននៅក្នុងការគ្រប់គ្រងសំណល់ ( MoE, 2008 as cited in Sour, 2017 )។ រូបភាពខាងក្រោម បង្ហាញពីលំហូរសំណល់ដែលគេឃើញញឹកញាប់បំផុតក្នុងប្រទេសកម្ពុជា ចាប់ពីចំណុចនៃការបង្កើតសំណល់ទៅដល់ចំណុចចុងក្រោយនៃការបោះចោល។

លក្ខណៈពិសេសនៃលំហូរសំណល់រឹងក្នុងក្រុងកែប និងក្រុងដទៃទៀត មានលក្ខណៈប្រែប្រួលទៅតាមមូលដ្ឋានជាក់ស្តែង ឧទាហរណ៍ លំហូរចាប់ពីអ្នកកែច្នៃសំណល់ទៅដល់ទីលានចាក់សំរាម គឺពុំត្រូវបានសង្កេតឃើញមាននៅក្នុងខេត្តកែបទេ។ អ្នកកែច្នៃសំណល់រឹងក្រៅប្រព័ន្ធ (អ្នកទិញអេតចាយ) ក្នុងស្រុកដំណាក់ចង្អើរ បញ្ជាក់អះអាងថា ភាគច្រើននៃសំណល់ដែលនៅសេសសល់ ជាទូទៅគឺជាថង់ប្លាស្ទិក និងត្រូវបានដុតចោល។[១០]

## ៣.២ និរន្តរភាពហិរញ្ញវត្ថុរបស់ប្រតិបត្តិការគ្រប់គ្រងសំណល់រឹង

ផ្អែកលើកិច្ចពិភាក្សាជាមួយមន្ត្រីថ្នាក់ខេត្ត និងមន្ត្រីក្រុងកែប ក៏ដូចជាប្រតិបត្តិករឯកជនដែលគ្រប់គ្រងលើការប្រមូល និងការចោលសំរាមនៅទីលានចាក់សំរាម យើងយល់ឃើញថា ប្រព័ន្ធផ្តល់សេវាបច្ចុប្បន្នដែលផ្អែកលើការបង់ថ្លៃសេវា ពឹងផ្អែកលើសមត្ថភាពរបស់ប្រតិបត្តិករក្នុងការប្រមូលថ្លៃឈ្នួលសេវាពីអ្នកបង្កើតសំណល់។ ផលវិបាកសម្រាប់ការមិនបង់ថ្លៃសេវា គឺមានត្រឹមតែការមិនបន្តសេវាប្រមូលសំណល់តែប៉ុណ្ណោះ។[១១]




*រូបភាពទី ៣៖ លំហូរសំណល់រឹងទីក្រុងក្នុងប្រទេសកម្ពុជា*

[១០] កិច្ចប្រជុំជាមួយអាជ្ញាធរស្រុកដំណាក់ចង្អើរ ក្នុងខែមេសា ឆ្នាំ ២០១៩
[១១] កិច្ចប្រជុំជាមួយប្រតិបត្តិករផ្តល់សេវាប្រមូលសំណល់ ក្នុងខែមេសា ឆ្នាំ ២០១៩

ដោយហេតុថា ព័ត៌មានស្តីពីចំណូលរបស់ប្រតិបត្តិករ គឺពុំអាចបង្ហាញឱ្យដឹងជាសាធារណៈ យើងមិនដឹងច្បាស់ថាតើកម្រិតផលចំណេញនៃប្រព័ន្ធប្រតិបត្តិការបច្ចុប្បន្នមានកម្រិតណានោះឡើយ។ តាមការយល់ឃើញរបស់ក្រុមការងារ ក.ជ.អ.ច. និងអង្គការមូលនិធិអាស៊ី អ្នកផ្តល់សេវាបច្ចុប្បន្ន ផ្តល់សេវាប្រមូលសំណល់ក្នុងក្រុងកែបតាមរយៈកិច្ចសន្យាចំនួនពីរ។ កិច្ចសន្យាប្រចាំឆ្នាំជាមួយសាលាក្រុងកែប គឺមានទឹកប្រាក់ ៥២.០០០ ដុល្លារ ដែលត្រូវបង់ទៅឱ្យអ្នកផ្តល់សេវាឯកជន តាមរយៈការកញ្ចប់ថវិកាបានមកពីក្រសួងបរិស្ថាន។ ប្រភពថវិកាទាំងអស់នេះ គឺបានមកពីកញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ តាមទីប្រជុំជនក្រុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។[១២] កិច្ចសន្យាមួយទៀតសម្រាប់សេវាគ្រប់គ្រងសំណល់ ជាកិច្ចសន្យារវាងប្រតិបត្តិករឯកជនជាមួយអាជ្ញាធរខេត្ត។ កិច្ចព្រមព្រៀងក្រៅផ្លូវការដែលពុំមានកិច្ចសន្យា ផ្តល់សេវាប្រមូលសំណល់សម្រាប់ប្រតិបត្តិករតូបលក់នៅក្នុងផ្សារ ហើយឈរលើការទូទាត់ប្រាក់ដោយផ្ទាល់ទៅឱ្យប្រតិបត្តិករឯកជន។

កិច្ចសន្យានាពេលបច្ចុប្បន្ន ក៏ដូចជាកិច្ចព្រមព្រៀងក្រៅផ្លូវការដើម្បីប្រមូលសំណល់ពីទីផ្សារ ត្រូវបានសង្ខេបដូចខាងក្រោម៖

- កិច្ចសន្យាទី ១៖ ទីភ្នាក់ងារទទួលខុសត្រូវ៖ អាជ្ញាធរខេត្ត - កិច្ចសន្យាសេវាផ្អែកលើការបង់ថ្លៃសេវា រយៈពេល ១៦ ឆ្នាំ[១៣] - ការប្រមូល និងការដឹកជញ្ជូនសំណល់ទៅចោលនៅទីលានចាក់សំរាម និងការថែទាំទីលានចាក់សំរាម ក៏ដូចជាផ្លូវចេញចូលទៅកាន់ទីលានចាក់សំរាម
- កិច្ចសន្យាទី ២៖ ទីភ្នាក់ងារទទួលខុសត្រូវ៖ សាលាក្រុងកែប - កិច្ចសន្យាប្រចាំឆ្នាំ - ការប្រមូលសំណល់ពីតាមផ្លូវ សួនច្បារ សាលារៀន (គ្របដណ្តប់លើសេវាចតយានយន្តផងដែរ)
- ការរៀបចំការប្រមូលសំណល់ក្រៅផ្លូវការ៖ សមភាគី៖ អាជ្ញាធរផ្សារ។ សេវាផ្អែកលើការបង់ថ្លៃសេវា ត្រូវបានផ្តល់ឱ្យតាមរយៈការរៀបចំជាលក្ខណៈក្រៅផ្លូវការ គ្មានកិច្ចសន្យាសម្រាប់ការប្រមូលសំណល់ចេញពីទីផ្សារធំៗ (រួមទាំងផ្សារក្តាម)។[១៤]

ថ្លៃសេវាយកពីអ្នកប្រើប្រាស់សេវាប្រមូលសំណល់ គឺខុសៗគ្នាទៅតាមប្រភេទ ដោយក្នុងនោះភោជនីយដ្ឋាន ត្រូវបង់ ១៥ ដុល្លារ ហើយសណ្ឋាគារត្រូវបង់ ១៧ ដុល្លារ ក្នុងមួយខែ (UNDP, 2019)។ ហាងលក់ទំនិញតូចៗត្រូវបង់ ១០ ដុល្លារក្នុងមួយខែ ផ្សារក្តាមត្រូវបង់ប្រមាណ ៥០០ ដុល្លារក្នុងមួយខែ ចំណែក ប្រជាជនត្រូវបង់ ២,៥ ដុល្លារក្នុងមួយខែ។[១៥]

ទិដ្ឋភាពទូទៅពីកម្មករ និងបុគ្គលិករបស់ប្រតិបត្តិករឯកជនប្រមូលសំណល់ មានដូចខាងក្រោម៖

**តារាងទី ២៖ កម្មករ និងបុគ្គលិកបច្ចុប្បន្នដែលអ្នកផ្តល់សេវាឯកជនជួលឱ្យធ្វើការក្នុងខេត្តកែប**

| កម្មករ និងបុគ្គលិក | ចំនួន | ការសង្កេត |
|---|---|---|
| ការសម្អាតឆ្នេរ | ៩ | កម្មករស្រ្តី |
| ការបោសផ្លូវ | ៩ | កម្មករស្រ្តី |
| អ្នកបើកឡានប្រមូលសំណល់ | ២ | កម្មករប្រុស - រថយន្តទំហំ ៨ តោន |
| កម្មករប្រមូលសំណល់ | ៣ | កម្មករប្រុស - រថយន្តទំហំ ៨ តោន |
| អ្នកបើកឡានប្រមូលសំណល់ | ២ | កម្មករប្រុស - រថយន្តទំហំ ១៣ តោន |
| កម្មករប្រមូលសំណល់ | ៤ | កម្មករប្រុស - រថយន្តទំហំ ១៣ តោន |
| អ្នកប្រមូលថ្លៃសេវា | ២ | |
| អ្នកគ្រប់គ្រងទូទៅ | ១ | |
| កម្មករ/និយោជិតសរុប | ៣២ | |

១២ ផ្អែកលើរបាយការណ៍ស្តីពីការអនុវត្តសេវាអនាម័យបរិស្ថានផ្តល់មូលនិធិដោយសាលាក្រុងកែប (ជាភាសាខ្មែរ)។ ក្នុងឆ្នាំ ២០១៨ សាលាក្រុងកែបបានទទួលទឹកប្រាក់ ២១០ លានរៀល (៥២.៥០០ ដុល្លារ)។

១៣ ផ្អែកលើអនុក្រឹត្យលេខ ១១៣ ការផ្តល់សិទ្ធិធ្វើសេវាសម្អាត សេវាប្រមូល និង/ឬសេវាដឹកជញ្ជូនសំណល់រឹងរបស់ទីប្រជុំ ត្រូវមាន រយៈពេលមិនលើសពី ១០ ឆ្នាំនោះទេ សម្រាប់កិច្ចសន្យានីមួយៗ។ កិច្ចសន្យានេះ គឺមិនមានភាពអនុលោមតាមអនុក្រឹត្យនេះទេ នេះបើតាមការយល់របស់ TAF ទៅលើលិខិតបទដ្ឋានគតិយុត្តិនាពេលបច្ចុប្បន្ន។

១៤ កិច្ចប្រជុំពិគ្រោះយោបល់នៅខេត្តកែប ក្នុងខែឧសភា ឆ្នាំ ២០១៩

១៥ កិច្ចប្រជុំជាមួយប្រតិបត្តិករផ្តល់សេវាគ្រប់គ្រងសំណល់រឹងក្នុងខែមេសា ឆ្នាំ ២០១៩

ទាក់ទងជាមួយការចំណាយប្រតិបត្តិការវិញ ក្នុងនោះ ធាតុចូល រួមមានដូចជាកម្លាំងពលកម្ម ឧបករណ៍ ការថែទាំ សម្ភារៈប្រើប្រាស់ ឥន្ធនៈ និងការវិនិយោគដទៃទៀត ដូចជាការងារផ្លូវថ្នល់ និងការកែលំអទីលានចាក់សំរាមជាដើម។ ថ្វីបើក្រុមការងារ ពុំបានមានលទ្ធភាពទទួលបានព័ត៌មានស្តីពីការចំណាយសព្វគ្រប់ជ្រុងជ្រោយពាក់ព័ន្ធជាមួយប្រតិបត្តិការគ្រប់គ្រងសំណល់ក្នុងខេត្តកែបក្តី ប៉ុន្តែគំរូ ត្រូវបានបង្កើតឡើងដោយ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ដើម្បីជួយសម្រួលដល់ក្រុងនានារបស់កម្ពុជា ក្នុងការប៉ាន់ប្រមាណថ្លៃចំណាយប្រតិបត្តិការ និងថ្លៃចំណាយលើឧបករណ៍ផ្អែកលើកម្រិតសេវាសម្មតិកម្មចំនួន ០៣ គឺ អាចទទួលយកបាន ប្រសើរ និងល្អឥតខ្ចោះ។ ដោយប្រើប្រាស់ទិន្នន័យពាក់ព័ន្ធជាមួយសំណល់សម្រាប់ក្រុងមួយ ការប៉ាន់ប្រមាណថ្លៃចំណាយ អាចត្រូវបានគណនាដោយប្រើប្រាស់គំរូនេះ ហើយផ្អែកលើតម្លៃស្វ័យជ្រើសរើសដែលកំណត់ឡើងដោយថ្លៃចំណាយរបស់ធាតុចូលបានមកពីប្រតិបត្តិករគ្រប់គ្រងសំណល់វិស័យឯកជន។ តម្លៃទាំងអស់នេះ ជួយកំណត់ពីតម្រូវការផ្នែកបុគ្គលិក និងការចំណាយពាក់ព័ន្ធតម្រូវការផ្នែកឧបករណ៍ ក៏ដូចជាការដឹកជញ្ជូន និងការចំណាយលើប្រេងឥន្ធនៈ។ ថ្លៃដើមទុនសម្រាប់រថយន្តដឹកសំរាម ផ្អែកលើការសន្មតស្តីពីយានយន្តប្រើប្រាស់មួយទឹកមានគុណភាពល្អ។ ធាតុចូលផ្សេងទៀត រួមមាន ចំនួនប្រជាជន ចំនួនគ្រួសារ ចំនួនគ្រឹះស្ថានពាណិជ្ជកម្ម ជាអ្នកបង្កើតសំណល់ តម្រូវការក្នុងការបោសសម្អាតថ្នល់ ទីធ្លាបៃតង និងរយៈចម្ងាយទៅកាន់ទីលានចាក់សំរាម។

ផ្អែកលើធាតុចូលស្វ័យជ្រើសរើសទាំងអស់នេះ ព្រមទាំងធាតុចូលជាទិន្នន័យពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់នៅក្រុងកែប និងការជ្រើសរើសកម្រិតសេវាមូលដ្ឋាន (កម្រិតអាចទទួលយកបាន) ការប៉ាន់ប្រមាណមួយលើថ្លៃចំណាយ និងតម្រូវការផ្នែកបុគ្គលិក ត្រូវបានបង្កើតឡើងដូចឃើញក្នុងប្រអប់ទី១។ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ បានកត់សម្គាល់ដោយយកចិត្តទុកដាក់ថា ធាតុចេញរបស់គម្រោងនេះ គឺជាថ្លៃចំណាយប៉ាន់ប្រមាណផ្អែកលើធាតុចូល ហើយពុំមានការធានាថា ព័ត៌មាននេះមានភាពសុក្រឹតទេ (UNDP, 2018)។

**កម្មករ/បុគ្គលិក**

| | |
|---|---|
| កម្មករប្រមូលសំណល់/ដឹកជញ្ជូន/សម្អាត៖ | **៧៣** នាក់ |
| បុគ្គលិករដ្ឋបាល៖ | **៦** នាក់ |

**ការគណនាថ្លៃចំណាយ**

| | |
|---|---|
| ថ្លៃចំណាយប្រតិបត្តិការសុរប៖ | **១៦.០៣៧** ដុល្លារ ក្នុងមួយខែ ដោយក្នុងនោះ |
| ថ្លៃចំណាយប្រតិបត្តិការ និងការថែទាំ៖ | **១.៩៨៧** ដុល្លារ |
| ថ្លៃចំណាយលើបុគ្គលិក៖ | **១៣.២០០** ដុល្លារ |
| ថ្លៃចំណាយផ្នែករដ្ឋបាល៖ | **៨៥០** ដុល្លារ |
| ថ្លៃចំណាយដើមទុនសម្រាប់យានយន្ត៖ | **២៤៥.000** ដុល្លារ (ការវិនិយោគតែមួយដង) |

*ប្រអប់ទី ១៖ ការចំណាយដែលត្រូវបានប៉ាន់ប្រមាណសម្រាប់សេវាក្នុងកម្រិត "អាចទទួលយកបាន" ផ្អែកលើ កម្មវិធីគណនាថ្លៃចំណាយសម្រាប់ការគ្រប់គ្រងសំណល់ទីក្រុង របស់កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ*

## ៣.៣ តួនាទីរបស់ស្ត្រីក្នុងការគ្រប់គ្រងសំណល់រឹង

ដូចបានកត់សម្គាល់ក្នុងការពិពណ៌នាលម្អិតខាងលើ ស្តីពីតម្រូវការផ្នែកបុគ្គលិកសម្រាប់សេវាគ្រប់គ្រងសំណល់ក្នុងក្រុងកែប ហើយថា ស្ត្រីមានចំនួនជាងពាក់កណ្តាលនៃបុគ្គលិកសរុប ដែលត្រូវបានជួលឱ្យធ្វើការក្នុងការគ្រប់គ្រងសំណល់ក្នុងក្រុងកែប។ ខណៈដែលបុរស មានចំនួនច្រើនក្នុងប្រតិបត្តិការឧបករណ៍ធុនធ្ងន់ ក៏ដូចជាក្នុងការប្រមូល និងបោះចោលសំណល់នៅទីលានចាក់សំរាម ស្ត្រីមានវត្តមានទាំងស្រុងនៅក្នុងប្រតិបត្តិការសម្អាត និងបោសថ្នល់ ដោយក្នុងនោះ កម្មករជាស្ត្រីចំនួន ១៨នាក់ ដែលត្រូវបានជួលឱ្យធ្វើការក្នុងវិស័យប្រតិបត្តិការនេះ។ តាមរយៈកិច្ចពិភាក្សាក្រៅផ្លូវការ និងការសង្កេតក្នុងពេលចុះទៅមូលដ្ឋានផ្ទាល់ យើង បានឃើញយ៉ាងច្បាស់ថា ស្ត្រីក៏ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការប្រមូល និងកែច្នៃសំណល់ផងដែរ។ ការជជែកជាមួយស្ត្រីដែលពិពណ៌នាខ្លួនឯងថា ជាចុងភៅពេញម៉ោង បានឱ្យដឹងថា គាត់រកចំណូលបន្ថែមតាមរយៈការប្រមូលដបប្លាស្ទិកនៅតាមមាត់សមុទ្រដែលផ្តល់ជាប្រភពចំណូលបន្ថែមដើម្បីជួយបង្កើនចំណូលសរុបប្រចាំខែរបស់គ្រួសារគាត់។[១៦] ការស្វែងយល់បន្ថែមទៀតលើការចូលរួមនៃទីផ្សារប្រមូលអេតចាយក្រៅផ្លូវការ អាចជាឱកាសសន្សំថ្លៃចំណាយចំពោះសេវារដ្ឋាភិបាលនៅក្នុងរយៈពេលវែង និងសម្រាប់ការរកចំណូលសម្រាប់អ្នករើស និងអ្នកប្រមូលសំរាម។

---

[១៦] ការសង្កេត និងសកម្មភាពអន្តរទំនាក់ទំនងរបស់ក្រុមសិក្សាស្រាវជ្រាវនៅតាមឆ្នេរកែប ក្នុងខែមេសា ឆ្នាំ ២០១៩



*រូបភាពទី ៤៖ ការកែច្នៃសំណល់ឱ្យក្លាយទៅជាផលិតផលផ្សេងៗ នៅក្នុងសមាគមស្ត្រីអន្តរជាតិកែប*

ទិដ្ឋភាពបន្ថែមទៀតនៃការចូលរួមរបស់ស្ត្រីក្នុងការគ្រប់គ្រងសំណល់ក្នុងខេត្តកែប គឺយើងបានជួបក្នុងពេលទស្សនកិច្ចផ្ទាល់ទៅកាន់សមាគមស្ត្រីអន្តរជាតិកែប ដែលជាក្រុមផ្តោតការយកចិត្តទុកដាក់លើការប្រមូល និងកែច្នៃថង់ប្លាស្ទិក និងសំបកវេចខ្ចប់ដទៃទៀត។ វត្ថុធាតុដើមទាំងអស់នេះ ត្រូវបានយកទៅសម្អាត កែច្នៃ និងក្រោយមកប្រែក្លាយទៅជាទំនិញផលិតផលសម្រេច ដូចជា កាបូបយួរដៃ កូនកាបូបដាក់លុយ សម្លៀត និងស្បោងដាក់អីវ៉ាន់។ ថ្វីបើប្រតិបត្តិការមានទំហំតូចក៏ពិតមែន ប៉ុន្តែស្ត្រីចំនួន ០៤ នាក់ដែលចូលរួមធ្វើការងារនេះ បានទទួលការបណ្តុះបណ្តាល ដើម្បីប្រែក្លាយវត្ថុធាតុដើម ឱ្យទៅជាផលិតផលសម្រាប់អ្នកប្រើប្រាស់មានតម្លៃបន្ថែម ដែលត្រូវបានយកទៅលក់នៅក្នុងខេត្តកែប កំពត និងរាជធានីភ្នំពេញ និងនាំចេញមួយចំនួនទៅលក់នៅប្រទេសស្វីសផងដែរ។ ប្រតិបត្តិការនេះ មានទំហំតូចក្តី ប៉ុន្តែការផ្តោតចម្បងលើការបណ្តុះបណ្តាលបុគ្គលិក ដើម្បីកែច្នៃសំរាមឱ្យទៅជាផលិតផលមានតម្លៃបន្ថែម គឺជាគោលការណ៍ដ៏មានឥទ្ធិពល។[១៧]

## ៣.៤ វិមជ្ឈការការគ្រប់គ្រងសំណល់រឹង

ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅកម្ពុជា រួមមានសមាសភាពរដ្ឋបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ រដ្ឋបាលទាំង ០៣ ថ្នាក់នៅថ្នាក់ក្រោមជាតិ រួមមាន៖ (i) ថ្នាក់រាជធានី និងខេត្ត (ii) ថ្នាក់ស្រុក/ក្រុង ពាក្យ ខណ្ឌត្រូវបានប្រើប្រាស់តែសម្រាប់រាជធានីភ្នំពេញប៉ុណ្ណោះ និង (iii) ថ្នាក់ឃុំ និងសង្កាត់។ រដ្ឋាភិបាលចាប់ផ្តើមដំណើរការកំណែទម្រង់វិមជ្ឈការជាផ្លូវការក្នុងឆ្នាំ២០០២ ដោយបានចាប់ផ្តើមព្រមជាមួយការបោះឆ្នោតថ្នាក់ឃុំ/សង្កាត់។ ក្នុងឆ្នាំ២០០៨ រដ្ឋាភិបាល បានចាប់ផ្តើមការយកចិត្តទុកដាក់លើវិមជ្ឈការនៅថ្នាក់ស្រុក និងក្រុង ដោយមានការរំពឹងថា រដ្ឋាភិបាលនៅថ្នាក់ស្រុក និងក្រុងនេះ នឹងទទួលខុសត្រូវលើការផ្តល់សេវាសាធារណៈ និងសេវាបន្ថែមដទៃទៀត។

រូបភាពទី ៥ បង្ហាញឱ្យឃើញពីទំនាក់ទំនងការមើលខុសត្រូវដែលត្រូវបានរំពឹងទុករវាងអង្គភាពរដ្ឋាភិបាល (NCDD, 2017)។




*រូបភាពទី ៥៖ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅកម្ពុជា និងតួនាទី*

[១៧] កិច្ចប្រជុំរបស់ក្រុមសិក្សាស្រាវជ្រាវជាមួយសមាគមស្ត្រីអន្តរជាតិ ក្នុងខែមេសា ឆ្នាំ ២០១៩

ការគ្រប់គ្រងសំណល់រឹងទីក្រុង គឺជាមុខងារចម្បងមួយដែលត្រូវបានរំពឹងថានឹងត្រូវបានផ្ទេរ ដែលជាផ្នែកមួយនៃដំណើរការវិមជ្ឈការនេះ។ ផ្នែកខាងក្រោម ពិភាក្សាពីបរិបទកំណែទម្រង់ផ្នែកច្បាប់សំខាន់ៗ ដែលនៅពីក្រោយវិមជ្ឈការការគ្រប់គ្រងសំណល់ក្នុងប្រទេសកម្ពុជា រួមជាមួយការពិភាក្សាលើដំណើរការការងារនេះក្នុងខេត្តកែប។

## ៣.៤.១ សាវតារផ្នែកលិខិតបទដ្ឋានគតិយុត្តិ

**អនុក្រឹត្យលេខ ១១៣ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងលិខិតបទដ្ឋានគតិយុត្តិដែលចេញជាបន្តបន្ទាប់**

មូលដ្ឋានគ្រឹះផ្នែកច្បាប់ចម្បងនាពេលបច្ចុប្បន្ន សម្រាប់ការគ្រប់គ្រងសំណល់បែបវិមជ្ឈការក្នុងប្រទេសកម្ពុជា គឺអនុក្រឹត្យលេខ ១១៣ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន (ខែសីហា ឆ្នាំ ២០១៥) (RGC, 2015)។ មុនពេលប្រកាសឱ្យប្រើប្រាស់អនុក្រឹត្យលេខ ១១៣ ការទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ គឺត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់រាជធានី/ខេត្ត តាមរយៈអនុក្រឹត្យលេខ ៣៦ ស្តីពីការគ្រប់គ្រងសំណល់រឹង។ នៅពេលអនុក្រឹត្យលេខ ១១៣ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ចូលជាធរមាន សមត្ថកិច្ចទាំងអស់ក្នុងការគ្រប់គ្រងសំណល់ ត្រូវធ្លាក់ទៅថ្នាក់រដ្ឋបាលក្រុង/ស្រុក។ លិខិតបទដ្ឋានគតិយុត្តិគាំទ្រជាច្រើន បានចេញជាបន្តបន្ទាប់ចាប់ពីឆ្នាំ២០១៥មក ដើម្បីគាំទ្រដល់ការជំរុញការអនុវត្តអនុក្រឹត្យលេខ ១១៣ ឱ្យបានរឹងមាំ ដូចមានពិពណ៌នាក្នុងប្រអប់ទី ២។

អនុលោមតាមអនុក្រឹត្យខាងលើ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធ តួនាទី និងការទទួលខុសត្រូវខាងក្រោមត្រូវបានចែងសម្រាប់រដ្ឋាភិបាលកម្រិតនីមួយៗ៖

- ថ្នាក់ជាតិ រួមមាន ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលទទួលខុសត្រូវរួមគ្នាក្នុងការបង្កើតគោលនយោបាយ ផ្តល់ការគាំទ្រដល់រដ្ឋាភិបាលថ្នាក់ក្រុង និងស្រុកបន្ថែមលើ ការពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តគោលនយោបាយទាំងនេះ។
- ថ្នាក់ខេត្ត ត្រូវបានរំពឹងថា ដើរតួនាទីច្រើនក្នុងការគាំទ្រដល់ថ្នាក់ ក្រុង និងស្រុកក្នុងការអនុវត្តមុខងារដែលបានផ្ទេរឱ្យ។
- ថ្នាក់ ក្រុង/ស្រុក គឺជាអ្នកទទួលខុសត្រូវចម្បងលើការគ្រប់គ្រង និងការអនុវត្តការគ្រប់គ្រងសំណល់នៅក្នុងទីតាំងរបស់ខ្លួនរៀងៗខ្លួន។

តួនាទីរបស់រដ្ឋាភិបាលថ្នាក់ក្រុង/ស្រុក ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន គ្របដណ្តប់លើសកម្មភាពជាច្រើន រួមមានដូចជា៖

- ធ្វើផែនការគ្រប់គ្រង ផែនការសកម្មភាព ផែនការថវិកា និងចុះកិច្ចសន្យាជាមួយក្រុមហ៊ុនប្រមូលសំរាម សម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងអាចធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំណល់មួយផ្នែកទៅឱ្យថ្នាក់ឃុំ សង្កាត់ ឬសហគមន៍។
- អនុម័តឱ្យមានលិខិតបទដ្ឋាន និងវិធានការដើម្បីធានាប្រសិទ្ធភាពនៃការប្រមូលសំណល់។
- កំណត់រក និងបង្កើតទីតាំងរក្សាទុកសំរាម សំណល់រឹងបណ្តោះអាសន្ន និងទីលានចាក់សំរាម។
- កំណត់ថ្លៃសេវាប្រមូលសំណល់ (ផ្អែកលើប្រកាសរបស់អន្តរក្រសួង និងដោយមានការអនុម័តពី ក្រុមប្រឹក្សាពាក់ព័ន្ធ)។
- ប្រមូល និងគ្រប់គ្រងថ្លៃសេវាដែលប្រមូលបាន (ជាប្រភពចំណូលចម្បង)។
- លើកកម្ពស់ការយល់ដឹងពីសំណល់ និងការគ្រប់គ្រងសំណល់។
- ដាក់ឱ្យមានវិធានការផាកពិន័យ និងដាក់ទណ្ឌកម្មបណ្តោះអាសន្ន។

បន្ទាប់ពីការអនុម័តលើអនុក្រឹត្យលេខ ១១៣ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ក្រុមការងារអន្តរក្រសួងមួយ ត្រូវបានបង្កើតឡើងដោយមានអ្នកតំណាងមកពី ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង គ.ជ.អ.ប។ គោលបំណងរបស់ក្រុមការងារនេះ គឺដើម្បីគាំទ្រដល់ការអនុវត្តអនុក្រឹត្យនេះ។ ជាលទ្ធផលនៃកិច្ចខិតខំរបស់ក្រុមការងារអន្តរក្រសួង លិខិតបទដ្ឋានគតិយុត្តិសំខាន់ៗជាច្រើន ត្រូវបានចេញឱ្យប្រើប្រាស់ រួមមានដូចជា៖

- សារាចរលេខ ១០៧០ (ខែវិច្ឆិកា ឆ្នាំ២០១៥) របស់ក្រសួងបរិស្ថាន និងក្រសួងមហាផ្ទៃគ្របដណ្តប់លើការអនុវត្តអនុក្រឹត្យលេខ ១១៣ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ប្រកាសអន្តរក្រសួងលេខ ១៤១១ (ខែធ្នូ ឆ្នាំ២០១៦) ទាក់ទងជាមួយការអនុវត្តសកម្មភាពទាក់ទងជាមួយសំណល់រឹង
- សិក្ខាសាលាដើម្បីផ្សព្វផ្សាយបទប្បញ្ញត្តិសំខាន់ៗរបស់អនុក្រឹត្យលេខ ១១៣ និងលិខិតបទដ្ឋានគតិយុត្តិដែលបានចេញជាបន្តបន្ទាប់
- ប្រកាសអន្តរក្រសួងលេខ ១៩៥ (ខែមិថុនា ឆ្នាំ២០១៨) គូសបញ្ជាក់ពីការកំណត់តម្រែអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន (MoI, 2019)។
- អនុក្រឹត្យលេខ ១៨២ (ខែធ្នូ ឆ្នាំ២០១៩) ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- អនុក្រឹត្យលេខ ១៨៣ (ខែធ្នូ ឆ្នាំ២០១៩) ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ
- អនុក្រឹត្យលេខ ១៨៤ (ខែធ្នូ ឆ្នាំ២០១៩) ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក

ឯកសារលិខិតបទដ្ឋានគតិយុត្តិដែលពិពណ៌នាពីនីតិវិធីពាក់ព័ន្ធជាមួយការគ្រប់គ្រង និងការប្រើប្រាស់ចំណូលបានមកពីការផាកពិន័យ ដូចមានចែងក្នុងអនុក្រឹត្យលេខ ១១៣ កំពុងត្រូវបានសរសេរព្រាង និងបង្ហើយឱ្យចប់ជាស្ថាពរដោយក្រុមការងារអន្តរក្រសួង។ គិតត្រឹមខែឧសភា ឆ្នាំ២០១៩ ក្រសួងមហាផ្ទៃកំពុងបន្តការងារ ប្រមូលព័ត៌មានបន្ថែមស្តីពីកិច្ចសន្យាដែលមានជាធរមានទាំងអស់ ពាក់ព័ន្ធជាមួយការគ្រប់គ្រងសំណល់រឹងថ្នាក់ខេត្ត និងថ្នាក់ក្រុង/ស្រុកនៅទូទាំងប្រទេស ដើម្បីផ្តល់ជាមូលដ្ឋានព័ត៌មានសម្រាប់ភារកិច្ចរបស់ក្រុមការងារ និងការសម្របសម្រួលជាបន្តបន្ទាប់របស់ក្រុមការងារដែលគាំទ្រដល់ការកែសម្រួលចាំបាច់នានា

នៅក្នុងការរៀបចំកិច្ចសន្យាក្នុងលក្ខណៈស៊ីសង្វាក់ជាមួយអនុក្រឹត្យលេខ ១១៣។

កិច្ចខិតខំជាបន្តបន្ទាប់ទាំងអស់នេះ មានសក្តានុពល ដើម្បីបកស្រាយបញ្ជាក់លើបញ្ហាអភិបាលកិច្ចនាពេលបច្ចុប្បន្នពាក់ព័ន្ធជាមួយការគ្រប់គ្រងសំណល់ កាត់បន្ថយការបកស្រាយបញ្ច្រាសគ្នាពីបទប្បញ្ញត្តិទាំងអស់នោះ និងសំខាន់ជាងនេះទៀត គឺដាក់សម្ពាធលើអ្នកដើរតួនាទីសំខាន់ៗឱ្យអនុវត្តតាមស្មារតីរបស់អនុក្រឹត្យលេខ ១១៣។

***ប្រអប់ទី ២៖ លិខិតបទដ្ឋានគតិយុត្តិសំខាន់ៗ និងវឌ្ឍនភាពនាពេលថ្មីៗនេះពាក់ព័ន្ធជាមួយការគ្រប់គ្រងសំណល់រឹងបែបវិមជ្ឈការក្នុងប្រទេសកម្ពុជា***

**ប្រកាសអន្តរក្រសួងលេខ ០៧៣ ស្តីពីការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថានសម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ តាមទីប្រជុំជនក្រុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ថ្វីបើប្រកាសនេះ ត្រូវបានអនុម័តមុនការប្រកាសឱ្យប្រើប្រាស់អនុក្រឹត្យលេខ ១១៣ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ក្តី ប្រកាសអន្តរក្រសួងលេខ ០៧៣ ស្តីពីការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថានសម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ តាមទីប្រជុំជនក្រុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ផ្តោតការយកចិត្តទុកដាក់លើការគ្រប់គ្រងសំណល់ ជាពិសេសនៅថ្នាក់ក្រុង/ស្រុក (ខែកុម្ភៈ ឆ្នាំ២០១៥)។ ប្រកាសនេះ គឺដាច់ដោយឡែកពីអនុក្រឹត្យ ១១៣ និងព្យាយាមផ្ទេរផ្នែកខ្លះនៃថវិកាជាតិទៅឱ្យរដ្ឋបាលក្រុង ពោលគឺ ក្រុងចំនួន ២៦ ក្នុងខេត្តចំនួន ២៤ ដោយក្នុងនោះ រួមមានការតម្រូវឱ្យមាន ការពិនិត្យតាមដាន និងវាយតម្លៃ អមជាមួយការបែងចែកកញ្ចប់ថវិកានេះផងដែរ។ មូលនិធិនេះ ត្រូវបានបែងចែកដោយប្រើប្រាស់រូបមន្ត ដែលអនុញ្ញាតឱ្យផ្តោតគោលដៅលើរដ្ឋបាលក្រុងនៅក្នុងឆ្នាំថវិកានីមួយៗ។

យោងតាមមាត្រា ៩ របស់ប្រកាសនេះ រដ្ឋបាលក្រុង/ស្រុកនីមួយៗ ចាំបាច់ត្រូវ៖

- រៀបចំផែនការគ្រប់គ្រង និងសកម្មភាព ប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។
- ស្នើផែនការចំណូល និងចំណាយផ្អែកលើកញ្ចប់ថវិកាពីថ្នាក់ជាតិ ដើម្បីអនុវត្តការគ្រប់គ្រងសំណល់។
- គ្រប់គ្រងលើការផ្តល់សេវាសំណល់។
- ជ្រើសរើសដៃគូសម្រាប់ការផ្តល់សេវាសំណល់អនុលោមតាមស្រុក/ក្រុងដែលពាក់ព័ន្ធ និងនីតិវិធីគ្រប់គ្រង និងលទ្ធកម្មហិរញ្ញវត្ថុស្រុក/ក្រុង។
- រៀបចំរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំស្តីពីការចំណាយ និងលទ្ធផលសម្រេចបានពាក់ព័ន្ធជាមួយសេវាសំណល់។

ក្រសួងបរិស្ថាន ត្រូវបានរំពឹងថា នឹងដើរតួនាទីក្នុងការពិនិត្យតាមដានលើការអនុវត្ត និងការចំណាយថវិកាដែលបានផ្ទេរឱ្យ ក៏ដូចជាផ្តល់ដំបូន្មានផ្នែកបច្ចេកទេសជូនដល់រដ្ឋបាលក្រុងដែលកំពុងទទួលមូលនិធិ។ ក្រសួងបរិស្ថាន ក៏បានទទួលសមត្ថកិច្ចក្នុងការស្នើឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បង្កកកញ្ចប់ថវិកាសម្រាប់រដ្ឋបាលក្រុងទាំងឡាយណា ដែលការអនុវត្តជាក់ស្តែងហាក់មិនមានភាពអនុលោមតាមប្រកាសនេះ។

**អនុក្រឹត្យលេខ ១៦៨ ស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក និងក្រុមការងារទទួលបន្ទុកការគ្រប់គ្រងសំណល់ប្លាស្ទិក**

អនុក្រឹត្យដ៏សំខាន់មួយទៀត គឺអនុក្រឹត្យលេខ ១៦៨ ស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក (ខែតុលា ឆ្នាំ ២០១៧) ដែលលើការនាំចេញ ការផលិត ការចែកចាយ និងការប្រើប្រាស់ថង់ប្លាស្ទិក។ ក្រសួង និងទីភ្នាក់ងារដូចខាងក្រោមត្រូវបានបញ្ជាក់ថា ជាអ្នកដើរតួនាទីសំខាន់ទាក់ទងជាមួយការគ្រប់គ្រងថង់ប្លាស្ទិក ក្នុងនោះរួមមាន ក្រសួងបរិស្ថាន ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដើម្បីធានាឱ្យមានការសម្របសម្រួល និងការអនុវត្តសកម្មភាពដូចមានចែងក្នុងអនុក្រឹត្យនេះ ឱ្យបានប្រកបដោយប្រសិទ្ធភាព ក្រុមការងារទទួលបន្ទុកការគ្រប់គ្រងសំណល់ប្លាស្ទិក ត្រូវបានបង្កើតឡើងក្នុងខែមេសា ឆ្នាំ២០១៩ នៅក្រោម ក.ជ.អ.ច.។ ក្រុមការងារដែលរួមមានសមាសភាពសមាជិកមកពីនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងបរិស្ថាន ត្រូវបានរំពឹងថានឹងរាយការណ៍ជូនដល់ប្រធាន ក.ជ.អ.ច. ពោលគឺឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន។ ក្រុមការងារនេះ រៀបចំកិច្ចប្រជុំលើកទីមួយរបស់ខ្លួននៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៩ ហើយមានការចូលរួមពីអ្នកតំណាងរបស់ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកលនិងសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ដើម្បីពិភាក្សាលើផែនការការងារអនុវត្តសាកល្បងរបស់ខ្លួន (ដែលគ្របដណ្តប់រយៈពេល ០៦ ខែ)។ កិច្ចពិភាក្សា រួមមានផែនការសម្រាប់ការកៀរគរធនធាន និងការបកស្រាយបញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវរបស់អ្នកដើរតួនាទីសំខាន់ៗ។ លទ្ធផលកិច្ចប្រជុំ រួមមានសេចក្តីសម្រេចក្នុងការពិចារណាកែសម្រួលឡើងវិញលើអនុក្រឹត្យលេខ ១១៣ ពាក់ព័ន្ធជាមួយការពិនិត្យតាមដាន និងការវាយតម្លៃលើតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងការគ្រប់គ្រងសំណល់រឹង និងកិច្ចហការឱ្យបានកាន់តែប្រសើរជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិលើការគ្រប់គ្រងសំណល់ប្លាស្ទិក (NCSD, 2019)។

## ៣.៤.២ ការអនុវត្ត និងបញ្ហាប្រឈម

ការចុះសិក្សាផ្ទាល់ទៅកាន់ខេត្តកែប បានផ្តោតការយកចិត្តទុកដាក់ទាំងទៅលើការអនុវត្តអនុក្រឹត្យលេខ ១១៣ និងប្រកាសអន្តរក្រសួងលេខ ០៧៣។ ផ្អែកលើការសិក្សាដែលមាន (Min, 2016) និងចំណេះដឹងកន្លងមករបស់ក្រុមការងារផ្នែកបច្ចេកទេសសម្រាប់អនុក្រឹត្យ និងប្រកាសខាងលើនេះ បញ្ហាប្រឈមដែលបានជួបប្រទះក្នុងខេត្តកែប ត្រូវបានរកឃើញស្រដៀងគ្នានឹងបញ្ហាប្រឈមដែលបានជួបនៅក្នុងកន្លែងដទៃទៀតទេ។ ការសង្កេតនេះ បានស្នើឱ្យឃើញថា បញ្ហាប្រឈមចំពោះការគ្រប់គ្រងសំណល់បែបវិមជ្ឈការក្នុងប្រទេសកម្ពុជា គឺផ្សារភ្ជាប់ជាមួយការអនុវត្តការ

ងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជារបៀបដែលថ្នាក់ជាតិបាន គាំទ្រលើការមើលខុសត្រូវចំពោះការអនុវត្តមុខងារនៅថ្នាក់ក្រោមជាតិ។

ផ្នែកខាងក្រោមនេះ គឺការបង្ហាញពីបញ្ហាប្រឈមជាក់លាក់ និងកិច្ចពិភាក្សាថាតើគួរធ្វើយ៉ាងណាដើម្បីឆ្លើយតបលើបញ្ហាទាំងអស់នេះ មានក្នុងផ្នែកបន្តបន្ទាប់។

## ថ្នាក់ក្រោមជាតិ

### *បញ្ហាប្រឈមទី ១៖ ទាំងអាជ្ញាធរខេត្ត និងអាជ្ញាធរក្រុង/ស្រុក ចុះកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន*

ឫសគល់ចម្បងដែលនាំឱ្យមានបញ្ហាប្រឈមនេះ រួមមាន៖

- ទំនាក់ទំនងជាលក្ខណៈឋានានុក្រមដ៏យូរលង់មកហើយរវាងអាជ្ញាធរខេត្ត និងអាជ្ញាធរក្រុង/ស្រុក ទាក់ទងនឹងការទទួលខុសត្រូវចម្បងលើការងារគ្រប់គ្រងសំណល់រឹង។ ថ្វីបើអនុក្រឹត្យចែងថា អាជ្ញាធរក្រុង/ស្រុក ជាអ្នកមានការទទួលខុសត្រូវលើផ្នែកនេះក្តី ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែងក្នុងករណីមួយចំនួន អាជ្ញាធរខេត្តនៅតែមើលឃើញតួនាទីរបស់ខ្លួនថា ខ្ពស់ជាងតួនាទីរបស់អាជ្ញាធរក្រុង/ស្រុក។
- ថ្វីបើអាជ្ញាធរក្រុង/ស្រុក មានតួនាទីជាន់គ្នាមួយចំនួនជាមួយអាជ្ញាធរខេត្តក្តី ប៉ុន្តែ ពួកគេ មិនបានលើកឡើងចំណុចនេះ ថាជាបញ្ហានៅឡើយ។
- ការលើកឡើង (មួយចំនួនមានមូលដ្ឋានគាំទ្រត្រឹមត្រូវ មួយចំនួនទៀតមិនសូវមានមូលដ្ឋានគាំទ្រ) ពីសមត្ថភាពទាបនៅកម្រិតស្រុក/ក្រុង ត្រូវបានប្រើប្រាស់ជាហេតុផលដើម្បីគាំទ្រឱ្យអាជ្ញាធរខេត្ត នៅតែតោងយកសមត្ថកិច្ចនេះ ហើយអាជ្ញាធរនៅកម្រិតស្រុក/ក្រុង ត្រូវលះបង់សមត្ថកិច្ចរបស់ខ្លួន។ អំណះអំណាងស្តីពីសមត្ថភាពទាបនេះ ច្រើនតែត្រូវបានយកមកប្រើប្រាស់ដោយមិនបញ្ជាក់ថាតើគេកំពុងសំដៅលើសមត្ថភាពអ្វីនោះឡើយ។
- កង្វះការយល់ដឹង និងការយល់មិនស្របគ្នា រវាងមន្ត្រីសំខាន់ៗ (និងអ្នកឯកទេសមួយចំនួន) ស្តីពីការអនុវត្តអនុក្រឹត្យលេខ ១១៣ ក្នុងចំណោមអាជ្ញាធរខេត្ត ស្រុក/ក្រុង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត និង មន្ទីរបរិស្ថានខេត្ត ។
- មានការយល់ឃើញថា មិនមានក្របខ័ណ្ឌច្បាប់ ឬគោលការណ៍ណែនាំច្បាស់លាស់ក្នុងការអនុវត្តការគ្រប់គ្រងសំណល់រឹងទីក្រុង។

### *បញ្ហាប្រឈមទី ២៖ ការប្រើប្រាស់ថវិការបស់អាជ្ញាធរខេត្ត និងស្រុក/ក្រុង មិនអនុលោម តាមប្រកាសលេខ ០៧៣ ពាក់ព័ន្ធនឹងការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថានសម្រាប់ការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅថ្នាក់ក្រោមជាតិ*

ឫសគល់ចម្បងដែលនាំឱ្យមានបញ្ហាប្រឈមនេះ រួមមាន៖

- ការយល់ឃើញពី និងទិដ្ឋភាពជាក់ស្តែងនៃភាពពិបាកបត់បែនក្នុងការប្រើប្រាស់ថវិកាសេវាអនាម័យ បរិស្ថានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជំរុញឱ្យស្រុក/ក្រុងខ្លះ ត្រូវចំណាយក្នុងលក្ខណៈរហ័សដែលមិនសូវមានលក្ខណៈស្មុគស្មាញ ហើយឆ្លើយតបបានប្រសើរជាមួយសេចក្តីត្រូវការមូលដ្ឋាន។ ឧទាហរណ៍ មានការយល់ឃើញថា ដើម្បីចំណាយធនធានថវិកា ចាំបាច់ត្រូវមានដំណើរការ និងនីតិវិធីវែងអន្លាយ ចំណែកដំណើរការក្នុងការចុះកិច្ចសន្យាលើសេវាប្រមូលសំរាមជាមួយក្រុមហ៊ុនឯកជន ត្រូវបានមើលឃើញថា មិនសូវមានភាពស្មុគស្មាញ និងងាយស្រួល។
- កង្វះការយល់ដឹង ឬមានទស្សនៈផ្ទុយគ្នាក្នុងចំណោមអាជ្ញាធរខេត្ត និងស្រុក/ក្រុងស្តីពីរបៀបយកថវិកាអនាម័យរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមកអនុវត្ត។ ឧទាហរណ៍ មនុស្សមួយចំនួនបដិសេធថា ថវិកានេះ មិនអាចឱ្យស្រុក/ក្រុងយកទៅប្រើប្រាស់ ដើម្បីចុះកិច្ចសន្យាសេវាជួលក្រុមហ៊ុនឯកជនឱ្យផ្តល់សេវានេះទេ ថ្វីបើប្រកាសបានចែងយ៉ាងច្បាស់ថា ការលើកឡើងនេះពុំមែនជាការពិតក្តី។

### *បញ្ហាប្រឈមទី ៣៖ ការជំរុញការអនុវត្តច្បាប់ និងការពិនិត្យតាមដាន និងវាយតម្លៃ នៅមានកម្រិតនៅឡើយពីសំណាក់អាជ្ញាធរខេត្ត និង/ឬស្រុក/ក្រុងលើការអនុវត្តកិច្ចសន្យា*

ឫសគល់ចម្បងដែលនាំឱ្យមានបញ្ហាប្រឈមនេះ រួមមាន៖

- ការផ្តោតការយកចិត្តទុកដាក់នៅមានកម្រិតនៅឡើយ ហើយក្នុងករណីមួយចំនួនគឺកង្វះសមត្ថភាពលើការងារ ការពិនិត្យតាមដាន និងវាយតម្លៃ នៅក្នុងកម្រិតអាជ្ញាធរខេត្ត និងស្រុក/ក្រុងក្នុងការជំរុញការអនុវត្ត និងពិនិត្យតាមដានលើការអនុវត្តកិច្ចសន្យារបស់ប្រតិបត្តិករប្រមូលសំណល់។
- ភាពមិនមានតម្លាភាពនៃកិច្ចព្រមព្រៀងរវាងអាជ្ញាធរខេត្ត/ស្រុក/ក្រុង និងប្រតិបត្តិករប្រមូលសំណល់។

### ការកំណត់និយមន័យ ការពិនិត្យតាមដាន និងវាយតម្លៃ

ការផ្តោតការយកចិត្តទុកដាក់លើ ការពិនិត្យតាមដាន និងវាយតម្លៃ និងប្រព័ន្ធគាំទ្ររបស់ ការពិនិត្យតាមដាន និងវាយតម្លៃ ពិនិត្យលើទិដ្ឋភាពផ្សេងៗនៃការគ្រប់គ្រងសំណល់រឹងនៅថ្នាក់ក្រោមជាតិ រួមមានការរៀបចំការចុះកិច្ចសន្យា ការគ្រប់គ្រងថវិកាពាក់ព័ន្ធ សកម្មភាពសំខាន់ៗ និងបញ្ហាប្រឈមសំខាន់ៗក្នុងការអនុវត្ត។ ការពិនិត្យតាមដាន និងវាយតម្លៃ លើការអនុវត្តការងារបច្ចេកទេស អាចត្រូវបានចាត់ទុកថា ជាជំហានបន្ទាប់ បើយោងទៅលើភាពស្មុគស្មាញនៃបញ្ហា និងតម្រូវការជាបន្ទាន់ ដើម្បីដាក់បញ្ហានេះឱ្យមានប្រតិបត្តិការបានល្អ។ អាចពិចារណាឱ្យមានការកែសម្រួលបន្ថែមទៀតក្នុងពេលអនាគតតាមរយៈការប្រើប្រាស់គោលវិធី "រៀនសូត្របណ្តើរ ធ្វើបណ្តើរ"។ ការអភិវឌ្ឍកម្រងទិន្នន័យជាបន្តបន្ទាប់នឹងជួយផ្តល់មូលដ្ឋានព័ត៌មានសម្រាប់ដំណើរការនេះ និងជាជម្រើសមួយសម្រាប់ក្រុមការងារបច្ចេកទេស (Technical Working Group) ដើម្បីពិចារណា។

*ប្រអប់ទី ៣៖ និយមន័យរបស់ការពិនិត្យតាមដាន និងវាយតម្លៃ*

## ថ្នាក់ជាតិ

### *បញ្ហាប្រឈមទី ១៖ មិនមានទិន្នន័យដែលជឿជាក់ស្តីពីស្ថានភាពបច្ចុប្បន្ននៃការរៀបចំផ្នែកកិច្ចសន្យាក្នុងការគ្រប់គ្រងសំណល់នៅថ្នាក់អាជ្ញាធរខេត្ត និងស្រុក/ក្រុង*

ឫសគល់ចម្បងដែលនាំឱ្យមានបញ្ហាប្រឈមនេះ រួមមាន៖

- កង្វះការប្រមូលព័ត៌មានពីកិច្ចសន្យានានា ដែលត្រូវបានចុះ និងអនុវត្តនៅថ្នាក់ខេត្ត និងស្រុក/ក្រុង ជាពិសេសបន្ទាប់ពីការចេញអនុក្រឹត្យលេខ ១១៣។

### *បញ្ហាប្រឈមទី ២៖ ការពិនិត្យតាមដាន និងវាយតម្លៃ នៅមានកម្រិត និងមិនមានការសម្របសម្រួលគ្នាបានល្អ ពីថ្នាក់ជាតិលើការគ្រប់គ្រងសំណល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ*

ឫសគល់ចម្បងដែលនាំឱ្យមានបញ្ហាប្រឈមនេះ រួមមាន៖

- កង្វះប្រព័ន្ធ និងផែនការការងារច្បាស់លាស់ស្តីពី ការពិនិត្យតាមដាន និងវាយតម្លៃ ជាពិសេស ប្រព័ន្ធ និងផែនការ រួមគ្នា ក្រោម ក្រុមការងារបច្ចេកទេស ទទួលបន្ទុកការគ្រប់គ្រងសំណល់នៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ការពិនិត្យតាមដាន និងវាយតម្លៃ ដែលធ្លាប់បានធ្វើកន្លងមក មានភាពមិនទៀងទាត់ ហើយមិនមានការសម្របសម្រួលគ្នារវាង ក្រសួងមហាផ្ទៃ ជាមួយ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ការចូលរួមរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនសូវច្បាស់លាស់/សកម្ម។

### *បញ្ហាប្រឈមទី ៣៖ ការគ្របដណ្តប់មានកម្រិតកំណត់របស់អនុក្រឹត្យលេខ ១១៣ និងប្រកាសលេខ ០៧៣ ទៅលើការគ្រប់គ្រងសំណល់នៅតាមទីផ្សារ*

ឫសគល់ចម្បងដែលនាំឱ្យមានបញ្ហាប្រឈមនេះ រួមមាន៖

- បច្ចុប្បន្ន សំណល់តាមទីផ្សារ នៅតែស្ថិតក្រោមការគ្រប់គ្រងរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទោះយ៉ាងណាក្តី នៅពេលមានបញ្ហាកើតឡើង មន្ទីរបរិស្ថានខេត្ត និងស្រុក/ក្រុងតែងតែជាអ្នករងការស្តីបន្ទោស។

# ៤. កំណែទម្រង់សាកល្បង - សកម្មភាពអនុវត្តសាកល្បង និង អនុសាសន៍ដែលស្នើឡើង

បន្ថែមលើការយល់ដឹងដ៏រឹងមាំពីប្រព័ន្ធការគ្រប់គ្រងសំណល់ក្នុងខេត្តកែបនាពេលបច្ចុប្បន្ន យើងអាចរៀបចំផែនការ ដើម្បីផ្តោតគោលដៅចំពោះវិស័យដែលត្រូវការកំណែទម្រង់ និងការវិនិយោគ។ ផែនការឆ្លើយតបចំពោះវិស័យ ជាសេចក្តីត្រូវការ ក្នុងលក្ខណៈទូលំទូលាយ រួមមានផ្នែកជាច្រើន ដែលផ្តោតការយកចិត្តទុកដាក់លើអភិបាលកិច្ច បច្ចេកវិទ្យា និងប្រព័ន្ធ ការចូលរួមរបស់ដៃគូ និងធនធាន។

## ៤.១ អភិបាលកិច្ចលើប្រព័ន្ធគ្រប់គ្រងសំណល់រឹង

យើងអាចចាត់ទុកថា អភិបាលកិច្ច ជាបញ្ហាប្រឈមធំជាងគេចំពោះខេត្តកែប នៅពេលដែលខេត្តនេះព្យាយាមបង្កើតឱ្យមានប្រព័ន្ធគ្រប់គ្រងសំណល់មានលក្ខណៈកាន់តែឆ្លើយតប និងមានប្រសិទ្ធផលថែមទៀត។ ជារឿយៗ គេតែងយល់ឃើញថា អភិបាលកិច្ច គឺជាការពិពណ៌នាពីក្របខ័ណ្ឌការងារអន្តរទំនាក់ទំនង និងទំនាក់ទំនងដែលមានរវាងអាជ្ញាធររដ្ឋាភិបាល ជាអ្នកចូលរួមក្នុងប្រតិបត្តិការគ្រប់គ្រងសំណល់ ប៉ុន្តែក្នុងករណីនេះ អភិបាលកិច្ចក៏សំដៅទៅលើទំនាក់ទំនងរវាងរដ្ឋាភិបាលជាមួយប្រតិបត្តិករក្នុងវិស័យឯកជនផងដែរ បើយោងទៅលើតួនាទីដែលត្រូវបានដាក់ឱ្យភាគីខាងក្រៅជាវិស័យឯកជន ត្រូវបំពេញក្នុងប្រព័ន្ធនេះ។ ផ្នែកខាងក្រោម បង្ហាញពីការពិចារណាលើទិដ្ឋភាពផ្សេងៗនៃទំនាក់ទំនងដែលមានភាពផ្សារភ្ជាប់គ្នាដ៏ចាំបាច់ទាំងអស់ ព្រមទាំងតុល្យភាពដ៏មានសារៈសំខាន់ដែលត្រូវមាន ដើម្បីសម្រេចបានលទ្ធផលប្រកបដោយជោគជ័យ។

ចំណុចសំខាន់ៗដែលគួរពិចារណាដើម្បីទទួលបានអភិបាលកិច្ចល្អក្នុងការគ្រប់គ្រងសំណល់ រួមមាន៖

ការធ្វើផែនការគ្រប់គ្រងសំណល់៖ ការសម្រេចចិត្តទាក់ទងនឹងការគ្រប់គ្រងសំណល់ អាចមានភាពស្មុគស្មាញ។ ការធ្វើផែនការផ្អែកលើការគ្រប់គ្រងបរិស្ថាន និងវិធីប្រតិបត្តិការដ៏ត្រឹមត្រូវរួមជាមួយធាតុចូលទិន្នន័យដ៏ល្អ និងប្រើប្រាស់ឧបករណ៍ដ៏សមស្រប ដែលជាទស្សនទានស្តីពីឋានានុក្រមការគ្រប់គ្រងសំណល់ជាទូទៅតែងនាំឆ្ពោះទៅរកលទ្ធផលល្អ។ ទស្សនទានដែលបានទទួលស្គាល់ជាសាកលនេះ គឺលើកទឹកចិត្តឱ្យមានការប្រើប្រាស់ឡើងវិញ ការកែច្នៃឡើងវិញ និងការកាត់បន្ថយការប្រើប្រាស់ ជាជម្រើសដែលត្រូវបានជ្រើសរើស (សូមមើលរូបភាពទី ៦) (Hansen, Christopher, & Verbuecheln, 2002)។ ជម្រើសទាំង ០៣ នេះ ត្រូវបានស្គាល់ថាជាគោលការណ៍នៃសេដ្ឋកិច្ចចក្រា (Kyriakopoulos, et. al, 2019) ដែលប្រទេសកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅរក។




*រូបភាពទី ៦៖ ក្របខ័ណ្ឌក្នុងការសម្រេចចិត្តពីឋានានុក្រមសំណល់*

ជាមួយនឹងការពិចារណាយ៉ាងហ្មត់ចត់ពី ទស្សនទានស្តីពីឋានានុក្រមការគ្រប់គ្រងសំណល់ វាជាការសំខាន់ណាស់ ដែលត្រូវវាយតម្លៃលើតម្រូវការការកែលំអដែលចាំបាច់នៅក្នុងប្រតិបត្តិការប្រព័ន្ធបច្ចុប្បន្ន ហើយត្រូវពិចារណាពីផលប៉ះពាល់នៃទិន្នាការប្រជាសាស្ត្រផងដែរ ដើម្បីព្យាករសេចក្តីត្រូវការនាពេលអនាគត។ តាមរយៈរូបភាពច្បាស់លាស់ពីចន្លោះខ្វះខាតនាពេលបច្ចុប្បន្ន ក៏ដូចជាសេចក្តីត្រូវការនាពេលអនាគត (ដូចជាព្យាករណ៍ពីបរិមាណសំណល់ និងសមាសធាតុរបស់សំណល់ផ្អែកលើចំនួនប្រជាជន និងចំនួនភ្ញៀវទេសចរ) ដំណើរការធ្វើផែនការ អាចចាប់ផ្តើមឆ្លើយតបយ៉ាងណា ដើម្បីបំពេញចន្លោះខ្វះខាតនាពេលបច្ចុប្បន្ន ក៏ដូចជាត្រៀមខ្លួនសម្រាប់តម្រូវការនាពេលអនាគត។

និន្នាការប្រជាសាស្ត្រដែលប៉ះពាល់ដល់ការគ្រប់គ្រងសំណល់៖

- កំណើនប្រជាជន
- កំណើនប្រាក់ចំណូល
- ទិន្នាការពង្រីកទីក្រុង
- ប្រវត្តិនៃការចោលកាកសំណល់កន្លងមក

***ប្រអប់ទី ៤៖ និន្នាការផ្នែកប្រជាសាស្ត្រដែលប៉ះពាល់ដល់ការគ្រប់គ្រងសំណល់***

តាមរយៈព្យាករណ៍ស្តីពីការបង្កើតសំណល់ដែលដាក់បញ្ចូលទាំងប្រតិបត្តិការនាពេលបច្ចុប្បន្ន និងសេណារីយ៉ូសម្រាប់ពេលអនាគត អ្នកធ្វើការសម្រេចចិត្ត អាចវិភាគថាតើធ្វើយ៉ាងណា ដើម្បីបំពេញភាពខ្វះខាតនាពេលបច្ចុប្បន្ន ព្រមទាំងវិភាគលើការចំណាយ និងធាតុចូលដែលចាំបាច់។ ភាពខ្វះខាត អាចមានទម្រង់ជាឧបករណ៍ (រថយន្ត ធុងសំរាម ការកែលំអផ្លូវ ការកែច្នៃ និងឧបករណ៍សម្រាប់ការបោះចោលសំណល់) ប្រព័ន្ធ (កែលំអប្រសិទ្ធផលនៃផ្លូវសម្រាប់ការប្រមូលសំណល់ កែលំអប្រតិបត្តិការទីលានចាក់សំរាម តម្រូវការឱ្យមានទីតាំងសម្រាប់ការផ្ទេរសំណល់)

ឬធាតុចូលជាធនធានមនុស្ស (ប្រតិបត្តិករទីតាំងចោលសំណល់ដែលមានជំនាញ បុគ្គលិកថែទាំឧបករណ៍ អ្នកគ្រប់គ្រងទីតាំងប្រព្រឹត្តិកម្មសំណល់ បុគ្គលិកគ្រប់គ្រងហិរញ្ញវត្ថុ។ល។)។ នៅពេលរូបភាពពេញលេញរបស់ធាតុចូលដែលចាំបាច់ ដើម្បីបំពេញភាពខ្វះខាតនាពេលបច្ចុប្បន្ននេះ ត្រូវបានកំណត់រួចហើយ ការចំណាយពាក់ព័ន្ធជាមួយធាតុចូលនីមួយៗ អាចត្រូវបានប៉ាន់ប្រមាណ និងដាក់ឱ្យអនុវត្តនៅក្នុងផែនការវិនិយោគរយៈពេលច្រើនឆ្នាំ ដែលត្រូវបានតាក់តែងឡើង ដើម្បីឆ្លើយតបចំពោះសេចក្តីត្រូវការផ្នែកវិនិយោគសម្រាប់រយៈពេល ០៥ ទៅ ១០ ឆ្នាំខាងមុខ ( ETAGIW Consortium, 2012 )។

ការដាក់ដេញថ្លៃ ការគ្រប់គ្រងកិច្ចសន្យា និង ការពិនិត្យតាមដាន និងវាយតម្លៃ៖ នៅពេលធ្វើលទ្ធកម្មសេវា ដើម្បីគាំទ្រដល់សកម្មភាពគ្រប់គ្រងសំណល់ គឺជាការងារសំខាន់ណាស់ដែលក្រុងត្រូវមានការយល់ដឹងច្បាស់ពីសេចក្តីត្រូវការរបស់ខ្លួនជាមុនសិន។ តាមរយៈការប្រើប្រាស់ធាតុចូលដែលបានកំណត់ក្នុងដំណើរការធ្វើផែនការដូចបានពិពណ៌នាខាងដើម ការវិនិយោគដែលចាំបាច់នៅក្នុងការប្រមូលសំណល់ ការបោះចោល ការដឹកជញ្ជូន និងរាល់ការវិនិយោគបន្ថែមដទៃទៀត និងការកែលំអ អាចត្រូវបានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រលទ្ធកម្មរយៈពេលមធ្យម និងរយៈពេលវែង ដែលផ្អែកតាមសេចក្តីត្រូវការដែលបានកំណត់ឃើញ។

នៅពេលចុះកិច្ចសន្យាជួលឱ្យអ្នកខាងក្រៅក្នុងការផ្តល់សេវាផ្នែកសំណល់ ការទទួលខុសត្រូវចម្បងរបស់រដ្ឋាភិបាល គឺការមើលខុសត្រូវលើការងាររបស់អ្នកផ្តល់សេវា ដោយធានាថា ការងារត្រូវបានអនុវត្តតាមកិច្ចព្រមព្រៀង ហើយគុណភាព និងកម្រិតនៃសេវា ត្រូវឆ្លើយតបតាមលក្ខខណ្ឌការងារដូចបានកំណត់ក្នុងកិច្ចសន្យា។ ការជ្រើសរើសអ្នកផ្តល់សេវា គួរផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យបច្ចេកទេសប្រកបដោយតម្លាភាព និងបានកំណត់ទុកជាមុន ព្រមទាំងសមត្ថភាពជាក់ស្តែងរបស់អ្នកផ្តល់សេវាក្នុងការឆ្លើយតបតាមលក្ខខណ្ឌវិនិច្ឆ័យនេះ។ បន្ទាប់ពីការជ្រើសរើសអ្នកផ្តល់សេវា ការអនុវត្តការងាររបស់អ្នកផ្តល់សេវាទាំងនោះ នឹងត្រូវបានវាយតម្លៃផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យដូចបានកំណត់រួចហើយ។ នៅពេលសេវាមិនឆ្លើយតបលក្ខខណ្ឌវិនិច្ឆ័យដែលបានកំណត់ ការដាក់ទណ្ឌកម្មក្នុងទម្រង់មួយចំនួន អាចនឹងត្រូវបានយកមកអនុវត្ត ( Olukanni et al., 2019 )។

ការដាក់ទណ្ឌកម្មនេះ អាចជាការផាកពិន័យ ឬការមិនទូទាត់ប្រាក់ឱ្យ។ យន្តការដើម្បីលើកទឹកចិត្តឱ្យមានការអនុវត្តការងារប្រសើរបំផុត ក៏អាចត្រូវបានដាក់បញ្ចូល ហើយអាចមានទម្រង់ជាការបន្តកិច្ចសន្យា ឬការទូទាត់ប្រាក់រង្វាន់ ដែលបានកំណត់ជាមុន។ ឱកាសសម្រាប់ប្រសិទ្ធផលនៅក្នុងលទ្ធកម្ម ក៏គួរត្រូវបានពិនិត្យស្វែងយល់ផងដែរ។ ក្នុងសេណារីយ៉ូប្រសើរបំផុត ទីភ្នាក់ងារឬអង្គភាពរដ្ឋាភិបាលណាមួយ គួរមើលខុសត្រូវលើគ្រប់សេវាប្រមូលសំណល់ទាំងអស់នៅក្នុងព្រំដែនភូមិសាស្ត្រជាក់លាក់។ ទីភ្នាក់ងារមានសមត្ថកិច្ចជាន់គ្នាដែលគ្រប់គ្រងលើកិច្ចសន្យាផ្តល់សេវាសម្រាប់អ្នកបង្កើតសំណល់នៅក្នុងដែនយុត្តាធិការតែមួយ អាចបង្កការលំបាកក្នុងការពិនិត្យតាមដានលើប្រសិទ្ធភាពនៃសេវារបស់អ្នកផ្តល់សេវា។ ការមានអង្គភាពតែមួយ ដើម្បីគ្រប់គ្រងលើសេវាទាំងអស់សម្រាប់តំបន់ជាក់លាក់ អាចជួយសម្រួលដល់កិច្ចសម្របសម្រួល និងការវិភាគព័ត៌មានពាក់ព័ន្ធជាមួយលទ្ធផលការអនុវត្តការងារ និងសេវា ( NZ MfE, 2007 )។

ជាចុងក្រោយ ការបង្កើតឱ្យមានព័ត៌មានមូលដ្ឋានច្បាស់លាស់ស្តីពីប្រតិបត្តិការ និងហេដ្ឋារចនាសម្ព័ន្ធ ដើរតួនាទីយ៉ាងសំខាន់សម្រាប់ការវាស់វែងនូវសកម្មភាពនាពេលអនាគតទាំងអស់។ នៅពេលមានការយល់ដឹងទាំងអស់នេះ រួមជាមួយការរំពឹងទុកថា នឹងមានការប្រមូលទិន្នន័យ និងការរាយការណ៍ដ៏រឹងមាំ ត្រូវបានដាក់បញ្ចូលជាធាតុផ្សំនៃកាតព្វកិច្ចក្នុងកិច្ចសន្យានោះ អាជ្ញាធរនឹងស្ថិតក្នុងគោលជំហរដ៏ប្រសើរ ដើម្បីផ្តោតការយកចិត្តទុកដាក់លើការងារទទួលខុសត្រូវរបស់ខ្លួន ក្នុងការពិនិត្យតាមដាន និងមើលខុសត្រូវលើលទ្ធផលការអនុវត្តការងាររបស់អ្នកផ្តល់សេវា ដូចមានចែងក្នុងកិច្ចសន្យាដែលបានព្រមព្រៀងគ្នា។

ការមើលខុសត្រូវផ្នែកហិរញ្ញវត្ថុ និងការគ្រប់គ្រងធនធាន៖ ការធានាឱ្យមានការគ្រប់គ្រងហិរញ្ញវត្ថុល្អនៅក្នុងប្រតិបត្តិការគ្រប់គ្រងសំណល់ ជួយគាំទ្រដល់ប្រតិបត្តិការប្រកបដោយស្ថិរភាព និងមានភាពស៊ីសង្វាក់សម្រាប់ប្រជាជន។ ប្រភពចំណូល នឹងខុសគ្នាពីក្រុងមួយទៅក្រុងមួយ និងពីប្រព័ន្ធមួយទៅប្រព័ន្ធមួយ។ ក្នុងករណីរបស់ខេត្តកែប ចំណូលមកពីប្រភពចម្បងពីរ គឺថ្លៃសេវាប្រមូលពីអ្នកបង្កើតសំណល់ ក្នុងនោះរួមមាន អាជីវកម្ម និងប្រជាជន និងចំណូលបានមកពីការទូទាត់ដោយផ្ទាល់ពីរដ្ឋាភិបាល ដែលផ្សារភ្ជាប់ជាមួយកាតព្វកិច្ចផ្នែកកិច្ចសន្យា។[១៨] នៅពេលគោលបំណងផ្នែកប្រតិបត្តិការ មានការលូតលាស់ និងផ្លាស់ប្តូរជាកិច្ចឆ្លើយតបចំពោះតម្រូវការក្នុងមូលដ្ឋាន តម្រូវការឱ្យមានធនធានហិរញ្ញវត្ថុបន្ថែម ក៏នឹងត្រូវមានផងដែរ។

ធនធានបន្ថែមទាំងអស់នេះ អាចបានមកពីប្រភពផ្សេងៗជាច្រើន៖

- ពន្ធដែលក្រុងកៀរគរបានមកដោយផ្ទាល់
- ការផាកពិន័យចំពោះភាពមិនអនុលោមតាមច្បាប់ស្តីពីសំណល់
- ការផាកពិន័យសម្រាប់ការចោលសំរាមពាសវាលពាសកាលក្រោមការជំរុញការអនុវត្តច្បាប់ពី អាជ្ញាធរមូលដ្ឋាន
- កម្រៃសេវាទីលានចាក់សំរាម
- ការលក់សម្ភារអេតចាយដែលអាចកែច្នៃជាថ្មី/ជីកំប៉ុស្ត
- ពន្ធអេកូទេសចរណ៍/ពន្ធសម្រាប់ការអភិវឌ្ឍបៃតង/ពន្ធការស្នាក់នៅពីអ្នកទេសចរ
- កម្ចី ឬហិរញ្ញប្បទាន ពីស្ថាប័នហិរញ្ញវត្ថុជាតិ ឬអន្តរជាតិ ( Lohri et al., 2014 )។

ម្យ៉ាងទៀត ការកំណត់ឱ្យមានយន្តការគ្រប់គ្រង ដើម្បីគាំទ្រដល់ស្ថិរភាពផ្នែកហិរញ្ញវត្ថុ និងនិរន្តរភាពរបស់ប្រតិបត្តិការគ្រប់គ្រងសំណល់ ក៏ជាការសំខាន់ផងដែរ។ យន្តការទាំងនោះ គួរសម្រួល

[១៨] កិច្ចប្រជុំជាមួយអាជ្ញាធរខេត្តកែប និងក្រុងកែប ក្នុងខែមេសា ឆ្នាំ ២០១៩

លទ្ធភាពទទួលបានដើមទុន តាមរយៈរចនាសម្ព័ន្ធផ្សេងៗ ដូចជាមូលនិធិវិនិយោគភូមិកំណើត (Hometown Investment Trust) ដែលអនុញ្ញាតឱ្យមាន ការវិនិយោគចាំបាច់នានានៅក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធ។ យន្តការទាំងនោះ គួរតែជាវិធានការទាំងឡាយណាដែលជួយធានាឱ្យបានថា ការសម្រេចចិត្តត្រូវបានធ្វើឡើងក្នុងបំណងដើម្បីបង្កើនប្រសិទ្ធភាពសេវាឱ្យបានប្រសើរបំផុត ហើយស្របពេលជាមួយគ្នានោះ ក៏ជួយកាត់បន្ថយការចំណាយ (Yoshino et al., 2018)។

**ការគ្រប់គ្រងផ្នែកបរិស្ថាន និងភាពអនុលោមតាមច្បាប់៖** ថ្វីបើការគ្រប់គ្រងសំណល់ ជាទិដ្ឋភាពដ៏មានសារៈសំខាន់ សម្រាប់ការគ្រប់គ្រងបរិស្ថានតំបន់ទីប្រជុំជនក្តី ប្រតិបត្តិការប្រព័ន្ធគ្រប់គ្រងសំណល់ ពេលខ្លះក៏មានផលវិបាកអវិជ្ជមានផ្នែកបរិស្ថានផងដែរ ដែលអាចប៉ះពាល់ដល់ធនធានបរិស្ថានដទៃទៀត ដូចជាខ្យល់ ដី ឬទឹកជាដើម។ ប្រតិបត្តិការគ្រប់គ្រងសំណល់ក្នុងតំបន់ទីប្រជុំជន ឬរាជធានី អាចមានទម្រង់ផ្សេងៗជាច្រើន ដូចជាប្រតិបត្តិការស្ថិតក្រោមរដ្ឋបាលក្រុង ការជួលប្រតិបត្តិករឯកជនឱ្យធ្វើការ ឬជាបន្សំរវាងប្រតិបត្តិការឯកជន និងរដ្ឋ។ មិនថាក្នុងករណីណាមួយ ជាការសំខាន់ណាស់ដែលត្រូវធានាឱ្យមានភាពអនុលោមតាមកិច្ចការពារបរិស្ថានជាធរមាន និងត្រូវធានាថាប្រតិបត្តិការអនុលោមតាមនិយាមបរិស្ថាន និងលិខិតបទដ្ឋានគតិយុត្តិផ្នែកបរិស្ថានជាធរមាន។ នៅពេលសេវាប្រមូលសំរាម សំណល់រឹង ត្រូវបានជួលទៅឱ្យអង្គភាពឯកជនទាំងស្រុង វត្តមាននៃយន្តការដ៏រឹងមាំរបស់រដ្ឋាភិបាល ដើម្បីធានាឱ្យមានភាពអនុលោមតាមផ្នែកបរិស្ថាន មានសារៈសំខាន់ជាពិសេស។ ការមើលខុសត្រូវនេះ នឹងផ្តោតលើដំណាក់កាលនីមួយៗនៃការគ្រប់គ្រងសំណល់ ហើយនឹងផ្តោតការយកចិត្តទុកដាក់លើទិដ្ឋភាពទាំងឡាយរបស់ប្រតិបត្តិការ ដែលបង្កហានិភ័យធំជាងគេបំផុត (SALGA, & Department of Environmental Affairs of Republic of South Africa, 2015)។



*រូបភាពទី ៧៖ ប្រតិបត្តិការទីលានចាក់សំរាមខាងក្រៅក្រុងកែប*

ហានិភ័យទាំងអស់នេះ អាចជួបប្រទះនៅក្នុងដំណាក់កាលដូចជា ៖

- **ដំណាក់កាលប្រមូល៖** ផ្តោតការយកចិត្តទុកដាក់មើលការខុសត្រូវលើការគ្រប់គ្រងឱ្យបានត្រឹមត្រូវ និងភាពស្អាតនៃទីតាំងដែលសំណល់ត្រូវបានប្រមូល និងធុងសំរាម ធានាឱ្យមានការទុកដាក់ និងការប្រមូលសំណល់ឱ្យបានត្រឹមត្រូវទៅតាមពេលវេលាដូចបានកំណត់ទុកជាមុន។
- **ដំណាក់កាលដឹកជញ្ជូន៖** ផ្តោតការយកចិត្តទុកដាក់មើលការខុសត្រូវលើ ការលើកសំរាមដាក់ចូលក្នុងរថយន្តដឹកជញ្ជូនឱ្យបានត្រឹមត្រូវ ធានាថាសំរាមមិនរសាត់ពាសវាលពាសកាល ឬមានក្លិន ការលើកសំរាមដាក់ចូលក្នុងឡានតាមកាលវិភាគបានកំណត់ទុកជាមុន និងការចាក់សំរាមចោលឱ្យបានត្រឹមត្រូវនៅទីលានចាក់សំរាម។
- **ដំណាក់កាលធ្វើប្រព្រឹត្តិកម្ម៖** ផ្តោតការយកចិត្តទុកដាក់មើលការខុសត្រូវលើ ការកាត់បន្ថយផលប៉ះពាល់នៃប្រតិបត្តិការញែកសំណល់ទៅលើអ្នកជិតខាង ក៏ដូចជាកំណត់ចរាចរណ៍របស់រថយន្ត និងយានជំនិះ ដើម្បីប្រមូល និងដឹកជញ្ជូនសំណល់ដទៃទៀតឱ្យទៅតាមកាលវិភាគពេលវេលាជាក់លាក់ដែលបានកំណត់ទុកជាមុន។
- **ដំណាក់កាលចោលសំណល់៖** ផ្តោតការយកចិត្តទុកដាក់មើលការខុសត្រូវលើការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន រួមមាន ការបំពុលទឹក និងបំពុលដីដែលបង្កឡើងដោយទឹកហៀរចេញពីសំណល់ និងទឹកភ្លៀង ភ្លើងឆេះគំនរសំរាមដែលធ្វើឱ្យមានការបំពុលខ្យល់ និងមានក្លិន និងការសាយភាយឧស្ម័នចេញពីទីលានចាក់សំរាមដែលបង្កឱ្យមានគ្រោះថ្នាក់ ផ្នែកសុវត្ថិភាពចំពោះកម្មករសំណល់ក្នុងទម្រង់ជាស្ថានភាពមិនមានខ្យល់គ្រប់គ្រាន់សម្រាប់ដកដង្ហើម អគ្គីភ័យ និងការផ្ទុះដែលអាចកើតឡើងក្នុងករណីកម្រណាមួយ (Dri et al., 2018)។

**ទិន្នន័យមានស្រាប់ ការប្រមូលទិន្នន័យ និងការរាយការណ៍៖** ទិន្នន័យដែលមាន និងការរាយការណ៍ ជះឥទ្ធិពលដោយផ្ទាល់លើសមត្ថភាពក្នុងការវាស់វែងលទ្ធផលការងារ ពាក់ព័ន្ធជាមួយប្រធានបទស្តីពីការគ្រប់គ្រង និងអភិបាលកិច្ចនីមួយៗ ដូចបានបញ្ជាក់ខាងដើម។ ដូចបានលើកឡើងក្នុងផ្នែកស្តីពីគោលវិធី និងវិធីសាស្ត្រហើយថា ទិន្នន័យដែលមាននៅក្នុងប្រទេសកម្ពុជាពាក់ព័ន្ធជាមួយការគ្រប់គ្រងសំណល់ គឺនៅតែជាបញ្ហាប្រឈមនៅឡើយ។ ថ្វីបើកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ បានសហការជាដៃគូជាមួយ ក្រសួងបរិស្ថាន និងការផ្តួចផ្តើមគំនិតដទៃទៀតបានអនុវត្តកិច្ចខិតខំឆ្លើយតបចំពោះភាពខ្វះខាតទាំងអស់នេះក្តី (UNDP, 2019) ការអនុវត្តនៃការពិចារណាលើការដាក់បញ្ចូលការប្រមូលទិន្នន័យទៅក្នុងប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងប្រចាំថ្ងៃ នៅពុំទាន់កើតមាននៅឡើយ។ បញ្ហានេះ គឺអាស្រ័យដោយកត្តាជាច្រើន រួមទាំងកង្វះធនធាន និងបរិធានគោលនយោបាយ កង្វះការយល់ដឹងពីវិធីសាស្ត្រសមស្រប ដើម្បីគណនាបរិមាណសំណល់ និងកង្វះយន្តការលើកទឹកចិត្តឱ្យមានការទទួលយកការ

អនុវត្ត ដែលដាក់បញ្ចូលគោលវិធីបែបវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ និងការគ្រប់គ្រងទិន្នន័យ (Singh et al., 2018)។

អាស្រ័យដោយភាពមានកម្រិតកំណត់នៃធនធាន ដែលបច្ចុប្បន្ន មានការប៉ះពាល់គ្រប់ទិដ្ឋភាពទាំងអស់នៃការគ្រប់គ្រងសំណល់ក្នុងខេត្តកែប យើងមើលឃើញថា ការប្រមូលទិន្នន័យ និងការរាយការណ៍ នៅពុំទាន់ត្រូវបានដាក់បញ្ចូលជាប្រព័ន្ធនៃកិច្ចខិតខំរបស់អ្នកផ្តល់សេវាប្រមូលសំណល់នោះទេ។ ទោះយ៉ាងណាក្តី ប្រសិនបើមិនមានការដាក់បញ្ចូលការប្រមូលទិន្នន័យ និងការរាយការណ៍ ជាកាតព្វកិច្ចនៅក្នុងការងាររបស់អ្នកផ្តល់សេវាទេនោះការវាស់វែងលើលទ្ធផលការអនុវត្តការងារនាពេលអនាគត និងការតាមដានលើការកែលំអសេវាពិតជាជួបការលំបាក។ គួរមានការគិតគូរ ក្នុងការកំណត់រកសូចនាករការអនុវត្តការងារសំខាន់ៗ ដែលមានរួចហើយ ដូចជាចំនួនដងនៃការប្រមូលសំណល់ដែលបានបញ្ចប់រួចរាល់ កម្មករបំពេញភារកិច្ចសកម្ម ឧបករណ៍ដែលមាន ការប្រើប្រាស់ឥន្ធនៈ និងបរិមាណសំណល់ដែលត្រូវបានបោះចោលជាដើម ដើម្បីចាប់ផ្តើមចងក្រងព័ត៌មានមូលដ្ឋានសម្រាប់ការអនុវត្តការងារ (Boldt et al., 2018)។ នៅពេលមានការវិនិយោគត្រូវបានធ្វើឡើង ការកែលំអដោយមានការដាក់បញ្ចូលនូវឱកាសក្នុងការបង្កើតប្រព័ន្ធដែលមាន លទ្ធភាពប្រមូលយកព័ត៌មានបន្ថែម ដែលអាចរកឃើញនិងពិធីសារជាកិច្ចឆ្លើយតបដើម្បីរាយការណ៍ព័ត៌មានទាំងអស់នេះទៅដល់មន្ត្រីទទួលខុសត្រូវ នឹងអាចបង្កើតឱ្យចេញពីជារូបរាងបាន។

## ៤.២ គោលវិធីបច្ចេកទេស និងលក្ខណៈប្រព័ន្ធ ដើម្បីឆ្លើយតបចំពោះអាទិភាពស្តីពីសំណល់

ការប្រឹងប្រែងបន្ថែមពីលើមូលដ្ឋានគ្រឹះនៃអភិបាលកិច្ចប្រព័ន្ធសំណល់ និងទស្សនទានសេដ្ឋកិច្ចចក្រាអាចនាំឆ្ពោះទៅរកកិច្ចពិភាក្សាដោយផ្ទាល់ពីវិស័យជាអាទិភាព ដើម្បីកែលំអសេវាសំណល់ក្នុងខេត្តកែប និងផ្តល់ឱកាសដើម្បីពិចារណារកចំណងទាក់ទងជាមួយប្រធានបទផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់ ដែលត្រូវបានពិភាក្សាជាញឹកញាប់នៅក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះនៅលើពិភពលោក។ ប្រធានបទអាទិភាពដែលមានភាពពាក់ព័ន្ធបំផុតជាមួយស្ថានភាពបច្ចុប្បន្នរបស់ខេត្តកែប គឺមានពិពណ៌នានៅផ្នែកខាងក្រោម និងអមជាមួយនឹងគោលវិធីដែលត្រូវបានស្នើឡើង ដើម្បីដោះស្រាយលើចំណុចនីមួយៗ៖

### *វិស័យអាទិភាព៖ ជំរុញអត្រាការប្រមូលសំណល់*

យើងខ្ញុំមើលឃើញថា កិច្ចខិតខំក្នុងការប្រមូលសំរាម សំណល់រឹងក្នុងប្រទេសកម្ពុជា គឺអាចឆ្លើយតបតែលើបរិមាណមានកម្រិតកំណត់ប៉ុណ្ណោះនៃសំណល់ទាំងអស់ដែលត្រូវបានបង្កើតឡើង (Sour, 2017)។ ចំណុចនេះ អាចបណ្តាលមកពីកត្តាជាច្រើន រួមមានដូចជា៖ លទ្ធភាពនៅមានកម្រិត ដើម្បីទទួលបានសេវាប្រមូលសំណល់ ការអនុវត្តតាមវិធីសាស្ត្របោះចោលសំណល់តាមបែបប្រពៃណី ដូចជាការដុតពាសវាលពាសកាល ឬកង្វះការយល់ដឹង ឬការយកចិត្តទុកដាក់ចំពោះផលប៉ះពាល់ផ្នែកបរិស្ថាន បណ្តាលមកពីការចោលសំណល់ខុសច្បាប់។ ធនាគារពិភពលោកបានប៉ាន់ប្រមាណថា នៅក្នុងបណ្តាប្រទេសមានប្រាក់ចំណូលទាប ដូចជាប្រទេសកម្ពុជាជាដើម មានតែសំណល់ ៤៨% ប៉ុណ្ណោះ នៃបរិមាណសំណល់ទាំងអស់ ដែលបានបង្កើតឡើងត្រូវបានប្រមូលនៅតាមទីក្រុង ហើយតួលេខនេះធ្លាក់ដល់ ២៦% ក្នុងតំបន់ជនបទ (Hoorweg et al., 2012)។ ការចំណាយដែលពុំត្រូវបានគេរាប់បញ្ចូល ប៉ុន្តែ គឺជាការចំណាយដ៏ពិតប្រាកដ បណ្តាលមកពីសំណល់មិនត្រូវបានប្រមូលត្រឹមត្រូវ ពោលគឺថ្លៃចំណាយផ្នែកសុខភាពដែលពាក់ព័ន្ធជាមួយទឹកផឹកមិនស្អាត ការបំពុលខ្យល់បណ្តាលមកពីការដុតសំណល់តាមទីវាល ឬគុណភាពដីធ្លាក់ចុះដែលរងផលប៉ះពាល់ពីទីតាំងនៅក្បែរកន្លែងចោលសំរាម។ ការចំណាយលើបញ្ហាទាំងនេះ គឺមានតម្លៃខ្ពស់ជាងថ្លៃចំណាយជាក់ស្តែងក្នុងការប្រមូល និងបោះចោលសំណល់ (Engel et al., 2016)។ ដើម្បីបង្កើនអត្រានៃការប្រមូលសំរាម សំណល់រឹង គឺត្រូវមាន និងរក្សានិរន្តរភាពនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នាមួយដែលរួមបញ្ចូលនូវការលើកទឹកចិត្តចំពោះការផ្លាស់ប្តូរអាកប្បកិរិយា ការលើកកម្ពស់ការយល់ដឹង និងការជំរុញការអនុវត្តច្បាប់។

គោលវិធីសម្រាប់ខេត្តកែប៖ ពង្រីកការយកចិត្តទុកដាក់លើការប្រមូលសំរាម សំណល់រឹងឱ្យបានទូលំទូលាយ បន្ថែមលើការផ្តោតតែទៅលើទីផ្សារពាណិជ្ជកម្ម និងអាជីវកម្ម និងត្រូវកំណត់គោលដៅឱ្យមានការពង្រីកការគ្របដណ្តប់ក្នុងការប្រមូលសំណល់បន្តិចម្តងៗ រហូតឈានដល់ការប្រមូលសំណល់ដែលគ្របដណ្តប់ទាំងស្រុង។

### *វិស័យអាទិភាព៖ សំណល់សមុទ្រ*

ជាទូទៅសំណល់សមុទ្រ គឺជាលទ្ធផលកើតចេញពីសំណល់ដែលពុំបានប្រមូល និងពុំបានធ្វើប្រព្រឹត្តិកម្ម បណ្តាលមកពីអត្រាការប្រមូលសំណល់កម្រិតទាប ឬវិធីសាស្ត្រចោលសំណល់មិនល្អ។ សំណល់សមុទ្រ ជាទូទៅ គឺពាក់ព័ន្ធជាមួយសំណល់ស្រាលៗ ដូចជាប្លាស្ទិក ដែលហូរមកតាមស្ទឹង និងទន្លេ ហើយទីបំផុតក៏ចូលទៅក្នុងមហាសមុទ្រ និងបណ្តាលឱ្យកើតមានសំរាមសមុទ្រកកកុញឡើងនៅតាមតំបន់ឆ្នេរ និងក្នុងតំបន់ដែនសមុទ្រ (Marine Litter Solutions, 2019) ។ ការពិនិត្យលើឆ្នេរកែបបង្ហាញឱ្យឃើញថា ផលប៉ះពាល់ស្តែងចេញយ៉ាងច្បាស់បំផុតនៃសំណល់សមុទ្រ តម្រូវឱ្យមានកិច្ចខិតខំមួយក្នុងការប្រមូលសំរាមជាប្រចាំ ដែលទាមទារឱ្យមានថ្លៃចំណាយ និងកម្លាំងពលកម្មបន្ថែម។ ផលប៉ះពាល់ដែលគេពុំសូវបានយល់ច្បាស់ដទៃទៀត ពាក់ព័ន្ធជាមួយផលប៉ះពាល់នៃប្លាស្ទិកក្នុងមហាសមុទ្រមកលើត្រី និងជីវចម្រុះដទៃទៀត និងការគំរាមកំហែងដល់ការរស់នៅរបស់ជីវចម្រុះទាំងនោះ និងឧស្សាហកម្មនេសាទ (Barboza et al., 2018)។ ថ្វីបើសំណល់ប្លាស្ទិកនៅតាមតំបន់សមុទ្រ គឺជាបញ្ហាស្មុគស្មាញកម្រិតសាកលក្តី ការពិនិត្យត្រួសៗក្នុងអំឡុងពេលទស្សនកិច្ចទៅកាន់កោះទាំងពីររបស់ខេត្តកែប ដែលមានមនុស្សរស់នៅ បង្ហាញឱ្យឃើញថា យ៉ាងហោចណាស់ ក៏មានសមាសធាតុណាមួយនៃសំណល់នេះ មានប្រភពមកពីប្រទេសកម្ពុជា ហើយក៏មានសំណល់ប្លាស្ទិកមានដាក់ស្លាកជាអក្សរថៃ និងអក្សរវៀតណាមមានវត្តមាន

នៅទីនោះផងដែរ។ ដើម្បីកំណត់ប្រភពប្លាស្ទិកទាំងអស់នេះ ឱ្យបានប្រាកដនោះ ចាំបាច់ត្រូវមានការសិក្សាផ្លូវការជាងនេះបន្ថែមទៀត។[១៩]

គោលវិធីសម្រាប់ខេត្តកែប៖ ពង្រីកអត្រាប្រមូលសំណល់ និងកែលំអប្រតិបត្តិការបស់ទីតាំងចោលសំណល់ ដែលធ្វើឱ្យការគ្រប់គ្រងសំណល់បានកាន់តែប្រសើរ បង្ការកុំឱ្យសំណល់ត្រូវទៅកកនៅក្នុងសមុទ្រ និងតាមតំបន់ឆ្នេរនៅពេលក្រោយ។ បំរាមលើដបប្លាស្ទិក ឬយុទ្ធនាការជំរុញការប្រើប្រាស់ដាក់ធុង និងដបទឹកប្រើប្រាស់ឡើងវិញបាន គឺជាយុទ្ធសាស្ត្រមួយចំនួនទៀតដែលគួរយកមកពិចារណា។

### *វិស័យអាទិភាព៖ ប្រព្រឹត្តិកម្មសំណល់សរីរាង្គ*

សំណល់សរីរាង្គ គឺជាប្រភេទសំណល់ដែលមានបរិមាណច្រើនគួរឱ្យកត់សម្គាល់នៃបរិមាណសំណល់រឹងដែលបានបង្កើតឡើងនៅខេត្តកែប ហើយក៏ជាចំណុចចាប់ផ្តើមដ៏ល្អនៅពេលពិចារណារកឱកាសសម្រាប់គ្រប់គ្រងសំណល់ (Sang-Arun et al., 2011)។ សំណល់សរីរាង្គ រួមចំណែកដល់បម្រែបម្រួលអាកាសធាតុតាមរយៈការបំភាយនូវឧស្ម័នមេតាន (US EPA, 2019; Zhang et al., 2019)។ យុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រសំខាន់ៗ គឺការកាត់បន្ថយឧស្ម័នមេតានពីទីលានចាក់សំរាម ដោយការកាត់បន្ថយបរិមាណសំណល់សរីរាង្គទៅកាន់ទីលានចាក់សំរាម។ ការកាត់បន្ថយបរិមាណសំណល់សរីរាង្គ អាចធ្វើបានតាមរយៈជម្រើសផ្សេងៗគ្នា ក្នុងនោះមានប្រព្រឹត្តិកម្មតាមបែបជីវសាស្ត្រ។

ការកែច្នៃសំណល់សរីរាង្គ អាចត្រូវបានធ្វើឡើងតាមច្រើនបែបច្រើនយ៉ាង (Bogner et al., 2007)។ ការប្រើប្រាស់សំណល់បែបនេះធ្វើជាជីកំប៉ុស្ត គឺជាបច្ចេកទេសងាយស្រួល និងចំណាយតិច ដែលត្រូវបានប្រើប្រាស់ភាគច្រើនក្នុងបរិបទនៃសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ (Ferronato et al., 2019)។ ការធ្វើជីកំប៉ុស្ត គឺជាការរួមផ្សំនូវសំណល់សរីរាង្គ ដែលជាទូទៅរួមមានកាកសំណល់បន្លែ និងសំណល់អាហារ ដែលត្រូវបានដាក់លាយបញ្ចូលគ្នា។ សីតុណ្ហភាព និងសំណើមត្រូវបានពិនិត្យ និងគ្រប់គ្រង ហើយសំណល់នោះត្រូវបានកូរយូរៗម្តង។ បន្ទាប់ពីរយៈពេលប្រមាណ ១២ សប្តាហ៍មក សំណល់នោះ ចាប់ផ្តើមងំ ហើយអាចយកទៅពិនិត្យ និងរៀបចំ ដើម្បីចែកចាយលក់ឱ្យយកទៅប្រើប្រាស់នៅក្នុងសកម្មភាពកសិកម្ម ឬព្រៃឈើបាន។ ការវិនិយោគក្នុងគោលវិធីនេះ ផ្តល់ភាគលាភតាមរយៈការកាត់បន្ថយបរិមាណសរុបនៃសំណល់ដែលត្រូវបានបោះចោល សំណល់ដែលធ្ងន់ និងអស់ថ្លៃច្រើនដើម្បីដឹកជញ្ជូន។ បន្ថែមលើនេះ សំណល់សរីរាង្គ ជារឿយៗបង្កឱ្យមានក្លិននិងបង្កើតឧស្ម័នមេតានហើយបង្កឱ្យមានហានិភ័យដល់បរិស្ថាន ដូចជាការបំពុលទឹក និងការបំពុលដី និងប៉ះពាល់ដល់សុខភាពមនុស្ស (Ferronato et al., 2019)។ ដើម្បីអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព ប្រព្រឹត្តិកម្មសំណល់សរីរាង្គ ចាំបាច់ត្រូវអនុវត្តក្នុងពេលដំណាលជាមួយការផ្តួចផ្តើមការញែកសំណល់នៅនឹងប្រភព ដោយក្នុងនោះ រួមមានការបណ្តុះបណ្តាលដល់បុគ្គលិកជាអ្នករៀបចំអាហារ ស្តីពីបច្ចេកទេសក្នុងការញែកសំណល់សរីរាង្គ និងសំណល់មិនមែនសរីរាង្គ ឱ្យបានត្រឹមត្រូវនៅប្រភពសំណល់។

គោលវិធីសម្រាប់ខេត្តកែប៖ មិនខុសពីតំបន់ត្រូពិកដទៃទៀតឡើយ សំណល់បន្លែ និងអាហារក្នុងខេត្តកែបតែងមានជាប្រចាំដែលផ្តល់ជាឱកាសដ៏ល្អ ដើម្បីប្រែក្លាយសំណល់ដែលនឹងត្រូវយកទៅដុតចោល ឬបោះចោលនោះ ឱ្យក្លាយជាប្រយោជន៍វិញ។ សារៈសំខាន់នៃផលិតផលកសិកម្មនាំចេញមានតម្លៃខ្ពស់ ដូចជាម្រេច និងស្វាយជាដើម គឺជាឱកាសដ៏ល្អសម្រាប់ជីកំប៉ុស្ត ដើម្បីយកទៅប្រើជំនួសឱ្យជីគីមី។ ប្រតិបត្តិការធ្វើជីកំប៉ុស្ត ជាឱកាសដ៏ល្អមួយទៀត សម្រាប់ដាក់បញ្ចូលឱ្យកម្មកររើសសំរាមក្នុងវិស័យក្រៅប្រព័ន្ធ។

### *វិស័យអាទិភាព៖ ការទាញយកអេតចាយស្ងួតដែលអាចកែច្នៃជាថ្មី*

អេតចាយស្ងួត ដូចជា ដបប្លាស្ទិក លោហៈ កេសក្រដាស និងក្រដាសធម្មតាជាដើម គឺជាប្រភេទសំណល់រឹង ដែលកំពុងមានការកើនឡើងនៅក្នុងខេត្តកែប ហើយក៏ជាសមាសធាតុដែលគួរទទួលការយកចិត្តទុកដាក់ នៅពេលធ្វើការពិចារណារកឱកាសសម្រាប់ការវិនិយោគនាពេលអនាគត។ ការទាញយកសំរាមស្ងួតដែលអាចកែច្នៃឡើងវិញបាន ដែលជាទម្រង់មួយនៃប្រព្រឹត្តិកម្មសំណល់ បម្រើឱ្យគោលបំណងជាច្រើនរួមមាន ការទាញយកធនធានដែលមានតម្លៃ ដើម្បីយកមកប្រើប្រាស់ឡើងវិញក្នុងខ្សែសង្វាក់តម្លៃនៃផលិតកម្មផ្សេងទៀត កាត់បន្ថយបរិមាណសំរាមដែលមានតម្រូវការទីលានសម្រាប់ចាក់ និងបង្វែរសំរាមចេញពីទីលានចាក់សំរាមជំនួសឱ្យការដុតសំរាម និងការបោះចោលសំរាមពាសវាលពាសកាល។



*រូបភាពទី ៨៖ ដេប៉ូអេតចាយក្នុងខេត្តកែប*

[១៩] ការសង្កេតក្នុងដំណើរទស្សនកិច្ចទៅមូលដ្ឋានផ្ទាល់ ក្នុងខែមេសា ឆ្នាំ ២០១៩

ប្រព័ន្ធគ្រប់គ្រងសំណល់ផ្លូវការរបស់ខេត្តកែប បច្ចុប្បន្ននេះ ពុំរួមមានការទាញយកវត្ថុធាតុដើមជាអេតចាយស្ងួតនោះឡើយ ដែលជាការបាត់បង់ប្រភពចំណូលបន្ថែមមួយ តាមរយៈការយកធនធានទាំងអស់នោះទៅលក់យកប្រាក់មកវិញ។[២០] បច្ចុប្បន្នមានតែវិស័យក្រៅប្រព័ន្ធប៉ុណ្ណោះ ដែលផ្តោតការយកចិត្តទុកដាក់លើការទាញយកអេតចាយស្ងួតមកវិញ និងដើរតួនាទីជាការផ្តួចផ្តើមគំនិតតែមួយគត់នៅក្នុងការញែកសំណល់នៅប្រភពដើម (សូមមើលមាតិកាដែលមានចំណងជើងថា "ការចូលរួមក្នុងភាពជាដៃគូ" ។ ដើម្បីទទួលបានអត្ថប្រយោជន៍ពេញលេញពីការទាញយកអេតចាយស្ងួត កម្មវិធីពង្រឹង និងជំរុញការញែកសំណល់នៅប្រភព ចាំបាច់ត្រូវធ្វើឡើង និងប្រកាន់ខ្ជាប់ដោយប្រជាជនក្នុងមូលដ្ឋាន។

**គោលវិធីសម្រាប់ខេត្តកែប៖** ការប៉ាន់ប្រមាណលើឱកាសដើម្បីដាក់បញ្ចូលការទាញយកអេតចាយក្នុងខេត្តកែប គួរត្រូវបានធ្វើឡើង បើទោះបីជានៅក្នុងទម្រង់បែបវិមជ្ឈការខ្នាតតូចក្តី ដោយហេតុថា ប្រព្រឹត្តិកម្មសំណល់ក្នុងទម្រង់បែបនេះ ផ្តល់ឱកាសដើម្បីបង្វែរសំណល់ចេញពីទីលានចាក់សំរាមផង ហើយស្របជាមួយគ្នានោះ ក៏ផ្តល់លទ្ធភាពរកបានចំណូលមួយចំនួន តាមរយៈការលក់សម្ភារៈដែលបានទាញយកមកវិញនោះផងដែរ។ ឱកាសក្នុងការស្ថាបនាទីតាំងកែច្នៃថ្នាក់តំបន់ជាមួយខេត្តកំពត គួរត្រូវបានពិចារណាដំណាលគ្នាជាមួយជម្រើសដទៃទៀត។

វិសោធនកម្មអនុសញ្ញា Basel ដែលបានអនុម័តក្នុងឆ្នាំ២០១៩ តម្រូវឱ្យមានការតាមដានលើការដឹកជញ្ជូនសំណល់ ប្លាស្ទិករវាងប្រទេស ដែលមានន័យថា ប្រទេសនាំចេញចាំបាច់ត្រូវបានទទួលការយល់ព្រមពីប្រទេសទទួលក្នុងការដឹកជញ្ជូនសំណល់ប្លាស្ទិកដែលមានជាប់មេរោគ សំណល់ចម្រុះ ឬមិនអាចកែច្នៃប្រើប្រាស់វិញបាន (Holden, 2019)។ ទោះយ៉ាងណាក្តី ការអនុវត្តនេះពុំបានជះឥទ្ធិពលដោយផ្ទាល់ដល់ការបង្កើតសំណល់ប្លាស្ទិកក្នុងស្រុកក្នុងប្រទេសកម្ពុជាឡើយ ដោយក្នុងនោះ មានការប៉ាន់ប្រមាណថា លំនៅដ្ឋានក្នុងទីប្រជុំជននីមួយៗបោះចង់ប្លាស្ទិកចំនួន ២.០០០ ថង់ចោលក្នុងមួយឆ្នាំ (Ellis-Petersen, 2018)។ ជាង ៨០% នៃប្លាស្ទិកក្នុងតំបន់សមុទ្រត្រូវបានបង្កើតឡើង ពីប្រភពក្នុងបណ្តាប្រទេសអាស៊ាន ដែលចូលទៅក្នុងសមុទ្រតាមបឹងស្ទឹង ទន្លេ (Faulder, 2018)។ ប្រជាជនក្រីក្រតាមតំបន់ឆ្នេររងផលប៉ះពាល់យ៉ាងធំធេង បើគិតទៅលើទិដ្ឋភាពដែលពួកគេត្រូវពឹងផ្អែកលើទឹកជប ព្រមទាំងកង្វះលទ្ធភាពទទួលបានជម្រើសក្នុងការប្រមូល និងបោះចោលសំណល់ ជាហេតុធ្វើឱ្យសហគមន៍ទាំងនោះពោរពេញទៅដោយប្លាស្ទិក (Ellis-Petersen, 2018)។

***ប្រអប់ទី ៥៖ ផលប៉ះពាល់នៃប្លាស្ទិកមកលើតំបន់ឆ្នេរកម្ពុជា***

### *វិស័យអាទិភាព៖ ការគ្រប់គ្រងសំណល់ដែលមានលក្ខណៈវិមជ្ឈការ*

ការដាក់ចេញនូវដំណោះស្រាយជាក់ស្តែង ដើម្បីដោះស្រាយបញ្ហាប្រឈមនៃការគ្រប់គ្រងសំណល់នៅក្នុងខេត្តកែប ទាមទារឱ្យមានការប្រើប្រាស់វិធីសាស្ត្រមួយ ដែលធ្វើការពិចារណាពីបញ្ហាពិបាកដែលប្រព័ន្ធបច្ចុប្បន្នកំពុងជួបប្រទះ ដូចជា ធនធានហិរញ្ញវត្ថុ និងកម្មករជំនាញនៅមានចំនួនកំណត់ជាដើម។ ថ្វីបើទីក្រុងធំៗកំពុងឈានទៅរកការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរួមមួយ ដែលមានថ្លៃចំណាយខ្ពស់ ដូចជា រោងចក្របំលែងសំណល់ទៅជាថាមពល និងកន្លែងទាញយកធនធានប្រើប្រាស់ឡើងវិញ ក្រុងតូចៗនៅពុំទាន់ស្ថិតក្នុងជំហរដ៏ល្អ ដើម្បីអាចទទួលបានអត្ថប្រយោជន៍ពីគោលវិធីទាំងអស់នេះទេ បើគិតទៅលើបរិមាណសំណល់តិចតួចរបស់ខ្លួន ថ្លៃចំណាយ និងបញ្ហាប្រឈមផ្នែកបច្ចេកវិទ្យាពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ប្រព័ន្ធទាំងនេះ។ ប្រព្រឹត្តិកម្មសំណល់រឹងទីប្រជុំជននៅកម្រិតសហគមន៍ អាចសម្រេចលទ្ធផលបានប្រហាក់ប្រហែលគ្នាជាមួយប្រព័ន្ធដែលមានតម្លៃខ្ពស់ៗ (ដូចជាការបង្វែរសំណល់ និងការកាត់បន្ថយសំណល់ជាដើម) និងផ្តល់ឱ្យសហគមន៍តូចៗ ដែលមានធនធានមានកម្រិតកំណត់នូវគំរូការវិនិយោគដែលអស់ថ្លៃតិច។ ស្របពេលជាមួយគ្នានេះ គំរូទាំងអស់នេះ ផ្តល់ឱកាសអាចដាក់បញ្ចូលកម្មករក្នុងវិស័យសំណល់ក្នុងមូលដ្ឋានទាំងកម្មករក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធបញ្ចូលទៅក្នុងប្រព័ន្ធទាំងអស់នេះ។

**គោលវិធីសម្រាប់ខេត្តកែប៖** ប្រព្រឹត្តិកម្មសំណល់ដែលមានលក្ខណៈ វិមជ្ឈការ មានប្រតិបត្តិការលើគោលការណ៍ដែលចាត់ទុកថាការធ្វើប្រព្រឹត្តិកម្មសំណល់បានប្រសើរបំផុតពេលនៅកៀកជាមួយចំណុចបង្កើតសំណល់។ ជម្រើសក្នុងការធ្វើប្រព្រឹត្តិកម្មរួមមាន៖ ការធ្វើជីកំប៉ុស្តខ្នាតតូច ដែលជាការពុកផុយនៃសំណល់អាហារ និងសំណល់សរីរាង្គដទៃទៀត ដោយសារចរន្តខ្យល់ និងការញែក និងប្រមូលអេតចាយស្ងួត ដើម្បីយកទៅលក់វិញ។ បើមានការប្តេជ្ញាចិត្តដ៏រឹងមាំ ខេត្តកែប អាចទទួលអត្ថប្រយោជន៍តាមរយៈការបង្កឱ្យមានការចូលរួមក្នុងការញែកវត្ថុធាតុដើមឱ្យកាន់តែបានប្រសើរថែមទៀត ការកាត់បន្ថយបរិមាណសំណល់សរុបដែលត្រូវយកទៅបោះចោល និងថ្លៃចំណាយដែលពាក់ព័ន្ធជាមួយថ្លៃដឹកជញ្ជូនកាកសំណល់ទាំងនោះទៅបោះចោល។ ករណីលើកលែងដ៏សំខាន់មួយចំពោះគោលវិធីនេះ គឺជាការអនុវត្តឡដុតកាកសំណល់ខ្នាតតូច។ កិច្ចពិភាក្សាមួយពីធាតុគ្រោះថ្នាក់បង្កឡើងដោយការអនុវត្តនេះក្នុងប្រទេសចិន ត្រូវបានពិពណ៌នាក្នុងប្រអប់ទី៦។

សាធារណជនមានក្តីកង្វល់ជាយូរមកហើយពីការកកើត និងការបំភាយដោយអចេតនានូវសារធាតុឌីអុកស៊ីនដែលជាសារធាតុពុល ស្ថិតនៅក្នុងបរិយាកាសរយៈពេលយូរ និងមិនងាយបំបែកធាតុ និងសារធាតុពុលផ្សេងទៀតដែលដូចនឹងសារធាតុឌីអុកស៊ីនបង្កឡើងពីឡដុតកាកសំណល់ទ្រង់ទ្រាយធំៗ។ កង្វល់ជាច្រើនទាំងនេះ ត្រូវបានដោះស្រាយតាមរយៈបច្ចេកវិទ្យាជឿនលឿន រួមមានបច្ចេកវិទ្យាគ្រប់គ្រងចំហេះ និងការបំពុលខ្យល់។ ទោះយ៉ាងណាក្តីជារឿយៗឡដុតដែលត្រូវបានប្រើប្រាស់ក្នុងតំបន់ជនបទប្រទេសចិនច្រើនតែមានទំហំតូច ហើយមានការគ្រប់គ្រងការបំភាយទៅក្នុងខ្យល់យ៉ាងសាមញ្ញបំផុត ឬគ្មានទាល់តែសោះ។

[២០] កិច្ចប្រជុំជាមួយអាជ្ញាធរក្រុងកែប ក្នុងខែមេសា ឆ្នាំ ២០១៩

ការពិនិត្យតាមដាន និងនិយ័តកម្មលើឡដុតខ្នាតតូចទាំងអស់នេះ ពុំត្រូវបានធ្វើឡើងជាប្រចាំ ដូចមានទូទៅក្នុងប្រតិបត្តិការឡដុតខ្នាតធំឡើយ។ ចំណុចនេះមានន័យថា ការកើតមានសារធាតុឌីអុកស៊ីនបង្កឡើងដោយឡដុតខ្នាតតូច មានកម្រិតខ្ពស់ជាងអត្រាកើតឡើងក្នុងឡដុតខ្នាតធំជាខ្លាំង។ ការសិក្សាមួយរបស់ US EPA បានកំណត់ឃើញថា ការបំភាយសារធាតុឌីអុកស៊ីន ដែលបង្កឱ្យមានជំងឺមហារីកចេញពីការដុតគំនរកាកសំណល់ចេញពីលំនៅដ្ឋាន អាចមានអត្រាខ្ពស់ជាងការបំភាយ ដែលកើតមាននៅក្នុងឡដុតកាកសំណល់ទំនើបៗចំនួន ២.០០០ ដង។

*ប្រភព៖ ( Yang et al., 2019 )*

***ប្រអប់ទី ៦៖ គ្រោះថ្នាក់បង្កឡើងដោយឡដុតសំរាមខ្នាតតូចក្នុងប្រទេសចិន***

### *វិស័យអាទិភាព៖ ការកែលំអទីលានចោលសំរាមឱ្យកាន់តែប្រសើរឡើង*

ការអភិវឌ្ឍប្រព័ន្ធដែលមានភាពអនុលោមតាមផ្នែកបរិស្ថាន និងមាននិរន្តរភាពសម្រាប់ការចោលសំរាម គឺជាធាតុដ៏ចាំបាច់សម្រាប់ការបំពេញមុខងាររបស់ប្រព័ន្ធគ្រប់គ្រងសំណល់ក្រុងឱ្យបានត្រឹមត្រូវ។ ទីលានចាក់សំរាមបច្ចុប្បន្នក្នុងខេត្តកែប ទាមទារឱ្យមានការកែលំអឱ្យប្រសើរឡើង ដើម្បីដាក់បញ្ចូលកិច្ចការពារផ្នែកបរិស្ថាន ដើម្បីការពារធនធានដី និងធនធានទឹក។ ការទុកដាក់សំណល់មានភាពរាយប៉ាយ មិនមានការគ្របត្រឹមត្រូវ ជាហេតុធ្វើឱ្យសំណល់ត្រូវបើកចំហ ដែលឱ្យទឹកភ្លៀងហូរចូលទៅក្នុងគំនរសំរាម និងនាំឱ្យកើតមានទឹកហៀរចេញពីសំរាមបន្ថែមទៀត។ ខណៈពេលដែលគួរតែមានការបង្កើតឡើងនូវយន្តការ ដើម្បីទប់ស្កាត់ដល់ការយកសំណល់ទៅបោះចោលពាលវាលពាសកាលទីលានចោលសំរាម សំណល់រឹង ចាំបាច់ត្រូវដំណើរការបានល្អដើម្បីទទួលសំណល់ដែលពុំអាចយកទៅធ្វើប្រព្រឹត្តិកម្ម ឬបង្វែរតាមវិធីផ្សេងទៀតបាន។

គោលវិធីសម្រាប់ខេត្តកែប៖ វិធានការដោះស្រាយបញ្ហានេះ គួរត្រូវបានធ្វើឡើងដើម្បីធានាឱ្យមានការទុកដាក់សំណល់ឱ្យបានសមស្រប និងការយកសម្ភារៈមកគ្របជាប្រចាំ ពោលគឺជាជំហានដែលនឹងជួយកាត់បន្ថយការបង្កើតឱ្យមានទឹកហៀរចេញពីសំណល់ និងករណីភ្លើងឆេះ ក្នុងពេលជាមួយគ្នានោះ ក៏ជួយរារាំងកុំឱ្យមានសត្វចង្រៃផងដែរ។ វិធានការគ្រប់គ្រងទឹកភ្លៀង គួរត្រូវបានយកមកពិចារណាផងដែរ។ ដោយហេតុថាប្រតិបត្តិការទីតាំងចោលសំណល់ដែលមានលក្ខណៈប្រសើរផ្នែកបរិស្ថាន ត្រូវចំណាយធនធានច្រើន ការរៀបចំឱ្យមានទីតាំងចោលសំណល់នៅថ្នាក់តំបន់ នៅទីកន្លែងដែលមានទីតាំងល្អ នៅចន្លោះពាក់កណ្ដាលផ្លូវរវាងខេត្តកែប និងខេត្តកំពត អាចដើរតួនាទីជាយុទ្ធសាស្ត្រមួយក្នុងការចែករំលែកការវិនិយោគ និងការចំណាយផ្នែកប្រតិបត្តិការជាមួយប្រជាជនកាន់តែច្រើនឡើង និងផ្អែកលើការបង់ពន្ធ។ នេះ គឺជាយុទ្ធសាស្ត្រប្រហាក់ប្រហែលជាមួយយុទ្ធសាស្ត្រ ដែលបានពិពណ៌នាខាងលើសម្រាប់ការទាញយកវត្ថុធាតុដើមអេតចាយមកប្រើប្រាស់ឡើងវិញផងដែរ។

## ៤.៣ វិមជ្ឈការ

ដំណើរការវិមជ្ឈការក្នុងការផ្តល់សេវារបស់ក្រុង កំពុងត្រូវបានអនុវត្ត ដោយក្នុងនោះ បញ្ហាសំណល់ គឺជាចំណុចផ្តោតការយកចិត្តទុកដាក់ដ៏សំខាន់របស់មន្ត្រីនៅគ្រប់កម្រិតទាំងអស់។ ផ្នែកនេះ លើកឡើងនូវដំណោះស្រាយ ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមពាក់ព័ន្ធជាមួយវិមជ្ឈការដែលកំពុងជួបប្រទះនៅខេត្តកែប។

### បញ្ហាប្រឈមនៅថ្នាក់ក្រោមជាតិ

#### *បញ្ហាប្រឈមទី១ ៖ ទាំងអាជ្ញាធរខេត្ត និងអាជ្ញាធរក្រុង/ស្រុក ចុះកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន*

ដំណោះស្រាយ និងអន្តរាគមន៍ដែលត្រូវបានស្នើឡើងសម្រាប់បញ្ហាប្រឈមនេះ មានដូចខាង ក្រោម៖

- ក្រសួងសំខាន់ៗទាំង ០៣ (ក្រសួងបរិស្ថាន ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) គួរបញ្ជូនសារឱ្យបានច្បាស់លាស់ ទៅកាន់អាជ្ញាធរថ្នាក់ខេត្ត ឱ្យដឹងថា ពួកគាត់ចាំបាច់ត្រូវអនុវត្តតាមអនុក្រឹត្យលេខ ១១៣ (សូមមើលបន្ថែមនៅផ្នែកខាងក្រោម)។ ការងារនេះ គួរត្រូវបានធ្វើឡើងតាមរយៈកិច្ចប្រជុំរួមគ្នា របាយការណ៍ ការពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីបញ្ជាក់អះអាងពីករណីមិនអនុលោមតាម ឬមធ្យោបាយដទៃទៀតក្នុងការផ្សព្វផ្សាយច្បាប់ដូចជា ខ្សែវីដេអូខ្លី នៅតាមអនឡាញដោយពិពណ៌នាពីរបៀបដែលការគ្រប់គ្រងសំណល់បែបវិមជ្ឈការ គួរត្រូវបានអនុវត្ត។
- អនុសាសន៍ច្បាស់លាស់ ទាក់ទងជាមួយនឹងតម្រូវការកសាងសមត្ថភាពនៅថ្នាក់ស្រុក/ក្រុង ដើម្បីអាចអនុវត្តអនុក្រឹត្យលេខ ១១៣។ ការងារនេះ អាចសម្រេចបាន តាមរយៈការរៀបចំឱ្យមានការវាយតម្លៃតម្រូវការកសាងសមត្ថភាពដែលមានលក្ខណៈសាមញ្ញ ប៉ុន្តែផ្តោតទិសដៅលើការអនុវត្តជាក់ស្តែង ហើយភ្ជាប់ជាមួយដោយផែនការលម្អិត ដើម្បីឆ្លើយតបចំពោះសេចក្តីត្រូវការទាំងនោះ។ តម្រូវការដែលចាំបាច់ រួមមាន ការគ្រប់គ្រងទូទៅ ការចុះកិច្ចសន្យា តួនាទីរបស់ស្រុក/ក្រុងដែលបានចែងក្នុងអនុក្រឹត្យលេខ ១១៣ ការលើកកម្ពស់ការយល់ដឹង និងប្រធានបទបច្ចេកទេសដទៃទៀតពាក់ព័ន្ធនឹងសំណល់។
- បង្កើតឱ្យមានគោលការណ៍ណែនាំច្បាស់លាស់ អំពីរបៀបអនុវត្តអនុក្រឹត្យលេខ ១១៣ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ។ គោលការណ៍ណែនាំនេះ នឹងជួយកាត់បន្ថយការបកស្រាយខុសឆ្គងជាចេតនាក្តី និងអចេតនាក្តីលើលិខិតបទដ្ឋានគតិយុត្តិ។ អាស្រ័យដោយមានការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមញឹកញាប់ក្នុងប្រទេសកម្ពុជា គោលការណ៍ណែនាំនេះ គួរដាក់ឱ្យមានវីដេអូខ្លីនៅតាមអនឡាញ ពោលគឺជាវីដេអូដែលសាមញ្ញ ប៉ុន្តែពន្យល់យ៉ាងច្បាស់លាស់ពីរបៀបដែលគួរអនុវត្តការគ្រប់គ្រងសំណល់បែបវិមជ្ឈការ។
- ចូលរួមដោយផ្ទាល់ថែមទៀត ជាមួយ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីអាចនាំពួកគេចូលមកក្នុងកិច្ចពិភាក្សាផងដែរ។ យើងយល់ច្បាស់ថា មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជា

អាជ្ញាធរមើលការខុសត្រូវលើបញ្ហាពាក់ព័ន្ធជាមួយ ១) ការរៀបចំចុះកិច្ចសន្យាជាមួយអ្នកផ្តល់សេវាវិស័យឯកជន ២) ការប្រើប្រាស់កញ្ចប់ថវិការបស់ក្រុង និង ៣) ប្រតិបត្តិការទីផ្សារ និងការទុកដាក់។ ទោះយ៉ាងនេះក្តី ក្នុងខេត្តកែប តួនាទីរបស់ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានលើកឡើងតិចតួច ហើយពុំមានកិច្ចពិភាក្សាដោយផ្ទាល់ ត្រូវបានធ្វើឡើងជាមួយមន្ទីរនេះនៅឡើយទេ។

*បញ្ហាប្រឈមទី ២ ៖ ការប្រើប្រាស់ថវិការបស់អាជ្ញាធរខេត្ត និងស្រុក/ក្រុង មិនអនុលោម ប្រកាសលេខ ០៧៣ ពាក់ព័ន្ធនឹងការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថានសម្រាប់ការអនុវត្តមុខងារគ្រប់គ្រង សំរាម សំណល់រឹងទីប្រជុំជននៅថ្នាក់ក្រោមជាតិ*

ដំណោះស្រាយ និងអន្តរាគមន៍ដែលត្រូវបានស្នើឡើងទាក់ទងជាមួយបញ្ហាប្រឈមនេះ មានដូចជា៖

- ស្វែងយល់ និងចងក្រងជាឯកសារពីបញ្ហាប្រឈមក្នុងការក្នុងការប្រើប្រាស់កញ្ចប់ថវិកា ដូចមានចែងក្នុងប្រកាសលេខ ០៧៣។
- ស្នើឱ្យមានដំណោះស្រាយ រួមទាំងវិសោធនកម្មដែលអាចធ្វើឡើងបាន ដើម្បីកាត់បន្ថយភាពរឹងត្អឹងដែលមិនចាំបាច់នៅក្នុងដំណើរការរៀបចំផែនការថវិកា។
- បង្កើតការណែនាំបង្ហាញ ឬគោលការណ៍ណែនាំច្បាស់លាស់ស្តីពីរបៀបប្រើប្រាស់ថវិកាអនាម័យរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយគោរពតាមស្មារតីរបស់ប្រកាសលេខ ០៧៣។

*បញ្ហាប្រឈមទី ៣៖ មានការជំរុញការអនុវត្ត និងការមើលខុសត្រូវ (ការពិនិត្យតាមដាន និងវាយតម្លៃ) មានកម្រិតកំណត់ពីសំណាក់អាជ្ញាធរខេត្ត និង/ឬស្រុក/ក្រុងលើការអនុវត្តកិច្ចសន្យា*

ដំណោះស្រាយ និងអន្តរាគមន៍ សម្រាប់បញ្ហាប្រឈមនេះ ត្រូវបានស្នើឡើងដូចខាងក្រោម៖

- គាំទ្រការបង្កើតឱ្យមានប្រព័ន្ធ ការពិនិត្យតាមដាន និងវាយតម្លៃ សម្រាប់ស្រុក/ក្រុងដែលមានកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន។
- ផ្តល់ការគាំទ្របច្ចេកទេស (យ៉ាងហោចណាស់នៅក្នុងដំណាក់កាលដំបូងៗ) ដែលផ្តល់មគ្គុទ្ទេសក៍ស្តីពីរបៀបអនុវត្តប្រព័ន្ធការពិនិត្យតាមដាន និងវាយតម្លៃ។
- ប្រើប្រាស់លទ្ធផលបានមកពីដំណើរការជំនួយបច្ចេកទេសស្តីពីការពិនិត្យតាមដាន និងវាយតម្លៃនេះ ដើម្បីជាមូលដ្ឋានព័ត៌មានសម្រាប់ថ្នាក់ជាតិ ស្តីពីរបៀបកែសម្រួលប្រកាស និងលិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធ។

### បញ្ហាប្រឈមនៅថ្នាក់ជាតិ

*បញ្ហាប្រឈមទី ១៖ មិនមានទិន្នន័យគួរជាទីជឿជាក់ដែលពិពណ៌នាពីការរៀបចំកិច្ចសន្យាគ្រប់គ្រងសំណល់នៅថ្នាក់ខេត្ត និងថ្នាក់ស្រុក/ក្រុង*

ដំណោះស្រាយ និងអន្តរាគមន៍សម្រាប់បញ្ហាប្រឈមនេះ រួមមាន៖

- ក្រសួងមហាផ្ទៃ (រួមជាមួយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន) គួរធ្វើផែនការដើម្បីរៀបចំឱ្យមានការធ្វើផែនទីកិច្ចសន្យាជាមួយអាជ្ញាធរខេត្ត និងស្រុក/ក្រុងទាំងអស់។
- ការធ្វើផែនទីនេះ ក៏គួរផ្តោតការយកចិត្តទុកដាក់លើការរៀបចំផ្នែកកិច្ចសន្យា សម្រាប់ការគ្រប់គ្រងសំណល់តាមទីផ្សារផងដែរ។

*បញ្ហាប្រឈមទី ២៖ ការពិនិត្យតាមដាន និងវាយតម្លៃ នៅមានកម្រិត និងមិនមានការសម្របសម្រួលគ្នាបានល្អពីថ្នាក់ជាតិមកលើការគ្រប់គ្រងការសំណល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ*

ដំណោះស្រាយ និងអន្តរាគមន៍សម្រាប់បញ្ហាប្រឈមនេះ រួមមាន៖

- រៀបចំឱ្យមានប្រព័ន្ធ ការពិនិត្យតាមដាន និងវាយតម្លៃ រួមគ្នាដែលមានដាក់នៅក្រោមក្រុមការងារបច្ចេកទេស ទទួលបន្ទុកការគ្រប់គ្រងសំណល់រឹងនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានការចូលរួមពី គ.ជ.អ.ប (ឧ. អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន និងអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ)។
- ស្វែងរកវិធីដើម្បីបង្កឱ្យមានការចូលរួមពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានកាន់តែជិតស្និទ្ធថែមទៀត។

*បញ្ហាប្រឈមទី ៣៖ ការគ្របដណ្តប់របស់អនុក្រឹត្យលេខ ១១៣ និងប្រកាសលេខ ០៧៣ នៅមានកម្រិតនៅឡើយ ជាមួយនឹងការគ្រប់គ្រងសំណល់នៅតាមទីផ្សារ*

ដំណោះស្រាយ និងអន្តរាគមន៍សម្រាប់បញ្ហាប្រឈមនេះ រួមមាន៖

- នៅក្នុងពេលវេលាសមស្រប គួរមានកិច្ចពិភាក្សា តាមរយៈក្រុមការងារបច្ចេកទេសស្តីពី ការគ្រប់គ្រងសំណល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិទាក់ទងជាមួយតួនាទី និងការទទួលខុសត្រូវលើការគ្រប់គ្រងសំណល់ក្នុងទីផ្សារ។

## ៤.៤ ការចូលរួមក្នុងភាពជាដៃគូ

ទំនាក់ទំនងដ៏រឹងមាំរវាងអ្នកពាក់ព័ន្ធនានាដែលទទួលបន្ទុកប្រតិបត្តិការ ក៏ដូចជាអ្នកពាក់ព័ន្ធដែលទទួលសេវាប្រមូលសំណល់ គឺមានភាពចាំបាច់ណាស់ ដើម្បីជួយដោះស្រាយបញ្ហាផ្នែក

អភិបាលកិច្ច និងអាទិភាពក្នុងការគ្រប់គ្រងសំណល់ប្រកបដោយភាពជោគជ័យ។ ភាពជាដៃគូនេះ ចាំបាច់ត្រូវមានការប្រាស្រ័យទាក់ទងទៅវិញទៅមកប្រកបដោយប្រសិទ្ធភាព ក៏ដូចជាត្រូវធ្វើការងារប្រកបដោយការសហការគ្នា ឈានទៅសម្រេចបានគោលបំណងរួម ដើម្បីទទួលបានលទ្ធផលគួរជាទីចង់បាន។ អ្នកពាក់ព័ន្ធសំខាន់ៗក្នុងខេត្តកែបដែលត្រូវបង្កឱ្យមានការចូលរួម មានដូចខាងក្រោម៖

## ៤.៤.១ វិស័យក្រៅប្រព័ន្ធ

ដូចបានកត់សម្គាល់រួចហើយថា វិស័យក្រៅប្រព័ន្ធដើរតួនាទីសំខាន់ ក្នុងការកែច្នៃវត្ថុធាតុដើមអេតចាយមានតម្លៃ ដូចជា៖ លោហៈ ប្លាស្ទិក និងក្រដាសរឹងជាដើម។ ប្រព័ន្ធក្រៅផ្លូវការក្នុងការកែច្នៃវត្ថុធាតុដើមមកប្រើប្រាស់ឡើងវិញ ត្រូវបានអភិវឌ្ឍឡើងផ្អែកលើតម្រូវការ ទីផ្សារសម្រាប់វត្ថុធាតុដើមទាំងនេះ។ ចំណុចនេះត្រូវបានបញ្ជាក់ ក្នុងអំឡុងដំណើរទស្សនកិច្ចរបស់ក្រុមការងារជាមួយឈ្មួញកណ្តាលទិញ-លក់អេតចាយនៅខេត្តកែប។ អ្នកធ្វើការក្នុងវិស័យក្រៅប្រព័ន្ធ មានចំណេះដឹងច្រើនពីតម្លៃវត្ថុធាតុដើម ហើយបានអភិវឌ្ឍន៍យុទ្ធសាស្ត្រ ដើម្បីបង្កើតកិច្ចខិតខំប្រឹងប្រែងក្នុងការប្រមូលឱ្យបានជាអតិបរមា ដើម្បីគាំទ្រដល់សង្វាក់តម្លៃនៃការកែច្នៃរបស់របរសម្រាប់ការប្រើប្រាស់ឡើងវិញ (GIZ, 2018)។ តំបន់អាមេរិកឡាទីន នៅជួរមុខគេក្នុងអភិវឌ្ឍភាពជាដៃគូរវាងអ្នកធ្វើការក្នុងវិស័យក្រៅប្រព័ន្ធជាមួយប្រព័ន្ធផ្លូវការ ហើយបានអភិវឌ្ឍវិធីសាស្ត្រដ៏ល្អ ដើម្បីបង្កើតភាពជាដៃគូទាំងអស់នេះ។ ការគាំទ្ររបស់រដ្ឋាភិបាលចំពោះសង្វាក់តម្លៃ ដែលមានបច្ចុប្បន្ននេះ ជួយពង្រឹងសហគមន៍ងាយរងគ្រោះ និងជំរុញឱ្យពួកគេគាំទ្រដល់ប្រព័ន្ធគ្រប់គ្រងសំណល់ដែលមានបច្ចុប្បន្ន (WRI, 2018)។

**បទពិសោធន៍ពីប្រទេសផ្សេងៗលើការដាក់បញ្ចូលវិស័យក្រៅប្រព័ន្ធទៅក្នុងប្រព័ន្ធផ្លូវការ**

ស្ថាបនាបន្ថែមលើទស្សនទាន ដែលដាក់បញ្ចូលអ្នករើសអេតចាយក្នុងវិស័យក្រៅប្រព័ន្ធទៅក្នុងប្រព័ន្ធប្រមូលសំណល់ផ្លូវការ មានគំរូផ្សេងៗជាច្រើនរួចជាស្រេចមកហើយ។ ឧទាហរណ៍មួយចំនួនដែលបានមកពីជុំវិញពិភពលោកមានដូចខាងក្រោម៖

- ធនាគារសំណល់ (ឥណ្ឌូណេស៊ី)៖ អង្គភាពទាំងអស់នេះប្រតិបត្តិការផ្អែកលើទស្សនទានរបស់ធនាគារពាណិជ្ជកម្មដោយអតិថិជនយកសំណល់មកដាក់ផ្ញើរ ហើយត្រូវបានកត់ត្រាក្នុងសៀវភៅបញ្ជីធនាគារ ហើយនៅចុងឆ្នាំ ការទូទាត់ជាសាច់ប្រាក់ត្រូវបានធ្វើឡើង ផ្អែកលើបរិមាណសំណល់ដែលបានយកមកផ្ញើរ (Salim, 2013)។
- ការវិភាគលើកិច្ចខិតខំ ដើម្បីដាក់បញ្ចូលអ្នកធ្វើការក្នុងវិស័យក្រៅប្រព័ន្ធទៅក្នុងប្រព័ន្ធផ្លូវការ (អាមេរិចឡាទីន)៖ របាយការណ៍របស់ EIU នេះ ពិនិត្យលើកិច្ចខិតខំក្នុងក្រុងទាំង ១២ នៅតំបន់អាមេរិចឡាទីនដោយផ្តោតការយកចិត្តទុកដាក់លើការដាក់បញ្ចូលកម្មករធ្វើការក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ (Economist Intelligence Unit, 2017)។
- ផែនទីបង្ហាញផ្លូវសម្រាប់ការដាក់បញ្ចូលកម្មករក្រៅប្រព័ន្ធទៅក្នុងកិច្ចខិតខំគ្រប់គ្រងសំណល់រឹងរបស់ក្រុង (ប្រទេសស៊ែប៊ី)៖ ឯកសាររៀបចំឡើងដោយ GIZ នេះ គូសបញ្ជាក់ពីដំណើរការ និងវិធីសាស្ត្រ ដើម្បីឆ្លើយតបជាមួយការដាក់បញ្ចូលអ្នករើសអេតចាយក្នុងវិស័យក្រៅប្រព័ន្ធ (GIZ, 2018)។
- សហករណ៍សំណល់តំបន់អាងទន្លេ Naivasha (ប្រទេសកេនយ៉ា)៖ ដោយមានដៃគូរអន្តរជាតិគាំទ្រដល់សហករណ៍ដែលផ្តោតការយកចិត្តទុកដាក់លើការប្រមូលប្លាស្ទិក និងក្រដាសរឹងនៅក្នុងតំបន់បឹងនេះ។ ការលក់វត្ថុធាតុដើមដែលប្រមូលបានទៅឱ្យអ្នកប្រមូលទិញ ចំណែកប្រាក់ដែលបានមកត្រូវបានយកទៅប្រើប្រាស់ដើម្បីគាំទ្រដល់សកម្មភាពរបស់សមាជិក (GIZ, 2018)។

***ប្រអប់ទី ៧៖ សហករណ៍សំណល់ និងធនាគារសំណល់***

ការផ្សារភ្ជាប់ជាមួយខេត្តកែប៖ កម្មករក្នុងវិស័យក្រៅប្រព័ន្ធក្នុងខេត្តកែប បានទ្រទង់ជីវភាពរស់នៅតាមរយៈការប្រមូល និងការលក់សម្ភារៈអេតចាយ។ តាមរយៈការគាំទ្រលើកិច្ចខិតខំរបស់ពួកគាត់ និងជួយជ្រោមជ្រែងក្នុងការពង្រីកការញែកសំណល់ និងការរើសយកវត្ថុធាតុដើមមកវិញ រដ្ឋាភិបាល អាចជួយសម្របសម្រួលការតភ្ជាប់កិច្ចខិតខំទាំងអស់នេះ ជាមួយប្រព័ន្ធគ្រប់គ្រងសំណល់ផ្លូវការដែលមានបច្ចុប្បន្ន ដោយផ្តល់ជាច្រកផ្លូវ ដើម្បីជំរុញប្រព្រឹត្តិកម្មសំណល់ និងគាំទ្រដល់ប្រជាជនងាយរងគ្រោះផងដែរ។ ការងារនេះ អាចសម្រេចបានតាមរយៈគំរូដែលមានបច្ចុប្បន្ន ដូចជាធនាគារសំណល់ប្រទេសឥណ្ឌូណេស៊ី ឬតាមរយៈក្រុមអ្នករើសសំណល់ (សូមមើល ប្រអប់ទី៧ ស្តីពី សហករណ៍សំណល់ និងធនាគារសំណល់)។

## ៤.៤.២ វិស័យឯកជន

តួនាទីវិស័យឯកជនក្នុងការគ្រប់គ្រងសំណល់កម្ពុជា ជាទូទៅមានភាពលេចធ្លោ ជាពិសេស ក្នុងតំបន់ទីប្រជុំជនដែលក្នុងនោះតម្រូវឱ្យមានសេវាសំណល់ដែលមានភាពជឿជាក់កម្រិតខ្ពស់។ ភាពញឹកញាប់នៃដំណើរការ និងភាពពឹងផ្អែកលើប្រតិបត្តិករឯកជនក្នុងទីក្រុងនៅកម្ពុជា គឺខុសប្លែកពីបទពិសោធន៍របស់ទីក្រុងនានាក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍជាច្រើនទៀត ដោយក្នុងនោះការប្រមូលសំណល់ជារឿយៗ ជាវិស័យរបស់អង្គភាពប្រតិបត្តិការសាធារណៈ ដោយមានទិដ្ឋភាពនៃការគ្រប់គ្រងសំណល់ ត្រូវបានជួលទៅឱ្យសេវាខាងក្រៅ (Cointreau-Levine, 1994)។ ភាពពឹងផ្អែករបស់កម្ពុជាលើប្រតិបត្តិករវិស័យឯកជនភ្ជាប់ជាមួយលទ្ធភាពកម្រិតទាបរបស់ពលរដ្ឋក្នុងការទទួលបានសេវាសំណល់ បង្ហាញពីភាពចាំបាច់នៃការគិតឡើងវិញពីទំនាក់ទំនងរវាងប្រតិបត្តិករវិស័យឯកជន និងអាជ្ញាធរគ្រប់គ្រងសំណល់។ យើងឃើញយ៉ាងច្បាស់ថាបច្ចុប្បន្ននេះ ប្រតិបត្តិករឯកជនបានឆ្លើយតបចំពោះតម្រូវការកាន់តែច្រើនឡើងរបស់សាធារណជន តាមរយៈការផ្តល់ជំនាញ ភាពអាចបត់បែនបាន និងធនធាន ជាកិច្ចឆ្លើយតបចំពោះបញ្ហាប្រឈមដ៏ធំធេងក្នុងវិស័យសំណល់ ដែលកន្លងមក គឺជាការចំណាយផ្ទាល់ដ៏តិចតួចចំពោះរដ្ឋាភិបាល (Kaza et al., 2018)។

ស្របពេលជាមួយគ្នានេះដែរ គំរូនេះក៏មានភាពចន្លោះខ្វះខាតមួយចំនួនដូចជា៖

- ភាពមានកម្រិតនៃចំណេះដឹងផ្នែកការគ្រប់គ្រងសំណល់ និងសមត្ថភាពទទួលខុសត្រូវពីរដ្ឋាភិបាល។
- ការពឹងផ្អែកហួសប្រមាណលើដំណោះស្រាយពីវិស័យឯកជនចំពោះបញ្ហាប្រឈមផ្នែកបរិស្ថាន និងការគ្រប់គ្រងសំណល់
- ការសម្របសម្រួលមានកម្រិតកំណត់រវាងអាជ្ញាធររដ្ឋាភិបាលដែលជាអ្នកទទួលខុសត្រូវ ប្រតិបត្តិករឯកជន និងអ្នកបង្កើតសំណល់ជាសាធារណជនដែលទទួលសេវា និងបញ្ហាប្រឈមក្នុងការបែងចែកការទទួលខុសត្រូវចំពោះភាពមិនអនុលោមតាមច្បាប់។
- កិច្ចសន្យាជាច្រើនធ្វើឡើងដោយរដ្ឋាភិបាលក្នុងកម្រិតផ្សេងៗជាមួយប្រតិបត្តិករតែមួយ ដែលទាមទារឱ្យមានការប្រាស្រ័យទាក់ទងផ្ទៃក្នុងរដ្ឋាភិបាលក្នុងកម្រិតខ្ពស់ ដើម្បីធានាប្រសិទ្ធផលនៃប្រតិបត្តិការ។
- ការជួលសេវាខាងក្រៅទាំងស្រុងសម្រាប់វិស័យសំណល់ ធ្វើឱ្យការជំរុញការអនុវត្តនិយ័តកម្មផ្នែកសំណល់ជួបការលំបាក ដោយហេតុថា ដែនសមត្ថកិច្ចកាន់តែមិនច្បាស់លាស់ ធ្វើឱ្យការវិនិច្ឆ័យពីភាពមិនអនុលោមតាម ឬការបំពានមានភាពស្រពេចស្រពិល (Spoann et al., 2019)។

ការផ្សារភ្ជាប់ជាមួយខេត្តកែប៖ បន្ទាប់ពីមានការធ្វើផែនទីសេវាប្រមូលសំណល់ដែលផ្តល់ដោយប្រតិបត្តិករឯកជន ត្រូវកំណត់រកចន្លោះខ្វះខាតសេវា និងកំណត់យុទ្ធសាស្រ្ត ដើម្បីឆ្លើយតបចំពោះភាពខ្វះខាតទាំងនោះ តាមរយៈការដាក់បញ្ចូល និងការពង្រីកការចុះកិច្ចសន្យា និងបង្កើនការមើលខុសត្រូវលើប្រតិបត្តិការទាំងអស់នោះពីសំណាក់រដ្ឋាភិបាល។

## ៤.៤.៣ ការចូលរួមរបស់សហគមន៍

ការផ្សារភ្ជាប់សហគមន៍មូលដ្ឋាន និងអង្គការនានាជាមួយសកម្មភាពកាត់បន្ថយសំណល់ និងការកែច្នៃសំណល់ឡើងវិញ តាមរយៈការផ្តួចផ្តើមគំនិតក្នុងការអប់រំ និងការលើកកម្ពស់ការយល់ដឹង គឺជាយុទ្ធសាស្រ្តដ៏រឹងមាំ ដើម្បីលើកទឹកចិត្តឱ្យមានការយល់ដឹងទូលំទូលាយថែមទៀត ពីសារៈសំខាន់នៃការគ្រប់គ្រងសំណល់បានត្រឹមត្រូវ។ ភាពជាដៃគូដ៏រឹងមាំជាមួយសហគមន៍ អាចត្រូវបានយកមកប្រើប្រាស់ ដើម្បីជ្រើសរើសបុគ្គល និងអង្គភាព "គំរូ" ដែលគាំទ្រដល់កំណែទម្រង់គ្រប់គ្រងប្រព័ន្ធសំណល់។ ការគាំទ្រនេះ គឺចាំបាច់ណាស់ដើម្បីបង្កើតឱ្យមានវប្បធម៌ ដែលដាក់បញ្ចូលការគ្រប់គ្រងសំណល់ ដោយយកចិត្តទុកដាក់ដោយមានការគិតគូរពីបរិស្ថាន។ ការចូលរួមពីសហគមន៍ អាចមានទម្រង់ផ្សេងៗជាច្រើន ដូចជា ទម្រង់សាមញ្ញមួយចំនួនដោយគ្រាន់តែបង្ហាញការចូលរួមពីអង្គការសហគមន៍ដែលមានបច្ចុប្បន្ន ដូចជា ក្រុមដែលផ្តោតការយកចិត្តទុកដាក់លើការអប់រំ ឬសកម្មភាពផ្នែកវប្បធម៌ ហើយអាចពង្រីកដល់អង្គការដែលផ្តោតការយកចិត្តទុកដាក់ខាងផ្នែកសង្គម ក្រុមសាសនា អង្គការផ្នែកបរិស្ថាន ឬស្ថានប័នដទៃទៀត។ សមាសភាពរបស់ក្រុមទាំងអស់នេះ ពឹងផ្អែកភាគច្រើនលើចំនួន និងចំណាប់អារម្មណ៍របស់ក្រុមដែលចូលរួមយ៉ាងសកម្មនៅក្នុងសហគមន៍ជាក់លាក់។

ការផ្សារភ្ជាប់ជាមួយខេត្តកែប៖ តាមរយៈការកំណត់រកអង្គការក្នុងសហគមន៍មូលដ្ឋាន ដែលមានចំណាប់អារម្មណ៍ទៅលើផ្នែកណាមួយនៃការគ្រប់គ្រងសំណល់ និងកិច្ចការពារបរិស្ថាន កិច្ចសន្ទនា អាចត្រូវបានបង្កើតឡើង ដើម្បីកំណត់រកវិស័យជាចំណុចផ្តោតការយកចិត្តទុកដាក់រួម ក៏ដូចជាឱកាសសម្រាប់ការអភិវឌ្ឍភាពជាដៃគូជាក់លាក់។ សកម្មភាពទាំងអស់នេះ អាចរួមមាន ការសម្អាតឆ្នេរ ឬសកម្មភាពលើកកម្ពស់ការយល់ដឹងបែបអប់រំជាដើម។

## ៤.៤.៤ ទេសចរណ៍ប្រកបដោយនិរន្តរភាព

ខេត្តកែប គឺជាតំបន់គោលដៅទេសចរណ៍ឆ្នេរសមុទ្រសម្រាប់អ្នកធ្វើដំណើរកម្សាន្តដែលផ្សារភ្ជាប់ សកម្មភាពជាមួយធម្មជាតិ។ ខេត្តកែប ក៏ជាតំបន់គោលដៅទេសចរណ៍ម្ហូបអាហារ ដែលគេតែងចង់ទៅទទួលទានក្តាមក្នុងមូលដ្ឋានផ្ទាល់ ដោយបន្ថែមរសជាតិជាមួយម្រេចដាំក្នុងតំបន់នេះ។ ធនធានទាំងអស់នេះ ពឹងផ្អែកជាខ្លាំងលើទឹកស្អាត និងសមុទ្រដែលគ្មានសំរាម ឆ្នេរមានសណ្តាប់ធ្នាប់ល្អ និងបរិស្ថានធម្មជាតិដែលលូតលាស់ល្អ និងមានលក្ខណៈគាំទ្រជាទូទៅ។ ប្រព័ន្ធអេកូឡូស៊ីដែលគាំទ្រដល់ជីវិតក្នុងសមុទ្រ និងជីវៈចម្រុះសមុទ្រមានភាពផុយស្រួយខ្លាំងណាស់ បើពុំមានកិច្ចការពារគ្រប់គ្រាន់ទេនោះ ប្រព័ន្ធនេះនឹងត្រូវដួលរលំ។ ការប្រកួតប្រជែងគ្នានៅកម្រិតអន្តរជាតិ ដើម្បីទទួលបានចំណូលពីវិស័យទេសចរណ៍អន្តរជាតិ និងជាពិសេស នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ គឺមានសភាពខ្លាំងក្លា (OBG, 2017)។ ម្យ៉ាងទៀត យើង ក៏បានយល់យ៉ាងច្បាស់ដែរថា ទេសចរណ៍បង្កផលប៉ះពាល់ដល់ការបង្កើតឱ្យមានសំរាមក្នុងមូលដ្ឋាន និងការប្រើប្រាស់ធនធានច្រើន។ ដើម្បីដោះស្រាយផលប៉ះពាល់ទាំងអស់នេះ ប្រតិបត្តិករទេសចរណ៍ម្ចាស់សណ្ឋាគារ និងភោជនីយដ្ឋាន ព្រមទាំងអ្នកផ្តល់សេវាដទៃទៀត ចាំបាច់ត្រូវប្តេជ្ញាចិត្តចំពោះកិច្ចខិតខំប្រឹងប្រែងរួម ដែលមានការសម្របសម្រួលគ្នា ដើម្បីបង្កឱ្យមានការចូលរួមពីភ្ញៀវទេសចរតាមរយៈការលើកទឹកចិត្តឱ្យមានការទទួលយកប្រតិបត្តិការបដិសណ្ឋារកិច្ច ដែលមានលក្ខណៈប្រកបដោយនិរន្តរភាព ដើម្បីកាត់បន្ថយការប្រើប្រាស់ធនធានជាទូទៅនិងការបង្កើតសំណល់។ ឧទាហរណ៍មួយនៃគំរូការអនុវត្តនេះ ត្រូវបានផ្តល់ដោយខេត្តសៀមរាប ដោយក្នុងនោះ ក្នុងរយៈពេល ០៤ឆ្នាំ កន្លងទៅនេះ យុទ្ធនាការប្រើប្រាស់ដបទឹកសម្រាប់ប្រើប្រាស់ឡើងវិញបានច្រើនដង ត្រូវបានផ្តួចផ្តើមឡើង ដើម្បីកាត់បន្ថយចំនួនដបទឹកប្លាស្ទិកដែលត្រូវបានបរិភោគដោយអ្នកទេសចរ។ ចំនួនការបង្កើតសំណល់ជាដបប្លាស្ទិករបស់កម្ពុជា បង្កើតឡើងដោយភ្ញៀវអន្តរជាតិ ត្រូវបានប៉ាន់ប្រមាណថា មានចំនួនជាង ១០ លានដបក្នុងមួយខែ (Refill Asia, 2019)។

ការផ្សារភ្ជាប់ជាមួយខេត្តកែប៖ មិនខុសពីសេដ្ឋកិច្ចពឹងផ្អែក

លើទេសចរណ៍ដទៃទៀតនោះឡើយខេត្តកែបមានឱកាសជាច្រើនដែលមានឥទ្ធិពលជាវិជ្ជមានលើបរិស្ថាន និងលើកកម្ពស់ការយល់ដឹង តាមរយៈការលើកទឹកចិត្តដល់ការខិតខំនានា ដូចជាការផ្តួចផ្តើមគំនិតដបទឹកសម្រាប់ប្រើប្រាស់ឡើងវិញបានច្រើនដង ឬសកម្មភាពសហគមន៍ដើម្បីសម្អាតឆ្នេរជាប្រចាំ និងការដាក់បញ្ចូលសារពីនិរន្តរភាព និងកិច្ចការពារបរិស្ថានទៅក្នុងអត្តសញ្ញាណរបស់សហគមន៍ជាទូទៅ។

## ៤.៥ សំណើសកម្មភាពអនុវត្តសាកល្បង

កិច្ចខិតខំរបស់ក្រុមការងារ ក.ជ.អ.ច. និងអង្គការមូលនិធិអាស៊ី ផ្តោតការយកចិត្តទុកលើការស្វែងយល់ពីបញ្ហាប្រឈមក្នុងការគ្រប់គ្រងសំណល់ក្នុងខេត្តកែប និងស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមទាំងអស់នេះផងដែរ។ អនុសាសន៍ផ្នែកគោលនយោបាយដ៏រឹងមាំ ផ្អែកលើកិច្ចសន្ទនាជាបន្តបន្ទាប់ និងផ្អែកលើព័ត៌មានបានមកពីកិច្ចពិភាក្សាជាមួយអ្នកពាក់ព័ន្ធក្នុងមូលដ្ឋានក្នុងខេត្តកែប។ ដោយមានការរំពឹងទុកនូវធាតុចេញទាំងអស់នេះ ជំហានកម្រិតមធ្យមមួយដែលត្រូវរៀបចំ រួមមាន ការស្នើឱ្យមានសកម្មភាពអនុវត្តសាកល្បងមួយចំនួនផ្តោតលើខេត្តកែប ដោយឈរលើមូលដ្ឋាននៃការយល់ដឹងបង្កើតឡើងដោយក្រុមការងារក្នុងកិច្ចពិភាក្សា និងកិច្ចប្រជុំរយៈពេល ០៣ថ្ងៃ ក៏ដូចជាដំណើរការគាំទ្រដែលត្រូវបានប្រើប្រាស់ ដើម្បីប្រមូល និងសំយោគព័ត៌មាននៅដំណាក់កាលផ្សេងៗនៃការស្រាវជ្រាវ។

ដើម្បីយល់ពីជំហានដែលចាំបាច់ ក្នុងការកែលំអការបំពេញមុខងាររបស់ប្រព័ន្ធគ្រប់គ្រងសំណល់នាពេលបច្ចុប្បន្នក្នុងខេត្តកែប ជាដំបូងគឺជាការសំខាន់ណាស់ ដែលត្រូវកំណត់ពីគោលបំណងនៃការកែលំអ។ ដំណើរការនេះ នឹងជួយជ្រោមជ្រែងដល់អ្នកធ្វើការសម្រេចចិត្តឱ្យអាចកំណត់បាន មិនត្រឹមតែពីជំហានដែលពាក់ព័ន្ធដើម្បីធ្វើការកែលំអតែប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងអាចយល់ច្បាស់ពីធនធានដែលត្រូវការដើម្បីធ្វើការ ផ្លាស់ប្តូរផងដែរ។ បន្ថែមលើការផ្តល់ផែនទីបង្ហាញផ្លូវ ដំណើរការនេះនឹងស្វែងឱ្យឃើញពីការប្តេជ្ញាចិត្តចំពោះសកម្មភាព និងដើរតួនាទីជាកាតាលីករសម្រាប់ការចូលរួមរបស់ដៃគូរជាតិ និងអន្តរជាតិ។

តារាងខាងក្រោមគូសបញ្ជាក់ពីជំហានរយៈពេលមធ្យម និងរយៈពេលវែងមួយចំនួនដែលត្រូវការ ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមជាក់លាក់ដែលបានរកឃើញនៅក្នុងខេត្តកែប។

**តារាងទី ៣៖ ជំហានរយៈពេលមធ្យម និងរយៈពេលវែងដែលចាំបាច់ត្រូវមាន ដើម្បីដោះស្រាយបញ្ហាប្រឈមស្តីពីសំណល់ក្នុងខេត្តកែប**

| បញ្ហាប្រឈមពាក់ព័ន្ធជាមួយសំណល់ | គោលដៅ | ជំហានរយៈពេលមធ្យម | ជំហានរយៈពេលវែង |
|---|---|---|---|
| ការគ្របដណ្តប់មិនបានពេញលេញនៃសេវាប្រមូលសំណល់ | ការគ្របដណ្តប់ទាំងស្រុងនៃសេវាប្រមូលសំណល់ | • ធ្វើផែនទីតំបន់ដែលមានលទ្ធភាពតិចតួចក្នុងការទទួលបានសេវាប្រមូលសំណល់<br>• កំណត់រកសមាសធាតុរបស់សំណល់<br>• កំណត់ពីធនធានមនុស្ស និងធនធានឧបករណ៍ដែលចាំបាច់ដើម្បីពង្រីកសេវា<br>• បង្កើតផែនទីបង្ហាញផ្លូវសម្រាប់ការពង្រីក សេវាកម្មប្រមូលសំណល់<br>• អភិវឌ្ឍយុទ្ធសាស្ត្រដើម្បីធានាឱ្យមានធនធានសម្រាប់ដំណើរឆ្ពោះទៅមុខ | • កៀរគរធនធានដើម្បីផ្តោតគោលដៅលើចន្លោះខ្វះខាតផ្នែកសេវា<br>• ដាក់បញ្ចូលធនធានមនុស្ស និងឧបករណ៍តាមការចាំបាច់<br>• អនុវត្តផែនទីបង្ហាញផ្លូវ<br>• បង្កើតប្រព័ន្ធ ការពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីធានាការតាមដានវឌ្ឍនភាព និងការកែលំអ |
| ការបោះចោលសំរាមខុសច្បាប់/ការដុតសំណល់ពាសវាលពាសកាល | លុបបំបាត់ករណីការចោលខុសច្បាប់/ការដុត | • ផ្តួចផ្តើមកិច្ចខិតខំដើម្បីសម្រេចបានការប្រមូលសំណល់ដែលមានការគ្របដណ្តប់ពេញលេញ<br>• រៀបចំ និងអនុវត្តយុទ្ធនាការលើកកម្ពស់ការយល់ដឹង<br>• វិភាគលើជម្រើសហាមឃាត់/ជំរុញការអនុវត្តច្បាប់ | • កិច្ចខិតខំជាបន្តបន្ទាប់ក្នុងការលើកកម្ពស់ការយល់ដឹងដែលគាំទ្រដល់សេវាប្រមូលសំណល់ដែលមានការគ្របដណ្តប់ពេញលេញ<br>• ដាក់ឱ្យប្រតិបត្តិការបំរាម/កិច្ចខិតខំក្នុងការជំរុញការអនុវត្តច្បាប់<br>• អនុវត្តគោលការណ៍គ្មានការអត់ឱន ( Zero tolerance ) នៅតំបន់ប្រជុំជន |

| បញ្ហាប្រឈមពាក់ព័ន្ធជាមួយសំណល់ | គោលដៅ | ជំហានរយៈពេលមធ្យម | ជំហានរយៈពេលវែង |
|---|---|---|---|
| ទីលានចាក់សំរាមមិនមានប្រតិបត្តិការ និងការគ្រប់គ្រងត្រឹមត្រូវ | ទីលានចាក់សំរាមដែលមានការគ្រប់គ្រង/ប្រតិបត្តិការត្រឹមត្រូវ | • វាយតម្លៃលើការអនុវត្តនាពេលបច្ចុប្បន្ន/អភិវឌ្ឍផែនទីបង្ហាញផ្លូវដើម្បីកែតម្រូវ<br>• អនុវត្តការផ្លាស់ប្តូរប្រតិបត្តិការដែលអស់តម្លៃថោក និងងាយស្រួលអនុវត្ត<br>• កំណត់រកឱកាសដើម្បីដាក់បញ្ចូលវិស័យក្រៅប្រព័ន្ធ<br>• ពិនិត្យរកឱកាសសម្រាប់ទីលានចាក់សំរាមថ្នាក់តំបន់ជាមួយខេត្តកំពត | • ការអនុវត្តជំហានផែនទីបង្ហាញផ្លូវដើម្បីកែទម្រង់/ដោះស្រាយផលប៉ះពាល់<br>• បង្កើតការផ្តួចផ្តើមគំនិតដើម្បីបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពកម្មករ<br>• ធានាឱ្យមានប្រាក់ចំណូលមានស្ថិរភាពដើម្បីគាំទ្រដល់ប្រតិបត្តិការទីលានចាក់សំរាម |
| ប្រព្រឹត្តិកម្មកាកសំណល់តិចតួចនៅមុនការចោលសំណល់ | ការញែកសំណល់ដែលអាចយកទៅកែច្នៃឡើងវិញ និងសំណល់សរីរាង្គនៅប្រភព មុនពេលយកទៅបោះចោល | • បង្កើតកិច្ចសន្ទនារវាងប្រជាពលរដ្ឋ និងពាណិជ្ជករ ដើម្បីរៀបចំគម្រោងលើក ទឹកចិត្តផ្នែកសេដ្ឋកិច្ចដើម្បីជំរុញការញែក សំណល់នៅប្រភពផ្ទាល់សម្រាប់គោលបំណង កែច្នៃឡើងវិញ<br>• បង្កើតកិច្ចសន្ទនាជាមួយអ្នកបង្កើតសំណល់ធំៗ ( ទីផ្សារ ) ស្តីពីការគ្រប់គ្រងសំណល់សរីរាង្គ<br>• ផ្តួចផ្តើមភាពជាដៃគូដើម្បីអភិវឌ្ឍប្រព្រឹត្តិកម្មខ្នាតតូចលើសំណល់សរីរាង្គ<br>• កំណត់រកឱកាសដើម្បីធ្វើជាដៃគូជាមួយវិស័យក្រៅប្រព័ន្ធលើការទាញយកសំណល់ស្ងួតដែលអាចកែច្នៃយកមកប្រើប្រាស់ឡើងវិញ | • កំណត់រកធនធាន និងជំនួយបច្ចេកទេសដើម្បីអនុវត្តគម្រោងលើកទឹកចិត្តដើម្បីលើកកម្ពស់ការញែកសំណល់នៅប្រភពផ្ទាល់ និងប្រព្រឹត្តិកម្មសំណល់សរីរាង្គ និងសំណល់ស្ងួតដែលអាចកែច្នៃប្រើប្រាស់ឡើងវិញ<br>• អនុវត្តយន្តការភាពជាដៃគូជាមួយវិស័យក្រៅប្រព័ន្ធ ដើម្បីជំរុញដំណើរការ |
| ប្លាស្ទិកក្នុងដែនសមុទ្រ និងនៅតាមឆ្នេរសមុទ្រ | កាត់បន្ថយប្លាស្ទិកនៅក្នុងដែនសមុទ្រ និងតាមឆ្នេរសមុទ្រ | • ជំរុញកិច្ចខិតខំក្នុងការប្រមូលសំណល់ក្នុងសណ្ឋាគារ/ភោជនីយដ្ឋាន<br>• ផ្តួចផ្តើមឱ្យមានផែនការដើម្បីកាត់បន្ថយប្លាស្ទិកប្រើប្រាស់តែមួយដង ( ដបចាក់ទឹកប្រើប្រាស់ឡើងវិញបាន )<br>• ដាក់សម្ពោធសកម្មភាពសម្អាតសហគមន៍/លើកកម្ពស់ការយល់ដឹង | • ពិភាក្សារកជម្រើសក្នុងការដាក់បំរាមចង់ប្លាស្ទិក និងផ្តល់ការលើកទឹកចិត្តចំពោះដបប្រើប្រាស់ឡើងវិញបាន<br>• ជំរុញកិច្ចខិតខំប្រឹងប្រែងប្រមូលសំណល់ ដើម្បីបង្កើនការគ្របដណ្តប់<br>• បង្កើតម៉ាកសំគាល់ ( Brand-identify ) ដោយដាក់បញ្ចូលវប្បធម៌នៃការការពារបរិស្ថាន និងការកាត់បន្ថយសំណល់ |
| ការយល់ដឹងរបស់សាធារណជនមានកម្រិតទាបពីបញ្ហាសំណល់ និងតួនាទីរបស់សាធារណជនក្នុងការគ្រប់គ្រងសំណល់ | ការទទួលស្គាល់តួនាទីរបស់សាធារណជននៅក្នុងការគ្រប់គ្រងសំណល់ប្រកបដោយប្រសិទ្ធភាព | • រៀបចំកិច្ចពិគ្រោះយោបល់ជាមួយក្រុមសហគមន៍មូលដ្ឋានដោយផ្តោតការយកចិត្តទុកដាក់លើការយល់ដឹងពីសំណល់<br>• អភិវឌ្ឍសកម្មភាពជាគោលដៅដែលផ្តោតការយកចិត្តទុកដាក់លើសំណល់<br>• អនុម័ត និងជំរុញការអនុវត្តលិខិតបទដ្ឋានគតិយុត្តិស្តីពីការផាកពិន័យ<br>• ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីលើកកម្ពស់ការយល់ដឹងពីការគ្រប់គ្រងសំណល់រឹង និងទេសចរណ៍ | • បង្កើតយន្តការដែលដាក់បញ្ចូលសកម្មភាពលើកកម្ពស់ការយល់ដឹងទៅក្នុងព្រឹត្តិការណ៍ក្នុងមូលដ្ឋាន/សកម្មភាពផ្នែកស្ថាប័ន<br>• បង្កើតយុទ្ធនាការដែលផ្សារភ្ជាប់វប្បធម៌ជាមួយកិច្ចការពារបរិស្ថាន និងសំណល់<br>• ការប្រើប្រាស់ការអប់រំផ្សព្វផ្សាយតាមអ៊ីនធឺណិតជាលក្ខណៈប្រព័ន្ធ ដើម្បីលើកកម្ពស់ការយល់ដឹង និងផ្សព្វផ្សាយពីខេត្តកែប |

| បញ្ហាប្រឈមពាក់ព័ន្ធជាមួយសំណល់ | គោលដៅ | ជំហានរយៈពេលមធ្យម | ជំហានរយៈពេលវែង |
|---|---|---|---|
| ដែនសមត្ថកិច្ចមិនច្បាស់លាស់សម្រាប់ការគ្រប់គ្រងសំណល់ក្នុងខេត្តកែប | ការមើលខុសត្រូវច្បាស់លាស់លើសំណល់អនុលោមតាមលិខិតបទដ្ឋានគតិយុត្តិ | • បកស្រាយបញ្ជាក់ និងជំរុញការយល់ដឹងពីតួនាទីរបស់អ្នកដើរតួនាទីនានានៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• បង្កើតកិច្ចសន្ទនារវាងដៃគូរដ្ឋាភិបាលដែលពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងសំណល់នាពេលបច្ចុប្បន្ន<br>• ធ្វើផែនទីឱកាសដើម្បីបង្កើតប្រសិទ្ធផលក្នុងប្រតិបត្តិការនាពេលបច្ចុប្បន្ន | • ឈានទៅសម្រេចបានគោលបំណងដែលអាជ្ញាធរក្រុងជាអ្នកផ្តល់សេវាចម្បងសម្រាប់ការងារគ្រប់គ្រងសំណល់រឹង |
| ការគាំទ្រ និង ការពិនិត្យតាមដាន និងវាយតម្លៃមានកម្រិតកំណត់ពីថ្នាក់ជាតិ | ការសម្របសម្រួលជាលក្ខណៈប្រព័ន្ធថែមទៀតពីថ្នាក់ជាតិមកលើគោលនយោបាយគ្រប់គ្រងសំណល់រឹង | • បង្កើតប្រព័ន្ធ ការពិនិត្យតាមដាន និងវាយតម្លៃ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>• ពង្រឹង ក្រុមការងារបច្ចេកទេសអន្តរក្រសួង | • ធ្វើការកែសម្រួលគោលនយោបាយដែលចាំបាច់ ចាត់ចែងធនធានការពិនិត្យតាមដាន និងវាយតម្លៃ និងយន្តការគាំទ្រដទៃទៀតនៅថ្នាក់ជាតិដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |

គោលដៅដែលបានស្នើរខាងលើ រួមទាំងជំហានរយៈពេលមធ្យម និងរយៈពេលវែង មានភាពស្របគ្នាជាមួយនឹងគម្រោងអាទិភាពដែលបានស្នើរឡើងនៅក្នុងពង្រាង ផែនការយុទ្ធសាស្រ្តអភិវឌ្ឍទីក្រុងនិរន្តរភាព ២០១៩-២០៣០ ដើម្បីដោះស្រាយបញ្ហាគ្រប់គ្រងសំណល់នៅទីក្រុងកែប (NCSD, MoI, & GGGI, 2019) និងស្របតាមផែនការវិនិយោគសាធារណៈបីឆ្នាំរំកិល ២០១៩-២០២១ របស់ខេត្តកែបផងដែរ (Kep Provincial Administration, 2019)។

ដោយពេលនេះយើង បានអភិវឌ្ឍការយល់ដឹងទូទៅពីបញ្ហាប្រឈមដែលទាមទារសកម្មភាព ក៏ដូចជាបានកំណត់ឃើញជំហានរយៈពេលមធ្យមមួយចំនួន ដែលចាំបាច់ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមនីមួយៗច្បាស់ហើយ ឥឡូវនេះយើង អាចចាប់ផ្តើមពិភាក្សារកជម្រើសដើម្បីអនុវត្តសកម្មភាពអនុវត្តសាកល្បង និងធនធានដែលចាំបាច់ដើម្បីធ្វើជំហានបន្ទាប់ដ៏សំខាន់នេះ។

ផ្អែកលើបញ្ហាប្រឈមក្នុងវិស័យសំណល់ដូចបានគូសបញ្ជាក់ក្នុងតារាងទី៣ ខាងលើ យើងអាចកំណត់ឃើញនូវកម្រងសកម្មភាពអនុវត្តសាកល្បងមួយចំនួន ជាកិច្ចឆ្លើយតបចំពោះបញ្ហាប្រឈមនីមួយៗ។ ទស្សនទានទាំងអស់នេះ ជាមូលដ្ឋាននៃសកម្មភាពអនុវត្តសាកល្បងដ៏រឹងមាំដោយខ្លួនឯងបាន ការយកចិត្តទុកដាក់ដែលត្រូវបានរួមផ្សំគ្នានៅលើផ្នែកផ្សេងៗជាច្រើន និងគាំទ្រឱ្យមានសកម្មភាពដ៏រឹងមាំ ហើយសកម្មភាពដែលត្រូវបានធ្វើឡើងនៅក្នុងផ្នែកទាំង ០៥ អាចដើរតួនាទីជាគោលវិធីបែបសព្វជ្រុងជ្រោយពិតប្រាកដដែលត្រូវបានតាក់តែងឡើង ដើម្បីឆ្លើយតបចំពោះសមាសធាតុសារវន្តដែលចាំបាច់ ដើម្បីបន្តជំរុញដំណោះស្រាយការគ្រប់គ្រងសំណល់រឹងរបស់ក្រុងកែបឱ្យបន្តឆ្ពោះទៅមុខ។

ទិដ្ឋភាពទូទៅនៃទស្សនទានសាកល្បងទាំង ០៥ ដែលត្រូវបានបង្កើតឡើង ជាកិច្ចឆ្លើយតបបញ្ហាប្រឈមជាក់លាក់ក្នុងការគ្រប់គ្រងសំណល់ដែលបានរកឃើញ ក្នុងអំឡុងពេលដំណើរទស្សនកិច្ចផ្ទាល់ទៅខេត្តកែប៖

១. អភិបាលកិច្ច - ការស្នើឡើងនូវទស្សនទាន គឺដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមដែលកើតឡើងដោយសារដំណើរការធ្វើវិមជ្ឈការមិនពេញលេញ ដែលនាំឱ្យមានភាពត្រួតគ្នានៃសមត្ថកិច្ចគ្រប់គ្រង និងការត្រួតពិនិត្យរបស់អាជ្ញាធរ ដែលនាំឱ្យប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងសំណល់រឹងនៅមានកម្រិត។ ទស្សនទានសាកល្បងនេះ នឹងបញ្ចូលការផ្តោតការយកចិត្តទុកដាក់លើ ការពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីឱ្យការគ្រប់គ្រង និងប្រតិបត្តិការកាន់តែមានភាពល្អប្រសើរជាងមុន។

២. បច្ចេកវិទ្យា និងប្រព័ន្ធបែបវិមជ្ឈការ - ការលើកឡើងនូវទស្សនទាននេះ គឺផ្អែកតាមទ្រឹស្តីស្តីពីការគ្រប់គ្រងសំណល់ដែលជំរុញឱ្យមានការធ្វើប្រព្រឹត្តិកម្មសំណល់ ដោយប្រើប្រាស់វិធីសាស្រ្តប្រព្រឹត្តិកម្មក្នុងទ្រង់ទ្រាយតូច ប្រើប្រាស់បច្ចេកវិទ្យាកម្រិតទាប និងចំណាយតិច នៅកៀកនឹងប្រភពដែលបង្កើតសំណល់ ដែលអាចឱ្យគេយកទៅប្រើប្រាស់បែបវិមជ្ឈការនៅកម្រិតសហគមន៍ ឬនៅថ្នាក់ស្រុក។

៣. សេវាប្រមូលសំរាមគ្របដណ្តប់ទាំងស្រុង និងកែលំអទីលានចាក់សំរាម - ទស្សនទាននេះ ផ្តោតលើកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រីកសេវាប្រមូលសំរាម តាមរយៈការកំណត់រកតំបន់ដែលមិនទាន់ទទួលបានសេវាប្រមូលសំរាម ឬតំបន់ដែលមិនទាន់ទទួលបានសេវាពេញលេញ និងដើម្បីកែលំអទីលានចាក់សំរាមរបស់ខេត្តកែប តាមរយៈការអនុវត្តវិធានការការពារបរិស្ថាន។

៤. តួនាទីនៃវិស័យក្រៅប្រព័ន្ធ - ទស្សនទាននេះ សំដៅលើការផ្ដួចផ្ដើមឱ្យមានការសន្ទនារវាងអាជ្ញាធរក្រុង និងកម្មករប្រមូលសំរាមក្នុងវិស័យក្រៅប្រព័ន្ធ។ តាមរយៈកិច្ចពិភាក្សា និងកិច្ចព្រមព្រៀង អាជ្ញាធរក្រុង អាចគាំទ្រដល់កម្មករប្រមូលសំរាមក្នុងវិស័យក្រៅប្រព័ន្ធ ក្នុងការធ្វើការងារឆ្ពោះទៅរកដំណោះស្រាយដែលនឹងផ្ដល់ផលប្រយោជន៍ដល់សហគមន៍ទាំងមូល ក្នុងនោះរួមទាំងភាពល្អប្រសើរជាងមុននៃការញែក និងការទាញយកធនធានដែលអាចកែច្នៃឡើងវិញបាន។

៥. ការអប់រំ និងការយល់ដឹង - ទស្សនទាននេះ គឺជាការរៀបចំយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈឱ្យស្របតាមបរិបទរបស់កម្ពុជា ដោយមានការចូលរួមពីតួអង្គពាក់ព័ន្ធនៅគ្រប់កម្រិត និងគ្រប់ផ្នែកនៃសង្គម កម្ពុជា។ ទស្សនទាននេះ នឹងផ្ដោតលើសារអប់រំផ្សព្វផ្សាយពីប្រធានបទដែលឆ្លុះបញ្ចាំងពីគុណតម្លៃ វប្បធម៌ និងប្រវត្តិសាស្ត្រក្នុងមូលដ្ឋាន និងផ្សារភ្ជាប់ជាមួយនឹងការគ្រប់គ្រងសំណល់រឹងផងដែរ។

ផែនការដើម្បីធ្វើដំណើរឈានទៅមុខជាមួយកិច្ចខិតខំនេះ តម្រូវឱ្យមានធាតុចូលពីអ្នកពាក់ព័ន្ធជាច្រើន ព្រមទាំងកិច្ចសម្របសម្រួលគាំទ្រយ៉ាងរឹងមាំរបស់ ក.ជ.អ.ច. និង អង្គការមូលនិធិអាស៊ី។ គោលវិធីពហុជំហានដែលត្រូវបានស្នើឡើងដើម្បីជំរុញទស្សនទានទាំងអស់នេះ ទៅជាសកម្មភាពមានដូចខាងក្រោម។ ការកែសម្រួលលើសកម្មភាព និងកាលវិភាគពេលវេលាលម្អិត ដើម្បីអមមកជាមួយគោលវិធីនេះ នឹងត្រូវពិនិត្យលម្អិតបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកក្រុមការងាររួចហើយ។

ដំណាក់កាលនៃការអនុវត្តសាកល្បងដែលត្រូវបានស្នើឡើងរួមមាន[២១]៖

- ការចេញផ្សាយរបាយការណ៍លម្អិត និងសង្ខេប របស់ ក.ជ.អ.ច. និងអង្គការមូលនិធិអាស៊ី
- ភាគីពាក់ព័ន្ធចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ និងធ្វើផែនការអនុវត្តសាកល្បង
- ផ្សព្វផ្សាយ "គម្រោងសាកល្បងភាពជាដៃគូសម្រាប់នវានុវត្តន៍ការគ្រប់គ្រងសំណល់ក្នុងខេត្តកែប"
- ក្រុមការងារបច្ចេកទេសចូលរួមកិច្ចប្រជុំ និងរៀបចំផែនការការងារ
- បង្កើតចរន្តការងារអនុលោមតាមគម្រោងសាកល្បង ដែលបានព្រមព្រៀងគ្នា
- អនុវត្តគម្រោងសាកល្បងរួមជាមួយការរាយការណ៍ពីវឌ្ឍនភាពឆ្ពោះទៅសម្រេចបានដំណាក់កាលសំខាន់ៗ
- ការវាយតម្លៃពាក់កណ្ដាលគម្រោង
- ការប្រមូលព័ត៌មាន៖ ខ្លឹមសារសង្ខេបស្ដីពីវឌ្ឍនភាព និងមេរៀនជាបទពិសោធន៍ បញ្ចប់សកម្មភាពអនុវត្តសាកល្បង។

## ៤.៦ ធាតុចូល ធនធាន និងកិច្ចសហការសម្រាប់សកម្មភាពអនុវត្តសាកល្បង

ដើម្បីផ្ដួចផ្ដើមដំណើរការនៃការរៀបចំសកម្មភាពសាកល្បង តារាងមួយ ត្រូវបានបង្កើតឡើង ដោយគូសបញ្ជាក់ពី ការចូលរួមរបស់អ្នកពាក់ព័ន្ធដែលចាំបាច់ យន្តការក្នុងការអនុវត្ត ធាតុចេញដែលត្រូវបានរំពឹងទុក ធនធាន និងទិន្នន័យដែលត្រូវការ។

ព័ត៌មានមូលដ្ឋានខាងលើ ត្រូវបានផ្ដល់ជូនក្នុងតារាងខាងក្រោម ដែលផ្ដល់ព័ត៌មានលម្អិតបន្ថែមទៀតសម្រាប់គោលវិធី ដែលត្រូវបានស្នើឡើងចំពោះសកម្មភាពអនុវត្តសាកល្បងទាំង ០៥ ដែលបានរៀបរាប់ខាងលើ ក្នុងផ្នែក "ទិដ្ឋភាពទូទៅនៃទស្សនទានសាកល្បងទាំង ០៥"។

**តារាងទី ៤៖ ធាតុផ្សេងៗទាំង ០៥ នៅក្នុងទស្សនទានសកម្មភាពអនុវត្តសាកល្បងដែលត្រូវបានស្នើឡើងសម្រាប់ខេត្តកែប**

| ចំណុចដែលត្រូវផ្ដោតក្នុងការសាកល្បង | ទិដ្ឋភាព | អ្នកចូលរួម | គោលបំណង | កត្តាហិរញ្ញវត្ថុ/សេដ្ឋកិច្ច | ធនធានដែលចាំបាច់ |
|---|---|---|---|---|---|
| ១. អភិបាលកិច្ច | • ការគ្រប់គ្រងសំណល់រឹងនាពេលបច្ចុប្បន្ននេះ ពុំបានឆ្លើយតបចំពោះចក្ខុវិស័យដែលត្រូវបានដាក់ចេញក្នុងអនុក្រឹត្យលេខ ១១៣ ប្រកាសលេខ ០៧៣ និងលិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធទៀតឡើយ។<br>• ការគាំទ្រ និងការពិនិត្យតាមដាន និងវាយតម្លៃ ពីថ្នាក់ជាតិនៅមានកម្រិត | • អាជ្ញាធរស្រុក/ក្រុងខេត្ត (រាប់បញ្ចូលទាំងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត និងមន្ទីរបរិស្ថានខេត្តផងដែរ)<br>• រដ្ឋាភិបាលនៅថ្នាក់ជាតិ (តាមរយៈក្រុមការងារបច្ចេកទេស) | • ការត្រួតពិនិត្យច្បាស់លាស់លើការអនុវត្តការគ្រប់គ្រងសំណល់ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តិនានា<br>• ការសម្របសម្រួល និងការត្រួតពិនិត្យក្នុងលក្ខណៈជាប្រព័ន្ធជាងមុនពីថ្នាក់ជាតិ | ការចំណាយ៖ ចំណាយរយៈពេលខ្លី ដើម្បីធ្វើឱ្យប្រព័ន្ធមានភាពអនុលោម<br>អត្ថប្រយោជន៍៖ ទទួលបានប្រសិទ្ធភាពរយៈពេលមធ្យម និងរយៈពេលវែង | • អ្នកចូលរួមដែលត្រូវបានចាត់តាំងពីអាជ្ញាធរនីមួយៗ<br>• ជំនួយបច្ចេកទេសដើម្បីគាំទ្រដល់អន្តរកាល<br>• យន្តការ/ទំនាក់ទំនងផ្លូវការរវាងដៃគូអភិវឌ្ឍន៍ និងយន្តការផ្លូវការរបស់រដ្ឋ (ឧទហរណ៍ក្រុមការងារបច្ចេកទេសជាដើម) |

[២១] ដំណាក់កាលដែលត្រូវបានស្នើឡើងនេះ ធ្វើការសន្មតពីការដាក់បញ្ចូលការពិភាក្សាផ្ទៃក្នុង និងការសម្រេចចិត្តទាក់ទងជាមួយការរៀបចំរបាយការណ៍សិក្សាវិសាលភាព និងសកម្មភាពអនុវត្តសាកល្បង។

| ចំណុចដែលត្រូវផ្ដោតក្នុងការសាកល្បង | ទិដ្ឋភាព | អ្នកចូលរួម | គោលបំណង | កត្តាហិរញ្ញវត្ថុ/សេដ្ឋកិច្ច | ធនធានដែលចាំបាច់ |
|---|---|---|---|---|---|
| ២. បច្ចេកវិទ្យា និងប្រព័ន្ធបែបវិមជ្ឈការ | ការផ្ទេរធនធានដោយផ្ទាល់ និងការផ្ដល់ចំណេះដឹងដល់តំបន់លំនៅដ្ឋានដែលពុំទាន់ទទួលសេវាគ្រប់គ្រាន់ និងដែលមានអត្រាប្រមូលសំរាមទាប | អាជ្ញាធរស្រុក/ក្រុង ខេត្ត និងប្រតិបត្តិករវិស័យឯកជន | អនុវត្តសកម្មភាពគ្រប់គ្រងសំណល់តាមសហគមន៍ក្នុងទ្រង់ទ្រាយតូច | ការចំណាយ៖ ការចំណាយមូលធន និងចំណាយលើការបណ្ដុះបណ្ដាល ដើម្បីអនុវត្តប្រព័ន្ធ<br>អត្ថប្រយោជន៍៖ ជម្រើសដែលអស់ចំណាយទាបជំនួសឱ្យប្រព័ន្ធបែបមជ្ឈការ | • តំបន់សម្រាប់អនុវត្តសាកល្បង<br>• ការផ្ដល់ជំនួយបច្ចេកទេសសម្រាប់ធ្វើការវិភាគ/សិក្សាពីសមិទ្ធលទ្ធភាព<br>• ធនធានសម្រាប់អនុវត្តសាកល្បង |
| ៣. សេវាប្រមូលសំរាមគ្របដណ្ដប់ទាំងស្រុង និងកែលំអទីលានចាក់សំរាម | ធ្វើការកែសម្រួលកិច្ចសន្យាផ្ដល់សេវាប្រមូលសំរាមនាពេលបច្ចុប្បន្ន ដោយធ្វើការពិចារណាពីមេរៀនដែលទទួលបាន | អាជ្ញាធរស្រុក/ក្រុង ខេត្ត និងប្រតិបត្តិករវិស័យឯកជន | រៀបចំវិធីសាស្ត្រសាកល្បងដើម្បីដោះស្រាយបញ្ហាសេវាប្រមូលសំរាមដែលមិនមានការគ្របដណ្ដប់ ពេញលេញ និងបញ្ហាទីលាន ចាក់សំរាម និងផ្ដោតលើឱកាសកែលំអដែលងាយស្រួលក្នុងការអនុវត្ត | ការចំណាយ៖ ចំណាយលើការអនុវត្តការពង្រីកសេវា និងការកែលំអទីតាំង<br>អត្ថប្រយោជន៍៖ ការបន្ថយការចំណាយលើបរិស្ថាន និងសុខភាពសម្រាប់អាជ្ញាធរ និងប្រជាពលរដ្ឋ | • តំបន់សម្រាប់អនុវត្តសាកល្បង<br>• ការផ្ដល់ជំនួយបច្ចេកទេសសម្រាប់ធ្វើការវិភាគ/សិក្សាពីសមិទ្ធលទ្ធភាព<br>• ធនធានសម្រាប់អនុវត្តសាកល្បង |
| ៤. តួនាទីនៃវិស័យក្រៅប្រព័ន្ធ | គិតរហូតមកដល់ពេលបច្ចុប្បន្ននេះ អភិបាលកិច្ចក្នុងវិស័យនេះ ធ្វើការពិចារណាតិចតួចប៉ុណ្ណោះលើផលប៉ះពាល់សង្គម ដែលបង្កឡើងដោយសារការគ្រប់គ្រងសំណល់ | អាជ្ញាធរស្រុក/ក្រុង ខេត្ត និងថ្នាក់ជាតិ<br>អង្គការ/ស្ថាប័នដែលជួយសម្របសម្រួលវិស័យក្រៅប្រព័ន្ធ | រៀបចំវេទិកាដើម្បីឱ្យមានការពិគ្រោះយោបល់ស្ដីពីគំរូសហការរវាងវិស័យផ្លូវការ និងក្រៅប្រព័ន្ធ | ការចំណាយ៖ ចំណាយលើការចាប់ផ្ដើមអនុវត្តន៍វិធីសាស្ត្របែបកម្មវិធីដើម្បីជំរុញឱ្យមានការចូលរួមពី វិស័យក្រៅប្រព័ន្ធ<br>អត្ថប្រយោជន៍៖ ឱកាសមួយចំនួន សម្រាប់ធ្វើការចែករំលែកប្រាក់ចំណូលដែលបានពីការទាញសម្ភារៈមកប្រើប្រាស់ឡើងវិញ និងការកែលំអជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលមានឱកាសតិចតួច | • ការគាំទ្រពី រដ្ឋាភិបាល ដើម្បីឱ្យមានការរៀបចំកិច្ចពិគ្រោះយោបល់ និងការធ្វើសកម្មភាពនានា<br>• ធនធានសម្រាប់សម្របសម្រួលកិច្ចពិគ្រោះយោបល់<br>• ការគាំទ្រពីអ្នកជំនាញអន្តរជាតិ ដែលមានបទពិសោធន៍ធ្វើការងារជាមួយនឹងវិស័យក្រៅប្រព័ន្ធ |
| ៥. ការអប់រំ និងយល់ដឹង | លទ្ធភាពផ្នែកថវិការបស់រដ្ឋាភិបាល នៅមានកម្រិត សម្រាប់ការអប់រំ និងការបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋ | អាជ្ញាធរស្រុក/ក្រុង ខេត្ត ប្រតិបត្តិករ វិស័យឯកជន<br>អង្គការពាក់ព័ន្ធដែលធ្វើការងារតាមសហគមន៍ អង្គការ/ស្ថាប័នដែលជួយសម្របសម្រួល | រៀបចំគំរូសម្រាប់បង្កើនការយល់ដឹងពីសំណល់ដល់ប្រជាពលរដ្ឋគោលដៅ | ការចំណាយ៖ ចំណាយលើការចាប់ផ្ដើមអនុវត្តវិធីសាស្ត្របែបកម្មវិធីដើម្បីអប់រំ និងជំរុញឱ្យមានការចូលរួមពីប្រជាពលរដ្ឋ<br>អត្ថប្រយោជន៍៖ ផលដែលបានពីការវិនិយោគក្នុងរយៈពេលវែង និងរយៈពេលខ្លី លើការកែលំអឥរិយាបថរបស់ប្រជាពលរដ្ឋ | • ការគាំទ្រពីរដ្ឋាភិបាលដល់កិច្ចពិគ្រោះយោបល់នៅតាមសហគមន៍<br>• ធនធានសម្រាប់រៀបចំសកម្មភាព និងសម្ភារៈនានា |

ក្នុងអំឡុងពេលអនុវត្ត គម្រោងសាកល្បងនេះ កិច្ចសម្របសម្រួលរួមគ្នារបស់ដៃគូអនុវត្ត គឺមានភាពចាំបាច់ជាពិសេស។ ការជួយសម្របសម្រួលនេះ នឹងជួយពង្រឹងប្រព័ន្ធគ្រប់គ្រងសំណល់នាពេលបច្ចុប្បន្នឡើងវិញជាមួយគោលបំណងចុងក្រោយក្នុងការបង្កើតឱ្យមានប្រតិបត្តិការប្រកបដោយនិរន្តរភាព និងមានប្រសិទ្ធផលដែលនឹងនាំឱ្យសម្រេចបានលទ្ធផលនៃការគ្រប់គ្រងសំណល់កាន់តែល្អប្រសើរនៅក្នុងរយៈពេលមធ្យម និងរយៈពេលវែង។

ការពិពណ៌នាពីអ្នកចូលរួមនីមួយៗ និងតួនាទីរបស់ពួកគេនៅក្នុងសកម្មភាពអនុវត្តសាកល្បង មានដូចខាងក្រោម។

- ក.ជ.អ.ច.៖ ដៃគូក្នុងការអនុវត្តអនុស្សរណៈនៃការយោគយល់ជាមួយ អង្គការមូលនិធិអាស៊ី។ នេះជាស្ថាប័នជាតិទទួលខុសត្រូវក្នុងការបញ្ជ្រាបនិរន្តរភាពទៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃសកម្មភាពសេដ្ឋកិច្ចជាតិ។
- តួនាទីក្នុងការអនុវត្តសាកល្បង៖ សម្របសម្រួលសកម្មភាពជាមួយអង្គការមូលនិធិអាស៊ី និងផ្តល់ធាតុចូលផ្នែកធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ដែលចាំបាច់សម្រាប់ការអនុវត្តសាកល្បង។
- នាយកដ្ឋានគ្រប់គ្រងសំណល់រឹងរបស់ក្រសួង/ក្រសួងបរិស្ថាន៖ ទទួលខុសត្រូវក្នុងការមើលខុសត្រូវផ្នែក និយ័តកម្មលើសកម្មភាពគ្រប់គ្រងសំណល់ថ្នាក់ជាតិ។
- តួនាទីក្នុងការអនុវត្តសាកល្បង៖ ផ្តល់ការគាំទ្រក្នុងកិច្ចឆ្លើយតបចំពោះសំណួរនានាពាក់ព័ន្ធជាមួយកំណែទម្រង់ទាក់ទងជាមួយបច្ចេកវិទ្យា និងប្រព័ន្ធគ្រប់គ្រងសំណល់ ក៏ដូចជាអភិបាលកិច្ចជាទូទៅលើប្រព័ន្ធគ្រប់គ្រងសំណល់។ ផ្តល់ធាតុចូលផ្នែកធនធានមនុស្សដែលចាំបាច់សម្រាប់ការអនុវត្តសាកល្បង។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ ស្ថាប័ននាំមុខរបស់រដ្ឋាភិបាលដែលឆ្លើយតបចំពោះសំណួរស្តីពីការមើលខុសត្រូវផ្នែកសារពើពន្ធ និងថវិកា។
- តួនាទីក្នុងការអនុវត្តសាកល្បង៖ ដឹកនាំលើសំណួរពាក់ព័ន្ធជាមួយការមើលខុសត្រូវផ្នែកហិរញ្ញវត្ថុ ការយកថ្លៃសេវា និងការផ្ទេរកញ្ចប់ថវិកាសម្រាប់ការគ្រប់គ្រងសំណល់។ ផ្តល់ធាតុចូលធនធានមនុស្សដែលចាំបាច់សម្រាប់ការអនុវត្តគម្រោងសាកល្បង។
- ក្រសួងមហាផ្ទៃ/គ.ជ.អ.ប៖ ស្ថាប័ននាំមុខរបស់រដ្ឋាភិបាលទាក់ទងជាមួយសំណួរស្តីពីវិមជ្ឈការការមើលខុសត្រូវការងារផ្ទៃក្នុង និងការសម្របសម្រួលរវាងអង្គភាពរដ្ឋាភិបាល។
- តួនាទីក្នុងការអនុវត្តសាកល្បង៖ នាំមុខលើសំណួរទាក់ទងជាមួយអភិបាលកិច្ច ជាពិសេសលើសំណួរដែលទាមទារឱ្យមានការបកស្រាយបញ្ជាក់ឱ្យច្បាស់សម្រាប់កំណែទម្រង់បន្ថែមទៀត និងការមើលខុសត្រូវកាន់តែប្រសើរឡើងលើការគ្រប់គ្រងសំណល់។ ផ្តល់ធាតុចូលផ្នែកធនធានមនុស្សដែលចាំបាច់សម្រាប់ការអនុវត្តគម្រោងសាកល្បង។
- ខេត្តកែប៖ អាជ្ញាធរមើលខុសត្រូវកិច្ចការរបស់ខេត្តកែប ដែលមានតួនាទីជាច្រើនក្នុងពេលបច្ចុប្បន្នក្នុងការគ្រប់គ្រងសំណល់ក្នុងក្រុងកែប។
- តួនាទីក្នុងការអនុវត្តសាកល្បង៖ ចូលរួម និងចូលរួមចំណែកក្នុងកិច្ចពិភាក្សា ដើរតួនាទីប្រកបដោយការស្ថាបនាក្នុងការដោះស្រាយសំណួរស្តីពីការទទួលខុសត្រូវមើលខុសត្រូវលើសំណល់ដែលបច្ចុប្បន្នមានភាពមិនច្បាស់លាស់។ ផ្តល់ធាតុចូលធនធានមនុស្សដែលចាំបាច់សម្រាប់ការអនុវត្តគម្រោងសាកល្បង។
- ក្រុងកែប៖ អាជ្ញាធរមើលខុសត្រូវលើកិច្ចការរបស់ក្រុងកែប។
- តួនាទីក្នុងការអនុវត្តសាកល្បង៖ ចូលរួម និងចូលរួមចំណែកក្នុងកិច្ចពិភាក្សា ដើរតួនាទីប្រកបដោយការស្ថាបនាក្នុងការដោះស្រាយសំណួរស្តីពីការទទួលខុសត្រូវមើលខុសត្រូវលើសំណល់ដែលបច្ចុប្បន្នមានភាពមិនច្បាស់លាស់។ ផ្តល់ធាតុចូលធនធានមនុស្សដែលចាំបាច់សម្រាប់ការអនុវត្តគម្រោងសាកល្បង។
- អង្គការមូលនិធិអាស៊ី៖ ដៃគូក្នុងការអនុវត្ត អនុស្សរណៈនៃការយោគយល់ជាមួយ ក.ជ.អ.ច. និងដឹកនាំការសម្របសម្រួលសកម្មភាពក្រុមការងារ។

តួនាទីក្នុងការអនុវត្តសាកល្បង៖ សម្របសម្រួលកិច្ចសន្ទនា និងការសម្រេចចិត្តក្នុងការគាំទ្រដល់ការអនុវត្តសកម្មភាពអនុវត្តសាកល្បងឱ្យមានប្រសិទ្ធភាព។ ផ្តល់ធាតុចូលផ្នែកធនធនមនុស្ស និងការគាំទ្រជំនួយបច្ចេកទេស ដែលចាំបាច់សម្រាប់ការអនុវត្តគម្រោងសាកល្បង។

តារាងទី ៥ បង្ហាញពីតម្រូវការ ធាតុចូលពីស្ថាប័នដៃគូទាំង ០៦ ដើម្បីអនុវត្តសកម្មភាពសាកល្បងណាដែលបានព្រមព្រៀងគ្នារួមគ្នា។

**តារាងទី ៥៖ ធាតុចូលសំខាន់ៗដែលត្រូវការពីដៃគូនៅក្នុងសកម្មភាពអនុវត្តសាកល្បងដែលត្រូវបានស្នើឡើងទាំង ០៥**

| ស្ថាប័នដៃគូ | អភិបាលកិច្ច | បច្ចេកវិទ្យា/ប្រព័ន្ធ | សេវាប្រមូលសំណល់គ្របដណ្តប់ទាំងស្រុង/កន្លែងចាក់សំរាម | វិស័យក្រៅប្រព័ន្ធ | ការអប់រំ/ការលើកកម្ពស់ការយល់ដឹង |
|---|---|---|---|---|---|
| ក.ជ.អ.ច. | | | | ✓ | ✓ |
| ក្រសួងបរិស្ថាន/នាយកដ្ឋានគ្រប់គ្រងសំណល់រឹង | ✓ | ✓ | ✓ | | |
| ក្រសួងមហាផ្ទៃ/គ.ជ.អ.ប | ✓ | | | ✓ | ✓ |
| ខេត្តកែប | | | ✓ | ✓ | ✓ |
| ក្រុងកែប | | ✓ | ✓ | ✓ | ✓ |
| អង្គការមូលនិធិអាស៊ី | ✓ | ✓ | ✓ | ✓ | ✓ |

# ៥. ការផ្តោតការយកចិត្តទុកដាក់លើកំណែទម្រង់គោលនយោបាយ

ស្របតាមគោលបំណងនៃសកម្មភាពសាកល្បងដែលលើកឡើងខាងក្រោមនេះ ជាអនុសាសន៍គោលនយោបាយមួយចំនួន ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា។ អនុសាសន៍ទាំងនេះ ត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមសំខាន់ៗក្នុងការគ្រប់គ្រងសំណល់ដែលត្រូវបានកំណត់រកឃើញក្នុងខេត្តកែប និងត្រូវកែសម្រួលបន្ថែមទៀត ផ្អែកតាមលទ្ធផលនៃសកម្មភាពសាកល្បងនីមួយៗ។ អនុសាសន៍ទាំងនេះ ឆ្លើយតបចំពោះគោលបំណងជាច្រើនក្នុងពេលជាមួយគ្នា ប៉ុន្តែ ផ្តោតជុំវិញទស្សនទានជាមូលដ្ឋានមួយចំនួន ដូចជា ការអភិវឌ្ឍបៃតង និរន្តរភាពបរិស្ថាន សេដ្ឋកិច្ចចក្រា ការលើកកម្ពស់ជីវភាពរស់នៅ និងប្រសិទ្ធភាពចំណាយ។

សកម្មភាពសាកល្បងសំខាន់ៗ ដែលពាក់ព័ន្ធជាមួយនឹងទស្សនទាននីមួយៗរួមមាន៖

១. **ពង្រឹង ការិយាល័យសាធារណៈការ ដឹកជញ្ជូន អនាម័យបរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ ក្នុងរដ្ឋបាលក្រុងកែប៖** សកម្មភាពនេះ មានគោលបំណងពង្រឹងគណនេយ្យភាពរបស់អាជ្ញាធរក្រុងលើការគ្រប់គ្រងសំណល់នៅមូលដ្ឋាន ជាមួយគ្នានឹងការផ្តល់លទ្ធភាពបង្កើនការយល់ដឹងរបស់មន្ត្រីក្រុងពីប្រតិបត្តិការគ្រប់គ្រងសំណល់រឹង។ សកម្មភាពនេះ ជាការផ្តោតផងដែរលើការធានានូវភាពជោគជ័យនៃការផ្ទេរតួនាទីត្រួតពិនិត្យសេវាគ្រប់គ្រងសំណល់ទៅឱ្យអាជ្ញាធរក្រុងកែប ជាពិសេសការិយាល័យដែលទើបបង្កើតថ្មី ឱ្យមានចំនួនមន្ត្រី និងថវិកាគ្រប់គ្រាន់។
*សកម្មភាពសាកល្បងនៅក្រោម៖ អភិបាលកិច្ច*

២. **រៀបចំប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីគាំទ្រការធ្វើវិមជ្ឈការ និងការកែលំអប្រតិបត្តិការគ្រប់គ្រងសំណល់រឹងតាមរយៈការផ្តោតលើការគ្រប់គ្រងទិន្នន័យ៖** ដើម្បីធានាប្រសិទ្ធភាពប្រតិបត្តិការ និងដំណើរការប្រព័ន្ធឱ្យបានរឹងមាំ ចាំបាច់ត្រូវយកចិត្តទុកដាក់បន្ថែមលើប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ។ គួរមានការផ្តោតការយកចិត្តទុកដាក់បែបនេះលើប្រតិបត្តិការគ្រប់គ្រង ដូចជា ការបំពេញការងារផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាលរបស់អង្គភាពគ្រប់គ្រងសំណល់ ដោយធ្វើការសម្របសម្រួលជាមួយនឹងស្ថាប័នដែលធ្វើការត្រួតពិនិត្យនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជាផ្សារភ្ជាប់ទំនាក់ទំនងជាមួយការពិនិត្យតាមដានប្រតិបត្តិការគ្រប់គ្រងសំណល់រឹងនៅក្នុងមូលដ្ឋានផងដែរ។ ការស្វែងយល់ឱ្យបានគ្រប់ជ្រុងជ្រោយពីប្រភេទសំណល់ និងបរិមាណសំណល់ មានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ការរៀបចំផែនការប្រតិបត្តិការ និងការវិនិយោគ ព្រមទាំងការធ្វើសេចក្តីសម្រេចចិត្តក្នុងការគ្រប់គ្រងសំណល់ ជាពិសេស ដើម្បីកំណត់ពីរបៀបគ្រប់គ្រងប្រភេទសំណល់ផ្សេងៗគ្នា។
*សកម្មភាពសាកល្បងនៅក្រោម៖ អភិបាលកិច្ច*

៣. **កំណត់ពីធនធានដែលចាំបាច់ ដើម្បីសម្រេចគោលដៅនៃការគ្រប់គ្រងសំណល់រឹងទីក្រុង និងរៀបចំយុទ្ធសាស្ត្របង្កើនចំណូល ដើម្បីឆ្លើយតបចំពោះតម្រូវការចាំបាច់៖** ស្របគ្នានឹងការពង្រឹងការយកចិត្តទុកដាក់លើការពិនិត្យតាមដាន និងវាយតម្លៃ អាជ្ញាធរដែលពាក់ព័ន្ធក្នុងខេត្ត និងក្រុងកែប ត្រូវធានាឱ្យមានការផ្តល់ធនធានឱ្យបានគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការសម្រេចគោលបំណងនៃការគ្រប់គ្រងសំណល់តាមរយៈភាពដៃគូនៅមូលដ្ឋាន។ នេះតម្រូវឱ្យមានការវិភាគលើជម្រើសយន្តការផ្តល់ថវិកា គាំទ្រដល់ប្រតិបត្តិការគ្រប់គ្រងសំណល់រឹង។ នាពេលបច្ចុប្បន្ន ប្រតិបត្តិការនៅក្នុងខេត្តកែបពឹងអាស្រ័យលើការប្រមូលថ្លៃសេវាគ្រប់គ្រងដោយប្រតិបត្តិករវិស័យឯកជនដែលនាំឱ្យសេវាប្រមូលសំរាមនេះ ផ្តោតការយកចិត្តទុកដាក់ភាគច្រើនលើតម្រូវការរបស់ សហគ្រាសពាណិជ្ជកម្មដែលជាអ្នកបង្កើតសំរាមក្នុងទ្រង់ទ្រាយធំ។ ដើម្បីយកចិត្តទុកដាក់ឱ្យបានគ្រប់គ្រាន់លើការគ្រប់គ្រងសំណល់នៅថ្នាក់សហគមន៍ ថវិកាសម្រាប់ប្រតិបត្តិការសំណល់ចាំបាច់ត្រូវមានការពង្រីក និងស្វែងរកបន្ថែមពីប្រភពផ្សេងៗ។
*សកម្មភាពសាកល្បងនៅក្រោម៖ អភិបាលកិច្ច*

៤. **សាកល្បងគំរូភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន ដែលរួមបញ្ចូលការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច ដើម្បីគាំទ្រការញែកសំរាមនៅប្រភពដើមផ្ទាល់ដែលជាផ្នែកមួយនៃសេដ្ឋកិច្ចចក្រា៖** គម្រោងលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច ត្រូវបានរកឃើញថា មានប្រសិទ្ធភាពក្នុងការបង្កើនការចូលរួមក្នុងការញែកសំណល់។ រដ្ឋបាលក្រុងកែប អាចទទួលបានលទ្ធផលនេះ តាមរយៈការអនុវត្តគំរូសាកល្បងដែលមានឈ្មោះថា ធនាគារសំណល់។ ប្រជាពលរដ្ឋ អាចទទួលបានការទូទាត់ជាសាច់ប្រាក់ពីសំរាមស្ងួត (ប្លាស្ទិក លោហៈ និងអាលុយមីញ៉ូមជាដើម) ដែលបានយកទៅដាក់នៅធនាគារ។ គំរូមួយទៀត គឺជាការដាក់បញ្ចូលកម្មករក្រៅប្រព័ន្ធទៅក្នុងប្រព័ន្ធគ្រប់គ្រងសំណល់ដែលមានស្រាប់។ ការខិតខំប្រឹងប្រែងប្រមូលសំរាមរបស់កម្មករក្នុងវិស័យក្នុង និងក្រៅប្រព័ន្ធ អាចកាត់បន្ថយបរិមាណសំរាមនៅទីលានចាក់សំរាមក្នុងខេត្តកែប ព្រមទាំងជួយគាំទ្រដល់ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋងាយរងគ្រោះផងដែរ។ រដ្ឋបាលក្រុងកែប គួរតែបង្កើតកន្លែងប្រមូលសំរាមស្ងួតដែលអាចកែច្នៃបាន និងធ្វើការងារជាមួយនឹងវិស័យក្រៅប្រព័ន្ធ ដើម្បីបង្កើតគំរូសហការគ្នាសម្រាប់ការប្រមូល និងលក់សំណល់ ដែលអាចកែច្នៃបានទៅជាផលិតផលថ្មី និងប្រភពនៃថាមពល។ ភាពជាដៃគូជាមួយដេប៉ូទិញ-លក់អេតចាយ និង/ឬវិស័យឯកជន គួរតែជាផ្នែកមួយនៃគំរូសាកល្បងទាំងពីរផងដែរ ដើម្បីបញ្ជូនសំណល់ទៅកាន់កន្លែងកែច្នៃសំណល់។
*សកម្មភាពសាកល្បងនៅក្រោម៖ ការអប់រំ និងការយល់ដឹង និងតួនាទីរបស់វិស័យក្រៅប្រព័ន្ធ*

៥. **បង្កើតភាពជាដៃគូ ដើម្បីសាកល្បងការផលិតជីវឧស្ម័នពីសំណល់សរីរាង្គពីផ្សារនៅខេត្តកែបតាមរយៈការបំបែកដោយគ្មានអុកស៊ីសែន ( Anaerobic Digestion ) ដែលអាចបញ្ចៀសសំណល់សរីរាង្គចេញពីទីលានចាក់សំរាមចុងក្រោយ និងធ្វើការសិក្សាសមិទ្ធិលទ្ធភាពនៃការធ្វើជីកំប៉ុស្តនៅនឹងប្រភពសំណល់ផ្ទាល់៖** ទីផ្សារ និងកន្លែងផ្តល់សេវាអាហារ រួមទាំងកន្លែងកែច្នៃអាហារផ្សេងទៀត បង្កើតបានសំណល់សរីរាង្គក្នុងបរិមាណដ៏ច្រើន។ សំណល់សរីរាង្គ អាចប្រើប្រាស់ជាវត្ថុធាតុដើមសម្រាប់ដំណើរការឡជីវឧស្ម័ន ដែលជាដំណើរការមួយជួយកាត់បន្ថយបរិមាណសំរាមក្នុងពេលជាមួយគ្នាអាចជួយផលិតជីវឧស្ម័នបានផងដែរ។ ទីផ្សារក្នុងក្រុងកែប ផ្តល់ឱកាសសាកល្បងគំនិតផ្តួចផ្តើមនេះជាមួយនឹង កម្មវិធីឡជីវឧស្ម័នជាតិ ដើម្បីគាំទ្រដល់និរន្តរភាពក្នុងការធ្វើប្រព្រឹត្តិកម្មសំណល់រឹងក្នុងក្រុងកែប។ សំណល់សរីរាង្គ ក៏ជាឱកាសមួយទៀតសម្រាប់ធ្វើជីកំប៉ុស្តសម្រាប់ប្រើប្រាស់ក្នុងវិស័យកសិកម្ម។ ក្រុងកែប គួរតែធ្វើការវាយតម្លៃសមិទ្ធិលទ្ធភាពសម្រាប់ការធ្វើជីកំប៉ុស្តនៅនឹងកន្លែងផ្ទាល់នៅក្នុងតំបន់ដែលមិនទទួលបានការផ្តល់សេវាប្រមូលសំរាម។
*សកម្មភាពសាកល្បងនៅក្រោម៖ បច្ចេកវិទ្យា និងប្រព័ន្ធបែបវិមជ្ឈការ*

៦. **បង្កើតផែនទីបង្ហាញផ្លូវដើម្បីសម្រេចឱ្យបាននូវការប្រមូលសំរាមទូទាំងខេត្តកែប៖** ការពង្រីកការគ្របដណ្តប់នៃការប្រមូលសំរាមឱ្យបានទាំងស្រុង មានសារៈសំខាន់ ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមនៃការគ្រប់គ្រងសំណល់ដែលខេត្តកែបកំពុងជួបប្រទះ។ ការជំរុញឱ្យមានការប្រមូលសំរាមទូទាំងខេត្តបែបនេះ នឹងជួយឱ្យរដ្ឋបាលខេត្តកែប អាចឆ្លើយតបចំពោះបញ្ហានៃការដុតសំរាមពាសវាលពាសកាល និងបញ្ហាកើនឡើង ប្លាស្ទិកក្នុងសមុទ្រផងដែរ។ ការកំណត់គោលដៅច្បាស់លាស់ និងជំហានដែលចាំបាច់ ជាមាគ៌ាបង្ហាញផ្លូវយ៉ាងច្បាស់ ដើម្បីឈានទៅសម្រេចគោលដៅ។
*សកម្មភាពសាកល្បងនៅក្រោម៖ សេវាប្រមូលសំរាមគ្របដណ្តប់ទាំងស្រុង និងកែលំអទីលានចាក់សំរាម*

៧. **រៀបចំផែនការសកម្មភាព ដើម្បីធានាឱ្យមានទីលានចាក់សំរាមត្រឹមត្រូវ និងកែលំអប្រតិបត្តិការដោយវិធីសាស្ត្រ ដែលចំណាយទាប ដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថាន៖** ខេត្តកែប គួរតែផ្តោតការយកចិត្តទុកដាក់លើការកែលំអប្រតិបត្តិការនៅទីលានចាក់សំរាម។ ផ្លូវចូលទៅកាន់ទីលាននេះគួរតែជួសជុល និងការប្រតិបត្តិការ គួរតែផ្លាស់ប្តូរតាមរយៈការកាត់បន្ថយការដុតសំរាម ការទុកដាក់សំរាមឱ្យបានសមស្រប និងការប្រើប្រាស់សម្ភារសម្រាប់គ្របសំរាមជាប្រចាំ ដើម្បីជួយកាត់បន្ថយផលប៉ះពាល់បរិស្ថាន។
*សកម្មភាពសាកល្បងនៅក្រោម៖ សេវាប្រមូលសំរាមគ្របដណ្តប់ទាំងស្រុង និងកែលំអទីលានចាក់សំរាម*

៨. **គាំទ្រដល់ការអនុវត្តគំនិតផ្តួចផ្តើមបង្កើនការយល់ដឹង ដើម្បីអប់រំប្រជាពលរដ្ឋពីសារៈសំខាន់នៃការចោលសំរាមឱ្យបានត្រឹមត្រូវ ផលប៉ះពាល់ទៅលើសុខភាព និងបរិស្ថានដែលបង្កឡើងដោយសារការដុតសំរាម និងការផាកពិន័យចំពោះករណីចោលសំរាមពុំបានត្រឹមត្រូវ៖** មានតែតាមរយៈការគាំទ្រ និងការជំរុញឱ្យមានការចូលរួមពីប្រជាពលរដ្ឋនៅមូលដ្ឋានតែប៉ុណ្ណោះ ដែលអាចធ្វើឱ្យមានភាពជឿនលឿនពិតប្រាកដឆ្ពោះទៅរកការកែលំអការគ្រប់គ្រងសំណល់។ ការបង្ហាញពីសញ្ញាយ៉ាងរឹងមាំរបស់អ្នកដឹកនាំនៅមូលដ្ឋាន គឺជាការបង្ហាញពីការប្តេជ្ញាចិត្តអនុវត្តសកម្មភាព ដើម្បីផ្សព្វផ្សាយសារនេះ ។ សកម្មភាពទាំងនេះ អាចរួមមានការរៀបចំយុទ្ធនាការសម្អាតឆ្នេរ ដោយមានការដឹកនាំពីមន្ត្រីនៅមូលដ្ឋាន ការរៀបចំព្រឹត្តិការណ៍ផ្សារភ្ជាប់ជាមួយនឹងការញែកសំរាម ការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ឬការប្តេជ្ញាមិនដុតសំរាមតាមទីវាល និងមិនចោលសំរាមខុសច្បាប់ជាដើម។
*សកម្មភាពសាកល្បងនៅក្រោម៖ ការអប់រំ និងការយល់ដឹង*

# ៦. សន្និដ្ឋាន

លក្ខណៈប្រជាសាស្ត្រ និន្នាការឈានឡើងនៃកំណើនសេដ្ឋកិច្ច និងកំណើនវិស័យទេសចរណ៍ ដើរតួនាទីសំខាន់ ក្នុងការព្យាករណ៍ទុកពីសេចក្តីត្រូវការក្នុងការគ្រប់គ្រងសំណល់នាពេលអនាគតក្នុងខេត្តកែប។ ចន្លោះខ្វះខាតក្នុងការឆ្លើយតបចំពោះសេចក្តីត្រូវការរបស់វិស័យសំណល់នាពេលបច្ចុប្បន្ន បង្កឱ្យមានបញ្ហាប្រឈមគួរឱ្យកត់សម្គាល់រួចទៅហើយ។

ថ្វីបើនៅមានសំណួរជាច្រើនក្តី យើងសង្កេតឃើញយ៉ាងច្បាស់ថា បញ្ហាប្រឈមដ៏ធំបំផុតមួយក្នុងការកែលំអការគ្រប់គ្រងសំណល់ក្នុងខេត្តកែប ពុំមែនជាបញ្ហាប្រឈមផ្នែកបច្ចេកវិទ្យានោះទេ ផ្ទុយទៅវិញ គឺជាបញ្ហាប្រឈមផ្នែកអភិបាលកិច្ចនៃវិស័យនេះ។ បញ្ហាប្រឈមផ្នែកអភិបាលកិច្ចដ៏លើសលប់ទាំងអស់នេះ ជាលទ្ធផលធ្វើឱ្យភាពមិនច្បាស់លាស់ផ្នែកថវិកា និងដែនសមត្ថកិច្ចគ្រប់គ្រង ក៏ដូចជាសញ្ញានៃការភាន់ច្រលំ ថាតើ សមត្ថកិច្ចកម្រិតណាខ្លះ ថ្នាក់ជាតិ ថ្នាក់ខេត្ត ឬថ្នាក់ក្រុង ដែលគោរពតាមបទដ្ឋានគតិយុត្តិនាពេលបច្ចុប្បន្ន ឬថាតើ ជាក់ស្តែងសមត្ថកិច្ច ផ្អែកទៅលើការអនុវត្តនាពេលកន្លងមកតែប៉ុណ្ណោះ ឬយ៉ាងណា។

ចំណុចសំខាន់ៗមួយចំនួនដែលត្រូវផ្តោតការយកចិត្តទុកដាក់ដើម្បីដោះស្រាយបញ្ហាអភិបាលកិច្ចទាំងអស់នេះ រួមមាន៖

- ការអនុវត្តវិមជ្ឈការឱ្យបានពេញលេញនិងអនុលោមតាមទាំងស្រុងជាមួយអនុក្រឹត្យលេខ ១១៣ ស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន។
- ការកសាងសមត្ថភាពរបស់មន្ត្រីមូលដ្ឋាន ដើម្បីឱ្យគាត់អាចប្រកាន់ខ្ជាប់នូវការទទួលខុសត្រូវរបស់ខ្លួនក្នុងការគ្រប់គ្រងសំណល់ប្រកបដោយប្រសិទ្ធភាព។
- ការអភិវឌ្ឍយន្តការដែលជួយធានាលំហូរធនធានសម្រាប់ការវិនិយោគចាំបាច់ក្នុងវិស័យនេះ។
- ការបង្កើតក្របខ័ណ្ឌដ៏រឹងមាំ ក្នុងនោះរួមមានទាំងវិធានការសម្រាប់ ការពិនិត្យតាមដាន និងវាយតម្លៃ និងការប្រមូលទិន្នន័យ ដែលអនុញ្ញាតឱ្យអាចតាមដានលទ្ធផលនៃការអនុវត្តការងារ។

ចំណុចខ្លាំងរបស់ការសិក្សានេះ គឺជាការនាំយកទស្សនទានចម្រុះជាច្រើនពីស្ថាប័នរដ្ឋាភិបាលជាច្រើន ដែលស្ថាប័ននីមួយៗចូលរួមចំណែកតាមវិធីផ្សេងៗគ្នាចំពោះការបំពេញមុខងាររបស់ប្រព័ន្ធគ្រប់គ្រងសំណល់រឹងនៅទូទាំងប្រទេសកម្ពុជា។ ការផ្តួចផ្តើមគំនិតនេះ ផ្អែកលើការចូលរួមរបស់រដ្ឋាភិបាលទាំង ០៣ ថ្នាក់ ពោលគឺថ្នាក់ក្រុង ថ្នាក់ខេត្ត និងថ្នាក់ជាតិ រួមជាមួយការគាំទ្ររបស់អង្គការអន្តរជាតិ ពោលគឺ អង្គការមូលនិធិអាស៊ី។

ការវិភាគក្នុងរបាយការណ៍នេះ បានផ្តល់នូវចំណុចចាប់ផ្តើមសម្រាប់កិច្ចពិភាក្សាក្នុងការឆ្លើយតបចំពោះបញ្ហាប្រឈមនានាក្នុងការគ្រប់គ្រងសំណល់រឹង រួមទាំងបញ្ហាប្រឈមផ្នែកអភិបាលកិច្ចដែលក្រុងកែបជួបប្រទះ និងបានបង្ហាញផ្លូវឆ្ពោះទៅមុខជាច្រើនដែលអាចយកទៅអនុវត្តបាននៅទីក្រុងផ្សេងទៀតក្នុងប្រទេសកម្ពុជា។

# ឧបសម្ព័ន្ធ ១៖ ការសិក្សាឯកសារពាក់ព័ន្ធមុនការចុះប្រមូលទិន្នន័យ

**គម្រោង៖ គោលនយោបាយ និងការធ្វើផែនការស្តីពីការគ្រប់គ្រងសំណល់រឹងទីប្រជុំជនសម្រាប់ខេត្តកែប**

ខែមីនា ឆ្នាំ ២០១៩

| | |
|---|---|
| **ដៃគូ៖** | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួងបរិស្ថាន លេខាធិការរដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| **គាំទ្រដោយ៖** | អង្គការមូលនិធិអាស៊ី |
| **រៀបចំដោយ៖** | Christopher Godlove, THINKCities |

## *ការសិក្សាឯកសារពាក់ព័ន្ធមុនការចុះប្រមូលទិន្នន័យ*

### ១. សេចក្តីផ្តើម

អង្គការមូលនិធិអាស៊ី កំពុងធ្វើការងារជាដៃគូជាមួយ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព លើការសិក្សាមួយ ដោយផ្តោតការយកចិត្តទុកដាក់លើការគ្រប់គ្រងសំណល់រឹងក្នុងក្រុងកែប។ ការសិក្សានេះ ត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបបញ្ហាប្រឈមក្នុងការកែលំអការអនុវត្ត និងប្រព័ន្ធគ្រប់គ្រងសំណល់រឹងទីប្រជុំជន នៅក្នុងក្រុងមានទំហំតូច និងមធ្យម ដូចជាក្រុងកែបជាដើម។ ទីប្រឹក្សាជាតិពីររូប និងទីប្រឹក្សាអន្តរជាតិមួយរូប នឹងធ្វើការសិក្សារួមគ្នាជាមួយអ្នកតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា និងបុគ្គលិករបស់អង្គការមូលនិធិអាស៊ី។

ឯកសារ "ការសិក្សាឯកសារពាក់ព័ន្ធមុនការចុះប្រមូលទិន្នន័យ" នាពេលនេះ ត្រូវបានធ្វើឡើងដើម្បីជួយសម្រួលដល់ការយល់ដឹងពីគោលនយោបាយ អភិបាលកិច្ច ហេដ្ឋារចនាសម្ព័ន្ធ ធនធាន ការធ្វើផែនការ សមត្ថភាព និងលិខិតបទដ្ឋានគតិយុត្តិដែលនឹងជះឥទ្ធិពលដល់ការគ្រប់គ្រងសំណល់រឹងក្នុងខេត្តកែបនាពេលបច្ចុប្បន្ននេះ និងនៅពេលអនាគត។ ក្នុងអំឡុងដំណាក់កាលទីពីរនៃគម្រោងនេះ ក្រុមការងារ នឹងធ្វើទស្សនកិច្ចផ្ទាល់ទៅខេត្តកែប ដែលជាឱកាសសម្រាប់ការសិក្សាពីការអនុវត្ត និងស្ថានភាពក្នុងការគ្រប់គ្រងកាកសំណល់ដោយផ្ទាល់ និងដើម្បីប្រមូលព័ត៌មានបន្ថែមទៀតស្តីពីការគ្រប់គ្រងសំណល់រឹងក្នុងមូលដ្ឋាន។

#### *១.១. សាវតារ*

កិច្ចពិភាក្សាជាមួយ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួងបរិស្ថាន បានផ្តោតការយកចិត្តទុកដាក់លើការស្តាបនាបន្ថែមលើបទពិសោធន៍របស់ខេត្តកែបក្នុងការគ្រប់គ្រងសំណល់ ដើម្បីបង្កើតឱ្យមានគំរូ ទីក្រុងបៃតង និងដើម្បីគាំទ្រដល់កិច្ចខិតខំក្នុងការធ្វើផែនការយុទ្ធសាស្ត្រសម្រាប់ទីក្រុងគោលដៅ ដែលត្រូវបានធ្វើឡើងដោយវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសាកល។ បន្ថែមលើការទទួលស្គាល់ពីសំណាក់សហគមន៍អាស៊ានក្នុងឆ្នាំ២០១៧ ថាក្រុងកែប ជាទីក្រុងមាននិរន្តរភាពផ្នែកបរិស្ថាន បទពិសោធន៍របស់ក្រុងកែប ត្រូវបានយកគេចាប់អារម្មណ៍យ៉ាងខ្លាំង សម្រាប់យកទៅប្រើប្រាស់ជាគំរូដល់ក្រុងគោលដៅដទៃទៀត ក្នុងការធ្វើការវាយតម្លៃលើយុទ្ធសាស្ត្រគ្រប់គ្រងសំណល់នាពេលអនាគត។




*រូបភាពទី ១៖ យុទ្ធនាការលើកកម្ពស់ការយល់ដឹងស្តីពីការញែកសំរាមនៅទីប្រភព* (Heng, 2017)

ទិដ្ឋភាពសំខាន់ៗជាច្រើនដែលទាមទារឱ្យមានការយកចិត្តទុកដាក់ និងដែលត្រូវបានលើកឡើងពីសំណាក់អាជ្ញាធរ រួមមាន៖

- ការកែច្នៃសំណល់/ការទាញយកធនធានមកប្រើប្រាស់វិញ
- ការផ្លាស់ប្តូរអាកប្បកិរិយា
- ការចូលរួមពីអាជីវកម្ម និងវិស័យទេសចរណ៍
- ទីភ្នាក់ងារប្រមូលសំណល់
- ការផលិតជីកំប៉ុស្ត
- សមាហរណកម្មទីលានចាក់សំរាម
- ការយកចិត្តទុកដាក់ពិសេសចំពោះការគ្រប់គ្រងសំណល់ក្នុងទីផ្សារ និងក្នុងតំបន់ឧស្សាហកម្ម។

ទិដ្ឋភាពចាំបាច់មួយទៀត គឺការវាយតម្លៃលើឥទ្ធិពលនៃវិមជ្ឈការមកលើការគ្រប់គ្រងសំណល់នៅខេត្តកែប និងសហគមន៍នានាដែលមានលក្ខណៈដូចខេត្តកែប និងការបង្កើតគំរូការគ្រប់គ្រងសំណល់ដែលមានលក្ខណៈសព្វជ្រុងជ្រោយ និងឆ្លើយតបចំពោះចំណុចខ្សោយរបស់ប្រព័ន្ធនាពេលបច្ចុប្បន្នផងដែរ។

## ១.២. គោលបំណងនៃការកំណត់ក្របខ័ណ្ឌការងារ

គោលបំណងរបស់ការសិក្សានេះ គឺដើម្បីអភិវឌ្ឍការយល់ដឹងពីការអនុវត្តក្នុងការគ្រប់គ្រងសំណល់ និងសេចក្តីត្រូវការនាពេលអនាគតក្នុងក្រុងកែប។ គោលបំណងទាំងអស់នេះ ត្រូវបានតាក់តែងឡើង ដើម្បីពង្រឹងការយល់ដឹងរបស់ដៃគូគម្រោង ក៏ដូចជារបស់មន្ត្រីក្រុងកែប និងអ្នកពាក់ព័ន្ធក្នុងសហគមន៍ផងដែរ។ កិច្ចពិភាក្សា នឹងមានការចូលរួមពីអ្នកពាក់ព័ន្ធផ្សេងៗជាច្រើន រាប់ចាប់តាំងពីមន្ត្រីគ្រប់កម្រិត វិស័យឯកជន និងអាជីវកម្ម ព្រមទាំងអ្នកធ្វើការងារផ្នែកសំណល់ក្នុងវិស័យក្រៅប្រព័ន្ធ។

គោលបំណងជាក់លាក់ រួមមាន៖

- ស្វែងយល់ពីលំនាំនៃការបង្កើតសំណល់រឹងក្នុងតំបន់គោលដៅក្នុងខេត្តកែប រួមទាំងការបោះចោលសំណល់នៅទីលានចាក់សំរាម ការបោះចោលសំណល់ដោយខុសច្បាប់ និងការដុតសំណល់
- បង្កើនការយល់ដឹងពីលំនាំ និងប្រសិទ្ធផលនៃការប្រមូលសំរាម
- ស្វែងយល់ពីកត្តានានាដែលជះឥទ្ធិពលលើអាកប្បកិរិយារបស់គ្រួសារ និងអាជីវកម្មក្នុងមូលដ្ឋានទាក់ទងជាមួយការចោលសំណល់
- ស្វែងយល់ពីសារៈសំខាន់នៃតួនាទីយេនឌ័រនៅក្នុងការគ្រប់គ្រងសំណល់
- ស្វែងយល់ពីវិធានការ (គោលនយោបាយ និង/ឬលិខិតបទដ្ឋានគតិយុត្តិ និង/ឬការផ្តួចផ្តើមគំនិត និងវិធានការនៅថ្នាក់ខេត្ត) ដែលដំណើរការបានល្អ/មិនបានល្អ ព្រមទាំងកិច្ចខិតខំនាពេលកន្លងមកដែលត្រូវបានធ្វើឡើង ដើម្បីកែលំអស្ថានភាពឱ្យប្រសើរឡើង។

ការសិក្សា ក៏មានគោលបំណងស្វែងយល់ថាតើអាជ្ញាធរ និងអ្នកពាក់ព័ន្ធនានាក្នុងការគ្រប់គ្រងសំណល់ធ្វើការរួមគ្នាយ៉ាងដូចម្តេច និងកំណត់រកថាតើតួនាទី និងទំនាក់ទំនង គួរត្រូវបានពង្រឹងបន្ថែមទៀតដោយរបៀបណា ដើម្បីធានាឱ្យប្រព័ន្ធមានការអភិវឌ្ឍប្រសើរឡើង។ បន្ទាប់ពីការសិក្សាឯកសារពាក់ព័ន្ធ និងទស្សនកិច្ចទៅទីតាំងផ្ទាល់ ព័ត៌មាន និងការវិភាគ នឹងត្រូវបានប្រើប្រាស់ជាធាតុចូលដើម្បីរៀបចំឯកសារសង្ខេបគោលនយោបាយ ដែលអាចត្រូវបានពិចារណានៅថ្នាក់ជាតិ ជាកិច្ចគាំទ្រដល់ការកែលំអការគ្រប់គ្រងសំណល់ទាំងមូលឱ្យបានកាន់តែប្រសើរឡើង។

## ១.៣. វិមជ្ឈការ និងការគ្រប់គ្រងសំណល់

ដំណើរការកំណែទម្រង់វិមជ្ឈការ បានចាប់ផ្តើមក្នុងប្រទេសកម្ពុជានៅដើមទសវត្សរ៍ឆ្នាំ២០០០ ដើម្បីពិនិត្យកែសម្រួលឡើងវិញលើទំនាក់ទំនងរវាងអាជ្ញាធរថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន និងបានជះឥទ្ធិពលលើការផ្តល់សេវានានាក្នុងទីប្រជុំជន។ នៅក្នុងវិស័យសំណល់ វិមជ្ឈការ បានធ្វើឱ្យការងារប្រមូល និងចោលសំណល់ភាគច្រើន ត្រូវបានជួលទៅឱ្យក្រុមហ៊ុនឯកជនដោយក្នុងនោះ ក្រុមហ៊ុនស៊ីនទ្រី ដែលជាប្រតិបត្តិករប្រមូលសំណល់ក្នុងក្រុងភ្នំពេញ គឺជាក្រុមហ៊ុនលេចធ្លោជាងគេបំផុត។ ថ្វីបើយុទ្ធសាស្ត្រគ្រប់គ្រងសំណល់នេះ ពឹងផ្អែកយ៉ាងខ្លាំងលើជំនាញ និងភាពដែលអាចបត់បែនបានរបស់វិស័យឯកជនក្តី ប៉ុន្តែយុទ្ធសាស្ត្រនេះ ក៏បន្សល់ទុកឱ្យមានចន្លោះខ្វះខាតគួរជាទីកត់សម្គាល់លើការគ្របដណ្តប់របស់សេវា និងលើលទ្ធផលអនុវត្តការងារផ្នែកបរិស្ថានដែលនិយ័តកររដ្ឋាភិបាល មានភាពស្ទាក់ស្ទើរ ឬមិនមានសមត្ថភាពអាចដោះស្រាយបានរហូតមកដល់បច្ចុប្បន្ន។ ចន្លោះខ្វះខាតជាច្រើន គឺជាលទ្ធផលកើតចេញពីប្រព័ន្ធដែលកង្វះធនធាន និងសមត្ថភាព។ ចំណុចខ្សោយទាំងអស់នេះ ក៏បណ្តាលមកពីការកំណត់តួនាទី និងការមើលខុសត្រូវមិនបានច្បាស់លាស់ផងដែរ ដែលជាហេតុធ្វើឱ្យមានភាពអសកម្ម និងការពឹងផ្អែកលើតែប្រព័ន្ធដែលមានស្រាប់។

## ១.៤. វិធីសាស្ត្រនៃការសិក្សាឯកសារពាក់ព័ន្ធ

ដើម្បីសម្រេចគោលបំណងខាងលើ បារ៉ាម៉ែត្រ និងវិធីសាស្ត្រនៃការសិក្សា ត្រូវបានកំណត់ដូចខាងក្រោម៖

ក) តំបន់សិក្សា៖ ព្រំដែនរដ្ឋបាលសម្រាប់ការសិក្សានេះ ត្រូវបានកំណត់ថា គឺជាខេត្តកែប ដោយក្នុងនោះរួមទាំងក្រុងកែបផងដែរ។ ទីតាំងបោះចោលសំណល់ (ទីលានចាក់សំរាម និង/ឬកន្លែងចាក់សំរាម) ដែលជាផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រងសំណល់រឹងរបស់ក្រុងកែប ក៏ត្រូវបានដាក់បញ្ចូលជាផ្នែកដ៏សំខាន់នៃការយកចិត្តទុកដាក់របស់ការសិក្សានេះ។ កោះពោធិ៍ កោះទន្សាយ ក៏ជាផ្នែកនៃតំបន់សិក្សាផងដែរ។

ខ) គោលវិធីបែបគ្រប់ជ្រុងជ្រោយក្នុងការគ្រប់គ្រងសំណល់រឹង៖ អាស្រ័យដោយការចាប់អារម្មណ៍របស់រដ្ឋាភិបាលក្នុងការបង្កើតឱ្យមានគំរូដែលអាចយកទៅអនុវត្តបន្តបាន ការសិក្សានេះ នឹងពិចារណាលើគោលវិធីបែបគ្រប់ជ្រុងជ្រោយក្នុងការគ្រប់គ្រង

សំណល់រឹង ពោល ជាវិធីសាស្ត្រដែលដាក់បញ្ចូលទស្សនទានស្ដីពីសមាហរណកម្មការគ្រប់គ្រងសំណល់រឹង (ការប្រមូល ការដឹកជញ្ជូន ការកែច្នៃ ប្រព្រឹត្តិកម្ម និងការបោះចោល) បន្ថែមលើការផ្ដោតការយកចិត្តទុកដាក់លើនិរន្តរភាពផ្នែកបរិស្ថានរបស់ប្រព័ន្ធនេះ។ ការពិចារណាដទៃទៀតដែលនឹងត្រូវដាក់បញ្ចូល មានដូចជា ទិដ្ឋភាពផ្នែកសង្គមដែលពាក់ព័ន្ធជាមួយយេនឌ័រ និងអ្នកប្រមូលសំណល់ក្នុងវិស័យក្រៅប្រព័ន្ធ ព្រមទាំងការចូលរួមចំណែកផ្នែកសេដ្ឋកិច្ច និងផ្នែកបច្ចេកទេសរបស់ក្រុមទាំងពីរនេះ ទៅក្នុងការគ្រប់គ្រងសំណល់រឹងក្នុងខេត្តកែប។

គ) ប្រភពទិន្នន័យបន្ទាប់បន្សំ៖ ប្រភពទិន្នន័យបន្ទាប់បន្សំ ត្រូវបានកំណត់ក្នុងដំណាក់កាលសិក្សាឯកសារពាក់ព័ន្ធ ហើយនឹងត្រូវពង្រីកនៅពេលបានរកឃើញប្រភពព័ត៌មានថ្មីៗ។ ការស្រាវជ្រាវនិងការពិនិត្យលើឯកសារពាក់ព័ន្ធត្រូវបានធ្វើឡើងដោយអង្គការមូលនិធិអាស៊ី ចំណែកប្រភព ឯកសារបន្ថែម ត្រូវបានដាក់បញ្ចូល ដើម្បីពង្រឹងការយល់ដឹងពីក្រុងកែប។ ម្យ៉ាងទៀត ព័ត៌មានដូចជាស្ថានភាពសេដ្ឋកិច្ច ការអភិវឌ្ឍន៍ ភូមិសាស្ត្រ -ល- របស់ក្រុងដែលមានស្ថានភាព និងលក្ខណៈប្រជាសាស្ត្រស្រដៀងគ្នាជាមួយក្រុងកែប ក៏ត្រូវបានប្រមូលផងដែរ។ ទិន្នន័យនេះនឹងយកទៅប្រើប្រាស់ ដើម្បីបំពេញបន្ថែមឱ្យទិន្នន័យខ្វះខាតរបស់ក្រុងកែប ដោយដើរតួនាទីជាធាតុចូលតំណាង។ ម្យ៉ាងទៀត ការសិក្សានេះ ក៏ស្វែងយល់ពីលិខិតបទដ្ឋានគតិយុត និងក្រឹត្យច្បាប់ជាធរមានដែលមានឥទ្ធិពលលើការគ្រប់គ្រងលើសំណល់ក្នុងខេត្តកែបផងដែរ។

ឃ) ប្រភពទិន្នន័យចម្បង៖ ក្រុមការងារ នឹងចុះសិក្សានៅមូលដ្ឋានផ្ទាល់ ដើម្បីប្រមូលការយល់ឃើញ ព័ត៌មាន និងទិន្នន័យបន្ថែមពីប្រភពព័ត៌មានចម្បង តាមរយៈការសម្ភាសន៍អ្នកពាក់ព័ន្ធសំខាន់ៗ ដែលរួមមានអ្នកតំណាងរដ្ឋាភិបាល សង្គមស៊ីវិល/អង្គការក្រៅរដ្ឋាភិបាល វិស័យឯកជន ទីភ្នាក់ងារម្ចាស់ជំនួយ អ្នកសិក្សាស្រាវជ្រាវ ក៏ដូចជាអ្នកតាំងលំនៅក្នុងមូលដ្ឋាន (ម្ចាស់តូបអ្នកធ្វើអាជីវកម្មក្នុងផ្សារអ្នករស់នៅតាមលំនៅដ្ឋាន វិស័យសណ្ឋាគារ/ភោជនីយដ្ឋាន សាលារៀន។ល។)

ង) ធាតុចូលបន្ថែម៖ ក្នុងសកម្មភាពចុះទស្សនកិច្ចផ្ទាល់ នឹងមានការថតរូប ដើម្បីចងក្រងជាឯកសារពីការអនុវត្តផ្នែកការគ្រប់គ្រងសំណល់រឹង ក៏ដូចជាដើម្បីផ្ដិតយកទិដ្ឋភាពស្ដីពីស្ថានភាពផ្លូវ ឆ្នេរ សមុទ្រ ទីសាធារណៈ និងបរិក្ខារដទៃទៀតផងដែរ។ បន្ថែមលើនេះ ការសិក្សា នឹងមានការកត់សម្គាល់ពិសេសពីតួនាទីរបស់ស្ត្រី និងវិស័យក្រៅប្រព័ន្ធក្នុងការប្រមូលសំណល់ផងដែរ។ អង្គការមូលនិធិអាស៊ី បានបង្កើតឯកសារម៉ាទ្រីសដែលជួយតម្រង់ទិសការគិតគូរជុំវិញគោលបំណងរបស់ការសិក្សា។ ឯកសារនេះ នឹងដើរតួនាទីជាមូលដ្ឋានគ្រឹះសម្រាប់ការងារនាពេលខាងមុខ។

## ១.៥. គំរូ “ទីក្រុងបៃតង”

ឯកសារយោងស្ដីពី គំរូ "ទីក្រុងបៃតង" ត្រូវបានចងក្រងឡើងដើម្បីជួយសម្រួលដល់ការប្រៀបធៀប និងដំណើរការក្នុងការកំណត់ថាតើគួរកែសម្រួលយកគំរូពីខាងក្រៅយ៉ាងណាឱ្យបានល្អបំផុត សម្រាប់បរិបទប្រទេសកម្ពុជា។ ក្រុងទាំងនេះ បានបង្ហាញនូវវិធីសាស្ត្រថ្មីៗ ក្នុងការគ្រប់គ្រងសំណល់ប្រកបដោយភាពជោគជ័យដោយប្រើប្រាស់ធនធាន និងសមត្ថភាពបច្ចេកទេសដែលមានស្រាប់។ ការពិពណ៌នាដោយសង្ខេបពីគំរូនីមួយៗ រួមទាំងការពិពណ៌នាដោយសង្ខេបពីទិដ្ឋភាពនានាដែលធ្វើឱ្យគំរូទាំងនេះមានលក្ខណៈពិសេសដោយឡែកពីគេ និងបានទទួលជោគជ័យ។ ឧទាហរណ៍គំរូមួយចំនួនពីទីក្រុងក្នុងទ្វីបអាស៊ីដែលបានអនុវត្តវិធីសាស្ត្រថ្មីៗក្នុងការងារគ្រប់គ្រងសំណល់ រួមមាន៖

- *ក្រុង Alapuzzha* (រដ្ឋ Kerala, ប្រទេសឥណ្ឌា - ចំនួនប្រជាជន៖ ១៧៤.០០០ នាក់) - ក្រុងនេះ បានបង្កើតឱ្យមានយុទ្ធនាការ "ផ្ទះស្អាត ទីក្រុងស្អាត" ដែលផ្ដោតការយកចិត្តទុកដាក់លើការញែកសំណល់នៅប្រភព។ ការអនុវត្តសាកល្បងតូចមួយត្រូវបានដាក់ឱ្យអនុវត្តក្នុងភូមិមួយក្នុងចំណោមភូមិទាំង ៥២ របស់ក្រុង ក្នុងឆ្នាំ ២០១២ ហើយបន្ទាប់មកទៀត មានភូមិចំនួន ១១ ទៀត បានអនុវត្តបន្ថែម។ បរិក្ខារផលិតជីកំប៉ុស្ដ និងជីវម៉ាស ត្រូវបានបង្កើតឡើងតាមគ្រួសារ តាមរយៈមានការឧបត្ថម្ភទុនពីរដ្ឋាភិបាល ដោយក្នុងនោះ បរិក្ខារផលិតជីកំប៉ុស្ដមួយមានតម្លៃ ១៥០ រូពី (២ ដុល្លារ) កន្លែងផលិតជីវម៉ាសមួយ មានតម្លៃ ៣.៣៧៥ រូពី (៥០ ដុល្លារ)។ មជ្ឈមណ្ឌលធ្វើជីកំប៉ុស្ដខ្នាតតូច ត្រូវបានកសាងឡើងក្នុងសហគមន៍សម្រាប់គ្រួសារ ដែលមិនមានបរិក្ខារធ្វើជីកំប៉ុស្ដនៅតាមផ្ទះ (Venugopal, n.d.)។



*រូបភាពទី ២៖ បរិក្ខារធ្វើជីកំប៉ុស្ដនៅក្រុង Alappuzha*

- *ក្រុង Panaji* (រដ្ឋ Goa, ប្រទេសឥណ្ឌា - ចំនួនប្រជាជន៖ ៤០.០០០ នាក់) - Panaji ត្រូវបានបែងចែកទៅជាតំបន់គ្រប់គ្រងសំណល់ចំនួន ១២ ដោយតំបន់គ្រប់គ្រងសំណល់នីមួយៗ ស្ថិតនៅក្រោមអ្នកមើលខុសត្រូវម្នាក់។ គ្រួសារចាំបាច់ត្រូវញែកកាកសំណល់ទៅជា ៥ ចំណែក៖ សំណល់សើម ប្លាស្ទិក ក្រដាស និងកាតុង លោហៈ និងកែវ និងសំណល់មិនអាចកែច្នៃប្រើប្រាស់វិញបាន។ សំណល់សើម ត្រូវបានបញ្ជូនទៅកន្លែងធ្វើជីកំប៉ុស្ដ សំណល់ស្ងួត ត្រូវបានបញ្ជូនទៅស្ថានីយញែកសំណល់។ បញ្ហាប្រឈមពីរ គឺការគ្រប់គ្រងក្លិន

នៅទីតាំងកែច្នៃសំណល់សើម និងបរិមាណសំណល់ដែលមានការកើនឡើងកាន់តែច្រើន។ ក្រុង គិតថ្លៃសេវាប្រចាំឆ្នាំចំនួន ៣៦៥ រូពី (៥ ដុល្លារ) ពីគ្រួសារនីមួយៗ និង៣០០-១០.០០០ រូពី (៤ ទៅ ១៤៤ ដុល្លារ) សម្រាប់សណ្ឋាគារ។ ក្រុងលក់សំណល់ដែលបានញែករួចទៅឱ្យឈ្មួញ និងក្រុមហ៊ុនផលិតស៊ីម៉ង់ (Agarwal, 2017)។

- *ក្រុង Mysuru* (រដ្ឋ Karnataka, ប្រទេសឥណ្ឌា - ចំនួនប្រជាជន៖ ៩២០.០០០ នាក់) - ក្រុងនេះ ត្រូវបានជ្រើសរើសដោយសារតែដំណើរការគ្រប់គ្រងសំណល់មានច្រើនថ្នាក់របស់ខ្លួន ក្នុងនោះរួមមានការផលិតជីកំប៉ុស្តតាមបែបវិមជ្ឈការតាមសហគមន៍ និងការញែកសំណល់ជាអតិបរមានៅប្រភព។ ក្រុងនេះ កំពុងព្យាយាមឈានទៅសម្រេចគោលដៅមិនឱ្យមានសំណល់ និងដាក់កញ្ចប់ថវិកាចំនួន ៣៦.០០០ ដុល្លារ ដើម្បីបំពេញផែនការនេះ (Aravind, 2014)។
- *ក្រុង Surabaya* (រដ្ឋ Java ខាងកើត ប្រទេសឥណ្ឌូណេស៊ី – ចំនួនប្រជាជន៖ ៣,៥ លាននាក់) – ក្រុង Surabaya អនុវត្តការគ្រប់គ្រងសំណល់រឹងតាមសហគមន៍ ក្រោយពេលមានការបិទទីលានចាក់សំរាមដ៏ធំមួយដោយមិនបានគ្រោងទុក ដែលជាហេតុធ្វើឱ្យសំណល់ ត្រូវនៅគរចោលពាសពេញផ្លូវក្នុងទីក្រុង។ ការចូលរួមរបស់ពលរដ្ឋ និងអង្គការក្រៅរដ្ឋាភិបាលដែលបានទទួលការគាំទ្រពីក្រុង Kitakyushu របស់ជប៉ុន បាននាំឱ្យមានការពង្រីកកម្មវិធីនេះ និងការអភិវឌ្ឍមជ្ឈមណ្ឌលធ្វើជីកំប៉ុស្ត ស្ថានីយប្រមូលបណ្តោះអាសន្ន និងបង្កការចូលរួមពីអ្នកតាំងទីលំនៅបានកាន់តែប្រសើរ។ ធនាគារសំណល់ ក៏បានជួយសម្រួលដល់កិច្ចខិតខំក្នុងការកែច្នៃសំណល់យ៉ាងច្រើនផងដែរ តាមរយៈការបង្កឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពពីពលរដ្ឋក្នុងការញែកសំណល់នៅប្រភព (Global Covenant of Mayors for Climate & Energy, 2019)។

ការវិភាគឧទាហរណ៍របស់ក្រុង Surabaya បានបង្ហាញថា កត្តាខាងក្រោមមានលក្ខណៈចាំបាច់សម្រាប់ការយកទៅអនុវត្តបន្ត៖

- ការកសាងសមត្ថភាព៖ អ្នកពាក់ព័ន្ធទាំងអស់ បានឆ្លងកាត់ការបណ្តុះបណ្តាលដើម្បីលើកកម្ពស់ជំនាញ និងបង្កើនចំណេះដឹង
- ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន៖ រដ្ឋាភិបាលថ្នាក់ក្រុងលើកទឹកចិត្តឱ្យមានការវិនិយោគលើបរិក្ខារគ្រប់គ្រងសំណល់
- ការគាំទ្រនៅថ្នាក់ជាតិ៖ គោលនយោបាយ និងគោលការណ៍ណែនាំរបស់រដ្ឋាភិបាលថ្នាក់ជាតិ បានជួយពង្រឹង និងជួយជ្រោមជ្រែងដល់កិច្ចខិតខំបន្ថែមទៀត

***ប្រអប់ទី១៖ ការវិភាគលើឧទាហរណ៍របស់ក្រុង Surabaya***

## ២. ទិដ្ឋភាពទូទៅពីការគ្រប់គ្រងសំរាមសំណល់រឹងក្នុងក្រុងកែប

ក្រុងកែប គឺជាសហគមន៍តំបន់ឆ្នេរសមុទ្រតូចមួយ ប៉ុន្តែក៏ជាកន្លែងទេសចរណ៍ក្នុងស្រុកដ៏សំខាន់ ដែលត្រូវបានរំពឹងទុកថា នឹងរីកលូតលាស់នាពេលអនាគត។ ក្រុងកែប មានប្រជាជន ២០.០០០ នាក់ និងជាកន្លែងដែលប្រមូលផ្តុំប្រជាជនច្រើនជាងគេបំផុតក្នុងខេត្តកែប ដែលជាខេត្តមួយមានទំហំ ៣៣៦ គម² និងប្រជាជនសរុបចំនួន ៤០.២០៨នាក់។ បើគិតពីទិដ្ឋភាពផ្នែករដ្ឋបាល កោះទន្សាយ និងកោះពោធិ៍ ក៏ជាផ្នែករបស់ក្រុងកែបផងដែរ។




***រូបភាពទី ៣៖ ផែនទីរដ្ឋបាលខេត្តកែប***

### *២.១. សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ*

កែប គឺជាតំបន់មួយហាក់នៅមិនទាន់មានការអភិវឌ្ឍ និងមានសក្តានុពលដ៏ប្រសើរសម្រាប់កំណើនទេសចរណ៍ អាស្រ័យដោយខេត្តនេះនៅជាប់សមុទ្រ និងមានឧទ្យានធម្មជាតិ ព្រមទាំងដីព្រៃដ៏ច្រើនសន្ធឹកសន្ធាប់។ វិស័យអេកូទេសចរណ៍ មានភាពទាក់ទាញជាពិសេស អាស្រ័យដោយសម្រស់ធម្មជាតិ និងសភាពស្ងប់ស្ងាត់នៃឆ្នេរសមុទ្រ និងតំបន់ទេសភាព។ សកម្មភាពសេដ្ឋកិច្ចដទៃទៀតភាគច្រើនផ្តោតលើវិស័យកសិកម្ម ដូចជាផ្លែឈើ ម្រេច និងជលផល។

### *២.២. ការអនុវត្តការគ្រប់គ្រងសំណល់រឹងក្នុងក្រុងគោលដៅនៅកម្ពុជា*

ដូចការអនុវត្តទូទៅនៅកន្លែងដទៃទៀតក្នុងទ្វីបអាស៊ីដែរ ការគ្រប់គ្រងសំណល់រឹង គឺជាប្រព័ន្ធដែលមានលក្ខណៈចម្រុះទាំងទិដ្ឋភាពផ្នែកផ្លូវការផង និងក្រៅផ្លូវការផង ដោយភាគច្រើនប្រមូលផ្តុំនៅក្នុងតំបន់ទីប្រជុំជន ដោយក្នុងនោះ អត្រានៃការប្រមូលសំណល់ច្រើនមានកម្រិតទាប។ នៅក្រុងកំពត មានតែគ្រួសារ ៣៦% ប៉ុណ្ណោះ ដែលទទួលបានសេវាប្រមូលសំណល់ជាប្រចាំ (Economic and Social Commission for Asia and the Pacific,

2017)។ កង្វះការប្រមូលសំណល់នេះ ធ្វើឱ្យអ្នកតាំងលំនៅព្យាយាមស្វែងរកវិធីសាស្រ្តដទៃទៀត ដើម្បីដោះស្រាយជាមួយគំនរសំណល់ ជាហេតុធ្វើឱ្យមានការចោលសំណល់ខុសច្បាប់ និងការដុតសំណល់ ហើយជម្រើសទាំងពីរនេះ ផ្តល់ឱ្យមានផលប៉ះពាល់ផ្នែកបរិស្ថានដូចជា ដី ខ្យល់ និងធនធានទឹក និងផ្នែកសុខភាព។

កន្លែងចាក់សំរាម គឺជាជម្រើសទូទៅដែលជ្រើសរើសសម្រាប់ការទុកដាក់សំណល់ដែលប្រមូលបាន។ ប្រព្រឹត្តិកម្មសំណល់ភាគច្រើន គឺមានត្រឹមតែការញែកសំណល់លក្ខណៈគ្រួសារ ដើម្បីយកទៅលក់ឱ្យឈ្មួញកណ្តាលប៉ុណ្ណោះ (Min, 2016)។ វិស័យក្រៅប្រព័ន្ធ ក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រមូលធនធានមានតម្លៃដូចជាដប PET លោហៈ និងអាលុយមីញ៉ូមជាដើម។

សំណល់សរីរាង្គ មានបរិមាណច្រើនគួរកត់សម្គាល់ នៅគ្រប់ក្រុងទាំងអស់របស់កម្ពុជា ប៉ុន្តែសំណល់នេះ កម្រត្រូវបានកែច្នៃណាស់ ជាហេតុធ្វើឱ្យសំណល់ទាំងនេះ ត្រូវបានគេយកទៅចោលនៅកន្លែងចាក់សំរាមដែលបង្កើតឱ្យមានឧស្ម័នមេតាន និងបង្កើតឱ្យមានទឹកហៀរចេញពីសំរាម ជ្រាបចូលទៅក្រោមដី និងលើដី។

## ២.៣. ទិន្នន័យស្តីពីសំណល់រឹងនៅខេត្តកែប និងក្រុងគោលដៅដទៃទៀត

ទិន្នន័យពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹងទីប្រជុំជនក្នុងប្រទេសកម្ពុជា នៅមានការខ្វះខាត ដោយសារធនធានសម្រាប់ការគ្រប់គ្រងសំណល់ មានកម្រិត ព្រមទាំងការខ្វះខាតឧបករណ៍ដើម្បីវាស់វែងលទ្ធផលអនុវត្តការងារប្រមូល និងចោលសំណល់។ ដើម្បីគណនាបរិមាណសំរាមចូលមកក្នុងទីលានចាក់សំរាមឱ្យបានសុក្រឹតយ៉ាងហោចណាស់ ត្រូវមានឧបករណ៍មួយចំនួន ដូចជាជញ្ជីងថ្លឹង ហើយទាំងអស់នេះ ទាមទារនូវធនធានហិរញ្ញវត្ថុ ព្រមទាំងប្រតិបត្តិករដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ។

ដោយសារកង្វះខាតទិន្នន័យ និងដើម្បីផ្តល់ជាក្របខ័ណ្ឌការងារសម្រាប់ការវិភាគ និងការសម្រេចចិត្ត ទិន្នន័យដែលពាក់ព័ន្ធនឹងវិស័យសំណល់ក្នុងប្រទេសកម្ពុជា នឹងត្រូវបានយកមកប្រើប្រាស់ដើម្បីបង្កើតជាក្របខ័ណ្ឌការងារសម្រាប់ការសិក្សានៅក្នុងខេត្តកែប។

*ការកំណត់សមាសធាតុសំណល់៖* ទិន្នន័យដែលមានបច្ចុប្បន្នបានមកពីក្រុងនានា អាចត្រូវបានប្រើប្រាស់ ដើម្បីប៉ាន់ប្រមាណលើសមាសធាតុសំណល់ក្នុងខេត្តកែប ដោយសារអវត្តមាននៃការវិភាគសំណល់សម្រាប់ខេត្តនេះ។ គោលវិធីនេះ ពុំមែនជាវិធីសាស្រ្តគួរជាទីជឿជាក់សម្រាប់ការវិភាគលទ្ធភាពគម្រោងទីលានចាក់សំរាម ឬការធ្វើជីកំប៉ុស្តនោះទេ ប៉ុន្តែជាវិធីសាស្រ្តដែលអាចទទួលយកបានសម្រាប់ការវិភាគកម្រិតមូលដ្ឋាន ដូចដែលយើងកំពុងធ្វើនាពេលនេះ។ រូបភាពទី ៤ រៀបរាប់លម្អិតពីសមាសធាតុសំណល់ក្នុងក្រុងភ្នំពេញ ដែលបង្ហាញឱ្យឃើញថា មានសមាមាត្រសំណល់សរីរាង្គមានកម្រិតខ្ពស់ ហើយបន្ទាប់មក គឺមានសំណល់ស្ងួតអាចកែច្នៃប្រើប្រាស់វិញបាន ដូចជាប្លាស្ទិក (២០%) ក្រដាស (១០%) ឈើ (២,៣%) និងកែវ (១,៦%)(Hul et al., 2015)។




***រូបភាពទី ៤៖ សមាសធាតុសំណល់ក្នុងក្រុងភ្នំពេញក្នុងឆ្នាំ ២០១៥***

សំណល់ចំណីអាហារ និងសំណល់សរីរាង្គដែលត្រូវបានបង្កើតឡើងនៅក្រុងគោលដៅដទៃទៀតក្នុង ប្រទេសកម្ពុជា គឺមានចាប់ពី ៦៣% ក្នុងខេត្តសៀមរាប រហូតដល់ ៨០% ក្នុងខេត្តកំពង់ឆ្នាំង។ សំណល់ប្លាស្ទិក និងលោហៈមួយចំនួនត្រូវបានញែកនៅតាមផ្ទះ និងតាមរយៈវិស័យក្រៅប្រព័ន្ធ ដោយសារសម្ភារៈទាំងអស់នេះ មានតម្លៃខ្ពស់ (Sour, 2017)។

*ការប្រមូលសំណល់៖* យោងតាមការប៉ាន់ប្រមាណមួយចំនួន ៩៩% នៃសំណល់របស់ទីក្រុង ត្រូវបានបោះចោលនៅក្នុងទីលានចាក់សំរាម ដោយបន្សល់ទុកធនធានអាចកែច្នៃប្រើប្រាស់ឡើងវិញប្រមាណតែ ១% ប៉ុណ្ណោះ ដែលត្រូវបានប្រមូលដោយអ្នកធ្វើការក្នុងវិស័យក្រៅប្រព័ន្ធ (Heng, 2017)។ ក្នុងក្រុងកែប ការបង្កើតសំណល់ត្រូវបានរាយការណ៍ថា មានបរិមាណ ៨,៥ តោន/ថ្ងៃ ដោយក្នុងនោះមានតែ ៥៧% ប៉ុណ្ណោះនៃសំណល់ទាំងនោះ ត្រូវបានយកទៅចាក់នៅកន្លែងចាក់សំរាម ដែលជាការបង្ហាញឱ្យឃើញថា បរិមាណ សំណល់ដែលនៅសេសសល់ គឺត្រូវបានដុតចោល ឬត្រូវបានបោះចោលដោយខុសច្បាប់។

*សំណល់សរីរាង្គ៖* ដូចបានពិពណ៌នាខាងលើហើយថាសំណល់សរីរាង្គភាគច្រើន គឺជាសំណល់ម្ហូបអាហារ និងបន្លែ និងមានសមាសធាតុច្រើនជាងគេបំផុតនៅក្នុងសមាមាត្រនៃសំណល់នៅក្នុងបណ្តាប្រទេសនានាទូទាំងសាកលលោក។ ក្នុងប្រទេសមានសេដ្ឋកិច្ចអភិវឌ្ឍន៍ សំណល់សរីរាង្គ ជាទូទៅមានបរិមាណចាប់ពី ៤០-៥០%ចំណែកនៅក្នុងប្រទេសមានសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ ជាពិសេសនៅផ្នែកខ្លះនៃតំបន់អាស៊ីភាគខាងត្បូង សំណល់នេះ អាចមានរហូតដល់ ៨០%។ ស្របពេលដែលប្រទេសកម្ពុជា កំពុងមានវឌ្ឍនភាពសេដ្ឋកិច្ច ភាគរយសំណល់សរីរាង្គ ក៏មានការកើនឡើងផងដែរ។ ក្រុងមានទំហំមធ្យម ដូចជាក្រុងសៀមរាប និងក្រុងបាត់ដំបងជាដើម មានសំណល់សរីរាង្គ ៦០% ទៅ ៧០% ក្នុងពាក់កណ្តាលទសវត្សឆ្នាំ២០០០។ ក្រុងភ្នំពេញ ក៏មានសំណល់សរីរាង្គក្នុងអត្រា ៦៣% ផងដែរក្នុងឆ្នាំ២០០៥។ បច្ចុប្បន្ន

បរិមាណនេះ គឺប្រមាណ ៥១%។ សំណល់ម្ហូបអាហារ អាចផ្តល់ឱកាសសម្រាប់ការកាត់បន្ថយផលប៉ះពាល់ផ្នែកបរិស្ថាន ដូចជាការបំពុលទឹក និងការបំភាយឧស្ម័នផ្ទះកញ្ចក់ជាដើម និងអាចកែច្នៃជាផលិតផលមានអត្ថប្រយោជន៍ និងប្រសិទ្ធភាពសម្រាប់ការបង្កើនគុណភាពដី និងការពារការហូរច្រោះដីក្នុងវិស័យកសិកម្ម ការដាំដុះ ឧទ្យាន និងព្រៃឈើ។

**តារាងទី ១ ទិន្នន័យពីប្រជាសាស្ត្រ និងសំណល់រឹងរបស់ខេត្តកែប**

| សាវតារផ្នែកប្រជាសាស្ត្ររបស់ខេត្តកែប | |
|---|---|
| ចំនួនឃុំ/សង្កាត់ | ៥ |
| ចំនួនប្រជាជន | ៤០.៧៦៣ |
| # គ្រួសារ | ៨.៩១៧ |
| # ភោជនីយដ្ឋាន សណ្ឋាគារ និងកន្លែងកម្សាន្តសប្បាយដទៃទៀត | សណ្ឋាគារចំនួន ៧២ + ៦ នៅកោះទន្សាយ (សរុបចំនួន ៧៨)<br>ភោជនីយដ្ឋានចំនួន 56 (យោងតាម tripadvisor)<br>សូមមើលបញ្ជីរាយឈ្មោះ សណ្ឋាគារក្នុងខេត្តកែប៖ https://www.kep-cambodia.com/mainpages/kep-hotels.html |
| # អ្នកទេសចរជាតិ | នឹងត្រូវកំណត់នៅពេលក្រោយ |
| # អ្នកទេសចរអន្តរជាតិ | នឹងត្រូវកំណត់នៅពេលក្រោយ |
| ទិន្នន័យសំខាន់ៗនៃសំណល់រឹងក្នុងខេត្តកែប | |
| បរិមាណសំណល់ក្នុងមួយថ្ងៃ | នឹងត្រូវកំណត់នៅពេលក្រោយ |
| អ្នកផ្តល់សេវា | នឹងត្រូវកំណត់នៅពេលក្រោយ |
| ការចាប់ផ្តើមប្រតិបត្តិការរបស់អង្គភាពគ្រប់គ្រងសំណល់ | នឹងត្រូវកំណត់នៅពេលក្រោយ |
| ការទទួលស្គាល់ចំពោះអង្គភាពគ្រប់គ្រងសំណល់ពីសំណាក់ក្រសួងមហាផ្ទៃ | នឹងត្រូវកំណត់នៅពេលក្រោយ |
| ខ្សែបន្ទាត់គណនេយ្យភាពរបស់អង្គភាពគ្រប់គ្រងសំណល់ | នឹងត្រូវកំណត់នៅពេលក្រោយ |
| # មន្ត្រីរាជការស៊ីវិលរបស់អង្គភាពគ្រប់គ្រងសំណល់ | នឹងត្រូវកំណត់នៅពេលក្រោយ |
| # កិច្ចសន្យារបស់អង្គភាពគ្រប់គ្រងសំណល់ក្រុង | នឹងត្រូវកំណត់នៅពេលក្រោយ |
| ការគ្របដណ្តប់នៃការផ្តល់សេវា | នឹងត្រូវកំណត់នៅពេលក្រោយ |
| ការប្រមូលថ្លៃសេវាប្រចាំខែ | នឹងត្រូវកំណត់នៅពេលក្រោយ |
| ទីលានចាក់សំរាម | នឹងត្រូវកំណត់នៅពេលក្រោយ |
| ចម្ងាយទៅកាន់ទីលានចាក់សំរាម | នឹងត្រូវកំណត់នៅពេលក្រោយ |

ទីផ្សារ និងប្រតិបត្តិការពាណិជ្ជកម្មដទៃទៀតពាក់ព័ន្ធជាមួយអាហារ៖ របាយការណ៍មួយ បង្ហាញថា សំណល់សរីរាង្គបង្កើតឡើងដោយផ្សារសាមគ្គីក្នុងខេត្តកំពត មាន ៨0% ដែលនេះ ជាការបង្ហាញឱ្យឃើញពី ឱកាសទាញយកសំណល់សរីរាង្គពីប្រភពតែម្តង ដូចជានៅទីផ្សារ សាលារៀន សណ្ឋាគារ និងភោជនីយដ្ឋាន។ ខេត្តកែប ក៏មានឱកាសជាសក្តានុពលជាច្រើនផងដែរក្នុងការទាញយកសំណល់ទាំងនេះ។

ការបោះចោល៖ យោងតាមរបាយការណ៍មួយក្នុងឆ្នាំ២០១៧ បានឱ្យដឹងថា មានទីតាំងចោលសំរាមចំនួន ៧២ កន្លែង ដែលបម្រើឱ្យក្រុងទំហំតូច និងមធ្យមនៅទូទាំងប្រទេស។ ទីតាំងទាំងអស់នេះ ច្រើនតែជា ទីលានចាក់សំរាមបើកចំហមិនមានសន្តិសុខ ខ្វះប្រព័ន្ធគ្រប់គ្រងបរិស្ថាន សុខភាព សុវត្ថិភាព ឬការចេញចូល។ ចំណុចទាំងអស់នេះ បង្កឱ្យមានហានិភ័យធ្ងន់ធ្ងរចំពោះកម្មករក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធគ្រប់គ្រងសំណល់ ក៏ដូចជាប្រជាជននៅក្បែរខាង ដែលរងផលប៉ះពាល់ពីបរិស្ថានដែលរងការខូចខាត និងអសន្តិសុខ។ សំណល់ដែលពុំបានទៅដល់ទីលានចាក់សំរាមទាំងនេះ អាចនឹងត្រូវបានបោះចោលដោយខុសច្បាប់ ហើយភាគច្រើនត្រូវបានបោះចោលនៅតាមបណ្តោយផ្លូវ ឬក្នុងផ្លូវទឹក។ ការសិក្សាមួយក្នុងឆ្នាំ២០០៤ ធ្វើឡើងដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន បានប៉ាន់ប្រមាណថា ការចោលសំរាមដោយខុសច្បាប់ក្នុងក្រុងភ្នំពេញ មានអត្រា ២,៥% នៃបរិមាណ សំណល់សរុបនៅកណ្តាលក្រុង និងមានកម្រិតខ្ពស់រហូតដល់ ១៥% នៅតាមតំបន់ជាយក្រុង។ អត្រានៃការដុតសំណល់ មានកម្រិតកាន់តែខ្ពស់ថែមទៀត ពោលគឺ ១៥% នៅមជ្ឈមណ្ឌលកណ្តាលក្រុង និង៥0% នៅតំបន់ជាយក្រុង (Sour, 2017)។

ការបង្កើតសំណល់ក្នុងប្រជាជនម្នាក់៖ ដើម្បីបង្ហាញឱ្យឃើញរូបភាពច្បាស់លាស់ស្តីពីសេណារីយ៉ូការបង្កើតសំណល់នាពេលអនាគតក្នុងខេត្តកែប ជាដំបូងជាការសំខាន់ណាស់ដែលត្រូវមានការប៉ាន់ប្រមាណយ៉ាងសមហេតុផលពីការបង្កើតសំណល់ក្នុងប្រជាជនម្នាក់ សម្រាប់ក្រុងដែលមានចំនួនប្រជាជនប្រហាក់ប្រហែលជាមួយប្រជាជននៅក្នុងខេត្តកែប។ ការបង្កើតសំណល់ក្នុងប្រជាជនម្នាក់ មានចាប់ពី 0,៧៣ គីឡូក្រាម ក្នុងក្រុងភ្នំពេញក្នុងឆ្នាំ ២០១៥ (PPCA, IGES, Nexus, UN Environment, & CCCA, 2018) រហូតដល់ 0,៥៨ គីឡូក្រាម ក្នុងខេត្តបាត់ដំបងក្នុងឆ្នាំ ២០១៦ (CCAC, 2016)។ អាស្រ័យដោយខេត្តបាត់ដំបង និងខេត្តកែប ត្រូវបានចាត់ទុកថា ជាទីក្រុងគោលដៅដែលមានស្ថានភាពផ្នែកសេដ្ឋកិច្ច និងប្រជាសាស្ត្រប្រហាក់ប្រហែលគ្នា យើង មានហេតុផលសមស្របក្នុងការប្រើប្រាស់តួលេខក្នុងខេត្តបាត់ដំបងក្នុងបរិមាណ 0,៥៨ គីឡូក្រាម សម្រាប់ខេត្តកែប រហូតដល់មានការសិក្សាបន្ថែមលើប្រធានបទនេះ ត្រូវបានធ្វើឡើង។

## ២.៤. ឧបករណ៍ប្រមូលទិន្នន័យ

ការផ្តួចផ្តើមគំនិតជាច្រើននៅថ្នាក់ជាតិ និងអន្តរជាតិ ដែលគាំទ្រដល់វគ្គបណ្តុះបណ្តាលស្តីពីសំណល់ទីក្រុង និងកិច្ចខិតខំក្នុងការកសាងសមត្ថភាព បានអភិវឌ្ឍឱ្យមានឧបករណ៍ និងធនធាននានា ដើម្បីគាំទ្រដល់ការសម្រេចចិត្តជុំវិញការគ្រប់គ្រងសំណល់ទីក្រុង។ ជាការសំខាន់ដែលត្រូវមានកម្រងព័ត៌មានស្តីពីសំណល់

ទីក្រុង និងទិន្នន័យរួមសម្រាប់ក្រុងនីមួយៗ ដើម្បីធានាឱ្យមានចំណុចយោងរួម។ សម្ព័ន្ធភាពអាកាសធាតុ និងខ្យល់ស្អាត និងធនាគារពិភពលោក បានបង្កើតឧបករណ៍មួយមានឈ្មោះថា ឧបករណ៍វាយតម្លៃរហ័សសម្រាប់ទីក្រុង ( City Rapid Assessment Tool ) ដើម្បីជួយសម្រួលដល់ការប្រមូល និងការផ្ទៀងផ្ទាត់ព័ត៌មាននេះ។

## ៣. បរិបទផ្នែកលិខិតបទដ្ឋានគតិយុត្តិ

ដើម្បីយល់ឱ្យកាន់តែច្បាស់ពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុងនានាក្នុងប្រទេសកម្ពុជាទាក់ទងជាមួយសំណល់រឹង ជាការល្អក្នុងការពិនិត្យឡើងវិញលើច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិសម្រាប់វិស័យនេះ។

### *៣.១. ក្រឹត្យច្បាប់/ប្រកាសជាធរមាន*

លិខិតបទដ្ឋានគតិយុត្តិសំខាន់ៗចំនួន ០៣ ដែលគ្របដណ្តប់លើការគ្រប់គ្រងសំណល់នៅកម្ពុជា៖

- អនុក្រឹត្យលេខ ៣៦៖ ដែលឆ្លើយតបចំពោះសំណួរ ស្តីពីការគ្រប់គ្រងសំណល់រឹងលើកដំបូងគេបំផុតត្រូវបានអនុម័តក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ។
- ប្រកាសលេខ ៨០ ស្តីពីការគ្រប់គ្រងសំណល់រឹងសម្រាប់ខេត្ត/ក្រុង៖ ត្រូវបានប្រកាសឱ្យប្រើប្រាស់ដោយក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន គ្របដណ្តប់លើទិដ្ឋភាពជាច្រើននៃការគ្រប់គ្រងសំណល់ក្នុងមូលដ្ឋាន រួមមានដូចជា ការប្រមូល ការសម្អាត ការទុកដាក់ ការដឹកជញ្ជូន ការកែច្នៃប្រើប្រាស់ឡើងវិញ និងការបោះចោលសំណល់។ ខេត្តកែប ត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងប្រកាសនេះ។ ការទទួលខុសត្រូវដែលត្រូវបានកំណត់រួមមាន៖ ការផ្តល់ធុងសម្រាប់ផ្ទុកសំណល់ ការយល់ដឹងរបស់សាធារណជន បទប្បញ្ញត្តិសម្រាប់ការចោលសំណល់។ ល ។
- អនុក្រឹត្យលេខ ១១៣ បញ្ជាក់កាន់តែច្បាស់ថែមទៀតពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋាភិបាល និងអង្គភាពថ្នាក់មូលដ្ឋាន ដែលបានចូលជាធរមានក្នុងឆ្នាំ២០១៥ ( Min, 2016 )។ ឥទ្ធិពលដទៃទៀតនៃអនុក្រឹត្យលេខ ១១៣ នេះ រួមមាន៖ កំណត់កាន់តែច្បាស់ពីតួនាទីសំខាន់ៗដែលក្រសួង និងរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការមើលខុសត្រូវ និងការគាំទ្រដល់ការគ្រប់គ្រងសំណល់ ការបែងចែកការទទួលខុសត្រូវច្បាស់លាស់ក្នុងការគ្រប់គ្រងសំណល់ជូនដល់រដ្ឋបាលក្រុង និងស្រុក ការកំណត់ការទទួលខុសត្រូវក្នុងការលើកកម្ពស់ក្នុងការយល់ដឹង និងការចូលរួមរបស់សាធារណជនក្នុងការគ្រប់គ្រងសំណល់រឹងក្នុងមូលដ្ឋាន។

ផ្អែកលើក្របខ័ណ្ឌការងារចែងក្នុងប្រកាសលេខ ៨០ ក្រុងកែប បានអនុម័តឱ្យមានលិខិតឧបករណ៍ផ្នែកច្បាប់ ដើម្បីបកស្រាយបញ្ជាក់បន្ថែមទៀត ស្តីពីការគ្រប់គ្រងសំណល់ក្នុងមូលដ្ឋាន ( Min, 2016 )។ អនុក្រឹត្យលេខ ១១៣ ត្រូវបានអនុវត្ត ប៉ុន្តែនៅពុំទាន់បានជំរុញការអនុវត្តពេញលេញពីសំណាក់រដ្ឋាភិបាលនៅឡើយ ( PPCA et al., 2018 )។

### *៣.២. ការកំណត់ពីតួនាទី*

មានភាពមិនទាន់ច្បាស់លាស់ថាតើ មានការិយាល័យបរិស្ថាននៅក្នុងក្រុងកែបឬទេ។ មានការយល់ឃើញថា ក្នុងពេលអវត្តមានការិយាល័យបរិស្ថាន ការិយាល័យទទួលបន្ទុករដ្ឋបាល និងហិរញ្ញវត្ថុជាអ្នកអនុវត្តការទទួលខុសត្រូវក្នុងការសម្រេចចិត្តពាក់ព័ន្ធជាមួយការគ្រប់គ្រងសំណល់ និងឬការិយាល័យគាំទ្រ និងធ្វើផែនការឃុំ។ តួនាទី និងការទទួលខុសត្រូវដទៃទៀតពាក់ព័ន្ធ ជាមួយការសម្រេចចិត្តលើការគ្រប់គ្រងសំណល់រឹង មានពណ៌នាក្នុងតារាងទី ២ ( Min, 2016 )។

**តារាងទី ២ តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងសំណល់**

| តួនាទី | ទីប្រឹក្សា | អាជ្ញាធរខេត្ត | មន្ទីរ បរិស្ថាន | មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | វិស័យ ឯកជន | ផ្សេងៗ |
|---|---|---|---|---|---|---|
| ការធ្វើផែនការ | | | | × | | |
| ការកំណត់ទីតាំងទីលានចាក់សំរាម | | × | × | | | |
| ការធ្វើផែនការថវិកា | | | | ×× | ××× | |
| កិច្ចសន្យា | | × | | ×× | ××× | |
| ការអនុវត្ត | | × | × | ×× | ××× | |
| ការកំណត់ថ្លៃសេវាប្រមូល និងការប្រមូល | | × | | ×× | ××× | |
| ការគាំទ្រ និងការសម្របសម្រួល | | ×× | ×× | ××× | | |
| ការតាមដាន និងការមើលខុសត្រូវ | | × | × | ××× | | |
| ការវាយតម្លៃ | | × | × | ××× | | |
| ការអប់រំ | | ×× | ×× | | | |

XXX: ការចូលរួមពេញទំហឹង , XX: ការចូលរួមកម្រិតមធ្យម , X: ការចូលរួមតិច

## ៤. ការផ្តល់ហិរញ្ញវត្ថុដល់ការគ្រប់គ្រងសំណល់រឹង

ការគ្រប់គ្រងសំណល់រឹងក្នុងប្រទេសកម្ពុជា ភាគច្រើនបានទទួលការគាំទ្រដោយថ្លៃសេវាដែលបង់ដោយអ្នកប្រើប្រាស់ផ្អែកលើទស្សនទានការស្តារយកថ្លៃចំណាយត្រឡប់មកវិញ។ ថ្លៃសេវា ត្រូវបានប៉ាន់ប្រមាណផ្អែកលើសកម្មភាពរបស់អ្នកបង្កើតសំណល់ជាក់លាក់នោះ ព្រមទាំងទំហំ និងប្រតិបត្តិការរបស់អ្នកបង្កើតសំណល់។ ប្រតិបត្តិករឯកជនដែលគ្រប់គ្រងលើការប្រមូលសំណល់ តាមកិច្ចសន្យាជាអ្នកទទួលខុសត្រូវក្នុងការប្រមូលថ្លៃសេវា និងការផ្តល់សេវា។ ការមិនបង់ថ្លៃសេវា តែងកើតមានជាសាមញ្ញ ហើយបង្កឱ្យមានបញ្ហាប្រឈមគួរជាទីកត់សម្គាល់ដល់លទ្ធភាពប្រតិបត្តិការផ្នែកហិរញ្ញវត្ថុ និងផ្នែកប្រតិបត្តិការរបស់ក្រុមហ៊ុន ហើយជាលទ្ធផលធ្វើឱ្យប្រតិបត្តិការមិនមានលក្ខណៈអាចព្យាករទុកជាមុនបាន និងអាចផ្លាស់ប្តូរដោយផ្អែកលើតថភាពជាក់ស្តែងផ្នែកហិរញ្ញវត្ថុ។ ការគណនាថ្លៃសេវាប្រមូលសំណល់ពីអ្នកប្រើប្រាស់ ពុំត្រូវបានគណនាផ្អែកលើបរិមាណសំណល់ដែលត្រូវបានបង្កើតនោះទេ ប៉ុន្តែផ្អែកលើប្រភេទ និងទំហំប្រតិបត្តិការ។ ការសិក្សាអង្កេតមួយនៅឆ្នាំ ២០១៦ បានបង្ហាញឱ្យឃើញថា ថ្លៃសេវាប្រមូលសំណល់ គឺមានចាប់ពី ០,៨ ដុល្លារ ដល់ ៣០ ដុល្លារក្នុងមួយខែ ( Min, 2016 )។

យន្តការមួយទៀតរបស់កម្ពុជា ក្នុងការផ្តល់មូលនិធិសម្រាប់សេវាប្រមូលសំណល់ គឺផ្តោតលើសំណល់បង្កើតឡើងដោយទីផ្សារនៅក្នុងក្រុង។ គំរូផ្នែកហិរញ្ញវត្ថុ និងការគ្រប់គ្រងនេះ ហាក់មានការវិវត្តដោយចាប់ផ្តើមពីការបង្កើតឱ្យមានកិច្ចសន្យារវាងក្រុមហ៊ុនប្រមូលសំណល់ ជាមួយប្រតិបត្តិករផ្សារ ហើយវិវត្តសន្សឹមៗទៅជាការផ្តល់សេវាដល់អ្នកបង្កើតសំណល់នៅតាមលំនៅដ្ឋាន និងជាលក្ខណៈពាណិជ្ជកម្ម ដោយសារតែកំណើនតម្រូវការជាក់ស្តែង។

ដោយសារលក្ខណៈពិសេសរបស់ខេត្តកែប ដែលជាគោលដៅទេសចរណ៍ដ៏មានប្រជាប្រិយភាពសម្រាប់ប្រជាជនកម្ពុជាផង និងភ្ញៀវអន្តរជាតិផង ក្រុមការងារស្រាវជ្រាវ បានពិនិត្យលើលទ្ធភាពនៃការកំណត់ថ្លៃសេវា ដែលផ្សារភ្ជាប់ជាមួយទិដ្ឋភាពនានានៃទេសចរណ៍ក្នុងមូលដ្ឋានដែលនឹងអាចបង្កើតឱ្យមានចំណូលហើយស្របពេលជាមួយគ្នានោះ ក៏ពុំបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានលើអ្នកតាំងលំនៅក្នុងមូលដ្ឋាន ដូចជាថ្លៃសេវាប្រមូលពីអ្នកស្នាក់នៅតាមសណ្ឋាគារ ឬជិះទូកទៅកាន់កោះនៅក្នុងរង្វង់ខេត្តនេះ។ ការស្រាវជ្រាវបឋមបានកំណត់ឃើញគំរូប្រភេទនេះ នៅក្នុងប្រទេសឥណ្ឌូណេស៊ី ហើយគោលវិធីនេះ ត្រូវបានអនុវត្តដោយជោគជ័យមួយចំនួន ( សូមមើលប្រអប់៖ Gili Trawanga Eco Tax )។

### ពន្ធអេកូទេសចរណ៍របស់កោះ Gili Trawanga នៅប្រទេសឥណ្ឌូណេស៊ី

ដើម្បីដោះស្រាយការផ្គត់ផ្គង់ហិរញ្ញវត្ថុ ដល់ការគ្រប់គ្រងសំណល់នៅក្នុងកន្លែងគោលដៅទេសចរណ៍ដ៏មានប្រជាប្រិយភាពនេះ អង្គការក្រៅរដ្ឋាភិបាល ក្នុងស្រុកមួយ និងអាជ្ញាធរគ្រប់គ្រងសំណល់ បានរួមកម្លាំងគ្នាដោះស្រាយបញ្ហានេះ។ មូលនិធិអេកូទេសចរណ៍ Gili Eco Trust ដែលជាបណ្តុំអ្នកផ្តល់សេវាទេសចរណ៍ និងហាងកីឡាមុជទឹកកម្សាន្ត បានអនុវត្តពន្ធអេកូឡូស៊ីដែលបង់ដោយអ្នកទេសចរនៅពេលមានការផ្តល់សេវាជូន។ មូលនិធិទាំងអស់នេះ ត្រូវបានយកទៅប្រើប្រាស់ដើម្បីឧបត្ថម្ភទុនសម្រាប់កិច្ចខិតខំគ្រប់គ្រងសំណល់នៅលើកោះ។ មូលនិធិនេះ បានជួយដល់គាំទ្រការគ្រប់គ្រងសំណល់ឱ្យអាចទប់ទល់លើការចំណាយ និងចៀសវាងការខាតដើមទុន ( Willmott et al., 2012 )។

***ប្រអប់ទី ២៖ ពន្ធអេកូទេសចរណ៍របស់កោះ Gili Trawanga នៅប្រទេសឥណ្ឌូណេស៊ី***

## ៥. គំរូនៃការគ្រប់គ្រង និងការលើកទឹកចិត្តដើម្បីលើកកម្ពស់ការគ្រប់គ្រងសំណល់រឹង

គំរូនៃការគ្រប់គ្រងជាច្រើនដែលអាចដើរតួនាទីជាគំរូសម្រាប់យកមកពិចារណានៅពេលធ្វើផែនការក្នុងខេត្តកែប។ គំរូទាំងនេះរួមមានដូចជា៖

- មជ្ឈមណ្ឌលស្តារធនធានចម្រុះ៖ មជ្ឈមណ្ឌលនេះ គឺជាគ្រឹះស្ថានស្តារសំណល់ខ្នាតតូចមានលក្ខណៈវិមជ្ឈការដែលកែច្នៃសំណល់ចន្លោះពី ២ តោនទៅ ២០ តោនក្នុងមួយថ្ងៃ ទទួលយកកាកសំណល់ ទីក្រុងដែលញែករួចហើយ ឬមិនទាន់ញែក និងប្រើប្រាស់បច្ចេកទេសអស់តម្លៃទាប ដើម្បីស្តារយកធនធានពីសំណល់មកវិញ។ មជ្ឈមណ្ឌលស្តារធនធានចម្រុះ ត្រូវបានបង្កើតឡើងផ្អែកលើសេចក្តីត្រូវការក្នុងមូលដ្ឋាន ហើយមានលក្ខណៈឆ្លើយតបចំពោះបរិមាណ និងគុណភាពនៃសំណល់ក្នុងមូលដ្ឋាន ( Economic and Social Commission for Asia and the Pacific, 2017 )។
- កម្មវិធីទីក្រុងស្អាត៖ ការផ្តួចផ្តើមគំនិតមួយរបស់កម្ពុជាដែលត្រូវបានធ្វើឡើង ដើម្បីទទួលស្គាល់កិច្ចខិតខំក្នុងការគ្រប់គ្រងសំណល់រឹងរបស់ក្រុងគំរូ។ កន្លងមក ក្រុងជាច្រើនបានសម្របសម្រួលកិច្ចខិតខំរបស់កម្មករក្នុងការប្រមូលសំណល់ចេញពីតាមដងផ្លូវនៅក្រោមគម្រោង "ការប្រកួតប្រជែងទីក្រុងស្អាត" ឬហៅថា "កម្មវិធីទីក្រុងស្អាត"។ កម្មវិធីកំពុងនៅអនុវត្តបន្ត។
- ក្រុងព្រះសីហនុ៖ ក្រុងមួយនេះ អនុវត្តការងារនៅរៀងរាល់ចុងសប្តាហ៍ជាមួយសង្កាត់ទាំង ០៥ របស់ខ្លួន ដើម្បីធ្វើយុទ្ធនាការបោសសម្អាតក្នុងសង្កាត់ណាមួយក្នុងចំណោមសង្កាត់ទាំង ០៥។ នៅពេល ទីតាំងបោសសម្អាតត្រូវបានស្នើឡើង និងសម្រេចពីសំណាក់ក្រុមប្រឹក្សាសង្កាត់នីមួយៗហើយ រដ្ឋបាលក្រុងធ្វើការរៀបចំព្រឹត្តិការណ៍សម្អាតជាក់ស្តែងតាមរយៈការអញ្ជើញមន្ត្រី យុវជន អង្គការក្រៅរដ្ឋាភិបាល ក៏ដូចជាអ្នកតំណាងសមាគមទីភ្នាក់ងារទេសចរណ៍ចំនួន ៤០ ទៅ ៦០ នាក់ឱ្យមកចូលរួម។
- ក្រុងស្ទឹងត្រែង គឺជាក្រុងមួយក្នុងចំណោមក្រុងមួយចំនួនតូចក្នុងប្រទេសកម្ពុជាដែលគ្រប់គ្រងសំណល់រឹងដោយផ្ទាល់តាមរយៈអង្គភាពគ្រប់គ្រងសំណល់របស់ខ្លួន ពោលគឺមិនមែន

តាមរយៈអ្នកផ្តល់សេវាឯកជន (ពោលគឺគំរូក្នុងការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនប្រមូលកាកសំណល់ ឬអ្នកយកភាស៊ីផ្សារ) នោះទេ។ គួរកត់សម្គាល់ថា មុនពេលបង្កើតអង្គភាពគ្រប់គ្រងសំណល់ក្រុងនៅដើមឆ្នាំ២០១១ ហើយត្រូវបានទទួលស្គាល់ដោយ ក្រសួងមហាផ្ទៃ ក្នុងឆ្នាំ២០១៣ ការប្រមូលសំណល់ក្នុងក្រុងស្ទឹងត្រែង ត្រូវបានចុះកិច្ចសន្យាប្រគល់ទៅឱ្យក្រុមហ៊ុនឯកជន (Min, 2016)។

- មជ្ឈមណ្ឌលគ្រប់គ្រងសំណល់បែបសង្គមក្នុងខេត្តបាត់ដំបង៖ មជ្ឈមណ្ឌលនេះ គឺជាគម្រោងបែបចម្រុះ និងជាមជ្ឈមណ្ឌលកែច្នៃសំណល់បែបសង្គម និងបែបសរីរាង្គ (កន្លែងផលិតជីកំប៉ុស្ត និងជីវម៉ាស)។ គោលបំណងចម្បងរបស់មជ្ឈមណ្ឌលនេះ គឺដើម្បីលើកកម្ពស់គុណភាពជីវិត និងលក្ខខណ្ឌការងាររបស់អ្នករើសសំរាម។ ការកែលំអឱ្យប្រសើរឡើងរួមមានដូចជា៖
    - បន្ទប់សម្រាក កន្លែងចម្អិនអាហារ កន្លែងងូតទឹក បង្គន់ ទឹកស្អាត ។ល។
    - ការធ្វើបទបង្ហាញជាញឹកញាប់ស្តីពីវិធានការសន្តិសុខ និងអនាម័យ ផ្តល់ជូនដល់កម្មករនិយោជិតដោយបុគ្គលិករបស់អង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា។
    - កុមារជាង ៣០ នាក់ដែលជាកូនៗរបស់គ្រួសារអ្នករើសសំរាមរស់នៅជុំវិញទីលានចាក់សំរាម ត្រូវបានលើកទឹកចិត្តឱ្យទៅសាលារៀន និងបានទទួលគុណប្រយោជន៍ពីការបង្រៀនក្រៅម៉ោងបន្ថែម។
    - លទ្ធភាពចូលទៅលេងក្នុងទីធ្លា និងបន្ទប់សម្រាប់កុមារលេងកម្សាន្ត។
    - ជីវម៉ាស ដែលផលិតបានត្រូវបានប្រើប្រាស់សម្រាប់ការដាំស្ល និងបំភ្លឺ ហើយជីកំប៉ុស្តត្រូវបានយកទៅលក់ដើម្បីបានចំណូលបន្ថែម (COMPED, 2013)។
- ធនាគារសំណល់ (ប្រទេសឥណ្ឌូណេស៊ី)៖ អង្គភាពឯករាជ្យទាំងអស់នេះ ធ្វើប្រតិបត្តិការដោយឈរលើទស្សនទានធនាគារពាណិជ្ជកម្ម ដោយក្នុងនោះសម្ភារៈដែលអាចកែច្នៃទៅប្រើប្រាស់វិញបាន គឺជារូបិយវត្ថុ។ អតិថិជនយកសម្ភារៈទាំងនោះមកដាក់ផ្ញើនៅធនាគារ ហើយបញ្ជីនោះត្រូវបានកត់ត្រាទុកក្នុងកូនសៀវភៅធនាគារ។ នៅចុងឆ្នាំក្នុងអំឡុងកម្មវិធីបុណ្យជាតិ ការទូទាត់ជាសាច់ប្រាក់ត្រូវបានធ្វើឡើងផ្អែកលើបរិមាណនៃសម្ភារៈដែលត្រូវបានផ្ញើ។ ជាទូទៅអង្គភាពទាំងនេះ មានប្រតិបត្តិការ ដោយមានការគាំទ្រពីរោងចក្រផលិតទំនិញប្រើប្រាស់ក្នុងវិស័យឯកជន (Salim, 2013)។

## ៦. តួនាទីវិស័យក្រៅប្រព័ន្ធ និងយេនឌ័រនៅក្នុងការគ្រប់គ្រងសំណល់

ចំណងទាក់ទងដ៏សំខាន់រវាង កម្មករធ្វើការក្នុងវិស័យក្រៅប្រព័ន្ធដែលមានជីវភាពពឹងផ្អែកលើការ គ្រប់គ្រងសំណល់ និងសកម្មភាពស្តារយកធនធានពីសំណល់មកវិញ ត្រូវបានទទួលស្គាល់កាន់តែច្រើនឡើងនៅទូទាំងសាកលលោក។ ជំនួសឱ្យការព្រងើយកន្តើយចំពោះតថភាពជាក់ស្តែងមួយនេះ គោលវិធីប្រកបដោយជោគជ័យ បានបង្កឱ្យមានការចូលរួមដោយផ្ទាល់ពីសហគមន៍ទាំងអស់នេះ ដោយព្យាយាមដាក់បញ្ចូលពួកគេទៅក្នុងគំរូការគ្រប់គ្រងសំណល់ថ្មី តាមវិធីយ៉ាងណាធានាឱ្យមានការគោរពចំពោះចំណេះដឹង និងបទពិសោធន៍របស់ពួកគេនៅក្នុងវិស័យនេះ ហើយស្របពេលជាមួយគ្នានោះ ក៏ផ្តល់កិច្ចការពារផ្នែកសុខភាព និងសុវត្ថិភាពកាន់តែប្រសើរឡើងបន្ថែមលើការផ្តល់សំណងចំពោះការងាររបស់ពួកគាត់។

ឧទាហរណ៍ពីខេត្តកំពតរបស់ប្រទេសកម្ពុជា ផ្តល់ឱ្យយើងនូវគំនិតមួយចំនួនទាក់ទងជាមួយចំណូលសម្រាប់កម្មករទាំងអស់នេះ។ វិស័យក្រៅប្រព័ន្ធមានភាពសកម្ម ជាពិសេសនៅក្នុងការគ្រប់គ្រងសំណល់ក្នុងខេត្តកំពត ដោយក្នុងនោះមានអ្នករើសអេតចាយជាង ៣០ នាក់ធ្វើការក្នុងក្រុងនេះ ហើយពួកគាត់ភាគច្រើន គឺជាស្ត្រីរកកម្រៃបានចន្លោះពី ២ ដុល្លារ ទៅ ៣,៥០ ដុល្លារ ក្នុងមួយថ្ងៃ (Community Sanitation and Recycling Organization, n.d.)។

ការសង្កេតមួយចំនួនទៀត ផ្តល់ឱ្យយើងនូវការយល់ដឹងពីបរិបទកម្ពុជា ក្នុងនោះរួមមានដូចជា៖

- ៥១% នៃអ្នករើសសំរាមដែលសកម្មក្នុងក្រុងភ្នំពេញ គឺជាកុមារ (អាយុតិចជាង ១៨ឆ្នាំ) ដោយក្នុងនោះ ៣៥%មានអាយុតិចជាង ១៥ ឆ្នាំ។ អាយុរបស់អ្នកដែលត្រូវបានសាកសួរ គឺមានចាប់ពី ៨ ឆ្នាំដល់ ៧៧ ឆ្នាំ។
- អ្នករើសសំរាមភាគច្រើន គឺមកពី "គ្រួសារមានសមាជិកច្រើនជាង ៥ នាក់ ដោយជាមធ្យមគ្រួសារអ្នករើសសំរាម មានសមាជិក ៥,៤២ នាក់"។
- ៣៤% នៃគ្រួសារអ្នករើសសំរាម គឺមានស្ត្រីជាមេគ្រួសារ ដោយក្នុងនោះភាគច្រើននៃអ្នករើសសំរាមក្នុងក្រុងភ្នំពេញ គឺជាបុរស (៦២%)។
- ភាគច្រើនសន្ធឹកសន្ធាប់នៃអ្នករើសសំរាមដែលសកម្ម គឺមាន ៦៨% ជាជនជាតិខ្មែរ ចំណែក ២៦% ជាជនជាតិវៀតណាម (Community Sanitation and Recycling Organization, n.d.)។

## ៧. ប្រធានបទនាពេលបច្ចុប្បន្នស្តីពីការគ្រប់គ្រងសំណល់ និងបរិស្ថានសាកល

### ៧.១. ឋានានុក្រមសំណល់

ឋានានុក្រមសំណល់ គឺជាវិធីសាស្ត្រនៃក្របខណ្ឌក្នុងការសម្រេចចិត្ត ដែលត្រូវបានប្រើប្រាស់ ដើម្បីជាមគ្គុទ្ទេសក៍លើការសម្រេចចិត្តបែបគ្រប់ជ្រុងជ្រោយពាក់ព័ន្ធជាមួយការគ្រប់គ្រង ការប្រមូល ការស្តារយកនូវធនធាន និងថាមពល និងការបោះចោលសំណល់ (សូមមើលរូបភាពទី ៥)។ អក្សរកាត់ 3Rs ដែលតំណាងឱ្យការកាត់បន្ថយសំណល់ (reduce) ការប្រើប្រាស់ឡើងវិញ (reuse) និងការកែច្នៃប្រើប្រាស់ឡើងវិញ (recycle) គឺជាសមាសធាតុនៅក្នុងឋានានុក្រមនេះ។




*រូបភាពទី៥៖ ក្របខណ្ឌក្នុងការសម្រេចចិត្តអំពីឋានានុក្រមសំណល់*

### *៧.២. សេដ្ឋកិច្ចចក្រា*

សេដ្ឋកិច្ចចក្រា មានបំណងកំណត់សារជាថ្មីឡើងវិញពីការលូតលាស់ដោយផ្តោតការយកចិត្តទុកដាក់លើអត្ថប្រយោជន៍ជាវិជ្ជមានសម្រាប់សង្គមទាំងមូល។ សេដ្ឋកិច្ចចក្រា សំដៅលើការកាត់បន្ថយសកម្មភាពសេដ្ឋកិច្ចចេញពីការប្រើប្រាស់ធនធានមានដែនកំណត់ និងការកាត់បន្ថយសំណល់។ ដោយឈរលើមូលដ្ឋាននៃការឈានទៅរកប្រភពថាមពលកកើតឡើងវិញ គំរូសេដ្ឋកិច្ចចក្រា ស្ថាបនាមូលធនផ្នែកសេដ្ឋកិច្ច ធនធាន និងសង្គម ( Ellen MacArthur Foundation, 2017 )។

### *៧.៣. ការមិនបង្កើតសំណល់ ( Zero Waste )*

ការមិនបង្កើតសំណល់ ( Zero Waste ) សំដៅលើការអភិរក្សធនធានទាំងអស់តាមមធ្យោបាយនៃផលិតកម្ម ការបរិភោគ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃប្រើប្រាស់ឡើងវិញប្រកបដោយការទទួលខុសត្រូវចំពោះគ្រប់ផលិតផល ការវេចខ្ចប់ និងវត្ថុធាតុដើមទាំងអស់ ដោយមិនដុតធនធានទាំងនោះ និងមិនបោះចោលទៅលើដី ទឹក ឬអាកាសដែលគំរាមដល់បរិស្ថាន ឬសុខភាពមនុស្សឡើយ ( Zero Waste International Alliance, 2018 )។

### *៧.៤. ការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក*

មូលនិធិ Ellen MacArthur ប៉ាន់ប្រមាណថាប្លាស្ទិក ៨ លានតោន ចូលទៅក្នុងមហាសមុទ្រជារៀងរាល់ឆ្នាំ ( Ellen MacArthur Foundation, 2017 ) ។វិធានការណ៍នានាដើម្បីការពារមហាសមុទ្រ និងសង្វាក់ចំណីអាហាររបស់យើងឱ្យរួចផុតពីការបំពុលដោយប្លាស្ទិកបន្ថែមទៀត រួមមានការកាត់បន្ថយប្លាស្ទិកប្រើប្រាស់តែមួយដងហើយចោល ពង្រឹងកិច្ចខិតខំក្នុងការកែច្នៃមកប្រើប្រាស់ឡើងវិញ និងការលើកកម្ពស់ការគ្រប់គ្រង និងការចោលកាកសំណល់។

### *៧.៥. សំណល់ចំណីអាហារ*

សំណល់ទីក្រុងនៅទូទាំងសាកល មានភាគរយសំណល់សរីរាង្គខ្ពស់ជាងគេ។ សំណល់សរីរាង្គ គឺជាសំណល់ដែលអាចពុកផុយបានតាមធម្មជាតិ ហើយភាគរយដ៏ខ្ពស់នៃសំណល់នេះ គឺមានទំនាក់ទំនងជាមួយការចម្អិនម្ហូបអាហារ ឬកម្ទេចកម្ទីម្ហូបអាហារ។ កិច្ចខិតខំកម្រិតអន្តរជាតិ បានផ្តោតការយកចិត្តទុកដាក់លើការកាត់បន្ថយការបោះចោលអាហារដែលអាចញ៉ាំបាន និងបង្វែរទិសដៅអាហារប្រភេទនេះសម្រាប់ការកាត់បន្ថយការអត់ឃ្លាន ចំណីសត្វ និងផលិតកម្មជីកំប៉ុស្ត ព្រមទាំងផលិតផលជួយបង្កើនជីវជាតិដីដទៃទៀត ដែលអាច យកទៅប្រើប្រាស់ជំនួសជីគីមី។ ការទាញយកកាកសំណល់នេះចេញពីទីលានចាក់សំរាម និងកន្លែងចាក់សំរាម ជួយកាត់បន្ថយការបំភាយឧស្ម័នមេតានដែលជាឧស្ម័នផ្ទះកញ្ចក់ ហើយក៏ជួយកាត់បន្ថយហានិភ័យផ្នែកបរិស្ថាន និងសុខភាពពាក់ព័ន្ធជាមួយការបំពុលខ្យល់ និងទឹកផងដែរ។

### *៧.៦. ប្រព្រឹត្តិកម្មសំណល់តាមបែបវិមជ្ឈការ*

ការកាត់បន្ថយបរិមាណសំណល់នៅមុនពេលយកទៅបោះចោល ជួយកាត់បន្ថយតម្រូវការទីលានចាក់សំរាម ក៏ដូចជាផលប៉ះពាល់នានាដែលពាក់ព័ន្ធជាមួយការចាក់បំពេញទីលានចាក់សំរាម។ ដើម្បីកាត់បន្ថយបរិមាណសំណល់ សំណល់ដែលមានប្រយោជន៍ ចាំបាច់ត្រូវញែក និងប្រមូលឱ្យបានត្រឹមត្រូវ។ គំរូនៃការញែក និងប្រព្រឹត្តិកម្មសំណល់នៅក្នុងស្រុក និងតាមសហគមន៍ជាច្រើន ត្រូវបានបង្កើតឡើង ដោយក្នុងនោះរួមមានការទាញយកសំរាមស្ងួតដែលអាចកែច្នៃយកទៅប្រើប្រាស់វិញបាន និងការធ្វើជីកំប៉ុស្តការផលិតជីវម៉ាសពីសំណល់សរីរាង្គដូចជាសំណល់អាហារជាដើម ដើម្បីផលិតជាជីកំប៉ុស្ត ផលិតផលជួយពង្រឹងគុណភាពដី ហើយអាចបូកផ្សំជាមួយឡជីវម៉ាស ដើម្បីផលិតជីវម៉ាសសម្រាប់ចម្អិន និងកម្តៅផងដែរ។

### *៧.៧. អត្ថប្រយោជន៍សម្រាប់អាកាសធាតុ និងគុណភាពខ្យល់*

ដោយហេតុថា ការអនុវត្តការគ្រប់គ្រងសំណល់នាពេលបច្ចុប្បន្ន រួមចំណែកធ្វើឱ្យមានការប្រែប្រួល អាកាសធាតុតាមរយៈការបំភាយឧស្ម័នផ្ទះកញ្ចក់ ដែលភាគច្រើនគឺមេតាន និងមានផលប៉ះពាល់ដល់ខ្យល់ ដី និងធនធានទឹក ដោយសារសារធាតុបំពុលផ្សេងៗជាច្រើន ដូចជា ទឹកដែលហៀរចេញពីកាកសំណល់ ឧស្ម័ននៅទីលានចាក់សំរាម បន្សំរវាងមេតានជាមួយឧស្ម័នកាបូនិច និងសមាសធាតុដទៃទៀត។ តាមរយៈការបង្កើតឱ្យមានយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយក្នុងការកាត់បន្ថយការចោលសំណល់ ផលប៉ះពាល់ដូចបានរៀបរាប់ខាងលើនេះជាច្រើន អាចត្រូវបានកាត់បន្ថយគួរឱ្យកត់សម្គាល់។

## ៨. គំនិតផ្តួចផ្តើមនានាសម្រាប់ការគ្រប់គ្រងសំណល់រឹងទីក្រុងនៅខេត្តកែប

ការសិក្សាពីឯកសារពាក់ព័ន្ធនាពេលនេះ បានបង្ហាញថា មានការផ្តួចផ្តើមគំនិតជាច្រើនដែលបាន គាំទ្រការលើកកម្ពស់ការគ្រប់គ្រងសំណល់ក្នុងខេត្តកែប។ ការផ្តួចផ្តើមគំនិតដទៃទៀត ក៏មាននៅថ្នាក់ជាតិផងដែរ។ ជាសង្ខេប ការផ្តួចផ្តើមគំនិតទាំងអស់នេះមានដូចជា៖

- ក្រសួងទេសចរណ៍ និងធនាគារអភិវឌ្ឍន៍អាស៊ី កំពុងពិភាក្សាឈានទៅរកការព្រមព្រៀងគ្នាលើកម្ចីក្នុងទឹកប្រាក់ ៣០ លានដុល្លារអាមេរិក ដើម្បីផ្តល់មូលនិធិសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ

ក្នុងបណ្ដាខេត្តតាមឆ្នេរសមុទ្រ ដែលនឹងគាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍។ កម្មវិធីនេះ ក៏គាំទ្រដល់ការគ្រប់គ្រងសំណល់ក្នុងខេត្តកែបផងដែរ (Chea, 2018)។

- អង្គការដទៃទៀត បានយកចិត្តទុកដាក់លើការគ្រប់គ្រងសំណល់ក្នុងខេត្តកែប ដូចជា វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល កម្មវិធីបរិស្ថានសហប្រជាជាតិ/គណៈកម្មាធិការអង្គការសហប្រជាជាតិផ្នែកសេដ្ឋកិច្ច សង្គម ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក ស្ថានទូតស៊ុយអែត កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ។
- ឯកសារបោះពុម្ពផ្សាយឆ្នាំ២០១៨ មានចំណងជើងថា *"យុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់សម្រាប់រាជធានីភ្នំពេញ ឆ្នាំ២០១៨-២០៣៥"* បានរួមបញ្ចូលនូវទិដ្ឋភាពទូទៅទូលំទូលាយស្ដីពីម្ចាស់ជំនួយអន្តរជាតិ និងម្ចាស់ជំនួយថ្នាក់តំបន់ដែលចូលរួមក្នុងការគាំទ្រដល់ការកែលំអការគ្រប់គ្រងសំណល់ក្នុងប្រទេសកម្ពុជា ដែលមាននៅក្នុងឧបសម្ព័ន្ធមានចំណងជើងថា *"ប្រភពមូលនិធិជាសក្ដានុពលសម្រាប់ការគ្រប់គ្រងកាកសំណល់"*។

## ៩. ខ្លឹមសារសង្ខេប និងជំហានបន្ទាប់

ការចុះសិក្សាទៅកាន់ខេត្តកែប នឹងត្រូវធ្វើឡើងក្នុងសប្ដាហ៍ទី១ ខែមេសា ឆ្នាំ២០១៩។ ការចុះសិក្សាផ្ទាល់នេះ នឹងផ្ដល់ឱកាសឱ្យក្រុមការងារស្រាវជ្រាវអាចស្វែងយល់បន្ថែមពីការអនុវត្តការគ្រប់គ្រងសំណល់រឹងនាពេលបច្ចុប្បន្នក្នុងខេត្តកែប តាមរយៈការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយបុគ្គលសំខាន់ៗ និងទស្សនកិច្ចផ្នែកបច្ចេកទេសទៅកាន់ទីតាំងបង្កើតសំណល់ និងកន្លែងចោលសំណល់។ ការងារតាមដានបន្តនឹងផ្ដោតការយកចិត្តទុកដាក់លើការរៀបចំឯកសារសង្ខេបគោលនយោបាយ បន្ថែមពីលើការវិភាគដែលត្រូវបានធ្វើឡើងនៅក្រោយពេលទស្សនកិច្ច ទៅមូលដ្ឋានផ្ទាល់។

ឯកសារសង្ខេបគោលនយោបាយ នឹងឆ្លើយតបចំពោះគោលបំណងធំជាច្រើន ក្នុងនោះអាចមាន៖

- ការផ្ដល់អនុសាសន៍គោលនយោបាយ ដែលគាំទ្រដល់ការគ្រប់គ្រងសំណល់ប្រកបដោយនិរន្តរភាព និងគិតគូរពីផលប៉ះពាល់បរិស្ថាន និងសង្គមដែលពាក់ព័ន្ធនឹងប្រទេសកម្ពុជា។
- ការបង្កើតឱ្យមានគំរូទស្សនទានមួយ ដែលសមស្របទៅតាមស្ថានភាពរបស់ប្រទេសកម្ពុជា ដោយផ្អែកលើប្រព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធដែលត្រូវបានសាកល្បងសម្រាប់ការគ្រប់គ្រងសំណល់។
- ឱកាសក្នុងការបង្កើនធនធានហិរញ្ញវត្ថុ និងចំណេះដឹង ដើម្បីគាំទ្រដល់ការគ្រប់គ្រងសំណល់ក្នុងប្រទេសកម្ពុជា។
- ការពិចារណាផ្នែកសង្គម និងយេនឌ័រ។

ប្រធានបទជាក់លាក់ដទៃទៀតដែលគួរយកមកពិចារណា មានដូចជា៖

- បច្ចេកវិទ្យា ប្រព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធ
- គំរូលើកទឹកចិត្តដែលផ្អែកលើហិរញ្ញវត្ថុ និងការដឹកនាំ
- ការរៀបចំគម្រោងអនុវត្តសាកល្បង
- ការចូលរួមក្នុងភាពជាដៃគូ។

# ឧបសម្ព័ន្ធ ២៖ ពង្រាងពីយុទ្ធសាស្ត្រនៅជាសកម្មភាពសាកល្បងរយៈពេល ០៣ឆ្នាំ

| យុទ្ធសាស្ត្រ និងសកម្មភាពគោល | | ឆ្នាំទី១ | | | | | | | | | | | | ឆ្នាំទី២ | | | | | | ថវិកាប៉ាន់ប្រមាណ (សម្រាប់ផ្នែកបច្ចេកទេសតែប៉ុណ្ណោះ) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | |
| **១. អភិបាលកិច្ច និងវិមជ្ឈការ** | | | | | | | | | | | | | | | | | | | | |
| ១.១ | ផ្សព្វផ្សាយ និងបន្តសម្រួលដល់ការអនុវត្តអនុក្រឹត្យលេខ ១១៣ និងប្រកាសលេខ ០៧៣ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | ៣០.០០០ |
| ១.២ | បង្កើតក្រុមការងារ និងអនុវត្តការតាមដានការអនុវត្តការងារនៅកម្រិតក្រុងកែប | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ២០.០០០ |
| ១.៣ | បង្កើតប្រព័ន្ធ និងអនុវត្តការត្រួតពិនិត្យតាមដានថ្នាក់ជាតិលើការអនុវត្តអនុក្រឹត្យលេខ ១១៣ | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ២០.០០០ |
| **២. ពង្រីកសេវាប្រមូលសំរាមឱ្យបានពេញលេញ** | | | | | | | | | | | | | | | | | | | | |
| ២.១ | កំណត់ទីតាំងដែលមិនទាន់បានប្រមូលសំរាម និងសិក្សាពីសមាសធាតុប្រមូលសំណល់ | | | | | | | ■ | ■ | ■ | ■ | ■ | ■ | | | | | | | ២០.០០០ |
| ២.២ | សម្រេចកម្រិតរដ្ឋបាលក្រុង ដើម្បីអនុវត្តការប្រមូលលើទីតាំងដែលបានកំណត់ | | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ១០.០០០ |
| **៣. ការអប់រំ ផ្សព្វផ្សាយ និងការចូលរួម** | | | | | | | | | | | | | | | | | | | | |
| ៣.១ | ពិចារណាពីលទ្ធភាពអនុវត្តម៉ូដែល គណនេយ្យភាពសង្គមលើសេវាគ្រប់គ្រងសំរាមនៅថ្នាក់ក្រុង | ■ | ■ | ■ | | | | | | | | | | | | | | | | ៥០.០០០ |
| ៣.២ | ស្ទង់មតិដើម្បីបង្កើតចំណេះដឹងជាមូលដ្ឋាននៃការយល់ដឹងមុនការអនុវត្តគម្រោង | ■ | ■ | ■ | | | | | | | | | | | | | | | | ២០.០០០ |

| យុទ្ធសាស្ត្រ និងសកម្មភាពគោល | | ឆ្នាំទី១ | | | | | | | | | | | | ឆ្នាំទី២ | | | | | | ថវិកាប៉ាន់ប្រមាណ (សម្រាប់ផ្នែកបច្ចេកទេសតែប៉ុណ្ណោះ) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | |
| ៣.៣ | ជំរុញបង្កើតឧបករណ៍ផ្សព្វផ្សាយអំពីបញ្ហាសំរាម និងផ្សារភ្ជាប់ជាមួយសក្តានុពលវិស័យទេសចរណ៍ខេត្តកែបតាមរយៈបណ្តាញសង្គម និងយុទ្ធនាការនានាដើម្បីលើកកម្ពស់ការយល់ដឹង | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ១០០.០០០ |
| ៤. បច្ចេកវិទ្យា វិស័យឯកជន និង វិស័យក្រៅប្រព័ន្ធ | | | | | | | | | | | | | | | | | | | | |
| ៤.១ | សិក្សាលទ្ធភាពនៃការកែច្នៃសំណល់សរីរាង្គនៅកម្រិតសហគមន៍នៅតំបន់ដែលមិនទទួលបាន សេវាប្រមូលសំណល់ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | ១៥.០០០ |
| ៤.២ | សាកល្បងការធ្វើកំប៉ុស្តខ្នាតតូច | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ៣០.០០០ |
| ៥. កែលំអទីលានចាក់សំរាម | | | | | | | | | | | | | | | | | | | | |
| ៥.១ | វាយតម្លៃប្រតិបត្តិការ និងការគ្រប់គ្រង ទីលានចាក់សំរាមបច្ចុប្បន្ន | ■ | ■ | ■ | | | | | | | | | | | | | | | | ២០.០០០ |
| ៥.២ | គាំទ្រដល់ថ្នាក់ក្រុងលើកផែនការជាក់លាក់ដើម្បីកែលំអទីលានចាក់សំរាមបច្ចុប្បន្ន | | | | ■ | ■ | ■ | | | | | | | | | | | | | ១០.០០០ |

| | យុទ្ធសាស្ត្រ និងសកម្មភាពគោល | ឆ្នាំទី២ | | | | | | ឆ្នាំទី៣ | | | | | | | | | | | | ថវិកាប៉ាន់ប្រមាណ (សម្រាប់ផ្នែកបច្ចេកទេសតែប៉ុណ្ណោះ) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ១. អភិបាលកិច្ច និងវិមជ្ឈការ | | | | | | | | | | | | | | | | | | | | |
| ១.១ | តាមដាន និងផ្តល់គំនិតបច្ចេកទេសពាក់ព័ន្ធនឹងការអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃទាំងនៅថ្នាក់ជាតិ និងក្រោមជាតិ | | | ■ | | | ■ | | | ■ | | | ■ | | | ■ | | | ■ | ១០.០០០ |
| ២. ពង្រីកសេវាប្រមូលសំរាមឱ្យបានពេញលេញ | | | | | | | | | | | | | | | | | | | | |
| ២.១ | តាមដាន និងផ្តល់គំនិតបច្ចេកទេសពាក់ព័ន្ធនឹងការអនុវត្តការងារពង្រីកសេវា | | | ■ | | | ■ | | | ■ | | | ■ | | | ■ | | | ■ | ១០.០០០ |
| ៣. ការអប់រំ ផ្សព្វផ្សាយ និងការចូលរួម | | | | | | | | | | | | | | | | | | | | |
| ៣.១ | បន្តផ្សព្វផ្សាយពីបញ្ហាសំរាមនិងផ្សារភ្ជាប់ជាមួយសក្តានុពលវិស័យទេសចរណ៍ខេត្តកែបតាមរយៈ បណ្តាញសង្គម និងយុទ្ធនាការនានាដើម្បីលើកកម្ពស់ការយល់ដឹង | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ១០០.០០០ |
| ៣.២ | វិភាគ សាកល្បង និងបន្តអនុវត្តការផាកពិន័យចំពោះការចោលសំរាមខុសច្បាប់ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ២៥.០០០ |
| ៣.៣ | សិក្សាពីការយល់ដឹងក្រោយការអនុវត្តសកម្មភាព | | | | | | | | | | | | | | | | ■ | ■ | ■ | ២០.០០០ |
| ៤. បច្ចេកវិទ្យា វិស័យឯកជន និងវិស័យក្រៅប្រព័ន្ធ | | | | | | | | | | | | | | | | | | | | |
| ៤.១ | តាមដាន និងផ្តល់គំនិតបច្ចេកទេសពាក់ព័ន្ធនឹងការធ្វើកំប៉ុស្តិ៍នៅកម្រិតសហគមន៍ | | | ■ | | | ■ | | | ■ | | | ■ | | | ■ | | | ■ | ២០.០០០ |
| ៤.២ | សាកល្បងកែច្នៃសំណល់សរីរាង្គពីផ្សារទៅជាជីវឧស្ម័ន | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ៥០.០០០ |
| ៤.៣ | បង្កើតក្របខណ្ឌកែច្នៃសំណល់ប្លាស្ទិក | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | ១៥.០០០ |
| ៤.៤ | សាកល្បងច្នៃសំរាមប្លាស្ទិក | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ៣០០.០០០ |

# ឯកសារយោង


Abila, B., & Kantola, J. (2019). The Perceived Role of Financial Incentives in Promoting Waste Recycling—Empirical Evidence from Finland. *Recycling, 4(1).*

Agarwal, R. (2017). *Why Panaji should not give up on decentralised waste management*. Retrieved from https://www.downtoearth.org.in/news/waste/back-to-bins-58380

Aravind, H. (2014). *Mysore City Corporation Launches Drive for Efficient Solid Waste Management*. Retrieved from https://timesofindia.indiatimes.com/city/mysuru/Mysore-City-Corporation-launches-drive-for-efficient-solid-waste-management/articleshow/31288878.cms

Barboza, L. G. A., Vethaak, A. D., Lavorante, B. R., Lundebye, A. K., & Guilhermino, L. (2018). Marine Microplastic Debris: An Emerging Issue for Food Security, Food Safety and Human Health. *Marine pollution bulletin*, 133, 336-348.

Bogner, J., Abdelrafie Ahmed, M., Diaz, C., Faaij, A., Gao, Q., Hashimoto, S., . . . Zhang, T. (2007). Waste Management. In B. Metz, O. R. Davidson, P. R. Bosch, R. Dave, & L. A. Meyer (Eds.), *Climate Change 2007: Mitigation. Contribution of Working Group III to the Fourth Assessment Report of the Intergovernmental Panel on Climate Change*. United Kindom and USA: Cambridge University Press.

Boldt, M., & Cleeve, A. (2018). *Solid Waste Management:* EC-Link Position Paper. Retrieved from http://www.eclink.org/upload/attachment/8ca8c29d6dfc44dbaf3e9514a94de63d.pdf

Bual, H. (2018). *Waste Management*. Retrieved from https://www.khmertimeskh.com/548828/waste-management/

CCAC. (2016). *Battambang Municipality, Cambodia*. Retrieved from https://www.waste.ccacoalition.org/sites/default/files/files/city_profiles/Battambang_City%20Profile%20Template_FINAL-04072014_EF-JS.pdf

CCAC MSW Initiative. (2013). *City MSW Rapid Assessment Data Collection Tool: English*. Retrieved from https://www.waste.ccacoalition.org/document/city-msw-rapid-assessment-data-collection-tool-english

Chea, V. (2018). Cambodia, ADB Discuss $30m Loan. Retrieved from https://www.khmertimeskh.com/555099/cambodia-adb-discuss-30m-loan/

Cointreau-Levine, S. (1994). Private Sector Participation in Municipal Solid Waste Services in Developing Countries (English). Urban Management Programme Discussion Paper. Retrieved from http://documents.worldbank.org/curated/en/325321468739287095/Private

Community Sanitation and Recycling Organization. (n.d.). *A Socio-economic Study of Waste Pickers in Phnom Penh*. Retrieved from http://www.bigpond.com.kh/users/csaro/organization_info.htm

COMPED. (2013). *Social Engagement*. Retrieved from https://comped-cam.org/socialengagement.php

Denny, L. (2016). *Working Politically in Practices Series – Case Study no. 8 – Reforming Solid Waste Management in Phnom Penh*. Retrieved from https://asiafoundation.org/wp-content/uploads/2016/06/Working-Politically-and-Flexibly-to-Reform-Solid-Waste-Management-in-Phnom-Penh.pdf

Dri, M., Canfora, P., Antonopoulos, L., & Gaudillat, P. (2018). *Best Environmental Management Practice for the Waste Management Sector*. Retrieved from https://ec.europa.eu/jrc/en/publication/eur-scientific-and-technical-research-reports/best-environmental

Economic and Social Commission for Asia and the Pacific, & W. (2017). *Sustainable Development Benefits of Integrated Waste Management: Integrated Resource Recovery Centers*. https://www.unescap.org/sites/default/files/Sustainable.

Economist Intelligence Unit. (2017). *Progress and Challenges for Inclusive Recycling: An Assessment of 12 Latin American and Carribean Cities*. New York, NY: EIU.

Ellen MacArthur Foundation. (2017). *What Is a Circular Economy?* Retrieved from https://www.ellenmacarthurfoundation.org/circular-economy/concept

Ellis-Petersen, H. (2018). *Mountains and Mountains of Plastic: Life on Cambodia's Polluted Coast*. Retrieved from The Guardian: https://www.theguardian.com/world/2018/apr/25/mountains-and-mountains-of-plastic-life-on-cambodias-polluted-coast

Engel, H., Stuchtey, M., & Vanthournout, M. (2016). *Managing Waste in Emerging Markets***.** Retrieved from https://www.mckinsey.com/business-functions/sustainability/our-insights/managing-waste-in-emerging-markets

ETAGIW Consortium. (2012). *Preparing a Waste Management Plan: A Methodological Guidance Note*. Retrieved from https://ec.europa.eu/environment/waste/plans/pdf/2012_guidance_note.pdf

Faulder, D. (2018). *Asian Plastic is Choking the World's Oceans.* Retrieved from https://asia.nikkei.com/Spotlight/Cover-Story/Asian-plastic-is-choking-the-world-s-oceans

Ferronato, N., & Torretta, V. (2019). Waste Mismanagement in Developing Countries: A Review of Global *Issues. International journal of environmental research and public health, 16(6).*

GIZ. (2018). *Inclusion of Informal Collectors into the Evolving Waste Management System in Serbia: A Roadmap for Serbia.* Retrieved from https://www.giz.de/en/downloads/GIZ_A_Road_Map_For_Integration_online_LiNKS.pdf

Global Covenant of Mayors for Climate & Energy. (2019). *Surabaya - Surabaya's Community-Led Approach to Waste Management.* Retrieved from https://www.globalcovenantofmayors.org/city-story/how-surabaya-solved-its-waste-problem/

Gordon, S. (2015). *Shocking images show horror of child labour at toxic Cambodia rubbish site... and the tourists who visit to photograph them.* Retrieved from https://www.dailymail.co.uk/travel/travel_news/article-2993216/Shocking-images-horror-child-la

Hansen, W., Christopher, M., & Verbuecheln, M. (2002). *EU Waste Policy and Challenges for Regional and Local Authorities.* Retrieved from https://www.ecologic.eu/sites/files/download/projekte/1900-1949/1921-1922/1921-1922_background_paper_waste_en.PD

Happenhofer, A., Beigl, P., & Salhofer, S. (2017). Analysis of Economic Incentive Schemes to Promote Efficient Source Separation. *Paper presented at the Sixteenth International Waste Management and Landfill Symposium*. Cagliari, Italy.

Heng, Y. (2017). IRRC, Solid Waste Management Experiences in Cambodia. *Paper presented at the Regional Workshop on Sustainable Development Benefits of Decentralized Municipal Solid Waste Management in Asia-Pacific Region.* Bangkok, Thailand.

Holden, E. (2019). *Nearly All Countries Agree to Stem Flow of Plastic Waste into Poor Nations.* Retrieved from https://www.theguardian.com/environment/2019/may/10/nearly-all-the-worlds-countries-sign-plastic-waste-deal-except-us

Hoornweg, D., & Bhada-Tata, P. (2012). *What a Waste : A Global Review of Solid Waste Management*. Retrieved from https://openknowledge.worldbank.org/handle/10986/17388

Hul, S., Kuok, F., Soy, T., & Khoeurn, K. (2015). *Solid Waste Generation and Life-span with Credible Growth Forecasts Waste Generation, Volume and Composition.*

Kaza, S., Yao, L., Bhada-Tata, P., & Woerden, F. V. (2018). *What a Waste 2.0: A Global Snapshot of Solid Waste Management to 2050.* . Retrieved from http://documents.worldbank.org/curated/en/697271544470229584/pdf/132827-PUB-9781464813290.pdf

Kep Municipal Administration. (2018). *Report on Implementation of Sanitation Service Fund in 2018 (Khmer).*

Kep Provincial Administration. (2019). *Kep's 3-Year Rolling Public Investment Program 2019-2021 (Khmer).*

Kham, V., & Heilmann, D. (2015). *Waste Management Challenges in Cambodia and Experiences from other countries. Retrieve from.* Phnom Penh: Parliamentary Institute of Cambodia. Retrieved from http://www.pic.org.kh/images/2015Research/20160429_Waste%20Management%20Challenge

Kyriakopoulos, G.L., Kapsalis, V.C., Aravossis, K.G., Zamparas, M., & Mitsikas, A. (2019). Evaluating Circular Economy under a Multi-Parametric Approach: A Technological Review. *Sustainability, 11***,** 6139.

Lohri, C. R., Camenzind, E. J., & Zurbrügg, C. (2014). Financial Sustainability in Municipal Solid *Waste Management* – Costs and Revenues in Bahir Dar, Ethiopia. Waste management, 34(2), 542–552.

Ly, S., Sanchez Martin, M.E., Phim, R., Ky, L., Tong, K., Provo, A.M., Nagpal, S., & Vashakmadze, E.T. (2019). *Cambodia Economic Update: Recent Economic Developments and Outlook.* Washington, D.C.: World Bank Group. Retrieved from http://documents.worldbank.org/curated/en/843251556908260855/pdf/Cambodia-Economic-Update-Recent-Economic-Developments-and-Outlook.pdf

Marine Litter Solutions. (2019). *What Causes Marine Litter?* Retrieved from https://www.marinelittersolutions.com/about-marine-litter/what-causes-marine-litter/

Mazza, A., Piscitelli, P., Neglia, C., Rosa, G. D., & Lannuzzi, L. (2015). Illegal Dumping of Toxic Waste and Its Effect on Human Health in Campania, Italy. *Int J Environ Res Public Health, 12*(6), 6818–6831.

Min, M. (2016). *Survey Report on the Implementation of Waste Management at Cambodian's Municipality/*District Level.

Modak, P., Pariatamby, A., Seadon, J., Bhada-Tata, P., Borongan, G., Thawn, N. S., & Lim, M. B. (2017). *Asia waste management outlook.* Retrieved from http://wedocs.unep.org/bitstream/handle/20.500.11822/27289/Asia_WMO.pdf?sequence=1&isAllowed=y

MoE & UNEP. (2009). *Cambodia Environment Outlook.* Retrieved from https://wedocs.unep.org/bitstream/handle/20.500.11822/8689/Cambodia_environment_outlook.pdf?sequence=3&isAllowed=y

MoE, MoI, & MEF. (2015). *Inter-Ministerial Prakas on No. 073 on Using Sanitation Service Fund to Implement Function of Managing Solid Waste and Wastewater of Municipalities of Sub-National Administrations (Khmer).*

MoE, MoI, & MEF. (2018). *Inter-Ministerial Prakas No. 195 on Determination of Maximum Service Fee for Management of Garbage and Solid waste of Municipalities (Khmer).*

MoI. (2019). Support of MoI and Role of Sub-National Administrations to Implement Function of Managing Garbage and Solid Waste of Municipalities (Khmer). *Paper Presented at the Exchange Forum on Solid Waste Management.*

NCDD. (2017). *3 Year Implementation Plan, Phase III (2018-2020) of the National Program for Sub-National Democratic Development (IP3-III).*

NCSD. (2019). *Meeting Report on the First Meeting of the Working Group on Plastic Waste Management (Khmer).*

NCSD, MoI, & GGGI. (2019). *Draft Sustainable City Stratic Plan 2019-2030.*

Niaza, T. H. (2011). *Deconcentration and Decentralization Reforms in Cambodia: Recommendations for an Institutional Framework.* Retrieved from https://www.adb.org/sites/default/files/publication/28879/deconcentration-decentralization-cambodia.pdf

NZ MfE. (2007). *Guidance Principles: Best Practice for Recycling and Waste Management Contracts.* Wellington: NZ MfE . Retrieved from https://www.mfe.govt.nz/sites/default/files/best-practice-recycling-waste-mgmt-jul07.pdf.

OBG. (2017). *Thailand to Maintain Its Competitive Advantage in Tourism.* Retrieved from https://oxfordbusinessgroup.com/overview/star-power-leader-globally-and-regionally-country-intent-maintaining-its-competitive-edge

Olukanni, D. O., & Nwafor, C. O. (2019). Public-Private Sector Involvement in Providing Efficient Solid Waste Management Services in Nigeria. *Recycling,* 4(2).

PDoE. (2018). *2018 Data and Information about Solid Waste Management in Kep (Khmer).*

PDoT. (2019). *Data Collection on Hotels, Guesthouses, Bungalows, Restaurants, and Other Entertainment Facilities for the First Quarter of 2019.*

Pech, S. (2018). *Waste Production Continues to Rise.* Retrieved from https://www.khmertimeskh.com/539241/waste-production-continues-to-rise/

PPCA, IGES, Nexus, UN Environment, & CCCA. (2018). *Phnom Penh Waste Management Strategy and Action Plan* 2018-2035.

Refill Asia. (2019). *Why refill?* Retrieved from https://refillasia.com/why-refill/

RGC. (1999). *Sub-decree No. 36 on Solid Waste Management.*

RGC. (2015). *Sub-decree No. 113 on Management of Garbage and Solid Waste of Municipalities.*

RGC. (2017). *Sub-decree No. 168 on Plastic Bag Management (Khmer).*

SALGA, & Department of Environmental Affairs of Republic of South Africa. (2015). *Defining the Role of Local Government in Environmental Management and Establishing the Costs of Performing Environmental Management Functions.*

Salim, R. (2013). *Waste Not, Want Not : "Waste Banks" in Indonesia.* Retrieved from https://blogs.worldbank.org/eastasiapacific/waste-not-want-not-waste-banks-indonesia

Sang-Arun, J., & Chau, K. H. (2019). *A Guide for Technology Selection and Implementation of Urban Organic Waste Utilization Projects in Cambodia.* . Retrieved from https://www.files.ethz.ch/isn/143827/IGES2011-Promoting-OWU-Cambodia-printed.pdf

Scharff, H., Kok, B., & Krom, A. H. (2007). The Role of Sustainable Landfill in Future Waste Management Systems. . *Paper presented at the Eleventh International Waste Management and Landfill Symposium* . S. Margherita di Pula, Cagliari, Italy.

Sen, D. (2019). *Sustainable Development Project with Sweden Approved*. Retrieved from https://www.khmertimeskh.com/50585849/sustainable-development-project-with-sweden-approved/

Sheau-Ting, L., Sin-Yee, T., & Weng-Wai, C. (2016). Preferred Attributes of Waste Separation Behaviour: An Empirical Study. *Procedia Engineering, 145*, 738-745.

Singh, R. K., Premakumara, D. G. J., Yagasa, R., & Onogawa, K. (2018). *State of Waste Management in Phnom Penh, Cambodia.* Retrieved from https://www.ccet.jp/sites/default/files/2018-07/State%20of%20Waste%20Management%20in%20Phnom%20Penh%2C%20Cambodia%20_w

Sok, C. (2019). *Cambodia Puts Circular Economy in Motion.* Retrieved from https://capitalcambodia.com/cambodia-puts-circular-economy-in-motion/

Sour, S. (2017). Country Chapter – State of the 3Rs in Asia and the Pacific, Kingdom of Cambodia. Retrieved from http://www.uncrd.or.jp/content/documents/5686[Nov%202017]%20Cambodia.pdf

Spoann, V., Fujiwara, T., Seng, B., C., L., & Yim, M. (2019). Assessment of Public–Private Partnership in Municipal Solid Waste Management in Phnom Penh, Cambodia. *Sustainability, 11*(5).

UNDP. (2018). *#CircularEconomy: Innovating Solid Waste Management in Cambodia* . Retrieved from https://www.kh.undp.org/content/cambodia/en/home/presscenter/pressreleases/2018/-circulareconomy--innovating-solid-waste-management-in-cambodia.html

UNDP. (2018). *Solid Waste Management [SWM] App.* Retrieved from http://www.kh.undp.org/content/cambodia/en/home/ourperspective/solid-waste-management-app.html

UNDP. (2019). *Factsheet: Status of Solid Waste Management in Cambodia.* Retrieved from https://www.kh.undp.org/content/cambodia/en/home/library/environment_energy/factsheet--status-of-solid-waste-management-in-cambodia.html

US EPA. (2003). *The Hidden Hazards of Backyard Burning.* Retrieved from https://archive.epa.gov/epawaste/nonhaz/municipal/web/pdf/residents.pdf

US EPA. (2019). *Overview of Greenhouse Gases.* Retrieved from https://www.epa.gov/ghgemissions/overview-greenhouse-gases

Venugopal, P. (n.d.). *Waste Management - The Alappuzha.* Retrieved from http://climatesouthasia.org/waste-management-the-alappuzha-approach-2/

Willmott, L., & Graci, S. (2012). *Solid Waste Management in Small Island Destinations: A Case Study of Gili Trawangan, Indonesia.*

WRI. (2018). *Cities Research Seminar Series: Making Cities Work for Informal Workers:* A Closer Look at Waste Pickers in Latin America. Retrieved from https://www.wri.org/wri-citiesforall/events/2018/05/cities-research-seminar-series-making

Yang, L., Liu, G., Zhu, Q., & Zheng, M. (2019). Small-scale Waste Incinerators in Rural China: Potential Risks of Dioxin and Polychlorinated Naphthalene Emissions. *Emerging Contaminants, 5,* 31-34.

Yoshino, N., & Taghizadeh-Hesary, F. (2018). *Sustainable Funding Schemes for the Development of Waste Management Projects in Asia.* Retrieved from https://www.asiapathways-adbi.org/2018/06/sustainable-funding-schemes-for-the-development-of-waste-management-projects-in-asia/

Zero Waste International Alliance. (2018). *Zero Waste Definition.* Retrieved from http://zwia.org/zero-waste-definition/

Zhang, C., Xu, T., Feng, H., & Chen, S. (2019). Greenhouse Gas Emissions from Landfills: A Review and Bibliometric Analysis. *Sustainability, 11*(8).

**អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**

អាសយដ្ឋាន៖ ជាន់ទី ៣ អគារមរតកតេជោ ដីឡូលេខ៥០៣
ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ (+៨៥៥) ៨៩ ២១៨ ៣៧០
គេហទំព័រ៖ http://ncsd.moe.gov.kh/

**ក្រសួងបរិស្ថាន**

អាសយដ្ឋាន៖ អគារមរតកតេជោ ដីឡូលេខ៥០៣ ផ្លូវកៅស៊ូអមមាត់
ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ (+៨៥៥) ២៣ ២១៣ ៩០៨ / ២២០ ៣៦៩
គេហទំព័រ៖ https://www.moe.gov.kh/

**លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

អាសយដ្ឋាន៖ ស្ថិតក្នុងបរិវេណក្រសួងមហាផ្ទៃ (អគារ T) មហាវិថីព្រះនរោត្តម
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ (+៨៥៥) ២៣ ៧២០ ០៣៨ / ៧២០ ០៦១
គេហទំព័រ៖ http://ncdd.gov.kh/

**អង្គការមូលនិធិអាស៊ី**

អាសយដ្ឋាន៖ ផ្ទះលេខ ៥៩ ផ្លូវ ឧកញ៉ាពេជ្រ (ផ្លូវ ២៤២)
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ (+៨៥៥) ២៣ ២១០ ៤៣១
គេហទំព័រ៖ https://asiafoundation.org/